# ប្រវត្តិនៃព្រលឹងមួយ

**( សម្រង់ )**

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៨៩៧ សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និង ព្រះភក្ត្រដ៏វិសុទ្ធ បានលាចាកលោកនេះ នៅក្នុងគិលានដ្ឋានអារាមកាមែល នៅលីស្សឺ ដោយរោគរបេងសួត ក្នុងជន្មាយុ ២៤ឆ្នាំ ៩ខែ។

ជីតារបស់ថេរេសាឈ្មោះ **លុី ម៉ារតាំង** កើតនៅ ប៊័រដូ ថ្ងៃទី២២ ខែសីហា ឆ្នាំ១៨២៣ ជាកូនរបស់ពលទាហានប្រចាំការ ក្នុងបន្ទាយរក្សាទីក្រុង។ គាត់រស់នៅក្នុងបន្ទាយតាំងពីក្មេង មានអនុស្សាវរីយ៍ជាច្រើន អំពីប្រវត្តិព្រះចៅអធិរាជណា-ប៉ូឡេអុង។ គាត់មានឋានន្តរសក្តិជាអនុសេនីយឯក ក្រោយពីចូលនិវត្តន៍ បានមករស់នៅអាឡង់សុង ក្នុងឆ្នាំ១៨៣០។

កូនប្រុសរបស់ លុី ម៉ារតាំង ឈ្មោះ **លុី** ជាមនុស្សមានសណ្តាប់ធ្នាប់ ការងារហ្មត់ចត់ ចូលចិត្តនៅស្ងប់ស្ងាត់តែម្នាក់ឯង ដើម្បីសញ្ជឹងគិត។ គាត់រៀនធ្វើនាឡិកា ដែលជាមុខរបរទាមទារឲ្យគាត់មានភាពអំណត់ និងជាក់លាក់។ ពេលមានអាយុ ២២ឆ្នាំ គាត់ស្រមៃចង់រស់នៅរឹតតែឆ្ងាយពីគេឯង និងស្ងប់ស្ងាត់ជាងមុន។ គាត់បានទៅសុំគេធ្វើការក្នុងអារាមមួយ តែដោយគាត់មិនចេះភាសាឡាតាំង គេមិនព្រមទទួលគាត់ទេ។ បន្ទាប់ពីស្នាក់នៅប៉ារីសមួយរយៈ គាត់ក៏ទៅនៅជាមួយឪពុកម្តាយ ប្រកបរបរជាជាងនាឡិកានៅអាឡង់សុងវិញ។ នៅ

ទីនោះអស់រយៈពេលប្រាំបីឆ្នាំ គាត់រស់នៅដូចជាអ្នកបួស គឺគាត់អធិដ្ឋាន និងអានសៀវភៅ។ គាត់ចូលចិត្តទៅស្លូចត្រី និងទៅលេងមិត្តភក្តិក្នុងព្រះសហគមន៍កាតូលិក។

ទីក្រុង អាឡង់សុង មានប្រជាជន ១៣.៦០០នាក់ ជាទីក្រុងតូចស្ងប់ស្ងាត់សមស្របនឹងបុរសមិនសូវចេះនិយាយស្ដីរូបនេះ។ ជាក្រុងល្បីល្បាញខាងសិល្បៈប៉ាក់ជរ ដែលត្រូវនាំចេញទៅលក់ពាសពេញប្រទេសបារាំង ជាពិសេស អ្នកក្រុងប៉ារីស ដែលចូលចិត្តភាពឆើតឆាយ ដើម្បីលាក់បំពួនសភាពផុយស្រួយនៃចក្រភពជំនាន់នោះ។

នាង ហ្សេលី គ្វេរ៉ាំង កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៨៣១ ក្នុងគ្រួសារដែលមានឫសគល់ជាកសិករ។ ឪពុកនាង ក្រោយពីបញ្ចប់ការងារជាកងអាវុធហត្ថក៏ទៅរស់នៅអាឡង់សុងដែរ ក្នុងផ្ទះមួយ នៅទល់មុខសាលាក្រុង។ ឪពុកនាងជាមនុស្សរឹងរូស និងប្រើអំណាច ឯម្ដាយវិញ មិនសូវយកចិត្តទុកដាក់នឹងកូនទេ។ ថ្ងៃមួយ ហ្សេលី សរសេរសំបុត្រទៅបងប្រុសរបស់នាងថា៖ *"កុមារភាពយុវវ័យរបស់ខ្ញុំ ប្រកបដោយភាពក្រៀមក្រំ ដូចស្នបរុំសព ខ្ញុំខ្លោចផ្សាក្នុងចិត្តណាស់"* (សំបុត្រគ្រួសារ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៨៦៥)។ ម្ដាយនាងស្រឡាញ់កូនប្រុស មានឈ្មោះ អ៊ីស៊ីដ័រ ជានិស្សិតឱសថការី និងកូនស្រីឈ្មោះ អេលីសនេះណាស់។ ទាំងពីរនាក់នេះ ជាអ្នកជិតស្និទ្ធនឹងហ្សេលីជាងគេ។ ថ្ងៃក្រោយមក អេលីសចូលបួសជាដូនជី ដែលមានឈ្មោះថា ម៉ារី ដូស៊ីតេ។ នាង ហ្សេលី តែងតែសរសេរសំបុត្រទាក់ទងទៅបងប្រុស បងស្រីទាំងពីរនាក់នេះ រហូតដល់ថ្ងៃចុងក្រោយរបស់នាង។ ក្នុងនោះនាងបានរៀបរាប់អំពីចរិតព្រួយបារម្ភ ជួនកាលក្រៀមក្រំ និងឫកពារហ័សរហួនពីកំណើត ស្ទិតស្ទាញក្នុងការងារ ជំនឿមាំមួន គំនិតយល់ត្រូវ និងចរិតកំប្លែងស្លូតរបស់គាត់។

ដូច ល្វី ម៉ារតាំង ដែរ នាងស្រមៃដល់ជីវិតជាអ្នកបួស។ ពេលចុះឈ្មោះសុំចូលបួសជាដូនជី នៅអាឡង់សុង នាងត្រូវគេបដិសេធដាច់ខាត ដូចល្វីដែរ។ ដូច្នេះ នាងក៏ចូលធ្វើការក្នុងរោងជាងប៉ាក់ជរ ក្រោយមកបើកហាងខ្លួនឯង។ ដោយនាងជាអ្នកប៉ាក់ស្ទាត់ជំនាញ និងបានជំនួយពីបងស្រីផង នាងក៏បានជោគជ័យលើមុខរបរនេះ ។

បន្ទាប់ពីពិធីភ្ជាប់ពាក្យដែលមានរយៈពេលខ្លី ក្នុងព្រះវិហារព្រះមាតា នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៨៥៨។ ជាងនាឡិកា ល្វី អាយុ ៣៥ឆ្នាំ និងនារី ប៉ាក់ជរ អាយុ ២៧ឆ្នាំ ទាំងពីរនាក់ជាមនុស្សដែលត្រូវគេបដិសេធជាអ្នកបួស បានរៀបការ។

ក្រោយពីរៀបការរួច ដប់ខែដំបូង ពួកគាត់រស់នៅជាមួយគ្នា ដូចបងប្អូនប្រុសស្រី តាមសំណូមពររបស់ល្វី និងការព្រមព្រៀងគ្នាទាំងសងខាង។ អន្តរាគមន៍របស់លោកបូជាចារ្យម្នាក់ ធ្វើឲ្យពួកគាត់ប្តូរគំនិត ចង់បង្កើតគ្រួសារធំមួយ។ ពួកគាត់មានកូនប្រាំបួននាក់ ចាប់កំណើតបន្តបន្ទាប់គ្នា ពីឆ្នាំ១៨៦០ ដល់ ១៨៧៣។ ខ្ញុំស្រឡាញ់កូនៗណាស់ ជីវិតខ្ញុំសម្រាប់តែពួកគេ ប៉ុន្តែ ល្មមដល់ពេលបញ្ចប់ហើយ នៅតែប៉ុន្មានថ្ងៃទៀតទេ ខ្ញុំអាយុ ៤១ឆ្នាំហើយ ជាអាយុជីដូនគេ!"។ នេះជាសេចក្តីក្នុងសំបុត្រ ដែលគាត់សរសេរមុនសម្រាលកូនពៅ *ថេរេសា (១៥-១២-១៨៧២)*។

អ្នកស្រី ម៉ារតាំង នៅសល់តែកូនស្រីប្រាំនាក់គត់ដែលនៅរស់ ដោយសារជំនាន់នោះ មរណភាពកុមារមានអត្រាកម្រិតខ្ពស់...។ អ្នកស្រី មានសុខភាពមិនមាំមួនទេ គាត់កើតមហារីកសុដន ព្យាបាលលែងជា។ នៅឆ្នាំ១៨៧៦ គាត់ស្ទាក់ស្ទើរចិត្តក្នុងការព្រមប្រគល់កូនស្រីទីប្រាំ និងកូនក្រោយទៀត ឲ្យទៅមេដោះដែលមិនប្រាកដថា ថេះថៃទាំពួកគេឡើយ។ រយៈពេលដប់ប្រាំឆ្នាំកន្លងមកនេះ គឺការឆ្លាស់គ្នារវាងការផ្តល់កំណើត និងការកាន់ទុក្ខៈ កូនប្រុសពីរនាក់ និងកូន

ស្រីពីរនាក់បានស្លាប់ ដែលមាន ហៅឡែន ក្មេងស្រីដ៏ស្អាតអស្ចារ្យ អាយុ ៥ឆ្នាំ។ *"តាំងពីពេលដែលខ្ញុំបាត់បង់កូននេះ ខ្ញុំចង់ជួបនាងណាស់។ ពេលនេះ កូនៗ ដែលរស់នៅ ត្រូវការខ្ញុំ ដោយសារពួកគេ ខ្ញុំទូលអង្វរព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ សូមព្រះអង្គជួយទុកពេលឲ្យខ្ញុំពីរបីឆ្នាំទៀត។ ខ្ញុំនឹកស្ដាយកូនប្រុសទាំងពីរណាស់ ប៉ុន្តែ បាត់បង់កូនស្រីមួយនេះ ធ្វើឲ្យខ្ញុំកាន់តែកើតទុក្ខថែមទៀត។ កាលនោះ ពេលនាងកើតមក ខ្ញុំសប្បាយចិត្តអ្វីម្ល៉េះទេ នាងស្អាតណាស់ គួរចង់ថើបអង្អែល កាន់តែធំកាន់តែស្អាត ខ្ញុំនឹកគ្មានលោះពេលណាសោះ" (២៨-៣-១៨៧០ )*។

សង្គ្រាមឆ្នាំ១៨៧០ បានទុកស្លាកស្នាមជាច្រើន។ ទោះបី ត្រូវឲ្យទាហាន អាល្លឺម៉ង់ប្រាំបួននាក់ ស្នាក់នៅជាមួយ ក៏សមាជិកគ្រួសារកើនឡើងថែមទៀត ដែរ។ ការឡើងឋានៈជាអ្នកជំនួញធូរធារ តម្រូវឲ្យគ្រួសារនេះ ខិតខំធ្វើការផត ឈប់ឈរ ក្រោកមុនគេ ចូលដំណេកក្រោយគេ។ ល្វី បានលក់ហាងនាឡិកា និងគ្រឿងអលង្ការចោល ដើម្បីមកជួយកិច្ចការប្រពន្ធ។ គ្រួសារ ម៉ារតាំង ប្ដូរមក នៅផ្ទះថ្មី ដែលមាននៅរហូតដល់សព្វថ្ងៃនេះ។

ជីវិតគ្រួសារនេះ ស្ថិតនៅក្នុងឋានៈពិសេស។ ពួកគេរីករាយណាស់ នៅ ពេលជួបជុំគ្នា។ ម៉ារី ជាកូនស្រីច្បង ដែលឪពុកស្រឡាញ់ជាងគេ។ ប៉ូលីន ជា ក្មេងរស់រវើក ជាទំនុកចិត្តរបស់ម្ដាយ ពួកគេទៅរៀននៅសំណាក់ដូនជី។ សិស្ស ទាំងពីរនាក់នេះ រស់នៅទីនោះ ក្រោមការគ្រប់គ្រងដ៏រាងរៃរបស់អ្នកមីង ដូស៊ីតេ ដែលតែងតែរាយការណ៍អំពីការសិក្សា និងចរិយារបស់ពួកនាង ប្រាប់អ្នកម្ដាយ ជានិច្ច។ អ្នកមីងចូលចិត្តឫកពារខុសពីគ្នារបស់ក្មេងទាំងពីរនាក់នេះណាស់។ រាល់វិស្សមកាល គេឮសូរសំណើចពេញផ្ទះ តែដល់បរវេសនកាលវិញ ទឹកភ្នែក ហូរដូចទឹកជ្រោះ។

មានតែ *"លេអូនី គួរឲ្យអាណិត"* ដែលមិនសូវឆ្លាតដូចគេ ឧស្សាហ៍ឈឺ

ថ្កាត់ ធ្វើឲ្យអ្នកម្តាយតែងតែបារម្ភជានិច្ច។ ចំណែកឯ សេលីន វិញ ជា *"អ្នកក្លាហាន"* ដែលក្រោយមក ជិតស្និទ្ធនឹងកូនស្រីពៅជាងគេ គឺ **ថេរេសា**។

ដំណើរកំសាន្តនៅស្រុកស្រែ ការជួបជុំគ្នាជាមួយគ្រួសារឪពុកមា ខាងម្តាយ ដែលជាឱសថការីនៅ លីស្យឺ ការធ្វើដំណើរតាមរថភ្លើង ទៅលេងអ្នកមីងជាដូនជី។ សកម្មភាពទាំងអស់នេះ ត្រូវបានចារឹកទុកជារៀងរហូត ក្នុងបេះដូងកូនៗគ្រួសារ ម៉ារតាំង។ ពួកគេមានអនុស្សាវរីយ៍ ដែលមិនអាចបំភ្លេចបានចំពោះការរីករាយនេះជានិច្ច។ មរណទុក្ខប្រាំពីរដង គឺមរណភាពរបស់ជីដូនជីតា និងក្មេងៗចាប់តាំងពីឆ្នាំ១៨៥៩ ដល់ ១៨៧០ មិនអាចពន្លត់សេចក្តីស្រឡាញ់ ដែលបង្រួបបង្រួមសមាជិកគ្រួសារនេះឡើយ ផ្ទុយទៅវិញ ពួកគេកាន់តែស្រឡាញ់គ្នាលើសមុនទៅទៀត។

ឫកពារតឹងរ៉ឹង មិនអាចបត់បែនបានរបស់ឪពុក ដែលចូលចិត្តភាពស្ងប់ស្ងាត់នេះ ក្លាយទៅជាការអត់ឱន និងសប្បុរសចំពោះនគរស្រីៗដ៏ទ្រហឹងអឺងកងនេះ។ គាត់ចូលចិត្តជួបជុំកូនៗក្រោយអាហារល្ងាច ដើម្បីសូត្រកំណាព្យអន្លង់អន្លោចរបស់កវីល្បីៗ និងបញ្ចេញសំឡេងពីរោះគ្រលួច ច្រៀងបទចាស់ៗពីសម័យមុន ព្រមទាំងធ្វើល្បែងក្មេងតូចៗ ឲ្យកូនសប្បាយចិត្តទៀតផង។

កម្លាំងអ្នកម្តាយថយជាងមុន គាត់មានការព្រួយបារម្ភចំពោះអនាគត។ គាត់ដឹកនាំការងារក្នុងផ្ទះយ៉ាងប៉ិនប្រសប់ និងស្វាហាប់ គួរឲ្យស្ងើចសរសើរ វាសនាអាក្រក់ មិនងាយផ្តួលរំលំគាត់ឡើយ ភាពសម្បូរសប្បាយក៏មិនអាចធ្វើឲ្យគាត់ភ្លើតភ្លើនដែរ!។ នេះជាសេចក្តីសំបុត្រ ដែលបងស្រីគាត់សរសេរនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៨៦៨។ ភាពប្រាកដប្រជា រហ័សរហួន ក្នុងការនិយាយត្រង់ៗ និងទន់ភ្លន់គួរឲ្យស្រឡាញ់ បានធ្វើឲ្យអ្នកស្រី ក្លាយទៅជាព្រលឹងនៃគ្រួសារនេះ។

គ្រួសារ ម៉ារតាំង មានជំនឿមុតមាំលើព្រះជាម្ចាស់ ពួកគេគោរពព្រះអង្គជានិច្ច អធិដ្ឋានជាមួយគ្នា និងថ្វាយអភិបូជាពេលព្រឹក ដោយទទួលព្រះកាយព្រះគ្រីស្តជានិច្ច។ ជីវិតរបស់ពួកគេ តែងតែប្រព្រឹត្តទៅតាមសង្វាក់នៃការគោរពបម្រើព្រះជាម្ចាស់ ដូចជា បូជនីយេសចរណ៍ តមអាហារ និងតមសាច់យ៉ាងតឹងរ៉ឹង។ ប៉ុន្តែ គេមិនជឿខុសទំនង ឬហួសហេតុពេកទេ។ គេរើសយកក្មេងដែលត្រូវបោះបង់ចោលមកចិញ្ចឹម ជួយយកអាសារជនអនាថា និងចាស់ជរា។ បើស្រីបម្រើឈឺ ហ្សេលីម៉ារតាំង លះបង់ដំណេកបន្តិចបន្តួចរបស់ខ្លួន មកថែទាំអ្នកជំងឺ ចំណែកឯលោក ម៉ារតាំង វិញ គាត់លះបង់ពេលវេលា ដើម្បីជួយអ្នកក្រីក្រ ជួយមនុស្សឆ្កួតជ្រូក និងអ្នកស្លាប់។ ពួកគេបង្រៀនកូនៗឲ្យចេះគោរពមិនត្រូវមាក់ងាយអ្នកក្រខ្សត់ឡើយ។

អ្នកម្តាយចូលចិត្តមើលកូនស្រីស្លៀកពាក់ស្អាតៗ។ កាលបើបងស្រី ម៉ារីដូស៊ីតេ បារម្ភចំពោះក្មួយស្រី ម៉ារី អាយុ ១៦ឆ្នាំ ដែលចេញទៅលេងកំសាន្តជាមួយក្មេងស្រីឯទៀត អាយុស្របាលគ្នា។ គាត់តែងតែសរសេរសំបុត្ររាយការណ៍មកអ្នកស្រីមិនដែលខាន។ គាត់សរសេរតបទៅវិញថា៖ *"តើត្រូវឲ្យពួកនាងឃុំខ្លួនក្នុងព្រះវិហារឬ?"* (សំបុត្រសរសេរនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៨៧៦)។

ពេលមានផ្ទៃពោះបួនខែ ហ្សេលីម៉ារតាំង ប្រាប់ដំណឹងនេះទៅបងៗគាត់ *"ព្រឹត្តិការណ៍មួយនឹងកើតមានឡើង នៅចុងឆ្នាំ១៨៧២ នេះ"* ហើយគាត់គិតក្នុងចិត្តម្នាក់ឯងថា *"ខ្ញុំសង្ឃឹមថា កូននេះនឹងមកយ៉ាងល្អ"*។ នេះហើយជារូបរាងដំបូងរបស់ស្រីតូច ថេរេសា *"ជាឈ្មោះរំឭកដល់ ថេរេសា ពីមុន"* ដែលស្លាប់ក្នុងអាយុ ពីរ បីខែ ប៉ុណ្ណោះ។

នេះជាដំណឹងល្អ *"កូនស្រីតូចច្រមក់របស់ខ្ញុំ កើតពីម្សិលមិញ ថ្ងៃព្រហស្បតិ៍វេលាម៉ោងដប់មួយកន្លះយប់។ នាងរឹងប៊ឹង ហើយមានសុខភាពល្អណាស់ គេប្រាប់ខ្ញុំថា នាងមានទម្ងន់បួនគីឡូ មិនអន់ទេ នាងហាក់ដូចជាស្លូតបូត។ ខ្ញុំឈឺ*

*ពោះតែកន្លះម៉ោងប៉ុណ្ណោះ បើប្រដូចទៅពេលមុន ហាក់ដូចជាតិចតួចណាស់ យើងនឹងជ្រមុជទឹកនាង នៅថ្ងៃអាទិត្យស្អែកនេះ។ សូមអ្នករាល់គ្នាអញ្ជើញមកចូលរួមកុំបីអាក់ខាន។ ម៉ារី និងក្មេងប្រុសម្នាក់ អាយុប្រហែលនាងដែរ នឹងក្លាយទៅជាឪពុកម្ដាយធម៌របស់ថេរេសា"* (ថ្ងៃទី៣ មករា ១៨៧៣)។

អ្វីៗប្រព្រឹត្តទៅតាមដែលអ្នកស្រី ម៉ារតាំង ប្រាប់ ប៉ុន្តែ ហេតុការណ៍ដែលឥតព្រៀងទុកមួយ បានកើតឡើង គឺសំបុត្រដ៏ខ្លី សរសេរជាកំណាព្យ ដោយឪពុកនាង ផ្ញើតាមក្មេងប្រុសម្នាក់៖

*"ញញឹមទៅ ហើយឆាប់ធំឡើង*
*សុភមង្គលហៅ ឯងឲ្យមក*
*ថៃទាំរក្សា និងស្នេហាទន់ភ្លន់*
*មែនហើយ ញញឹម ពេលព្រឹកព្រលឹម*
*ផ្កាក្រពុំ ដែលទើបនឹងរីក*
*ឯង ជាកុលាប នៃអនាគតកាល"*

ប៉ុន្តែ គ្រាន់តែកើតមកបានបន្តិច ម៉ារី-ហ្វ្រង់ស័រ-ថេរេសា ម៉ារតាំង ជួបនឹងការឈឺចាប់ភ្លាម នាងហៀបនឹងបាត់បង់ជីវិត នៅអាយុដប់ប្រាំថ្ងៃ ដោយសាររោគរាកមួលយ៉ាងខ្លាំងក្លា។ អាយុបីខែ គ្រោះអាសន្នខ្លាំងជាងមុនទៅទៀត៖ ថេរេសាឈឺធ្ងន់ណាស់ ខ្ញុំគ្មានសង្ឃឹមជួយសង្គ្រោះនាងបានឡើយ។ ស្រីតូចគួរឲ្យអាណិតនេះ ឈឺតាំងពីម្សិលមិញម្ល៉េះ ខ្ញុំខ្លោចផ្សាក្នុងចិត្តពន់ពេក (ថ្ងៃទី១ ខែមីនា ឆ្នាំ១៨៧៣)។

ថេរេសាជាសះស្បើយហើយ ប៉ុន្តែយោបល់គ្រូពេទ្យ បង្ខំឲ្យម្ដាយផ្ដាច់ដោះប្រគល់នាងទៅមេដោះបំបៅវិញ។ រយៈពេលមួយឆ្នាំ ថេរេសា បៅដោះអ្នកស្រី រ៉ូស្ស តៃយេ ដែលជាមិត្តភក្តិរបស់ឪពុកម្ដាយនាង។ គាត់ជាស្ត្រីមានមាឌធំមាំ

រហ័សរហួន។ ថេរេសា រស់នៅជាកូនកសិករ។ នៅទីនោះ នាងជា *"ទារិកាសម្បុរស្រអែម ដោយពន្លឺព្រះអាទិត្យ"* កណ្តាលធម្មជាតិ ហ៊ុំព័ទ្ធដោយបុប្ផា និងសត្វ៖ *"មេដោះដឹកនាងដោយរទេះរុញទៅចម្ការ ជិះលើពំនូកស្មៅ នាងមិនដែលយំទេ"*។ គេនិយាយថា មិនដែលឃើញក្មេងណាស្អាតជាង *"កុលាបតូចនេះឡើយ"* (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៨៧៣)។

នាងមានសម្បុរស ភ្នែកខៀវ មុខញញឹមជានិច្ច ឆ្លាតតាំងពីតូច រហ័សរហួន ឆាប់យល់ការណ៍ ក្លាហាន វាងវៃ តែពេលខឹងម្តងៗ ពិបាកទប់ទល់។ ថេរេសា ក្លាយទៅជាអ្នកដែលគេស្រឡាញ់ ថ្នាក់ថ្នមជាងគេក្នុងគ្រួសារ ដែលគេថើបមិនចេះឆ្អែតឆ្អន់ឡើយ។ *"ព្រះជាម្ចាស់សព្វព្រះហឫទ័យបញ្ជូនសេចក្តីស្រឡាញ់មកឲ្យខ្ញុំពេញមួយជីវិត អនុស្សាវរីយ៍ដំបូងរបស់ខ្ញុំ គឺស្នាមញញឹម និងការបបោសអង្អែលដ៏ស្រទន់រាប់មិនអស់!..."*។

នៅអាឡង់សុង មិនមែនជាសេចក្តីស្នេហាដ៏ផ្អែមល្ហែមទេ តែជាការរីករាយដែលធ្វើឲ្យដូនជី ថេរេសា អាយុ ២៣ឆ្នាំ សរសេរទុកនូវអនុស្សាវរីយ៍ បញ្ជាក់ពីកុមារភាពដែលគេនឹងអាន៖ *"ឱ! កុមារភាពក្រោមកម្តៅព្រះអាទិត្យរបស់ខ្ញុំបានរសាត់ទៅយ៉ាងរហ័ស ប៉ុន្តែ វាបានទុកដានយ៉ាងស្រទន់ក្នុងអារម្មណ៍ខ្ញុំ (....) អ្វីៗទាំងអស់លើផែនដីនេះ ញញឹមរាក់ទាក់រកខ្ញុំជានិច្ច ខ្ញុំឈានជើងដើរលើផ្កាដែលដុះពាសពេញ ចរិតរួសរាយរបស់ខ្ញុំ បានរួមចំណែកធ្វើឲ្យជីវិតខ្ញុំស្រស់បំព្រងដែរ"* ( Ms A, 11v° / 12 r° )។

មរណភាពរបស់ម្តាយនាង បានបំបែកសុភមង្គលនេះយ៉ាងគំហុក បណ្តាលឲ្យនាងចាកចេញពីផ្ទះទៅ លីស្យឺ។ គឺ ថេរេសា ជាអ្នកនិទានរឿងនេះប្រាប់ពួកយើងដោយខ្លួនឯង...។

# សៀវភៅ **ឧទ្ទិសជូនអ្នកម៉ែ អាញ្ញេស នៃព្រះយេស៊ូ ជាទីគោរព**

## សៀវភៅ "ក"

### អាឡង់សុង

**( ១៨៧៣-១៨៧៧ )**

[ ] J.M.J.T មករា ១៨៩៥

ព្រះយេស៊ូ +

ជាប្រវត្តិរបស់បុប្ផាពណ៌សតូចមួយ សរសេរដោយខ្លួនឯង ឧទ្ទិសជូនចំពោះអ្នកម្តាយ អាញ្ញេស នៃព្រះយេស៊ូ។

ខ្ញុំសូមឧទ្ទិសជូនអ្នកម្តាយជាទីស្រឡាញ់បំផុត និងជាមាតាទីពីរ ដែលខ្ញុំប្រគល់ប្រវត្តិនៃព្រលឹងរបស់ខ្ញុំ។ ពេលដែលអ្នកម៉ែសុំឲ្យខ្ញុំសរសេរ ខ្ញុំហាក់ដូចជារំលាយបេះដូងដែលផ្ទុកប្រវត្តិនេះ។ ប៉ុន្តែ ចាប់តាំងពីពេលដែលព្រះយេស៊ូបណ្តាលឲ្យខ្ញុំយល់ថា គ្រាន់តែស្តាប់បង្គាប់ អាចធ្វើឲ្យព្រះអង្គសព្វព្រះរាជហឫទ័យ ហើយ

ដូច្នេះ ខ្ញុំនឹងប្រតិបត្តិតាមឥតល្មៀង គឺផ្ដើមច្រៀងនូវទំនុកដែលខ្ញុំទន្ទេញរហូតដល់អវសាន *"សេចក្ដីមេត្តាករុណារបស់ព្រះយេស៊ូ!..."*

មុននឹងចាប់ដងប៉ាកកា ខ្ញុំសូមបន្ទន់ខ្លួន លុតជង្គង់ចំពោះព្រះរូបបដិមាព្រះមាតា (ជាអ្នកបានបង្ហាញសក្ខីភាពនៃសេចក្ដីស្រឡាញ់របស់ម្ដាយ ដែលជាពជនីនៃស្ថានបរមសុខសម្រាប់គ្រួសារយើង)។ ខ្ញុំបានសូមព្រះមាតាដឹកដៃខ្ញុំ ដើម្បីកុំឲ្យខ្ញុំសរសេរឃ្លាណា ដែលព្រះនាងមិនសព្វព្រះហឫទ័យ។ បន្ទាប់មកខ្ញុំបើកព្រះគម្ពីរដំណឹងល្អ ហើយប្រទះនឹងល្បះនេះ៖ *"ពេលយាងឡើងលើភ្នំមួយ ព្រះយេស៊ូបានត្រាស់ហៅអ្នកដែលព្រះអង្គស្រឡាញ់ ឲ្យមករកព្រះអម្ចាស់ ហើយពួកគេក៏មករកព្រះអង្គមែន"* (មក ៣. ១៣)។ នេះហើយជាអាថ៌កំបាំងដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំ អាថ៌កំបាំងនៃជីវិតទាំងមូល ជាពិសេស គឺជាអត្ថិភាពរបស់ព្រះយេស៊ូមកលើព្រលឹងខ្ញុំ... ព្រះអង្គមិនត្រាស់ហៅអ្នកដែលសក្ដិសមទេ គឺអ្នកដែលព្រះអង្គចូលចិត្ត ដូចសម្ដីរបស់សន្តប៉ូល៖ *"ព្រះជាម្ចាស់នឹងមានចិត្តមេត្តាករុណាដល់នរណា ដែលព្រះអង្គមេត្តាករុណា ហើយព្រះអង្គក៏នឹងអាណិតអាសូរនរណា ដែលព្រះអង្គអាណិតអាសូរដែរ"*។ ដូច្នេះ មិនមែនស្រេចតែបំណងចិត្ត ឬការខំប្រឹងប្រែងរបស់មនុស្សឡើយ គឺ *"ស្រេចតែព្រះជាម្ចាស់ដែលមានព្រះហឫទ័យមេត្តាករុណានោះវិញ"* (រ៉ូម ៩. ១៥-១៦)។ ជាយូរមកហើយ ខ្ញុំតែងតែដណ្ដឹងសួរខ្លួនឯងថា ហេតុអ្វីបានជាព្រះជាម្ចាស់ប្រោសប្រទានអ្នកនេះជាងអ្នកនោះ ហេតុអ្វីក៏ព្រលឹងទាំងអស់ មិនបានទទួលការប្រទានស្មើៗគ្នាពីព្រះអង្គ ខ្ញុំឆ្ងល់ណាស់ ដោយឃើញព្រះអង្គសព្វព្រះហឫទ័យយ៉ាងអស្ចារ្យចំពោះសន្តបុគ្គលខ្លះ ដែលធ្លាប់ប្រឆាំងនឹងព្រះអង្គ ដូចជា សន្តៈ ប៉ូល និង សន្តៈ អូគូស្តាំង ហើយព្រះអង្គបង្ខំពួកលោកឲ្យទទួលការប្រោសប្រណីទៀតផង។ ដោយបានអានជីវប្រវត្តិរបស់សន្តបុគ្គលទាំងនោះ ដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យបបោសអង្អែលតាំងពីក្នុងអង្រឹង រហូតដល់ចូលក្នុងផ្នូរ គ្មានទុកឧបសគ្គមករារាំង

ពួកលោក រហូតទាល់តែបានជួបព្រះអង្គនៅស្ថានបរមសុខ ហើយព្រះអង្គនៅតែប្រោសប្រទានការពារព្រលឹងសន្តបុគ្គលទាំងនោះ។ ខ្ញុំតែងតែគិតថា ហេតុអ្វីមនុស្សជាច្រើននាក់ ស្លាប់មុននឹងស្គាល់ឈ្មោះព្រះជាម្ចាស់ទៅទៀត។ ព្រះយេស៊ូបានបង្រៀនឲ្យខ្ញុំយល់អាថ៌កំបាំងនេះ។ ព្រះអង្គបានដាក់សៀវភៅដែលជាបុប្ផាធម្មជាតិពីមុខខ្ញុំ ហើយខ្ញុំយល់ថា បុប្ផាទាំងអស់ដែលព្រះជាម្ចាស់បង្កើតមក សុទ្ធតែស្អាតស្រស់បំព្រងទាំងអស់ ពណ៌ចែងចាំងនៃផ្កាកុលាប និងពណ៌សក្បុសនៃផ្កាម្លិះ មិនអាចហូតយកក្លិនក្រអូបនៃផ្កាវិយូឡែត ឬសម្រស់ធម្មតាៗរបស់ផ្កាប៉ាកឺរ៉ែតបានទេ...។ ខ្ញុំយល់ថា ប្រសិនបើផ្កាតូចៗទាំងអស់ ចង់ក្លាយទៅជាកុលាបធម្មជាតិ នឹងបាត់បង់សម្រស់នៃរដូវផ្ការីកជាពុំខាន វាលចម្ការនឹងលែងមានផ្កាតូចៗបង្អួតខ្លួនលំអទៀតហើយ។

ហេតុនេះហើយ ព្រលឹងនៃសកលលោក ជាសួនច្បាររបស់ព្រះយេស៊ូ។ ព្រះអង្គចង់បង្កើតសន្តបុគ្គលធំៗ ដែលអាចប្រដូចទៅនឹងផ្កាម្លិះ និងផ្កាកុលាប ប៉ុន្តែ ព្រះអង្គក៏បង្កើតផ្កាតូចៗជាងគេ ដែលត្រូវតែយល់ព្រមទទួលខ្លួនជាផ្កាប៉ាកឺរ៉ែត ឬផ្កាវិយូឡែត ដើម្បីផ្គាប់ព្រះនេត្រព្រះជាម្ចាស់ នៅពេលដែលព្រះអង្គដាក់ព្រះបាទាពីលើ។ ភាពល្អឥតខ្ចោះ គឺការប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គតាមតែទ្រង់ប្រោសប្រទាន...។

ខ្ញុំគិតឃើញទៀតថា ព្រះអម្ចាស់នៃយើង ព្រះអង្គស្រឡាញ់ព្រលឹងដែលងាយយល់ មិនស្មុគ្រស្មាញ មិនប្រឆាំងតបតជាមួយនឹងការប្រោសប្រណីរបស់ព្រះអង្គ ដូចគ្នានឹងព្រលឹងក៏ខ្ពង់ខ្ពស់ដាច់គេដែរ។ តាមការពិត សេចក្តីស្រឡាញ់គឺការបន្ទាបខ្លួន។ ប្រសិនបើព្រលឹងទាំងអស់ ដូចព្រលឹងនៃសន្តបុគ្គលជាច្រើនដែលមកបំភ្លឺព្រះសហគមន៍ ដោយយកវិជ្ជារបស់ខ្លួនមកបំភ្លឺ ប្រហែលជាព្រះជាម្ចាស់មិនបាច់បន្ទាបព្រះកាយ ចូលមកក្នុងចិត្តពួកគាត់ទេ ប៉ុន្តែ ព្រះអង្គបានបង្កើតកុមារមិនទាន់ចេះធ្វើអ្វីសោះ ក្រៅពីយំ។ ព្រះអង្គបានបង្កើតអ្នកស្រុកព្រៃក្រីក្រ

យកច្បាប់ធម្មជាតិមកអនុវត្ត ហើយព្រះអង្គបន្ទាបព្រះកាយ រហូតដល់បេះដូងពួកគេ នោះគឺជាផ្កាមានសម្រស់ធម្មតា ដុះក្នុងវាលចម្ការដែលធ្វើឲ្យព្រះអង្គគាប់ព្រះហឫទ័យ។ ដោយសារការយាងចុះមកនេះ ព្រះអង្គបង្ហាញនូវឧត្ដមភាពឥតព្រំដែន។ ព្រះអាទិត្យបំភ្លឺដើមឈើខ្ពស់ៗ និងបុប្ផាតូចៗនីមួយៗ ហាក់ដូចជាផ្កាទាំងនោះ ដុះឯកឯងលើផែនដី។ ព្រះជាម្ចាស់របស់យើង ក៏ដូច្នោះដែរ ព្រះអង្គទទួលខុសត្រូវជាពិសេស លើព្រលឹងនីមួយៗ ដូចជាគ្មានព្រលឹងឯទៀត ស្ថិតនៅជិតឡើយ។ ចំណែកឯធម្មជាតិក៏ដូចគ្នាដែរ រដូវទាំងអស់សុទ្ធតែត្រូវរៀបរយតាមលំដាប់ ដើម្បីឲ្យផ្កាប៉ាកឺរ៉ែតដ៏តូចនេះ រីកចំពេលវេលាដែលបានកំណត់ទុក។ ដូច្នេះ អ្វីទាំងអស់បានបង្កើតឡើង សមស្របនឹងព្រលឹងនីមួយៗ។ (...)

ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រទានសេចក្ដីស្រឡាញ់មកដល់ខ្ញុំ ពេញមួយជីវិត។ អនុស្សាវរីយ៍ដំបូង គឺស្នាមញញឹម និងការថ្នាក់ថ្នមយ៉ាងទន់ភ្លន់បំផុត! ព្រះអង្គប្រទានសេចក្ដីស្រឡាញ់មកឲ្យខ្ញុំ ទ្រង់ក៏ប្រទានវិធីបង្កើតសេចក្ដីស្រឡាញ់ និងអារម្មណ៍ឆាប់រំភើបញាប់ញ័រមកឲ្យខ្ញុំផងដែរ។ កាលពីក្មេង ខ្ញុំស្រឡាញ់ឪពុកម្ដាយខ្ញុំណាស់ ហើយខ្ញុំចូលចិត្តបង្ហាញភាពទន់ភ្លន់ ម្ទិកម្ទក់រាប់ពាន់ជំពូក ព្រោះខ្ញុំជាមនុស្សមិនចេះលាក់លៀមនោសញ្ចេតនាឡើយ គ្រាន់តែមធ្យោបាយដែលខ្ញុំប្រើនោះ ជួនកាលហាក់ដូចជាចម្លែក៖ *"កូននេះ ជាក្មេងរបុិលរប៉ូចឥតគូប្រៀប នាងមកស្ទាបអង្អែលខ្ញុំ ហើយជូនពរឲ្យខ្ញុំស្លាប់ -ឱ! សូមឲ្យម៉ែស្លាប់ទៅចុះ ម៉ែដ៏កម្សត់របស់កូនអើយ!..."* ។ គេនាំគ្នាស្ដីបន្ទោសឲ្យនាងៗនិយាយថា៖ *"ដើម្បីឲ្យម៉ែបានទៅឋានសួគ៌ ព្រោះម៉ែថា ទាល់តែស្លាប់ទើបទៅឋានសួគ៌បាន"* ។ នាងក៏ជូនពរការស្លាប់ដល់ឪពុកផងដែរ កាលណានាងបង្ហាញសេចក្ដីស្រឡាញ់!"។ (...)

ខ្ញុំមានមោទនភាពណាស់ ចំពោះបងស្រីធំទាំងពីរនាក់ ប៉ុន្តែ បង ប៉ូលីនជាឧត្ដមគតិខ្ញុំ។ កាលទើបតែចេះនិយាយ ម៉ែសួរខ្ញុំថា -*"តើឯងគិតពីអ្វី?"* ខ្ញុំ



តែងតែឆ្លើយថា -*"ប៉ូលីន!..."* ។ មានម្តងនោះ ខ្ញុំយកក្រមាមដៃសរសេរលើកម្រាលឥដ្ឋ ហើយខ្ញុំទន្ទេញថា៖ *"ខ្ញុំសរសេរ៖ ប៉ូលីន!..."* ។ ខ្ញុំឧស្សាហ៍ស្តាប់ឮថា ប៉ូលីននឹងបួសជាដូនជី ខ្ញុំបានគិតដោយមិនដឹងខ្លួនថា៖ ខ្ញុំក៏បួសជាដូនជីដែរ។ នោះហើយជាអនុស្សាវរីយ៍ដំបូងមួយរបស់ខ្ញុំ ហើយតាំងពីពេលនោះមក ខ្ញុំមិនប្តូរការសម្រេចចិត្តឡើយ!។ គឺអ្នកម៉ែទេ ដែលព្រះយេស៊ូជ្រើសរើសឲ្យមកដណ្តឹងខ្ញុំថ្វាយព្រះអង្គ។ កាលនោះ អ្នកម៉ែនៅឆ្ងាយពីខ្ញុំ ប៉ុន្តែ យើងមានចំណងចងភ្ជាប់ព្រលឹងជាមួយគ្នា... អ្នកម៉ែជាមនុស្សដែលខ្ញុំទុកជាគំរូ តាំងពីខ្ញុំអាយុ ២ឆ្នាំ អ្នកនាំខ្ញុំមករកព្រះជាម្ចាស់ ជាស្វាមីនៃនារីព្រហ្មចារី... ឱ! ពេលនោះ ខ្ញុំមានអារម្មណ៍រីករាយ ហើយចង់ជម្រាបអ្នកជាសម្ងាត់! ប៉ុន្តែ ខ្ញុំត្រូវបន្តរឿងផ្កាតូចជាប្រវត្តិពិស្តារ និងទូទៅ ព្រោះខ្ញុំចង់និយាយលំអិតអំពីទំនាក់ទំនងជាមួយ *"ប៉ូលីន"* រឿងផ្សេងទៀត ខ្ញុំទុកមួយឡែកសិន។ (...)

ឥឡូវនេះ ខ្ញុំត្រលប់មកនិយាយពីសំបុត្រដែលម៉ែសរសេរអំពីសេលីន និងខ្ញុំវិញ ព្រោះជាមធ្យោបាយប្រសើរបំផុត ដើម្បីខ្ញុំអាចបញ្ជាក់លក្ខណៈសម្បត្តិរបស់ខ្ញុំ ហើយនេះជាផ្នែកមួយបង្ហាញគុណវិបត្តិរបស់ខ្ញុំ -*"សេលីនលេងដុំគូបជាមួយនាងតូច ជួនកាលក៏ឈ្លោះគ្នាដែរ។ សេលីនព្រមចុះចាញ់ ដោយសារចង់បានអង្កាំមួយ នៅលើក្បាំងដែលនាងពាក់។ ខ្ញុំត្រូវតែកែកំហុសរបស់នាងច្រមក់នេះ ដែលខុសចិត្តខឹងស្រែកទ្រហោយំខ្លាំងៗ។ នាងននៀលលើដី ដូចមនុស្សអស់សង្ឃឹម ដោយបាត់បង់អ្វីៗទាំងអស់។ មានពេលខ្លះ នាងយំយ៉ាងខ្លាំង រហូតដល់បាត់មាត់។ នាងជាក្មេងឆាប់ច្រឡោតខឹង ប៉ុន្តែ នាងស្អាត ហើយឆ្លាតណាស់។ និយាយប្រាប់អ្វី នាងចាំបានទាំងអស់"* ។ ដូចអ្នកម៉ែឃើញស្រាប់ កាលនោះ ខ្ញុំមិនមែនល្អគ្រប់យ៉ាងទេ! ។ (...)

គុណវិបត្តិមួយទៀត ដែលម៉ែមិនបានសរសេរក្នុងសំបុត្រគាត់ គឺការស្រឡាញ់មុខមាត់ខ្លួនឯង។ ថ្ងៃមួយ ម៉ែប្រាប់ខ្ញុំថា៖ -*"ថេរេសា បើឯងថើបដី ម៉ែឲ្យឯង*

*មួយកាក់*"។ សម្រាប់ខ្ញុំ មួយកាក់ គឺច្រើនណាស់ ដើម្បីបានចំណេញមួយកាក់ ខ្ញុំមិនចាំបាច់ឱនចុះខ្លាំងប៉ុន្មានទេ ព្រោះខ្ញុំតូចទាប ប៉ុន្តែ ចិត្តក្រអឺតក្រទមរបស់ខ្ញុំ ប្រឆាំងទៅនឹងគំនិតចើបដី បានទាញឲ្យខ្ញុំឈរត្រង់ខ្លួន ប្រាប់ទៅម៉ែថា -អូហ៍! (ទេ) ខ្ញុំមិនចង់បានកាក់នោះទេ! ... ។ (...)

ឫកពាពីកំណើតរបៀបនេះ ប្រសិនជាត្រូវបានចិញ្ចឹមដោយឪពុកម្ដាយគ្មានសីលធម៌ ឬដូចសេលីន ដែលល្ងីស៍មើលថែទម្រើស ប្រហែលជាខ្ញុំក្លាយទៅជាក្មេងកំណាច និងទៅជាមនុស្សឥតបានការម្នាក់បាត់ទៅហើយ...។ ប៉ុន្តែ ព្រះយេស៊ូបានមើលថែគូដណ្ដឹងតូចរបស់ព្រះអង្គ។ ព្រះអង្គមានបំណងឲ្យអ្វីៗបានល្អប្រសើរ ទោះជានាងមានគុណវិបត្តិក៏ដោយ ព្រះអង្គបានបង្ក្រាបវាតាំងពីក្មេង ធ្វើឲ្យនាងធំធាត់ក្នុងភាពល្អឥតខ្ចោះ។ ដោយខ្ញុំស្រឡាញ់កិត្តិយសខ្លួនឯង និងអំពើល្អតាំងពីតូច ខ្ញុំតែងតែគិតគូរល្អិតល្អន់ (អ្វីៗដែលខ្ញុំបានធ្វើតាំងពីតូចមក) កាលណាដែលគេប្រាប់ថា មិនល្អ ខ្ញុំឈប់ធ្វើភ្លាម មិនចាំបាច់ប្រាប់ម្ដងទៀតឡើយ។ (...)

ដោយខ្ញុំនៅតូចពេក ថ្ងៃអាទិត្យ ខ្ញុំមិនអាចទៅព្រះវិហារបាន ខ្ញុំនៅផ្ទះជាមួយម៉ែ។ កាលនោះ ខ្ញុំមិនរពិសទេ ខ្ញុំដើរតិចៗលើចុងជើង នៅពេលអភិបូជា។ ប៉ុន្តែ កាលណាឃើញទ្វាររបើកភ្លាម គឺការផ្ទុះសំណើចរីករាយ ខ្ញុំស្ទុះយ៉ាងលឿនទៅរកបងស្រីសម្លាញ់ខ្ញុំ ដែលតុបតែងខ្លួនយ៉ាងស្អាត ហើយប្រាប់គាត់ថា៖ *"អូហ៍! បង សេលីន លឿនឡើង ឲ្យខ្ញុំសុំនំប៉័ងពិសិដ្ឋមក!"* ។ ជួនកាល គាត់គ្មានទេ ដោយទៅយឺតពេក... ដូច្នេះ ត្រូវធ្វើដូចម្ដេច? មិនអាចអត់នំប៉័ងនោះបានទេ ព្រោះជា "អភិបូជារបស់ខ្ញុំ... មធ្យោបាយរកឃើញភ្លាម... បងគ្មាននំប៉័ងអញ្ចឹងធ្វើទៅ!"។ ថាភ្លាម ធ្វើភ្លែត។ សេលីនទាញកៅអីមួយ បើកទូយកនំប៉័ងមួយដុំ ល្មមមួយម៉ាត់ រួចហើយសូត្រ Ave Maria ពីលើនំ ហើយហុចមកឲ្យខ្ញុំ បន្ទាប់ពីធ្វើសញ្ញាឈើឆ្កាង។ ចំណែកឯខ្ញុំវិញ ទទួលនំមកញ៉ាំដោយគោរពបំផុត

ហើយយល់ថា នំនោះមានរសជាតិដូចនំប៉ុងពិសិដ្ឋពិតៗ។ ជួនកាល យើងលេង ជួបជុំជាមួយគ្នា។ នេះគឺជាឧទាហរណ៍មួយ ដែលខ្ញុំដកស្រង់អំពីសំបុត្រម៉ែ - "ស្រីតូចទាំងពីរនាក់របស់យើង សេលីន និងថេរេសា ជាទេវតានៃការប្រទានពរ មកពីស្ថានបរមសុខ។ ថេរេសា គឺជាសេចក្តីរីករាយ សុភមង្គលរបស់ព្រះមាតា និងសិរីរុងរឿងរបស់ព្រះនាង។ មិនគួរឲ្យជឿ នាងមានមោទនភាពណាស់។ ការ ពិត នាងមានបញ្ញាលើសអាយុ។ នាងបង្ហាញទៅ សេលីន ដែលមានអាយុ លើសនាងពីរដង។ ថ្ងៃមុន សេលីននិយាយថា៖ *"ហេតុអ្វីក៏ព្រះជាម្ចាស់សណ្ឋិត ក្នុងនំដង្វាយដ៏តូចយ៉ាងនេះ?"* នាងតូចនិយាយថា៖ *"មិនបាច់ឆ្ងល់ទេ ពីព្រោះ ព្រះជាម្ចាស់មានតេជានុភាពសព្វប្រការ" -តើតេជានុភាពសព្វប្រការមានន័យ ដូចម្តេច?" -"គឺអាចធ្វើអ្វីៗតាមតែព្រះអង្គចង់ធ្វើ!"* ។

ថ្ងៃមួយ លេអូនី គិតថា នាងធំហួសពេលលេងកូនតុក្កតាទៀតហើយៗ នាងកាន់កញ្ច្រែងមួយពេញទៅដោយសំពត់ និងកម្ទេចក្រណាត់ល្អៗ សម្រាប់ ធ្វើសំពត់អាវកូនតុក្កតាថែមទៀត។ នាងដាក់តុក្កតាពីលើ -*"ប្អូនស្រីទាំងពីររើស យកទៅ បងឲ្យទាំងអស់"* ។ សេលីន លូកដៃទៅចាប់យកកូនកញ្ចប់ខ្សែអារ ដែលនាងចូលចិត្ត។ ដល់វេនខ្ញុំហើយ បន្ទាប់ពីគិតបន្តិច ខ្ញុំលូកដៃទៅដោយ និយាយថា៖ *"ខ្ញុំរើសយកទាំងអស់!"* ។ មិនបាច់គិតគូរច្រើន ខ្ញុំស្រវាយកទាំង កញ្ច្រែងតែម្តង។ អ្នកនៅទីនោះទាំងប៉ុន្មាន យល់ថា សមរម្យហើយ។ សេលីន ក៏មិនតវ៉ាអ្វីដែរ ព្រោះឪពុកធម៌នាង ឲ្យអំណោយជាញឹកញយ នាងមិនខ្វះល្បែង លេងទេ។

លក្ខណៈសម្គាល់ កាលពីក្មេងដ៏តូចមួយនេះ ជាសេចក្តីសង្ខេបនៃជីវិតខ្ញុំ។ កាលដែលខ្ញុំធំឡើង ខ្ញុំយល់ថា ដើម្បីក្លាយទៅជាសន្តី ត្រូវទទួលការរងទុក្ខលំបាក ជាច្រើន ត្រូវស្វែងរកភាពគ្រប់លក្ខណ៍ ហើយត្រូវបំភ្លេចខ្លួនឯង។ ខ្ញុំក៏យល់ដែរ ថា ភាពគ្រប់លក្ខណ៍ត្រូវមានច្រើនជាន់ថ្នាក់ ព្រលឹងនីមួយៗមានសេរីភាពក្នុង

ការឆ្លើយតបចំពោះតម្រូវការរបស់ព្រះជាម្ចាស់ តើត្រូវធ្វើតិច ឬច្រើន ចំពោះព្រះអង្គ និយាយឲ្យចំទៅ គឺត្រូវជ្រើសរើសរវាងកិច្ចការបូជាទាំងឡាយ ដែលព្រះជាម្ចាស់ត្រូវការ។ ដូច្នេះហើយបានជាកាលនៅពីតូច ខ្ញុំតែងតែនិយាយខ្លាំងៗថា៖ *"ព្រះជាម្ចាស់អើយ កូនរើសយកទាំងអស់។ កូនមិនចង់ក្លាយជាសន្តិតែពាក់កណ្តាលទេ កូនមិនខ្លាចរងទុក្ខ ដើម្បីព្រះអង្គឡើយ កូនខ្លាចតែមួយមុខគត់ គឺខ្វះឆន្ទៈ សូមព្រះអង្គទទួលយកការបូជានេះចុះ ព្រោះកូនរើសយកទាំងអស់តាមតែព្រះបំណង"*។

ខ្ញុំត្រូវឈប់និយាយអំពីកុមារភាព តែនិយាយអំពីក្មេងតូចអាយុ ៤ឆ្នាំវិញ។ ខ្ញុំនៅចងចាំអំពីការយល់សប្តិ កាលពីខ្ញុំអាយុ ៤ឆ្នាំ ហើយសុបិននោះ បានចារជាប់ក្នុងក្តីស្រមៃរបស់ខ្ញុំជានិច្ច។ មានយប់មួយ ខ្ញុំយល់សប្តិឃើញថា ខ្ញុំដើរលេងម្នាក់ឯងក្នុងសួនច្បារ។ ពេលដើរមកដល់កាំជណ្តើរខាងក្រោមបង្អស់ ខ្ញុំឈប់ឈរទ្រើង ហាក់ដូចជាខ្លាចញញើត។ ខាងមុខខ្ញុំ ក្បែរទ្រើងផ្កា មានធុងកំបោរមួយ។ ក្នុងធុងនោះ មានកូនបីសាចពីរ រូបអាក្រក់ក្រៃលែង កំពុងរាំយ៉ាងរហ័សរហួន ទោះជាមានឆ្នាំងអ៊ុតចងភ្ជាប់ជើងក៏ដោយ។ ភ្លាមនោះ កូនបីសាចបានក្រលេកមើលមកខ្ញុំ ទាំងភ្នែកក្រហមច្រាល។ ពួកវាហាក់ដូចជាភ័យខ្លាចជាងខ្ញុំទៅទៀត ហើយក៏សម្រូតចុះពីធុងទៅពួនក្នុងខោអាវ ដែលគរទុកក្បែរនោះ។ ដោយឃើញពួកវាភ័យ ខ្ញុំចង់ដឹងថា តើពួកវាធ្វើអ្វី ទើបខ្ញុំដើរចូលទៅជិតបង្អួច។ កូនបីសាចទាំងនោះ រត់លើតុ មិនដឹងជាធ្វើដូចម្តេច ដើម្បីគេចចេញពីក្រសែភ្នែកខ្ញុំបាន។ ជួនកាល វារត់មកជិតបង្អួច ទាំងទឹកមុខព្រួយបារម្ភ។ ពេលក្រលេកឃើញខ្ញុំភ្លាម វាក៏រត់ដូចជាអស់សង្ឃឹម។ សុបិននេះ គ្មានអ្វីអស្ចារ្យទេ ប៉ុន្តែ ខ្ញុំជឿថា ព្រះជាម្ចាស់ដែលអនុញ្ញាតឲ្យខ្ញុំនៅចាំ ដើម្បីបង្ហាញថា ព្រលឹងដែលទទួលការប្រោសប្រណី មិនត្រូវខ្លាចពួកបីសាចដែលកំសាករត់គេចពីក្រសែភ្នែកកូនក្មេង...។ (...)

ខ្ញុំនៅចាំជានិច្ច ពិសេសដំណើរកំសាន្តថ្ងៃអាទិត្យ ដែលម៉ែឪស្សាហ៍នាំយើងទៅ។ ស្ទើរតែរាល់លើក ពេលដើរតាមផ្លូវ យើងតែងតែជួបអ្នកក្រីក្រ ហើយនាងតូច ថេរេសា ជាអ្នកដាក់ទានដោយសេចក្តីរីករាយ។ ប៉ុន្តែ ពុកយល់ថាផ្លូវនោះហាក់ដូចជាឆ្ងាយជ្រុល សម្រាប់ម្ចាស់ក្សត្រីតូចរបស់គាត់ គាត់ក៏នាំថេរេសាមកផ្ទះមុនគេ (នាងមិនសប្បាយចិត្តទេ)។ ពេលត្រលប់មកវិញ ដើម្បីលួងលោម ថេរេសា សេលីន បានបេះផ្កាប៉ាកឺរ៉េត ដាក់ពេញកូនកន្ត្រកតូចច្រលឹងមួយ យកមកឲ្យនាង។ ម៉ែឃើញផ្កានោះច្រើនជ្រុល ក៏រំលែកមួយចំណែកទៅថ្វាយព្រះមាតា។ ថេរេសាមិនសប្បាយចិត្តទេ តែនាងមិនចេញស្តី ព្រោះនាងមានទម្លាប់មិនចេះត្អូញត្អែរ ទោះជាគេយករបស់អ្វីពីនាង ឬចោទប្រកាន់ដោយអយុត្តិធម៌ក៏ដោយ នាងស៊ូនៅស្ងៀម ហើយមិនព្រមសូមទោសទៀតផង។ ទាំងនេះ មិនមែនជាគុណសម្បត្តិរបស់នាងទេ គឺជាគុណធម៌ពីកំណើត។ តែគួរឲ្យស្តាយណាស់ គុណធម៌បែបនេះ បានបាត់បង់អស់ហើយ!... ប្រាកដហើយ! អ្វីៗលើលោកនេះ ញញឹមដាក់ខ្ញុំជានិច្ច។ ខ្ញុំជួបផ្កាគ្រប់ជំហាន ហើយលក្ខណៈរីករាយរបស់ខ្ញុំ ក៏ចូលរួមចំណែក ធ្វើឲ្យជីវិតខ្ញុំស្រស់ស្រាយដែរ ប៉ុន្តែ ដំណាក់កាលថ្មីមួយ នឹងចាប់ផ្តើមសម្រាប់ព្រលឹងរបស់ខ្ញុំ ហើយខ្ញុំត្រូវតែឆ្លងកាត់ឧបសគ្គរងទុក្ខសោកតាំងពីក្មេង ដើម្បីអាចឆាប់បានចូលទៅជិតព្រះយេស៊ូ។ ផ្កានៃនិទាឃរដូវក៏ដូចគ្នាដែរ ពួកវាប៉ិចពន្លកក្រោមស្រទាប់ព្រិល ហើយរីកក្រោមរស្មីព្រះអាទិត្យដំបូង។ ដូច្នេះហើយផ្កាតូចដែលខ្ញុំសរសេរអំពីការចងចាំរបស់នាងក៏ត្រូវឆ្លងកាត់ការលំបាកវេទនានៃសិសិររដូវដែរ...។ (...)

ថ្ងៃមរណភាពរបស់ម៉ែ ឬថ្ងៃបន្ទាប់ ពុកឱបខ្ញុំ ហើយនិយាយប្រាប់ថា៖ -*"មកឱបម្តាយឯងជាលើកចុងក្រោយទៅ"* ។ ពេលនោះ ខ្ញុំដើរចូលទៅដោយស្ងប់ស្ងាត់ ហើយថើបថ្ពាស់ម្តាយកម្សត់របស់ខ្ញុំ... ខ្ញុំមិនបានចាំថា ខ្ញុំយំច្រើន ឬតិចទេ ខ្ញុំមិននិយាយប្រាប់នរណាទាំងអស់ អំពីមនោសញ្ចេតនាដែលកប់ជ្រៅក្នុងទ្រូងខ្ញុំ... ខ្ញុំមើល ហើយស្តាប់ដោយស្ងៀមស្ងាត់... គ្មាននរណាមានពេល



វេលាមើលថៃខ្ញុំទេ ដូច្នេះ ខ្ញុំយល់ច្បាស់នូវវត្ថុដែលគេចង់លាក់លៀម។ មានម្តងនោះ ខ្ញុំដើរទៅជិតគំរបក្តារមឈូស... ខ្ញុំឈរមើលយ៉ាងយូរ ខ្ញុំមិនដែលឃើញសោះ តែខ្ញុំយល់។ កាលនោះ ខ្ញុំនៅតូចណាស់ ទោះជាម៉ែមានមាឌតូចក៏ខ្ញុំត្រូវងើយក្បាល មើលទៅគាត់ដែរ។ ក្តារមឈូសហាក់ដូចជាធំ ហើយក្រៀមក្រំផង។ ដប់ប្រាំឆ្នាំក្រោយមក ខ្ញុំនៅក្បែរក្តារមឈូសមួយទៀត គឺមឈូសរស់អ្នកម៉ែ សឺណឺរីយែរ ដែលមានទំហំប៉ុនមឈូសម៉ែពីមុនដែរ ហើយខ្ញុំហាក់ដូចជាស្រមៃឃើញ កាលខ្ញុំនៅពីក្មេង! អនុស្សាវរីយ៍ទាំងប៉ុន្មាន ប្រជ្រៀតគ្នាចេញមកទាំងហ្វូង គឺក្មេងស្រី ថេរេសា ដដែល ឈរមើល ប៉ុន្តែ នាងធំហើយ ក្តារមឈូសហាក់ដូចជាតូច នាងមិនចាំបាច់ងើយក្បាល ដើម្បីមើលទេ។ នាងងើយក្បាលសម្រាប់តែមើលមេឃប៉ុណ្ណោះ។ មេឃដែលធ្វើឲ្យរីករាយណាស់ ការលំបាកទាំងប៉ុន្មាន បានចប់សព្វគ្រប់ហើយ សិសិររដូវនៃព្រលឹងរបស់នាង ក៏បានរសាត់ផុតទៅជារៀងរហូតដែរ...។

ថ្ងៃដែលព្រះសហគមន៍ប្រសិទ្ធិពរជូនសពម៉ែ ព្រះជាម្ចាស់មានបំណងផ្តល់ម្តាយម្នាក់ទៀតលើផែនដីនេះមកឲ្យខ្ញុំ ព្រះអង្គប្រទានឲ្យខ្ញុំជ្រើសរើសតាមចិត្ត។ វេលាបងប្អូនយើងទាំងប្រាំនាក់នៅជាមួយគ្នា មើលមុខគ្នាទៅវិញទៅមកដោយក្រៀមក្រំ មេដោះក៏នៅទីនោះដែរ ដោយឃើញ សេលីន និង ខ្ញុំ គាត់និយាយថា៖ *"ក្មេងស្រីកម្សត់អើយ ពួកឯងលែងមានម្តាយហើយ!..."* ។ ពេលនោះ សេលីន លោតចូលរង្វង់ដៃ ម៉ារី ដោយនិយាយថា៖ -*"បើអញ្ចឹង បងម៉ារីនឹងទៅជាម៉ែ!"*។ រីឯខ្ញុំវិញ ខ្ញុំមានទម្លាប់ធ្វើត្រាប់តាម សេលីន ប៉ុន្តែ ពេលនោះ ខ្ញុំងាកមកអ្នកម៉ែវិញ ហាក់ដូចជាអនាគតកាលបានហែករបាំង ខ្ញុំបានរត់ចូលក្នុងរង្វង់ដៃរបស់អ្នក ដោយស្រែកថា៖ *"ចំណែកខ្ញុំ ខ្ញុំយកប៉ូលីនជាម៉ែ!"* ( ... )

អ្នកម៉ែ ខ្ញុំសូមជម្រាបថា តាំងពីម៉ែយើងអនិច្ចកម្មទៅ លក្ខណៈសប្បាយរីករាយរបស់យើង បានប្តូរស្រេលះ ខ្ញុំជាមនុស្សរហ័សរហួន ចូលចិត្តនិយាយច្រើន ក្លាយទៅជាអៀនប្រៀន ស្លូតបូត ឆាប់រំជួលចិត្ត គ្រាន់តែគេក្រលេកចំ

ទឹកភ្នែកក៏ហូរចេញមកភ្លាម។ ដើម្បីឲ្យខ្ញុំរីករាយ ត្រូវកុំឲ្យមាននរណាមករវីរវល់ជាមួយខ្ញុំ។ ខ្ញុំមិនអាចនៅជាមួយអ្នកដទៃ ខ្ញុំរីករាយបានតែក្នុងរង្វង់គ្រួសារប៉ុណ្ណោះ។ អ្នកនៅជុំវិញខ្លួន គេយកចិត្តទុកដាក់ថ្នាក់ថ្នមខ្ញុំជាពិសេស។ ពុកតាំងពីដើមមកស្រឡាញ់ថ្នាក់ថ្នមខ្ញុំដូចម៉ែដែរ! ចំណែកអ្នកម៉ែ និងម៉ារី តើអ្នកមិនមែនជាម្ដាយដ៏ទន់ភ្លន់ ថ្នាក់ថ្នម និងយកចិត្តទុកដាក់ថៃទាំជាងគេបំផុតទេឬ? ឱ! ប្រសិនបើព្រះជាម្ចាស់មិនប្រទានរស្មីដ៏កក់ក្ដៅមកឲ្យផ្កាតូចនេះទេ ម្ល៉េះសមផ្កាមិនអាចទ្រាំទ្របានទេ ផ្កានឹងចុះខ្សោយ ពុំអាចទ្រាំនឹងតំណក់ទឹកភ្លៀង និងព្យុះព្យោមាដែលបក់បោកបានឡើយ។ ផ្កាតូចនេះ ត្រូវការកម្ដៅ ទឹកសន្សើម និងជំនោរនិទាឃរដូវ។ តែផ្កានេះ មិនដែលខ្វះវត្ថុទាំងនេះឡើយ ដ្បិតព្រះយេស៊ូបានប្រោសប្រទានឲ្យបានដូចបំណង ទោះជាក្រោមគំនរព្រិលនៃទុក្ខក៏ដោយ!... ។

ខ្ញុំចាកចេញពីអាឡង់សុង ទៅនៅលីស្សឺ ដោយគ្មានទុក្ខព្រួយឡើយ ផ្ទុយទៅវិញ ខ្ញុំសប្បាយចិត្តណាស់ (ក្មេងៗចូលចិត្តការផ្លាស់ប្ដូរ) ។ (...) នៅលីស្សឺរាល់ព្រឹក អ្នកម៉ែតែងតែមករកខ្ញុំ សួរខ្ញុំថា តើយល់ព្រមប្រគល់បេះដូងថ្វាយព្រះជាម្ចាស់ហើយឬនៅ បន្ទាប់មក អ្នកម៉ែស្លៀកពាក់ឲ្យខ្ញុំ ដោយរៀបរាប់អំពីព្រះអង្គប្រាប់ខ្ញុំ ហើយពួកយើងនាំគ្នាអធិដ្ឋាន បន្ទាប់មកគឺរៀនអាន។ ពាក្យដំបូងបង្អស់ដែលខ្ញុំចេះអាន គឺ *"ស្ថានបរមសុខ"* ។ ម៉ែធម៌ខ្ញុំទទួលបន្ទុកបង្រៀនសរសេរ ចំណែកឯអ្នកម៉ែវិញ បង្រៀនមុខវិជ្ជាផ្សេងៗទៀត។ ខ្ញុំត្រូវតែខិតខំណាស់ទើបចេះ ប៉ុន្តែ ខ្ញុំមានការចងចាំល្អ។ ខ្ញុំចូលចិត្តការអប់រំគោលសំខាន់ៗនៃសាសនា និងប្រវត្តិរបស់សន្តបុគ្គល ប៉ុន្តែខ្ញុំមិនចូលចិត្តវេយ្យាករណ៍ទេ...។ (...)

រាល់ពេលរសៀល ខ្ញុំតែងតែដើរកំសាន្តជាមួយពុក យើងទៅជួបព្រះយេស៊ូក្នុងអគ្គសញ្ញាព្រះកាយព្រះអង្គ ដើរមើលវិហារថ្មីជារៀងរាល់ថ្ងៃ។ ហេតុនេះហើយខ្ញុំបានចូលព្រះវិហារតូចកាមែលជាលើកទីមួយ។ ពុកចង្អុលចម្រឹងខណ្ឌទីសក្ការបូជាប្រាប់ថា ខាងក្រោមនោះ គឺកន្លែងដូនជី។ កាលនោះ ខ្ញុំមិនបាននឹកស្មានថា

ប្រាំបួនឆ្នាំក្រោយមក ខ្ញុំមករស់នៅជាមួយពួកគាត់ទេ!... (...)

ថ្ងៃណាដែលពុកជាទីស្រឡាញ់ នាំខ្ញុំទៅស្ទូចត្រី ថ្ងៃនោះ ជាថ្ងៃល្អសម្រាប់ខ្ញុំ។ ខ្ញុំចូលចិត្តស្រុកស្រែ និងសត្វស្លាបណាស់! ជួនកាល ខ្ញុំសាកល្បងស្ទូចត្រីដោយសន្ទូចដ៏តូចរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំចូលចិត្តអង្គុយម្នាក់ឯងលើស្មៅ ដែលមានផ្កាព្រោងព្រាតជាង។ ពេលនោះហើយ គំនិតខ្ញុំចុះទៅដល់ទីជម្រៅ ដោយមិនដឹងថា ខ្លួនជាការស្ងឹងស្ងាធ។ ព្រលឹងខ្ញុំមុជចុះយ៉ាងជ្រៅ... ខ្ញុំស្តាប់សំឡេងរសាត់មកពីឆ្ងាយ ស្នូរខ្យល់បក់ល្ហើយៗ និងភ្លេងទាហាន ដែលរសាត់មកប៉ះ សោតារម្មណ៍ បណ្តាលឲ្យចិត្តខ្ញុំអណ្តែតអណ្តូង លន្លង់លន្លោច... ផែនដីហាក់ដូចជាកន្លែងនិរទេសខ្លួន ហើយខ្ញុំ ស្រមៃដល់ស្ថានបរមសុខ... ថ្ងៃរសៀលហាក់ដូចជាកន្លងទៅយ៉ាងលឿន ដល់ពេលត្រូវត្រលប់មកផ្ទះវិញ។ មុននឹងចាកចេញ ខ្ញុំញ៉ាំចំណីចំណុក ដែលយកមកដាក់ក្នុងកូនកន្ត្រកមួយ។ នំប៉័ងលាបដំណាប់ដែលអ្នកម៉ែរៀបចំឲ្យខ្ញុំ បានប្តូរសភាពអស់ហើយ។ កាលធ្វើភ្លាម វាមានពណ៌ស្រស់ ឥឡូវនេះ វាជ្រួញស្វិតពណ៌ក្រហមភ្លាវ។ ពេលនោះ ភពផែនដី ហាក់ដូចជាស្វិតស្រពោន ហើយខ្ញុំយល់ថា មានតែស្ថានបរមសុខទេ ដែលមានការរីករាយ គ្មានពពកដែលជាឧបសគ្គ។ (...)

រាល់ពេលដើរកំសាន្តជាមួយពុក គាត់ចូលចិត្តឲ្យខ្ញុំកាន់វត្ថុសម្រាប់ដាក់ទានដល់អ្នកក្រីក្រ ដែលយើងតែងតែជួប។ ថ្ងៃមួយនោះ យើងឃើញមនុស្សម្នាក់ដើរអូសជើងយ៉ាងលំបាក ទប់ខ្លួននឹងឈើច្រត់ ខ្ញុំបានចូលទៅជិត ដើម្បីដាក់ទាន ប៉ុន្តែ គាត់មិនមែនជាអ្នកសុំទានទេ។ គាត់មើលមុខខ្ញុំដោយញញឹមយ៉ាងក្រៀមក្រំ ហើយមិនព្រមទទួលយកអ្វីៗដែលខ្ញុំជូនគាត់ឡើយ។ ខ្ញុំមិនអាចរៀបរាប់ អំពីទឹកចិត្តខ្ញុំពេលនោះបានទេ ខ្ញុំគ្រាន់តែចង់លួងលោម សម្រាលទុក្ខគាត់តែប៉ុណ្ណោះ ផ្ទុយទៅវិញ ខ្ញុំគិតថា ខ្ញុំធ្វើឲ្យគាត់រឹតតែលំបាកចិត្តជាងមុនទៅទៀត ប្រហែលជាគាត់ យល់ពីគំនិតខ្ញុំហើយមើលទៅ ទើបគាត់បែរមកញញឹម

ដាក់ខ្ញុំ។ ខ្ញុំចង់ជូនអ្វីមួយដែលគាត់បដិសេធមិនបាន ព្រោះខ្ញុំពិតជា មានសមានចិត្ត ចំពោះគាត់ណាស់។ កាលនោះ ខ្ញុំនឹកឃើញសម្ដីគេនិយាយថា ថ្ងៃទទួលព្រះកាយព្រះគ្រីស្ដដំបូង គេអាចទទួលបានតាមបំណងប្រាថ្នាដែលចង់។ គំនិតនេះ បានលួងលោមខ្ញុំ ទោះជាខ្ញុំទើបតែមានអាយុ ៦ឆ្នាំក៏ដោយខ្ញុំគិតក្នុងចិត្តថា៖

*"ខ្ញុំនឹងអធិដ្ឋានដើម្បីគាត់ ថ្ងៃទទួលព្រះកាយព្រះគ្រីស្ដដំបូងគេ"*។ ប្រាំឆ្នាំក្រោយ ខ្ញុំបានគោរពតាមពាក្យសន្យា ហើយខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់ទទួលសេចក្ដីអធិដ្ឋាន ដែលព្រះអង្គបណ្ដាលចិត្តខ្ញុំនេះ សូមឲ្យជើងគាត់ជាសះស្បើយទៅ។ (...)

ល្ងាចមួយនោះ យើងបានប្រុងប្រៀបជាស្រេច ដើម្បីធ្វើការអធិដ្ឋាន ខ្ញុំនិយាយទៅអ្នកបម្រើថា៖ *"បងចាប់ផ្ដើមទៅ ខ្ញុំអុជទៀន"*។ គាត់ធ្វើហាក់ដូចជាផ្ដើមសូត្រ ប៉ុន្តែ ឥតនិយាយសោះ គាត់មើលមុខខ្ញុំដោយអស់សំណើច។ ខ្ញុំឃើញគ្រាប់ឈើគូសឆេះយ៉ាងលឿន ខ្ញុំអង្វរគាត់ឲ្យអធិដ្ឋាន គាត់នៅស្ងៀម។ ពេលនោះ ខ្ញុំក្រោកឈរឡើង ស្ដីឲ្យគាត់ថា៖ *"បងចិត្តអាក្រក់"*។ ខ្ញុំលែងជាក្មេងស្លូតបូតទៀតហើយ ខ្ញុំទន្ទ្រាំជើងយ៉ាងខ្លាំង គាត់សើចលែងចេញ មើលមុខខ្ញុំដោយឆ្ងល់ ហើយចង្អុលទៅទៀន សម្រាប់បំភ្លឺបន្ទប់ក្រោមដី ដែលគាត់យកមក...។ ក្រោយ ពីខឹងហូរទឹកភ្នែក ម្ដងនេះខ្ញុំយំស្ដាយខ្លួន ដែលស្ដីបន្ទោសឲ្យគាត់ ហើយខ្ញុំសារភាពថា លែងធ្វើបែបនេះទៀតហើយ!...

ខ្ញុំមានរឿងជាមួយគាត់ម្ដងទៀត តែលើកនេះ ខ្ញុំមិនព្រមសារភាពទេ ខ្ញុំធ្វើមិនដឹង។ កាលនោះ ខ្ញុំចង់បានដបទឹកខ្មៅនៅជិតបំពង់ផ្សែង ក្នុងផ្ទះបាយ។ ដោយខ្ញុំនៅតូចពេក ឈោងមិនដល់ ខ្ញុំទទូចសុំយ៉ាងខ្លាំង តែគាត់មិនព្រមយកឲ្យខ្ញុំទេ គាត់ប្រើឲ្យខ្ញុំឡើងឈរលើកៅអី។ ខ្ញុំយកកៅអីមកដាក់ ឥតស្ដីមួយម៉ាត់ គិតថា គាត់ជាមនុស្សមិនល្អ។ ខ្ញុំចង់ឲ្យគាត់ដឹងខ្លួន ព្រោះគាត់ឧស្សាហ៍ហៅខ្ញុំថា ក្មេងក្មាង ពេលណាគាត់ធុញថប់។ ពាក្យនេះ ជាពាក្យបង្អាប់ ដែលខ្ញុំស្អប់ជាង

គេ។ ដូច្នេះហើយ មុននឹងលោតចុះពីកៅអី ខ្ញុំបែរមុខយ៉ាងសង្ហារ ហើយប្រាប់គាត់ថា៖ *"បងឯងជាក្មេងក្មាង"* រួចខ្ញុំរត់ចេញទៅ ទុកឲ្យគាត់ឈរទ្រឹង គិតអំពីជម្រៅពាក្យដែលខ្ញុំថា...។ លទ្ធផលមិនបាច់រង់ចាំយូរ។ ភ្លាមនោះ ខ្ញុំឮគាត់ស្រែកថា៖ *"អ្នកនាងម៉ារី ថេរេសា ហៅខ្ញុំថា ក្មេងក្មាង!"* ។ ម៉ារី មកដល់ហើយបង្គាប់ឲ្យខ្ញុំសុំទោស ប៉ុន្តែ ខ្ញុំគ្មានទោសទេ ព្រោះគាត់មានដៃវែង តែមិនព្រមជួយយកដបទឹកខ្មៅនោះ គាត់ត្រូវតែទទួលឈ្មោះថា ក្មេងក្មាងអញ្ចឹងហើយ...។ (...)

មានថ្ងៃពុធមួយនោះ លោកបូជាចារ្យ ឌុសសៃលីយេ មកលេងនឹងខ្ញុំ។ អ្នកបម្រើនេះជម្រាបគាត់ថា ក្នុងផ្ទះគ្មានមនុស្សនៅទេ មានតែនាងតូច ថេរេសា ប៉ុណ្ណោះ។ គាត់ចូលទៅក្នុងចង្ក្រានបាយ ហើយមើលកិច្ចការរបស់ខ្ញុំ។ ខ្ញុំមានមោទនភាពណាស់ ដោយបានទទួលលោក ព្រោះខ្ញុំទើបតែសុំទទួលអគ្គសញ្ញាលើកលែងទោសជាលើកទីមួយ កន្លងមកថ្មីៗនេះ។ គឺជាអនុស្សាវរីយ៍ដ៏ផ្អែមល្ហែមរបស់ខ្ញុំ! ... ឱអ្នកម៉ែ! អ្នកបានបង្រៀនឲ្យខ្ញុំយកចិត្តទុកដាក់ អ្នកប្រាប់ខ្ញុំថា ឯងមិនមែនសារភាពអំពើបាបចំពោះមនុស្សទេ តែចំពោះព្រះជាម្ចាស់ ខ្ញុំក៏ជឿតាមអ្នក ខ្ញុំបានសារភាពដោយមុតមាំ ខ្ញុំថែមទាំងសួរទៅអ្នកម៉ែថា តើខ្ញុំមិនត្រូវនិយាយប្រាប់លោកថា ខ្ញុំស្រឡាញ់គាត់យ៉ាងខ្លាំងទេឬ? ព្រោះកាលណាខ្ញុំនិយាយ គឺខ្ញុំនិយាយទូលដល់ព្រះជាម្ចាស់ហើយ....។

ដោយចេះចាំសព្វប្រការដែលត្រូវនិយាយ និងប្រតិបត្តិតាម ខ្ញុំដើរចូលទៅកន្លែងស្រាយបាប ហើយខ្ញុំលុតជង្គង់ចុះ។ ប៉ុន្តែ លោកបូជាចារ្យមិនបានមើលឃើញខ្ញុំសោះ។ កាលនោះ ខ្ញុំតូចក្បាលទាបជាងជើងម៉ា ដែលគេត្រូវដាក់ដៃពីលើ ដូច្នេះហើយ លោកប្រាប់ឲ្យខ្ញុំឈរ មិនបាច់លុតជង្គង់ទេ។ ខ្ញុំក្រោកឈរភ្លាម បែរមុខទៅរកគាត់ ព្រោះស្រួលមើលមុខគ្នា ខ្ញុំសារភាពបាបរបស់ខ្ញុំដូចក្មេងស្រីធំម្នាក់ ហើយខ្ញុំទទួលការប្រសិទ្ធិពរ ដោយជំនឿយ៉ាងជ្រាលជ្រៅបំផុត ព្រោះអ្នកម៉ែប្រាប់ខ្ញុំថា ពេលនោះទឹកព្រះនេត្ររបស់ព្រះកុមារយេស៊ូនឹង

បន្សុតព្រលឹងរបស់ខ្ញុំ។ ខ្ញុំនៅចាំពាក្យដាស់តឿនដែលគេប្រាប់លើកដំបូង នឹងនាំឲ្យខ្ញុំមានសេចក្តីស្រឡាញ់ ជាពិសេសចំពោះព្រះមាតា ហើយខ្ញុំប្តេជ្ញាក្នុងចិត្តថា នឹងរឹតតែស្រឡាញ់ និងគោរពព្រះនាងលើសមុនទៅទៀត។ ក្រោយពេលចាកចេញពីនោះ ខ្ញុំសប្បាយចិត្ត និងស្រាលខ្លួនយ៉ាងខ្លាំង ហាក់ដូចជាមិនដែលបានទទួលអារម្មណ៍រីករាយ ដូចលើកនេះឡើយ។ ចាប់ពីថ្ងៃនោះមក ខ្ញុំតែងតែត្រលប់មកសារភាពបាបរបស់ខ្លួន រាល់ឱកាសបុណ្យធំៗ ហើយរាល់លើកដែលខ្ញុំចូលទៅទីនោះ គឺជាពិធីបុណ្យសម្រាប់ខ្ញុំយ៉ាងពិតប្រាដក។ (...)

ខ្ញុំចាត់ទុកថា ជាការប្រោសប្រទានមួយ ដើម្បីជម្នះលើការភ័យខ្លាច ដែលអ្នកម៉ែមានទម្លាប់ប្រើខ្ញុំតែម្នាក់ឯង វេលាយប់ងងឹត ឲ្យទៅយកវត្ថុអ្វីមួយនៅបន្ទប់ឆ្ងាយ។ ប្រសិនបើមិនបានដឹកនាំយ៉ាងល្អទេ ប្រហែលខ្ញុំក្លាយជាមនុស្សកំសាក ភ័យខ្លាចមិនសមហេតុផល។ តាំងពីពេលនោះរហូតដល់សព្វថ្ងៃនេះ ខ្ញុំជាមនុស្សមិនងាយនឹងបន្លាចឡើយ។ អ្នកម៉ែខ្ញុំសួរខ្លួនឯងថា តើអ្នកចិញ្ចឹមខ្ញុំដោយសេចក្តីស្រឡាញ់ និងយកចិត្តទុកដាក់យ៉ាងណា ទើបខ្ញុំមិនមែនជាក្មេងទម្រើស ព្រោះអ្នកម៉ែមិនបណ្តែតបណ្តោយឲ្យខ្ញុំខូច អ្នកមិនដែលស្តីបន្ទោស ដោយគ្មានហេតុផលទេ តែបើសម្រេចអ្វីមួយហើយ អ្នកមិនថយក្រោយឡើយ។ (...)

ប៉ូលីន ជាអ្នកទទួលដោះស្រាយបំភ្លឺរាល់ការសម្ងាត់របស់ខ្ញុំ...។ មានម្តងនោះ ខ្ញុំឆ្ងល់ថា ព្រះជាម្ចាស់មិនប្រទានសិរីរុងរឿងរបស់ស្ថានបរមសុខ ឲ្យអ្នកដែលព្រះអង្គគាប់ព្រះហឫទ័យស្មើៗគ្នាទេ។ ខ្ញុំខ្លាចថា គ្រប់គ្នាមិនបានទទួលសុភមង្គល។ ពេលនោះ ប៉ូលីន បង្គាប់ឲ្យខ្ញុំទៅយកកែវធំរបស់ពុក មកដាក់ទន្ទឹមនឹងប្រដាប់ស៊កម្រាមដៃសម្រាប់ដេរ រួចចាក់ទឹកឲ្យចេញ បន្ទាប់មកប៉ូលីនសួរខ្ញុំថា មួយណាពេញជាងគេ។ ខ្ញុំឆ្លើយថា ពេញដូចគ្នា មិនអាចចាក់បន្ថែមទៀតបានទេ ពុំនោះទេ ទឹកនឹងហូរហៀរពុំខានឡើយ។ អ្នកប្រាប់ឲ្យខ្ញុំយល់ថា នៅស្ថានបរមសុខ ព្រះជាម្ចាស់ប្រទានសិរីរុងរឿងដល់អ្នកដែលព្រះអង្គគាប់ព្រះហឫទ័យ

តាមតែអ្នកទាំងនោះអាចទទួលបាន បែបនេះអ្នកចុងក្រោយមិនអាចច្រណែននឹងអ្នកទីមួយបានឡើយ។ តាមការពន្យល់បែបនេះហើយ ទើបខ្ញុំបានយល់ច្បាស់ពល់អាថ៌កំបាំងដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គបាន។ អ្នកម៉ែជ្រាបទេ គឺអ្នកនេះហើយដែលបានបំប៉នចំណីចាំបាច់ដល់ព្រលឹងរបស់ខ្ញុំ...។ (...)

មានថ្ងៃមួយនោះ ព្រះជាម្ចាស់បានបង្ហាញឲ្យខ្ញុំឃើញ ក្នុងនិមិត្តមួយអស្ចារ្យបំផុត នូវរូបភាពរស់រវើក នៃទុក្ខលំបាកមួយ ដែលព្រះអង្គសព្វព្រះហឫទ័យរៀបចំយើងបម្រុងទុកជាមុន។ ពែងរបស់ព្រះអង្គបានចាក់បំពេញរួចជាស្រេច។

ពុកបានចាកចេញពីផ្ទះ ធ្វើដំណើរជាច្រើនថ្ងៃមកហើយ សល់ពីរថ្ងៃទៀតទើបត្រូវត្រលប់មកវិញ។ ប្រហែលជាម៉ោងពីរ ឬម៉ោងបីរសៀល ព្រះអាទិត្យជះពន្លឺពេញមេឃ ធម្មជាតិទាំងឡាយ ហាក់ដូចជានាំគ្នាចូលរួមក្នុងពិធីបុណ្យមួយ។ កាលនោះ ខ្ញុំឈរម្នាក់ឯង ក្បែរបង្អួចបន្ទប់ក្រោមដំបូល ដែលបែរទៅរកសួនច្បារធំ។ ខ្ញុំមើលទៅមុខ ស្មារតីស្រស់ថ្លា ពេលនោះខ្ញុំឃើញនៅចំពីមុខបន្ទប់បោកគក់ មានបុរសម្នាក់ស្លៀកពាក់ដូចពុក មាឌប៉ុនគ្នា ដំណើរដូចគ្នាខុសតែគាត់មានខ្នងកោងជាងពុក ក្បាលទទូរអាវអៀមមានពណ៌មិនប្រាកដធ្វើឲ្យខ្ញុំមើលមិនច្បាស់ គាត់ពាក់មួកដូចមួកពុក។ គាត់ដើរទៅមុខ បោះជំហានមួយៗ កាត់តាមសួនច្បារតូច... ភ្លាមនោះ អារម្មណ៍ភ័យខ្លាចមិនធម្មតាមួយ រត់មកប៉ះវិញ្ញាណខ្ញុំ ប៉ុន្តែមួយភ្លែតនោះ ខ្ញុំគិតថា ពុកត្រលប់មកវិញហើយៗ គាត់ពួនដើម្បីពញ្ញាក់ខ្ញុំ ដូច្នេះខ្ញុំក៏ស្រែកហៅខ្លាំងៗអស់មួយទំហឹង ដោយសំឡេងញាប់ញ័ររំជួលចិត្ត៖ *"ពុក! ពុក!"* ។ ប៉ុន្តែបុរសដ៏អាថ៌កំបាំងនោះ ហាក់ដូចជាមិនឮខ្ញុំហៅទេ គាត់បន្តដំណើរយឺតៗដោយឥតងាកមកសោះ។ ខ្ញុំខំសម្លឹងតាមឃើញគាត់ដើរឆ្ពោះទៅរកគុម្ពោតមួយ នៅចំកណ្តាលផ្លូវធំ។ ខ្ញុំរង់ចាំមើល ក្រែងលោគាត់ដើរដល់ជ្រុងម្ខាងដែលមានដើមឈើធំៗ ប៉ុន្តែ ការនិមិត្តបែបទំនាយនោះ បានរលាយបាត់ទៅ! ... ព្រឹត្តិការណ៍នេះ កើតឡើងតែមួយស្របក់ប៉ុណ្ណោះ

ប៉ុន្តែបានត្រូវចារឹកទុកយ៉ាងជ្រៅក្នុងបេះដូងខ្ញុំរហូតដល់សព្វថ្ងៃនេះ។ ដប់ប្រាំឆ្នាំកន្លងមកហើយ តែការចងចាំនៅតែផុសពីមុខខ្ញុំជានិច្ច។ (...)

កន្លងមកដប់បួនឆ្នាំ ព្រះជាម្ចាស់បានទម្លាយអាថ៌កំបាំង។ យើងចូលចិត្តជជែកគ្នាអំពីជីវិតក្នុងអនាគតជាតិ និងអនុស្សាវរីយ៍ពីកុមារ។ កាលដែលខ្ញុំជម្រាបប្រាប់ទៅបងស្រីម៉ារី អំពីនិមិត្តដែលខ្ញុំបានឃើញកាលពីអាយុ ៦ ទៅ ៧ឆ្នាំ នោះហើយនាំគ្នាពិចារណាជាលំអិតទៅ យើងបានយល់អំពីអត្ថន័យ... គឺ ពិតជាពុកមែន ដែលខ្ញុំបានឃើញ ដើរកោងៗចាស់ជរា គឺពិតជាគាត់ដែលបាំងមុខ សក់ក្បាលស្កូវព្រោង គឺជានិមិត្តសញ្ញានៃលំបាកដ៏មានសិរីរុងរឿងរបស់គាត់... ដូចជាព្រះភ័ក្ត្រគួរឲ្យគោរពរបស់ព្រះយេស៊ូ ដែលគ្របស្បៃនៅពេលរងទុក្ខលំបាក ដូច្នេះផ្ទៃមុខនៃអ្នកបម្រើព្រះអង្គ ក៏ត្រូវតែបាំងបិទនៅថ្ងៃរងទុក្ខលំបាកដែរ ដើម្បីអាចបញ្ចេញរស្មីនៅស្ថានបរមសុខ ក្បែរព្រះជាម្ចាស់ ជាព្រះបន្ទូលដែលស្ថិតនៅអស់កល្បជានិច្ច...។ ក្នុងរង្វង់សិរីរុងរឿងដែលមិនអាចថ្លែងបាននេះហើយ ដែលព្រះអង្គសោយរាជ្យនៅស្ថានបរមសុខ ប្រោសប្រទានឲ្យពុកជាទីស្រឡាញ់នៃយើង យល់អំពីនិមិត្តដែលព្រះនាងតូចរបស់គាត់បានឃើញក្នុងវ័យមួយ ដែលការភ័ន្តច្រលំ មិនធ្វើឲ្យភ័យខ្លាច! តាមរយៈសិរីរុងរឿងនេះហើយ ដែលព្រះជាម្ចាស់បានបង្ហាញប្រាប់ថា ដប់ឆ្នាំមុន ទុក្ខលំបាកធំៗរបស់យើងៗ បានឆ្លងផុតរួចទៅហើយ ដូចឪពុកប្រាប់ឲ្យកូនដឹងជាមុននូវអនាគតកាលដ៏រុងរឿង ដែលគាត់បានរៀបចំទុកឲ្យ និងអាចប៉ាន់ស្មានទុកជាមុននូវភាពសម្បូរសប្បាយកាត់ថ្លៃពុំបាន ជាមរតកដែលត្រូវទទួល។

ឱ! ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានពរនេះដល់ខ្ញុំ? ហេតុអ្វីបានជាព្រះអង្គបង្ហាញដល់កូនក្មេងតូចមិនយល់ការណ៍ដូច្នេះ? ប្រសិនបើនាងយល់នាងអាចស្លាប់ដោយការឈឺចាប់បាន តើហេតុអ្វីទៅហ្ន៎? មិនបាច់ឆ្ងល់ទេ នោះហើយជាអាថ៌កំបាំងមួយ ក្នុងចំណោមអាថ៌កំបាំងជាច្រើនដែលយើងនឹងយល់នៅស្ថានបរមសុខ ដែលយើងនឹងស្ងប់ស្ងែងអស់កល្បជានិច្ច!។

ព្រះជាម្ចាស់សប្បុរសណាស់ ព្រះអង្គបែងចែកការលំបាកទៅតាមកម្លាំងដែលព្រះអង្គប្រទាន។ ខ្ញុំមិនដែលបានគិតសោះថា ខ្ញុំអាចទ្រាំទ្រនឹងការលំបាកដ៏ល្វីងជូរចត់ ដែលអនាគតកាលទុកឲ្យខ្ញុំ... ខ្ញុំមិនដែលបានគិតដោយគ្មានញាប់ញ័រថាពុកអាចស្លាប់... មានម្តងនោះគាត់ឡើងជណ្តើរផ្អែក ឯខ្ញុំៗឈរពីក្រោម គាត់ស្រែកប្រាប់ថា៖

*"ថយចេញឲ្យឆ្ងាយទៅកូន បើពុកធ្លាក់ពុកនឹងសង្កត់ឯងមិនខានឡើយ"*។ ដោយពាក្យនេះ ខ្ញុំមានៈប្រឆាំង មិនព្រមជៀសចេញ ខ្ញុំកាន់តែឈរឯបនឹងជណ្តើរ ដោយគិតថា៖ *"ទោះជាយ៉ាងណា បើពុកធ្លាក់ ខ្ញុំមិនបាច់កើតទុក្ខ ដោយឃើញពុកស្លាប់ឡើយ ព្រោះខ្ញុំនឹងស្លាប់ជាមួយគាត់!"*។ (...)

ខ្ញុំរស់នៅស្ងប់ស្ងាត់ សប្បាយរីករាយ ចម្រើនវ័យក្នុងរង្វង់នៃសេចក្តីស្រឡាញ់ ប៉ុន្តែខ្ញុំធំល្មមដើម្បីតស៊ូ ចាប់ផ្តើមស្គាល់ពិភពលោក ដែលពោរពេញទៅដោយទុក្ខសោកនេះហើយ។

# ឆ្នាំនៃការឈឺចាប់

## (១៩៨១ – ១៩៨៣)

កាលអាយុប្រាំបីឆ្នាំកន្លះ ខ្ញុំទៅនៅក្នុងព្រះវិហារជំនួសឲ្យ លេអូនី ដែលត្រូវចេញពីអន្តេវាសិកដ្ឋាន។ ខ្ញុំតែងតែឮគេនិយាយថា រស់នៅក្នុងអន្តេវាសិកដ្ឋាន គឺជាឱកាសដ៏ល្អ និងរីកចម្រើនបំផុតសម្រាប់ជីវិត។ ផ្ទុយទៅវិញ ប្រាំឆ្នាំដែលខ្ញុំស្នាក់នៅទីនោះ ជាវេលាដ៏ក្រៀមក្រំសម្រាប់ខ្ញុំ បើសេលីនមិនទៅនៅជាមួយទេ ម្ល៉េះសមខ្ញុំមិនអាចរស់នៅបានមួយខែ ដោយមិនធ្លាក់ខ្លួនឈឺឡើយ។ បុប្ផាតូចនេះ ធ្លាប់តែចាក់ឫសដ៏ទន់ខ្សោយ ក្នុងដីដែលជាជម្រើសសម្រាប់តែផ្កានេះ។ ហាក់ដូចជាលំបាកណាស់ចំពោះនាង ដែលត្រូវប្តូរទីតាំង ទៅរស់នៅក្នុងចំណោមអ្នកឯទៀត មកពីគ្រប់មជ្ឈដ្ឋាន!...។

ពេលទៅដល់ទីនោះ ដោយមានអ្នកម៉ែជាអ្នកបង្រៀន ខ្ញុំជាក្មេងដែលចេះចាំជាងគេ ក្នុងចំណោមសិស្សមានអាយុស្របាលគ្នា។ ខ្ញុំរៀនក្នុងថ្នាក់មួយដែលមានសិស្សធំៗជាងខ្ញុំ មានម្នាក់អាយុ ១៣ ទៅ ១៤ឆ្នាំ មិនសូវឆ្លាតទេ តែពូកែគ្រួតគ្រាលើគេឯងរហូតដល់អ្នកគ្រូផង។ ដោយខ្ញុំអាយុតិចជាងគេ រៀនបានចំណាត់ថ្នាក់លេខមួយ ស្ទើរតែរាល់ខែ ដូនជីស្រឡាញ់ចូលចិត្តខ្ញុំណាស់ ក្មេងស្រីនោះច្រណែន ធ្វើបាបខ្ញុំតាមតែគេនឹកឃើញ។

ខ្ញុំជាក្មេងមិនសូវក្លាហាន និងចេះគួរសមតាំងពីកំណើត ខ្ញុំមិនចេះការពារខ្លួនទេ ដឹងតែយំឥតចេញស្តី ខ្ញុំមិនដែលហ៊ាននិយាយជម្រាបអ្នកម៉ែផង។ ដោយ

មិនអាចជម្នះលើភាពលំបាកលំបិននេះ ខ្ញុំកើតទុក្ខយ៉ាងខ្លាំង... តែសំណាងល្អ រាល់ល្ងាច ខ្ញុំត្រលប់ទៅផ្ទះជួបពុក ដែលជាឱកាសរីករាយបំផុត។ ខ្ញុំតែងតែលោតចូលក្នុងរង្វង់ដៃពុក អង្គុយលើក្បាលជង្គង់គាត់ រៀបរាប់អំពីពិន្ទុដែលខ្ញុំទទួលបាន ហើយការថ្នាក់ថ្នមរបស់គាត់ ធ្វើឲ្យខ្ញុំភ្លេចអស់នូវកង្វល់ទាំងឡាយ... តើខ្ញុំសប្បាយចិត្តយ៉ាងណា នៅពេលរៀបរាប់ជូនពុកស្តាប់នូវលទ្ធផលប្រលងលើកទីមួយរបស់ខ្ញុំ (អំពីប្រវត្តិនៃសន្តបុគ្គល) ដែលខ្វះតែមួយពិន្ទុទៀតប៉ុណ្ណោះ កុំអីបាន ១០/១០ ទៅហើយ ព្រោះខ្ញុំមិនស្គាល់ឈ្មោះឪពុករបស់ម៉ូសេ។ ពេលនោះ ខ្ញុំជាប់លេខមួយ បានមេដាយប្រាក់។ (...)

កាលនោះ ខ្ញុំរីករាយណាស់ ពេលបានដើរលេងជាមួយ ម៉ារី (បងជីដូនមួយ) គាត់បណ្តោយឲ្យខ្ញុំលេងតាមចិត្ត ហើយខ្ញុំជ្រើសយកល្បែងថ្មីបំផុត។ ម៉ារី និង ថេរេសា ក្លាយទៅជាមនុស្សឯកោដូចជាឥសី មានតែកូនខ្ទមតូច ក្នុងចម្ការស្រូវសាលីមួយ និងបន្លែខ្លះ។ ទាំងពីរនាក់ចូលចិត្តគយគន់ទេសភាពមិនចេះជិនណាយ គឺម្នាក់ជំនួសឲ្យម្នាក់ទៀត ពេលជាប់រវល់កិច្ចការប្រចាំថ្ងៃ។ ពួកគេស្រុះស្រួលគ្នា អង្គុយយ៉ាងស្ងៀមស្ងាត់ មិននិយាយស្តីអ្វីឡើយ។ នៅពេលអ្នកមីងនាំដើរលេង យើងនៅតែបន្តលេងល្បែងនេះតទៅទៀត ទោះជានៅតាមផ្លូវក៏ដោយ។ អ្នកឯកោទាំងពីរអ្នកនេះ នាំគ្នាសូត្រធម៌ដោយប្រើម្រាមដៃជំនួសផ្គាំ ដើម្បីកុំឲ្យគេចាប់អារម្មណ៍។ ថ្ងៃមួយនោះ អ្នកមីងទិញនំឲ្យម្នាក់មួយ អ្នកឯកោក្មេងជាងគេ ទទួលនំដោយធ្វើសញ្ញាឈើឆ្កាង បណ្តាលឲ្យអ្នកដទៃសើចគ្រប់គ្នា...។ (...)

យប់មួយនោះ ខ្ញុំឮអ្នកម៉ែថា ក្រោយពិធីទទួលព្រះកាយព្រះគ្រីស្តលើកដំបូង ត្រូវតែរស់នៅរបៀបថ្មី។ ភ្លាមនោះ ខ្ញុំសម្រេចចិត្តចាប់ផ្តើមជីវិតថ្មី ជាមួយសេលីន ដែរ មិនបាច់រង់ចាំដល់ថ្ងៃនោះឡើយ...។ (...)



មានថ្ងៃមួយ ខ្ញុំប្រាប់ ប៉ូលីន ថាខ្ញុំចង់រស់នៅឯកោឆ្ងាយដាច់ពីគេ ដើរតាមគាត់ក្នុងវាលលំហដ៏សែនឆ្ងាយ។ គាត់ឆ្លើយថា គាត់ក៏មានបំណងនេះដែរ ហើយចាំដល់ពេលខ្ញុំធំល្មម នឹងចាកចេញទៅ។ តាមការពិត កាលនោះគាត់និយាយលេង តែ ថេរេសា យល់ថាពិតប្រាកដ ហេតុនេះហើយបានជាថ្ងៃដែល ប៉ូលីន ប្រាប់ម៉ារីថា ជាពេលដែលគាត់ត្រូវចូលទៅរស់នៅក្នុងអារាមកាមែលហើយ។ ពេលនោះ ខ្ញុំមិនដឹងថា កាមែលជាអ្វីផង តែខ្ញុំយល់ថា ប៉ូលីន ចាកចេញពីខ្ញុំ ទៅរស់នៅក្នុងអារាម គាត់មិនរង់ចាំខ្ញុំទៀតទេ ខ្ញុំនឹងបាត់បង់ម្ដាយទីពីរទៀតហើយ... ព្រះអើយ! ពេលនោះ ខ្ញុំមិនដឹងជានិយាយយ៉ាងណាឲ្យសមល្មមនឹងការព្រួយបារម្ភរបស់ខ្ញុំឡើយ... តែមួយស្របក់សោះ ខ្ញុំយល់ថា នេះហើយជីវិត។

ពីមុនមក ខ្ញុំមិនដែលបានចាប់អារម្មណ៍ តែពេលនេះ សេចក្ដីពិតបានឈានចូលមកសណ្ឋិតក្នុងចិត្តខ្ញុំៗយល់ថា ជីវិតគឺជាការឈឺចាប់ ការនិរាសព្រាត់ប្រាស់ ដែលមានជាបន្តបន្ទាប់។ ទឹកភ្នែកល្វីងជូរចត់របស់ខ្ញុំ ហូររហែងព្រោះកាលនោះ ខ្ញុំមិនទាន់យល់អំពីបីតិសោមនស្សនៃការបូជា ដោយពេលនោះខ្ញុំទន់ខ្សោយណាស់ ហើយខ្ញុំចាត់ទុកភាពខ្សោយនេះ ជាអំណោយទានដ៏ធំធេងមួយ ដែលអាចឲ្យខ្ញុំទ្រាំទ្រការលំបាក ដែលធ្ងន់ធ្ងរហួសកម្លាំងនេះបាន!... ប្រសិនបើកាលនោះ ខ្ញុំទទួលដំណឹងនេះបន្តិចម្ដងៗ ប្រហែលជាខ្ញុំមិនឈឺចាប់ដូច្នេះឡើយ តែវាមកដល់យ៉ាងគំហុក ហាក់ដូចជាលំពែងដ៏មុតស្រួច មកចាក់ចំបេះដូងរបស់ខ្ញុំ។

ខ្ញុំនៅចាំថា កាលនោះ អ្នកម៉ែលួងលោមខ្ញុំយ៉ាងទន់ភ្លន់ បន្ទាប់មក គាត់ពន្យល់អំពីការរស់នៅក្នុងអារាមកាមែល ដែលហាក់ដូចជាសុខស្រួលណាស់។ សម្ដីរបស់អ្នកម៉ែ ធ្វើឲ្យខ្ញុំនឹកឃើញដល់វាលលំហ។ ខ្ញុំគិតថា អារាមកាមែល ជាវាលលំហ ដែលព្រះជាម្ចាស់មានព្រះហឫទ័យ ចង់ឲ្យខ្ញុំទៅលាក់ខ្លួននៅទីនោះដែរ... ខ្ញុំមានអារម្មណ៍ច្បាស់លាស់ ដែលឥតសង្ស័យថា មិនមែនជាការស្រមៃ

របស់ក្មេងៗ ដែលស្រូបទាក់ទាញទេ តែជាភាពជាក់លាក់មួយនៃការត្រាស់ហៅ របស់ព្រះជាម្ចាស់។ ខ្ញុំចង់ទៅអារាមកាមែលដែរ មិនមែនដោយសារប៉ូលីនទេ តែដោយសារព្រះយេស៊ូមួយអង្គគត់... ខ្ញុំបានគិតដល់គ្រប់យ៉ាង ដែលមិនអាចនិយាយបញ្ជាក់ជាពាក្យសម្ដីបានឡើយ តែជាគំនិតដែលធ្វើឲ្យខ្ញុំទទួលនូវសេចក្ដីស្ងប់យ៉ាងធំធេងមួយក្នុងអារម្មណ៍។ (...)

ក្រោយពីបានស្ដាប់រឿងសម្ងាត់របស់ខ្ញុំហើយ ដូនជីប្រមុខ ជឿថាខ្ញុំពិតជាបានទទួលការត្រាស់ហៅអំពីព្រះជាម្ចាស់មែន ប៉ុន្តែគាត់ប្រាប់ខ្ញុំថា គេមិនអាចទទួលយកសំណើសុំចូលអារាមនេះ ពីក្មេងអាយុ ៩ឆ្នាំទេ ត្រូវរង់ចាំរហូតដល់អាយុ ១៦ឆ្នាំ... ខ្ញុំត្រូវតែយល់ព្រម ទោះជាចង់ចូលរួមក្នុងពិធីទទួលព្រះកាយព្រះគ្រីស្ដលើកទីមួយ ស្រករគ្នានឹងការទទួលសម្លៀកបំពាក់ដូនជីរបស់ប៉ូលីនក៏ដោយ ខ្ញុំត្រូវតែទ្រាំចាំ... គឺថ្ងៃនោះហើយ ដែលខ្ញុំបានទទួលការសរសើរ លើកទឹកចិត្តជាថ្មីម្ដងទៀត។ ដូនជី ថេរេសា នៃព្រះវិហារសន្ត អូគូស្តាំង បានអញ្ជើញមកជួបខ្ញុំ សរសើរមិនដាច់ពីមាត់ថា ខ្ញុំស្លូតបូត។ ចំណែកឯខ្ញុំវិញ ខ្ញុំមកអារាមកាមែល មិនមែនចង់ទទួលពាក្យសរសើរទាំងនោះទេ តែខ្ញុំទន្ទេញក្នុងចិត្តទូលព្រះជាម្ចាស់ថា ទូលព្រះបង្គំជាខ្ញុំចង់មកនៅទីនេះ ដើម្បីជួបព្រះអង្គតែមួយអង្គគត់។ (...)

អ្នកម៉ែជាទីស្រឡាញ់ ប្រហែលជាអ្នកគិតថា ខ្ញុំនិយាយពន្លើសអំពីទុក្ខព្រួយពីមុននោះហើយមើលទៅ... ឥឡូវនេះ ទើបខ្ញុំយល់ថា ការលំបាកនោះមិនធំប៉ុន្មានទេ ព្រោះកាលនោះ ខ្ញុំសង្ឃឹមថា បានទៅជួបជាមួយអ្នកនៅកាមែល ប៉ុន្តែកាលនោះ ខ្ញុំនៅក្មេងខ្ចីពេក មិនអាចយល់រាក់ជ្រៅឡើយ។ ខ្ញុំត្រូវឆ្លងកាត់ការលត់ដំជាច្រើន ទើបអាចឈានទៅដល់គោលដៅបាន។

ថ្ងៃទី២ ខែតុលា ជាថ្ងៃកំណត់ដែលប៉ូលីន ត្រូវចូលក្នុងអារាម ទោះជាខ្ញុំកើតទុក្ខក្រៀមក្រំយ៉ាងណាក៏ដោយ។ ពេលរសៀល អ្នកបាននាំយើងទៅកាមែល

ហើយខ្ញុំឃើញប៉ូលីនឈរក្បែរចម្រឹងទ្វារ... ឱ! ពេលនោះ ខ្ញុំសែនពិបាកចិត្ត ក្រៃលែង នៅកន្លែងជួបនិយាយគ្នានេះ! ដោយខ្ញុំត្រូវសរសេរអំពីប្រវត្តិរបស់ព្រលឹងខ្ញុំៗ ត្រូវតែជម្រាបអ្នកសព្វគ្រប់ទាំងអស់។ ខ្ញុំសូមសារភាពថា ការឈឺចាប់មុនពេលប៉ូលីនទៅរស់នៅក្នុងអារាម មិនស្មើមួយចំណិតតូចនៃការឈឺចាប់ពេលក្រោយទេ... រៀងរាល់ថ្ងៃព្រហស្បតិ៍ ពួកយើងតែងតែទៅអារាមកាមែលជាក្រុមគ្រួសារ ហើយខ្ញុំធ្លាប់តែស្និទស្នាលជាមួយប៉ូលីន តែឥឡូវនេះ យើងអាចជួបនិយាយគ្នាបានតែពីរបីនាទីប៉ុណ្ណោះ តាមការពិត ខ្ញុំបានត្រឹមតែយំ និងត្រលប់មកវិញដោយចិត្តប្រេះស្រាំ... កាលនោះ ខ្ញុំមិនយល់សោះ អ្នកម៉ែចូលចិត្តនិយាយជាមួយបងប្អូនជីដូនមួយទាំងពីរនាក់ ជាងពួកយើង ដើម្បីសម្តែងការគួរសមជាមួយអ្នកមីងទេ... ដោយមិនយល់ ខ្ញុំតែងតែគិតថា៖ *"ខ្ញុំបាត់បង់ប៉ូលីនហើយ!"* ស្មារតីខ្ញុំរីកចម្រើនក្នុងរង្វង់ការឈឺចាប់យ៉ាងចម្លែក រហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺ។

ជាជំងឺបណ្តាលមកពីពួកអារក្ស ដែលខឹងនឹងការចូលទៅរស់នៅក្នុងអារាមរបស់អ្នកម៉ែ ពួកវាចង់សងសឹកមកលើរូបខ្ញុំ លើគ្រួសារយើងដែលប្រឆាំងតបនឹងវានៅអនាគតកាល ប៉ុន្តែ វាមិនបានដឹងថា ម្ចាស់ក្សត្រីយ៍នៅស្ថានបរមសុខបានថែទាំបុប្ផាតូចច្រឡឹងនេះទេ។ ព្រះនាងញញឹមមករកបុប្ផាតូចនេះ ពីនៅបល្លង្គនៃស្ថានបរមសុខ ហើយប្រុងប្រៀបជានិច្ច ដើម្បីបញ្ឈប់ព្យុះព្យោមា នៅពេលដែលផ្កានេះ ហៀបតែនឹងបាក់ចាកទង។

ចុងឆ្នាំនោះ ខ្ញុំឈឺក្បាលជាប្រចាំរាល់ថ្ងៃ តែខ្ញុំហាក់ដូចជាមិនដឹងខ្លួន ខ្ញុំនៅតែបន្តការសិក្សា ពេលនោះ គ្មាននរណាចាប់អារម្មណ៍នឹងខ្ញុំឡើយ។ ជំងឺនេះបន្តរហូតដល់បុណ្យចម្លងឆ្នាំ១៨៨៣។ (...)

កាលដែលពុក និងបងស្រីរបស់ខ្ញុំ ត្រលប់មកពីប៉ារីសវិញ អ្នកបម្រើទៅទទួលពួកគាត់ ដោយទឹកមុខក្រៀមក្រំ។ ម៉ារី ស្មានថាខ្ញុំស្លាប់... ប៉ុន្តែ ជំងឺនេះមិនធ្វើឲ្យខ្ញុំស្លាប់ភ្លាមៗទេ ជាជំងឺរបស់ ឡាសារ ដើម្បីឲ្យព្រះជាម្ចាស់ទទួល

សិរីរុងរឿង... តាមការពិត ព្រះអង្គទទួលសិរីរុងរឿងមែន ដោយសារការយល់ព្រមរបស់ពុក។ គាត់គិតថា៖ *"កូនស្រីតូចរបស់គាត់ និងក្លាយទៅជាផ្កាលីលា ឬនាងមុខជាស្លាប់ពុំខាន"*។ (...)

ថ្ងៃ ប៉ូលីន បួសជាដូនជី កាន់តែខិតចូលមកហើយ គេមិនឲ្យខ្ញុំដឹងទេ ខ្លាចខ្ញុំព្រួយ ព្រោះទៅមិនរួច តែខ្ញុំនិយាយជាញឹកញយថា ចង់ទៅជួយប៉ូលីន។ តាមពិតទៅព្រះជាម្ចាស់ប្រោសប្រណីលួងលោមខ្ញុំ ឬព្រះអង្គចង់លួងលោមគូដណ្ដឹងរបស់ព្រះអង្គ ដែលកើតទុក្ខជាខ្លាំង ចំពោះជំងឺរបស់កូនស្រីតូចរបស់ទ្រង់... ខ្ញុំសង្កេតឃើញថា ព្រះយេស៊ូមិនចង់សាកល្បងបុត្រធីតារបស់ព្រះអង្គនៅថ្ងៃមង្គលរបស់ពួកគេឡើយ។ ពិធីនេះត្រូវតែឧឡារិក ជារសជាតិរីករាយមុនពេលទៅដល់ស្ថានបរមសុខ តើព្រះអង្គមិនបានបង្ហាញប្រាំលើកមកហើយទេឬ? ពេលនោះ ខ្ញុំអាចឱបអ្នកម៉ែក្នុងដៃ អង្គុយលើភ្លៅ និងស្ទាបអង្អែល... ខ្ញុំឃើញគាត់ស្អាត គួរឲ្យចាប់ចិត្ត ក្នុងសម្លៀកបំពាក់ពណ៌ស។ ឱ! ជាថ្ងៃដ៏ល្អមួយសម្រាប់ការលំបាកដ៏ខ្មៅងងឹតរបស់ខ្ញុំ តែថ្ងៃនោះ បានកន្លងទៅយ៉ាងឆាប់បំផុត... គ្រាន់តែរួចរាល់ភ្លាម ខ្ញុំត្រូវឡើងរទេះ ត្រលប់មកវិញ ឃ្លាតឆ្ងាយពីប៉ូលីន ឃ្លាតឆ្ងាយពីអារាមកាមែលជាទីស្រឡាញ់។ គ្រាន់តែមកដល់ផ្ទះភ្លាម គេផ្ដេកខ្ញុំលើគ្រែ ខ្ញុំប្រាប់គេថា ខ្ញុំជាហើយ មិនបាច់មើលថែទាំទៀតទេ។ ប៉ុន្តែ ព្រះអើយ! នេះគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ! ថ្ងៃបន្ទាប់ ខ្ញុំឈឺឡើងវិញ គេរាល់គ្នាគិតថា ខ្ញុំមិនអាចជាសះស្បើយឡើយ។ ខ្ញុំមិនដឹងជារៀបរាប់ជំងឺចម្លែកនេះដូចម្ដេចទេ ខ្ញុំយល់ថា ជាស្នាដៃរបស់អារក្ស។ ប៉ុន្តែ ក្រោយពីជាសះស្បើយមកយ៉ាងយូរ ខ្ញុំតែងតែគិតថា ខ្ញុំធ្វើពុត ហើយពេលនោះ ខ្ញុំឈឺចាប់ពិតៗ។

ខ្ញុំបានជម្រាបរឿងនោះដល់ម៉ារី ដែលខិតខំលួងលោមខ្ញុំ ដោយចិត្តសប្បុរស។ ខ្ញុំបានលន់តួ ជម្រាបដល់លោកបូជាចារ្យ គាត់ក៏បានលួងលោមខ្ញុំថា៖ បើគិតដល់ជំងឺរបស់ខ្ញុំកន្លងមកនោះ មិនមែនជាពុតត្បុតទេ។ ដោយឥត

សង្ស័យ ច្បាស់ជាព្រះជាម្ចាស់ មានព្រះបំណងធ្វើឲ្យខ្ញុំបន្ទាបខ្លួន ជាពិសេស ព្រះអង្គបញ្ឈឺចិត្តខ្ញុំ ដោយបន្សល់ទុកនូវការរងទុក្ខលំបាក ដែលកប់នៅក្នុងជម្រៅចិត្តនេះ រហូតដល់វេលាដែលខ្ញុំត្រូវចូលទៅក្នុងអារាមកាមែល ជាកន្លែងព្រះបិតានៃព្រលឹងពួកយើង។ កាលនោះ ហាក់ដូចជាព្រះអង្គប្រើព្រះហស្តមកហូតយកសេចក្តីសង្ស័យទាំងអស់អំពីខ្លួនខ្ញុំ ហើយចាប់ពីពេលនោះមក ខ្ញុំមានអារម្មណ៍នឹងនបំផុត។

តាមពិតទៅ កាលនោះ ខ្ញុំឈឺដូចជាមិនឈឺ ព្រោះខ្ញុំធ្វើអ្វីៗ ឬនិយាយអ្វីៗ ដែលខ្ញុំពុំដែលបានគិតទុក។ ខ្ញុំហាក់ដូចជារវើរវាយ និយាយពាក្យឥតន័យ ប៉ុន្តែពេលនោះ ខ្ញុំចាំច្បាស់ថា ខ្លួនឯងមានសតិគ្រាប់គ្រាន់... ខ្ញុំហាក់ដូចជាសន្លប់ស្តូកស្តឹង ឥតកម្រើក គេចង់នាំទៅណា ឬសម្លាប់ក៏បាន ប៉ុន្តែ ខ្ញុំឮសម្តីគេនិយាយជុំវិញខ្លួន ហើយនៅចាំពាក្យទាំងនោះរហូតដល់សព្វថ្ងៃនេះ។ មានម្តងនោះ ខ្ញុំមិនអាចបើកភ្នែករួចយ៉ាងយូរ (ខ្ញុំបិទភ្នែករហូត) ហើយខ្ញុំបើកភ្នែកមួយស្របក់កាលណាខ្ញុំនៅម្នាក់ឯង...។

ខ្ញុំជឿថា អារក្សបានគ្រប់គ្រងលើរូបរាងខាងក្រៅខ្ញុំហើយ ប៉ុន្តែ វាមិនអាចចូលទៅជិតព្រលឹង និងសតិខ្ញុំបានឡើយ។ វាគ្រាន់តែបន្លាចឲ្យខ្ញុំខ្លាចញញើតយ៉ាងខ្លាំងលើចំណុចខ្លះៗ ឧទាហរណ៍ខ្ញុំខ្លាចពុំព្រមផឹកថ្នាំ ដែលគេយកមកឲ្យ។ ប៉ុន្តែ ប្រសិនបើព្រះជាម្ចាស់បណ្តោយឲ្យអារក្សចូលមកជិតខ្លួនខ្ញុំបាន ព្រះអង្គក៏ប្រោសបញ្ជូនទេវទូត ដែលមានរូបរាង គឺម៉ារី ដែលតែងតែនៅក្បែរគ្រែ ថែទាំនិងលួងលោមខ្ញុំ ដោយកាយវិការទន់ភ្លន់របស់ម្តាយ។ ម៉ារីមិនដែលបង្ហាញការធុញទ្រាន់បន្តិចណាឡើយ ទោះជាខ្ញុំធ្វើបាបគាត់ក៏ដោយ។ កាលនោះ ខ្ញុំចង់តែឲ្យម៉ារីនៅក្បែរខ្លួន មិនព្រមឲ្យដើរចេញឆ្ងាយពីគ្រែទេ ទោះជាពេលបាយក៏ដោយ ខ្ញុំស្រែកហៅរកគាត់ រហូតទាល់តែគាត់ត្រលប់មកវិញ... លើកលែងតែគាត់អាចទៅព្រះវិហារ ឬទៅលេងប៉ូលីន ទើបខ្ញុំឥតស្រែករកទេ។ (...)

ចុះសេលីនវិញ តើបានជួយ ថេរេសា អ្វីខ្លះដែរ? រៀងរាល់ថ្ងៃអាទិត្យ

សេលីន មិនចេញដើរកំសាន្តទេ គាត់មកអង្គុយយ៉ាងយូរក្បែរគ្រែក្មេងស្រីចម្លែតនេះ។ ព្រោះតែសេចក្តីស្រឡាញ់ ទាំងអស់គ្នាមិនបានគេចវេះពីខ្ញុំទេ... ឱ! បងស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំបានធ្វើឲ្យបងពិបាកខ្លាំងណាស់! គ្មាននរណាធ្វើបាបបងជាងខ្ញុំទេ ហើយគ្មាននរណាទទួលសេចក្តីស្រឡាញ់ជាងខ្ញុំឡើយ... តែជាសំណាងល្អ ខ្ញុំនឹងសងសឹកជាមួយព្រះជាម្ចាស់ ព្រះអង្គជាព្រះស្វាមី ដែលជាអ្នកមានកំពូលរបស់ខ្ញុំៗ នឹងយកមហាសម្បត្តិនៃសេចក្តី មកចែកជូនបងៗ មួយជាមួយរយដង ជាសំណងនៃការរងទុក្ខរបស់ពួកអ្នក ចំពោះរូបខ្ញុំ... (...)

ថ្ងៃមួយ ខ្ញុំឃើញពុកដើរចូលមកក្នុងបន្ទប់ម៉ារី ដែលទុកឲ្យខ្ញុំគេង ពុកហុចកាក់មាសយ៉ាងច្រើនទៅម៉ារី ដោយទឹកមុខក្រៀមក្រំ។ គាត់ប្រាប់ឲ្យម៉ារីសរសេរសំបុត្រទៅប៉ារីស និងសូមឲ្យធ្វើអភិបូជានៅព្រះវិហារ ព្រះមាតានៃជ័យជម្នះដើម្បីឲ្យកូនស្រីតូចដ៏កម្សត់នេះ បានជាសះស្បើយផង។ ព្រះអើយ! ខ្ញុំរំភើបយ៉ាងខ្លាំងចំពោះជំនឿ និងសេចក្តីស្រឡាញ់របស់លោកពុក។ ខ្ញុំចង់តែប្រាប់គាត់ថា ខ្ញុំជាហើយ ប៉ុន្តែ ខ្ញុំបានធ្វើឲ្យគាត់ខកចិត្តជាច្រើនដងមកហើយ។ បំណងខ្ញុំមិនអាចបង្កើតអព្ភូតហេតុបានទេ ប៉ុន្តែ ព្រះមាតានៃជ័យជម្នះ អាចបង្កើតបាន។ ថ្ងៃអាទិត្យមួយ ម៉ារីចេញទៅសួនច្បារ ទុកឲ្យខ្ញុំនៅជាមួយលេអូនី អង្គុយអានសៀវភៅក្បែរមាត់បង្អួច។ ប្រហែលពីរ ឬបីនាទីក្រោយមក ខ្ញុំហៅខ្សឹបៗ *"ម៉ែ! ម៉ែ!"* ។ លេអូនីមិនចាប់អារម្មណ៍ឡើយ ព្រោះខ្ញុំហៅបែបនេះរាល់ថ្ងៃ។ ខ្ញុំចេះតែហៅតិចៗយ៉ាងយូរ បន្ទាប់មក ខ្ញុំស្រែកខ្លាំងៗ ហើយម៉ារីក៏ត្រលប់មកវិញ។ ខ្ញុំឃើញច្បាស់ថា គឺជាម៉ារីដែលដើរចូលមក តែខ្ញុំមិនអាចនិយាយថា ខ្ញុំចំណាំស្គាល់ម៉ារីឡើយ ខ្ញុំក៏បន្តស្រែកហៅកាន់តែខ្លាំងឡើង៖ *"ម៉ែ! ម៉ែ!"* ។ កាលនោះខ្លួនប្រាណខ្ញុំឈឺចុកចាប់ខ្លាំងណាស់ ដោយការប្រយុទ្ធយ៉ាងប្តូរផ្តាច់ ពិបាកនិយាយពន្យល់នេះ។ ម៉ារីប្រហែលជាឈឺចាប់ជាងខ្ញុំទៅទៀតផង។ ដើម្បីឲ្យខ្ញុំឃើញថា គាត់នៅជិត គាត់ក៏លុតជង្គង់ចុះក្បែរគ្រែខ្ញុំ ជាមួយ លេអូនី និងសេលីន បែរមុខទៅរូបព្រះមាតា នាំគ្នាសូត្រអធិដ្ឋាន ដោយទឹកចិត្តមេត្តាករុណា


LA VIERGE DU

របស់ម្ដាយចំពោះកូន។ ម៉ារីបានទទួលនូវអ្វីៗ ដែលគាត់ប៉ងប្រាថ្នា...។

ស្ថិតនៅក្នុងសភាពអស់សង្ឃឹម ថេរេសា ក៏បែរមុខទៅរកព្រះមាតានៃស្ថានបរមសុខដែរ នាងទូលអង្វរសូមព្រះនាងមេត្តាដល់ក្មេងស្រីកម្សត់នេះផង... ភ្លាមនោះ ព្រះមាតាហាក់ដូចជាស្រស់ស្អាតឡើងៗ។ ខ្ញុំមិនដែលបានឃើញអ្វីដែលប្រកបដោយសោភ័ណភាពបែបនេះទេ។ ព្រះភក្ត្របង្ហាញនូវមេត្តាធម៌ និងមនោសញ្ចេតនាទន់ភ្លន់ មិនអាចថ្លែងបាន (ឥតផ្ទឹម)។ *"ព្រះភក្ត្រញញឹមប្រិមប្រិយរបស់ព្រះនាង"* បានជ្រៀតចូលយ៉ាងជ្រៅក្នុងដួងព្រលឹងខ្ញុំ។ ទុក្ខព្រួយនិងការឈឺចាប់ទាំងប៉ុន្មាន ក៏រលាយខ្យល់ បាត់ស្រមោល ដំណក់ទឹកភ្នែកធំៗបានហូរចេញមកយ៉ាងស្ងៀមស្ងាត់ កាត់ផែនថ្ពាល់ដ៏ស្លេកស្លាំងរបស់ខ្ញុំ ប៉ុន្តែនោះជាទឹកភ្នែកនៃសេចក្ដីរីករាយពិតៗ... ខ្ញុំគិតថា ឱ! ព្រះមាតា ព្រះមាតាញញឹមដាក់ខ្ញុំៗ ត្រេកអរណាស់.., មែនហើយ ខ្ញុំមិនត្រូវនិយាយប្រាប់គេឡើយពុំនោះទេ សុភមង្គលរបស់ខ្ញុំ និងវិនាសបាត់ជាពុំខាន។ ខ្ញុំឱនមុខចុះក្រោម ឃើញម៉ារីកំពុងតែសម្លឹងមើលមុខខ្ញុំ ដោយសេចក្ដីស្រឡាញ់។ គាត់ហាក់ដូចជារំភើបនិងសង្ស័យលើការអនុគ្រោះរបស់ព្រះមាតាចំពោះរូបខ្ញុំ... ម៉ារីជាអ្នកអធិដ្ឋាន ទទូចសុំសេចក្ដីអនុគ្រោះនេះ ទើបមហាក្សត្រីយ៍នៃស្ថានបរមសុខ ប្រទានភាពញញឹមប្រកបដោយមេត្តាធម៌នេះមកឲ្យខ្ញុំ។

ដោយឃើញភ្នែកខ្ញុំ ចេះតែសម្លឹងមើលទៅព្រះរូបព្រះវរមាតា គាត់នឹកថា៖ *"ថេរេសាជាហើយ!"*។ ពិតមែន បុប្ផាតូចនឹងកើតម្ដងទៀត កាំរស្មីបានបំភ្លឺកម្ដៅរូបរាង មិនបោះបង់នាងចោលទេ ធ្វើឲ្យនាងកក់ក្ដៅបន្តិចម្ដងៗ ឃើតៗ គួរឲ្យត្រេកត្រអាល លើកបុប្ផាដែលទោរទន់ ដួលដេក ឲ្យងើបឈរ ផ្ដល់កម្លាំងរហូតដល់ប្រាំឆ្នាំ ទើបនាងអាចបើកត្របក រីកលើដីភ្នំ ប្រកបដោយជីជាតិនៃអារាមកាមែល។

ដូចខ្ញុំបានជម្រាបហើយថា ម៉ារីយល់យ៉ាងច្បាស់ថា គឺព្រះមាតា ជាអ្នក

ប្រោសប្រណីដ៏អាថ៌កំបាំងនេះដល់រូបខ្ញុំ។ ដូច្នេះ ពេលយើងនៅស្ងាត់ៗតែពីរនាក់ គាត់លួចសួរខ្ញុំថា តើខ្ញុំបានឃើញអ្វីខ្លះ? ដោយមិនអាចលាក់លៀមចំពោះមនុស្សជាទីស្រឡាញ់បាន ខ្ញុំក៏ជម្រាបជូនគាត់ទាំងអស់... ព្រះអើយ ពេលនោះដូចខ្ញុំគិតទុកជាមុនមែន សុភមង្គលរបស់ខ្ញុំទាំងប៉ុន្មាន រសាត់បាត់អស់ហើយប្ដូរមកវិញនូវភាពល្វីងជូរចត់។ អនុស្សាវរីយ៍នៃសេចក្ដីប្រោសប្រណីដែលមិនអាចថ្លែងបាននេះ ក្លាយទៅជាទុក្ខទោសនៃព្រលឹងរបស់ខ្ញុំ រហូតដល់ទៅបួនឆ្នាំ។ ទីបំផុត ខ្ញុំរកសុភមង្គលឃើញវិញ នៅទៀបព្រះបាទារបស់ព្រះមាតានៃជ័យជម្នះ។ ម្ដងនេះ គឺជាសុភមង្គលដែលពេញព្រៀប ឥតមានខ្វះកន្លះឡើយ។ ហើយខ្ញុំនឹងរៀបរាប់នូវការប្រោសប្រណីជាលើកទីពីរនេះ នៅពេលក្រោយ។ ពេលនេះ ខ្ញុំសូមជម្រាបជូនអ្នកម៉ែអំពីសេចក្ដីរីករាយ ប្រែក្លាយទៅជាភាពក្រៀមក្រំវិញ។ ម៉ារី ក្រោយពីស្ដាប់សម្ដីយ៉ាងល្ងីល្ងើ និងស្មោះស្ម័គ្រអំពី *"ការប្រោសប្រណី"* នេះ បានសុំខ្ញុំយកហេតុការណ៍នេះ ទៅប្រាប់ដល់អារាមកាមែល។ ពេលនោះ ខ្ញុំមិនអាចបដិសេធបានទេ...។ ក្រោយពីជាសះស្បើយហើយ ខ្ញុំទៅលេងអារាមជាលើកទីមួយ។ កាលនោះ ខ្ញុំត្រេកអរណាស់ ដោយបានឃើញប៉ូលីន ក្នុងសម្លៀកបំពាក់ដូចព្រះមាតា។ គឺជាឱកាសកម្រមួយសម្រាប់យើងទាំងពីរនាក់ យើងមានរឿងត្រូវនិយាយប្រាប់គ្នាច្រើនណាស់ តែខ្ញុំបែរជានិយាយមិនចេញ បេះដូងខ្ញុំហាក់ដូចជាពេញជ្រុល... ពេលនោះ ដូនជីដែលជាប្រធានអារាម និងដូនជីឯទៀត ក៏ចេញមកទទួលយើងដែរ។ ដូនជីប្រធាន រួសរាយរាក់ទាក់ ពោរពេញទៅដោយសេចក្ដីស្រឡាញ់។ ពួកគេបានសាកសួរខ្ញុំអំពីការប្រោសប្រណីចំពោះមុខដូនជីទាំងអស់។ ម៉ារីសួរខ្ញុំថា តើព្រះមាតាមានពរ *"ព្រះកុមារយេស៊ូ ដែលនៅជាទារកឬទេ? ហើយតើមានពន្លឺខ្លាំងទេ?។ល។* សំណួរទាំងនេះ ធ្វើឲ្យខ្ញុំវង្វេង ពិបាកចិត្ត ហើយខ្ញុំគ្រាន់តែឆ្លើយបានថា៖ *"ព្រះមាតាហាក់ដូចជាស្អាតណាស់ ខ្ញុំឃើញព្រះនាងញញឹមដាក់ខ្ញុំ"* ។ ពេលនោះ មានតែព្រះភក្ត្រទេ ដែលទាក់ទាញខ្ញុំ កាលបើឃើញអ្នកនៅអារាមកាមែលស្រមៃ

ទៅដល់អ្វីៗផ្សេងទៀត ខ្ញុំហាក់ដូចជាមានអារម្មណ៍ថាជាការកុហក...។ ស្ដាយណាស់! ពេលនោះ បើខ្ញុំលាក់អាថ៌កំបាំងនេះ ប្រហែលជាខ្ញុំអាចរក្សាទុកសុភមង្គលរបស់ខ្ញុំបាន ប្រហែលជាខ្ញុំអាចមានអំនួតខ្លះៗ គ្រាន់បើជាងមកទទួលការខ្មាស់អៀន ដោយសារការនិយាយប្រាប់គេឯងនេះ។ ពេលសម្លឹងមើលមុខ ខ្ញុំខ្លាចខ្លួនឯងយ៉ាងខ្លាំង ប៉ុន្តែ ព្រះអើយ! ខ្ញុំអាចនិយាយការឈឺចាប់នេះ ទូលបានតែព្រះអង្គទេ! ...។

# ការទទួលព្រះកាយព្រះគ្រីស្តលើកដំបូង អន្តេវាសិកដ្ឋាន

**( ១៨៨១ - ១៨៨៦ )**

បើនិយាយអំពីការទៅលេងនៅកាមែល ខ្ញុំនៅចាំរឿងមួយ ដែលកើតឡើងបន្ទាប់ពីចូលទៅនៅក្នុងអារាម ប៉ូលីនបន្តិច ដែលខ្ញុំភ្លេចជម្រាបពីខាងលើ តែជាហេតុការណ៍មួយដែលមិនគួររំលងចោល។ កាលនោះ ជាលើកទីមួយ ក្រោយប៉ូលីនទៅកាមែល ពេលព្រឹកនៃថ្ងៃដែលខ្ញុំត្រូវទៅកន្លែងណាត់ជួប ខ្ញុំបានគិតតែម្នាក់ឯងលើគ្រែ (ព្រោះខ្ញុំតែងតែអធិដ្ឋាន ស្ងឹងស្ងាធយ៉ាងយូរ) ខ្ញុំគិតថា ប្រសិនបើខ្ញុំទៅនៅក្នុងអារាមកាមែល តើខ្ញុំនឹងមានឈ្មោះដូចម្តេចទៅ ព្រោះនៅទីនោះ មានឈ្មោះដូនជី ថេរេសា នៃព្រះយេស៊ូរួចទៅហើយ។ ឈ្មោះថេរេសា ជាឈ្មោះល្អ មិនគួរដកចេញទេ។ រំពេចនោះ ខ្ញុំនឹកឃើញទៅដល់ព្រះកុមារយេស៊ូ ដែលខ្ញុំស្រឡាញ់យ៉ាងខ្លាំង ហើយខ្ញុំគិតថា៖ *"ឱ! ខ្ញុំមិនដឹងជាសប្បាយចិត្តយ៉ាងណាទេ បើខ្ញុំឈ្មោះ ថេរេសា នៃព្រះកុមារយេស៊ូ!"* ។ នៅកន្លែងជួបនិយាយគ្នា ខ្ញុំគ្មានបាននិយាយអំពីការស្រមៃ ទាំងភ្នែកស្រស់របស់ខ្ញុំប្រាប់គេទេ ប៉ុន្តែ ដូនជីប្រធានបានសួរទៅដូនជីឯទៀតថា តើគួរដាក់ឈ្មោះអ្វីឲ្យខ្ញុំ តែពេលនោះ គាត់នឹកឃើញដល់ឈ្មោះដែលខ្ញុំស្រមៃ... សេចក្តីរីករាយរបស់ខ្ញុំពេលនោះ មានទំហំធំធេងណាស់ គំនិតត្រូវគ្នាជាចៃដន្យនេះ ហាក់ដូចជាស្នាព្រះហស្តរបស់ព្រះកុមារយេស៊ូជាទីស្រឡាញ់របស់ខ្ញុំមែន។ (...)

ដោយខ្ញុំចូលចិត្តអានសៀវភៅ រៀបរាប់ស៊ីអំពីសកម្មភាពស្នេហាជាតិរបស់វិរៈនារីជនជាតិបារាំងជាច្រើននាក់ ជាពិសេសប្រវត្តិរបស់សានដាក (Jeanne d'Arc) ខ្ញុំមានបំណងធ្វើត្រាប់តាម។ សេចក្តីក្លាហានរបស់គាត់ ការណែនាំនិងការបំភ្លឺរបស់ព្រះជាម្ចាស់ ហាក់ដូចជាមកសណ្ឋិតក្នុងខ្លួនខ្ញុំ។ ដូច្នេះ ខ្ញុំទទួលបានការប្រោសប្រណីមួយ ដែលខ្ញុំចាត់ទុកជាការប្រោសប្រណីមួយធំជាងគេក្នុងជីវិត ព្រោះវ័យក្មេងខ្ចីរបស់ខ្ញុំ មិនដែលទទួលពន្លឺដូចក្នុងពេលនេះទេ។ វេលានោះ ខ្ញុំគិតថា ខ្ញុំកើតមកសម្រាប់ទទួលកិត្តិយសដ៏ឧត្តម ខ្ញុំត្រូវតែខិតខំទាល់តែបានជោគជ័យ។ ព្រះជាម្ចាស់ ជាអ្នកណែនាំបំភ្លឺនូវអារម្មណ៍ ដែលខ្ញុំទើបតែសរសេរនេះ។ ព្រះអង្គទ្រង់ប្រោសពន្យល់ទៀតថា មនុស្សផងទាំងពួងមើលមិនឃើញទេ កិត្តិយសឧត្តុង្គឧត្តមនេះ ដើម្បីក្លាយទៅជាសន្តីម្នាក់ដ៏ខ្ពង់ខ្ពស់! ចំណងនេះ ហាក់ដូចជាខ្ពង់ខ្ពស់ពេកណាស់ សម្រាប់រូបខ្ញុំ ដែលជាមនុស្សទន់ខ្សោយមិនគ្រប់លក្ខណ៍ ទើបតែចូលបួសបានប្រាំពីរឆ្នាំប៉ុណ្ណោះ ប៉ុន្តែ ទោះជាយ៉ាងណាខ្ញុំនៅតែមានជំនឿយ៉ាងខ្លាំងក្លាថា ខ្ញុំអាចក្លាយទៅជាសន្តីម្នាក់ដែរ ព្រោះខ្ញុំមិនដែលរំពឹងលើកុសលផលបុណ្យ ដែលខ្ញុំគ្មានសោះឡើយ ខ្ញុំសង្ឃឹមតែលើព្រះជាម្ចាស់ ដែលមានព្រហ្មវិហារធម៌ និងវិសុទ្ធភាព។ មានតែព្រះអង្គទេ ដែលព្រមទទួលស្គាល់ការខិតខំដ៏ទន់ខ្សោយរបស់ខ្ញុំ ព្រះអង្គនឹងលើកខ្ញុំឲ្យនៅក្បែរព្រះអង្គ ដោយសារបុណ្យកុសលជាច្រើនអនេករបស់ព្រះអង្គ និងធ្វើឲ្យខ្ញុំជាសន្តីបុគ្គល។ កាលនោះ ខ្ញុំមិនបានគិតថា ត្រូវទទួលការឈឺចាប់ច្រើនណាស់ទើបឈានក្លាយទៅជាសន្តីបាន។ ព្រះជាម្ចាស់មិនបានបង្អែរបង្អង់យូរ ដើម្បីបង្ហាញប្រាប់ខ្ញុំទេ ព្រះអង្គបញ្ជូនទុកលំបាកផងទាំងពួង ដែលខ្ញុំបានរៀបរាប់ជូនពីខាងលើ។ (...)

ព្រះអង្គទ្រង់ប្រោសប្រទានឲ្យខ្ញុំស្គាល់ពិភពលោកនេះ សមល្មមធ្វើឲ្យខ្ញុំជិនណាយអាចចាកចេញទៅឆ្ងាយ។ ខ្ញុំអាចនិយាយបានថា ការស្នាក់នៅអាឡង់សុង

ជាឱកាសដែលឲ្យខ្ញុំឈានជើងចូលក្នុងពិភពលោកនេះ។ អ្វីៗសុទ្ធតែជាការត្រេកត្រអាលសុភមង្គលជុំវិញខ្លួន។ គេទទួលយ៉ាងរាក់ទាក់ គេថ្នាក់ថ្នម កោតសរសើរនិយាយឲ្យខ្លីទៅ រយៈពេលដប់ប្រាំថ្ងៃ ជីវិតខ្ញុំរីករាយឥតឧបមា (ពោរពេញទៅដោយសុភមង្គល)។ ខ្ញុំសារភាពថា ជីវិតបែបនេះ គួរឲ្យទាក់ទាញណាស់។ គតិបណ្ឌិតពិតជាត្រឹមត្រូវពិតមែន៖ *"ការជក់ចិត្តជិតអារម្មណ៍លើវត្ថុឥតប្រយោជន៍លើលោកនេះ ទាក់ទាញស្មារតី ទោះជាឃ្លាតឆ្ងាយអំពីអំពើអាក្រក់ក៏ដោយ"* ។ ក្នុងវ័យដប់ឆ្នាំ ទឹកចិត្តឆាប់ទទួលការស្រវាំងភ្នែក ភ្លឹកទៅតាមការទាក់ទាញហេតុនេះហើយ ខ្ញុំយល់ថាជាការប្រោសប្រណីមួយយ៉ាងធំ ដែលមិនបានរស់នៅអាឡង់សុង។ មិត្តភក្តិនៅទីនោះ សុទ្ធតែអ្នកចូលចិត្តសប្បាយជ្រុល ពួកគេពូកែយកសេចក្ដីរីករាយលើលោកនេះ ទៅបញ្ចូលជាមួយនឹងការបម្រើព្រះជាម្ចាស់។ ពួកគេមិនបានគិតឲ្យដិតដល់ចំពោះសេចក្ដីស្លាប់ឡើយ ទោះជាសេចក្ដីស្លាប់នោះបានមកដល់ជនទាំងឡាយជាច្រើននាក់ ដែលខ្ញុំបានស្គាល់ មានក្មេងជាអ្នកមានទ្រព្យស្តុកស្តម និងមានសុភមង្គលក៏ដោយ!.... ខ្ញុំនឹកគិតដល់កន្លែងដែលពួកគេធ្លាប់រស់នៅ (ជាទីសម្បូរសប្បាយ) ចោទសួរខ្លួនឯងថា តើឥឡូវនេះ ពួកគេនៅឯណា? តើវិមាន និងឧទ្យានដែលគេបានសោយសុខពីមុននោះ ឥឡូវនេះបានទៅនរណាហើយ? ហើយខ្ញុំគិតឃើញថា ទាំងអស់នោះ សុទ្ធតែជាអំនួត និងទុក្ខព្រួយនៃព្រលឹងនៅលើលោកនេះ.... សម្បត្តិតែមួយគត់ គឺស្រឡាញ់ និងជឿជាក់លើព្រះជាម្ចាស់អស់ពីដួងចិត្ត ហើយរស់នៅក្រោមមេឃនេះ ដូចជាមនុស្សអន់បញ្ញា។ (...)

ជំនាន់នោះ មិនទាន់មានអ្នកបង្រៀនរបៀបអធិដ្ឋានដល់ខ្ញុំទេ ទោះជាខ្ញុំចង់ចេះក៏ដោយ។ ម៉ារីយល់ឃើញថា ខ្ញុំចូលចិត្តស្ងឹងស្ងាធស្រាប់ទៅហើយ គាត់បណ្ដោយឲ្យខ្ញុំធ្វើការអធិដ្ឋានដោយខ្លួនឯង។ មានថ្ងៃមួយ អ្នកគ្រូម្នាក់ នៅព្រះវិហារសួរខ្ញុំថា តើខ្ញុំធ្វើអ្វីខ្លះ នៅថ្ងៃឈប់សម្រាកពេលនៅម្នាក់ឯង? ខ្ញុំឆ្លើយ

ទៅគាត់ថា ខ្ញុំទៅកន្លែងទំនេរមួយខាងក្រោយគ្រែ ស្រួលទាញវាំងននបាំង ហើយខ្ញុំ *"សញ្ជឹងគិត"* នៅទីនោះ។ តើអ្នកគិតអំពីអ្វី? ខ្ញុំគិតទៅដល់ព្រះជាម្ចាស់.... ដល់ជីវិត ដល់ស្ថានបរមសុខ និយាយឲ្យចំទៅ ខ្ញុំរិះគិត!... ដូនជីសើច ហើយពេលក្រោយៗមក គាត់តែងតែនាំខ្ញុំនិយាយឡើងវិញ អំពីវេលាដែលខ្ញុំរិះគិត រួចសួរខ្ញុំថា តើខ្ញុំនៅបន្តការរិះគិតទៀតទេ។ ឥឡូវនេះ ទើបខ្ញុំយល់ថា កាលនោះខ្ញុំអធិដ្ឋានដោយមិនដឹងខ្លួន គឺព្រះជាម្ចាស់បានបង្រៀនខ្ញុំជាសម្ងាត់។ (...)

ទីបំផុត ថ្ងៃល្អមកដល់ហើយ (ថ្ងៃទទួលព្រះកាយព្រះគ្រីស្តដំបូង)។ គឺជាអនុស្សាវរីយ៍ដែលមិនអាចរៀបរាប់ ត្រូវបានចារឹកទុកយ៉ាងលំអិតក្នុងវិញ្ញាណ ខ្ញុំទិវានៃព្រះជាម្ចាស់នេះ! (...)

គឺជាការថើប ដោយសេចក្តីស្រឡាញ់ មានអ្នកស្រឡាញ់ខ្ញុំហើយ។ ខ្ញុំក៏បាននិយាយថាៈ *"ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ ព្រះអង្គជាម្ចាស់របស់ខ្ញុំរហូតទៅ"* ។ កាលនោះ គ្មានពាក្យសុំ គ្មានការប្រយុទ្ធ ការបូជា ព្រោះតាំងពីយូរមកហើយព្រះយេស៊ូ និងកុមារីថេរេសាដ៏កម្សត់ បានមើលឃើញគ្នា និងយល់ចិត្តគ្នាទៅវិញទៅមក... ថ្ងៃនោះលែងជាថ្ងៃមើលដើម្បីស្គាល់គ្នាទៀតហើយ តែជាថ្ងៃដែលត្រូវរលាយចូលគ្នា។ មិនមែនតែពីរនាក់ទេ ថេរេសា បានរលាយបាត់ ដូចតំណក់ទឹកដែលធ្លាក់ចូលក្នុងមហាសមុទ្រ។ ព្រះយេស៊ូមានតែមួយអង្គឯង ព្រះអង្គជាម្ចាស់ ជាព្រះរាជា។ ថេរេសា មិនបានទូលសុំឲ្យព្រះអង្គ កុំដកហូតសេរីភាពរបស់នាងទេ ព្រោះសេរីភាពធ្វើឲ្យនាងខ្លាច នាងហាក់ដូចជាទន់ខ្សោយ ផុយស្រួយណាស់ នាងចង់តែនៅរួបរួមជាមួយនឹងកម្លាំងព្រះជាម្ចាស់! បីតិសោមនស្សមានទំហំធំធេង និងជ្រាលជ្រៅណាស់ ធ្វើឲ្យនាងទប់ទល់ពុំបាន ទឹកភ្នែកនៃសេចក្តីរីករាយ ហូរស្រពថ្ពាល់ នាំឲ្យមិត្តភក្តិដែលមកចូលរួម មានចម្ងល់យ៉ាងខ្លាំង ហើយនាំគ្នាខ្សឹបខ្សៀវថាៈ *"ហេតុអ្វីបានជានាងយំ? តើមានអ្វីមករំខានឬ?... ទេ! មកពីនាងមិនឃើញម្តាយ ឬបងស្រីនៅអារាមកាមែល ដែលស្រឡាញ់*

*នាងជាងគេ"* ។ អ្នកទាំងនោះមិនយល់ថា សេចក្តីសោមនស្សរីករាយដែលបានមកពីព្រះជាម្ចាស់ បានជ្រៀតចូលក្នុងបេះដូង ហើយបេះដូងឯកោនេះ មិនអាចទ្រាំទ្របាន ដោយគ្មានបង្ហូរទឹកភ្នែកឡើយ។ ....អូហ៍ទេ អវត្តមានរបស់ម៉ែ មិនបានធ្វើឲ្យខ្ញុំកើតទុក្ខនៅថ្ងៃទទួលព្រះកាយព្រះគ្រីស្តមុនដំបូងទេ ស្ថានបរមសុខស្ថិតនៅក្នុងវិញ្ញាណខ្ញុំហើយៗ ម៉ែរស់នៅទីនោះជាយូរយាមកហើយដែរ បើព្រះយេស៊ូយាងមកលេងខ្ញុំ ម៉ែក៏មកដែរ គាត់ច្បាស់ជាប្រសិទ្ធិពរឲ្យខ្ញុំរីករាយជួបសុភមង្គលពុំខាន.... ខ្ញុំមិនយំ ព្រោះមិនឃើញប៉ូលីនដែរ ខ្ញុំចង់ឲ្យគាត់នៅក្បែរ ប៉ុន្តែតាំងពីដើមមក ការបូជារបស់ខ្ញុំត្រូវបានទទួល។ ថ្ងៃនោះ ខ្ញុំយំ ព្រោះខ្ញុំមានអំណរ ខ្ញុំ និងប៉ូលីន យើងរួបរួមគ្នា ដើម្បីបម្រើព្រះជាម្ចាស់។ (...)

បន្ទាប់ពីថ្ងៃបុណ្យទទួលព្រះកាយព្រះគ្រីស្តមួយថ្ងៃ ខ្ញុំនឹកឃើញដល់សម្តីម៉ារី ខ្ញុំមានអារម្មណ៍ចង់ឲ្យទុក្ខលំបាក ព្រមគ្នាជាមួយនឹងការធានារ៉ាប់រងយ៉ាងជិតស្និទ្ធអំពីព្រះយេស៊ូ ដែលបានទុកឈើឆ្កាងយ៉ាងច្រើនដល់ខ្ញុំ។ ខ្ញុំហាក់ដូចជាបានទទួលការល្បួងលោមយ៉ាងធំធេងដែលចាត់ទុកជាការប្រោសប្រណីធំបំផុតសម្រាប់ជីវិតខ្ញុំ។ ការរងទុក្ខលំបាក ក្លាយទៅជាភាពទាក់ទាញ វាមានសម្រស់មកល្បួងខ្ញុំ ដោយមិនចាំបាច់ស្គាល់ច្បាស់។ តាំងពីដើមរហូតមក ខ្ញុំរងទុក្ខលំបាកដោយមិនបានស្រឡាញ់ទុក្ខលំបាកនោះ ចាប់ពីថ្ងៃនេះទៅ ខ្ញុំនឹងស្រឡាញ់ទុក្ខលំបាកនោះ។ ខ្ញុំក៏មានអារម្មណ៍ថាស្រឡាញ់តែព្រះជាម្ចាស់មួយអង្គប៉ុណ្ណោះ។ ប្រគល់សេចក្តីរីករាយទាំងអស់ថ្វាយព្រះអង្គ រាល់ពិធីទទួលព្រះកាយ ខ្ញុំតែងតែទន្ទេញសម្តីនៅក្នុងសៀវភៅ Imitation *"ឱ! ព្រះយេស៊ូអើយ! ព្រះអង្គមានកិរិយាស្លូតបូត មិនអាចថ្លែងបាន សូមព្រះអង្គប្តូរការល្បួងលោមនៅលើផែនដីនេះ ជាភាពល្វីងជូរចត់ ដើម្បីខ្ញុំម្ចាស់ផង!..."* សេចក្តីអធិដ្ឋាននេះ បានហូរចេញពីមាត់ខ្ញុំ ដោយមិនបាច់ប្រឹង មិនបាច់បង្ខំ ហាក់ដូចជាខ្ញុំថា តាមសម្តីនរណាម្នាក់ដូចក្មេងម្នាក់ថាគ្រាប់តាមពាក្យមនុស្សធំ។ (...)

កាលនោះ អ្វីៗដែលខ្ញុំរៀន ខ្ញុំចាំអត្ថន័យយ៉ាងងាយ ប៉ុន្តែ ខ្ញុំមានការលំបាក

ក្នុងការរៀនពាក្យមួយម៉ាត់ៗ ដូច្នេះ ដើម្បីរៀនការអប់រំគោលសំខាន់នៃសាសនា ខ្ញុំត្រូវសួរគេស្ទើររាល់ថ្ងៃ ពេញមួយឆ្នាំ សុំការអនុញ្ញាតរៀននៅពេលចេញលេង ទីបំផុត ខ្ញុំទទួលជោគជ័យដោយការខិតខំនេះ ខ្ញុំជាសិស្សលេខមួយជានិច្ច។ បើជាថៃ្ងដន្យ បើមានភ្លេចពាក្យណាមួយ ខ្ញុំត្រូវបាត់បង់ចំណាត់ថ្នាក់នោះ លោកអាចារ្យមិនអាចទប់ទឹកភ្នែកខ្ញុំបានឡើយ។ គាត់សប្បាយចិត្តនឹងខ្ញុំណាស់ ហើយតែងតែហៅខ្ញុំថា បណ្ឌិតតូច ដោយសារឈ្មោះ ថេរេសា។ មានម្តងនោះ សិស្សដែលមានចំណាត់ថ្នាក់បន្ទាប់ពីខ្ញុំ មិនចេះលើកសំណួរសួរទៅមិត្តភក្តិអំពីគោលសំខាន់នៃសាសនា លោកបូជាចារ្យបានហៅសិស្សបន្តបន្ទាប់គ្រប់ៗគ្នា តែពួកគេមិនអាចធ្វើកើត ទីបំផុតដល់វេនខ្ញុំ គាត់ពោលថា ចាំមើល តើខ្ញុំសក្តិសមនឹងចំណាត់ថ្នាក់លេខមួយឬទេ។ កន្លងមក ខ្ញុំមិនចង់លើកកំពស់ខ្លួនឯងទេ ប៉ុន្តែពេលនេះ ជាឱកាសល្អសម្រាប់ខ្ញុំហើយ។ ដោយជឿជាក់ក្នុងចិត្ត ខ្ញុំក្រោកឈរឆ្លើយ គ្មានខុសមួយម៉ាត់ ធ្វើឲ្យសិស្សឯទៀតឆ្ងល់គ្រប់គ្នា។ ក្រោយពិធីប្រគល់ព្រះកាយព្រះគ្រីស្តលើកដំបូង ការសិក្សារបស់ខ្ញុំ ចេះតែរីកចម្រើនទៅមុខរហូតដល់ពេលខ្ញុំចាកចេញពីអន្តេវាសិកដ្ឋាន។ ខ្ញុំជាប់លេខមួយស្ទើររៀងរាល់ខែ។ មុខវិជ្ជាដែលខ្ញុំឈ្នះដាច់គេ គឺប្រវត្តិវិទ្យា និងរចនាបថ។ អ្នកគ្រូទាំងអស់ចាត់ទុកថា ខ្ញុំជាសិស្សមានប្រាជ្ញាខ្លាំងក្លា ប៉ុន្តែ នៅផ្ទះលោកមា ពួកគេទុកខ្ញុំជាក្មេងល្ងង់ ចិត្តល្អ ស្លូតបូត គិតបានត្រឹមត្រូវ តែគ្មានសមត្ថភាព និងឆ្គងៗ។ ខ្ញុំគិតថា នោះជាការប្រោសប្រណីរបស់ព្រះជាម្ចាស់ ទ្រង់ចង់ឲ្យបេះដូងខ្ញុំ ជារបស់ទ្រង់តែមួយអង្គគត់។ ព្រះអង្គយល់ព្រមទទួលការអង្វររបស់ខ្ញុំហើយ *"ប្រែក្លាយភាពផ្អែមល្ហែមនៅលើលោកនេះ ទៅជាភាពល្វីងជូរចត់"*។ (...) ខ្ញុំចង់ឲ្យគេសរសើរខ្ញុំដែរ។ គេតែងអួតសរសើរប្រាជ្ញាអ្នកឯទៀតចំពោះមុខខ្ញុំជារឿយ ប៉ុន្តែ គ្មាននរណាសរសើរប្រាជ្ញាខ្ញុំទាល់តែសោះ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ខ្ញុំគ្មានប្រាជ្ញា ហើយខ្លួនខ្ញុំផ្ទាល់ក៏ព្រមទទួលស្គាល់ដែរ។

បេះដូងខ្ញុំរំភើប និងពោរពេញដោយសេចក្តីស្រឡាញ់ ងាយស្រួលប្រគល់



ទៅឲ្យបេះដូង ដែលអាចយល់គ្នាបាន.... ខ្ញុំបានសាកល្បងចងសម្ព័ន្ធភាពជាមួយក្មេងស្រីឯទៀត មានអាយុស្រករគ្នា ជាពិសេសក្មេងស្រីពីរនាក់។ ខ្ញុំស្រឡាញ់គេចំណែកគេវិញ គេស្រឡាញ់ខ្ញុំតាមតែអាចធ្វើបាន។ គួរឲ្យស្តាយ! ចិត្តមនុស្សចង្អៀតចង្អល និងសាវាណាស់!.... បន្តិចក្រោយមក ខ្ញុំគិតថា គេមិនយល់អំពីសេចក្តីស្រឡាញ់របស់ខ្ញុំទេ។ មិត្តរបស់ខ្ញុំម្នាក់ ទៅផ្ទះជួបជុំគ្រួសារ ពីរបីខែក្រោយមក ត្រលប់មកវិញ។ ពេលគេមិននៅខ្ញុំនឹកគេ រក្សាចិញ្ចៀនតូចមួយដែលគេឲ្យ ដោយប្រុងប្រយ័ត្ន។ ពេលជួបគ្នាម្តងទៀត ខ្ញុំត្រេកអរណាស់ ប៉ុន្តែគេធ្វើព្រងើយដាក់ខ្ញុំ...។ ខ្ញុំដឹងថា គេមិនយល់អំពីការស្រឡាញ់របស់ខ្ញុំទេ ខ្ញុំក៏មិនទៅអង្វរសុំសេចក្តីស្រឡាញ់ ដែលគេបដិសេធឡើយ ប៉ុន្តែ ព្រះជាម្ចាស់បានប្រគល់បេះដូងប្រកបដោយភក្តីភាពមកដល់ខ្ញុំ កាលបើព្រះអង្គស្រឡាញ់ដោយបរិសុទ្ធ ហើយព្រះអង្គស្រឡាញ់ជារៀងរហូត ដូច្នេះហើយខ្ញុំនៅតែបន្តអធិដ្ឋានទូលអង្វរ សូមឲ្យមិត្តខ្ញុំបានសុខ ព្រោះខ្ញុំនៅតែស្រឡាញ់គេ....។ ឃើញ សេលីនស្រឡាញ់អ្នកគ្រូយើងម្នាក់ ខ្ញុំចង់ធ្វើតាមដែរ ប៉ុន្តែ ដោយមិនចេះយកចិត្តថ្លើមគេ ខ្ញុំមិនបានជោគជ័យទេ។ ឱ! ភាពល្ងង់ខ្លៅអើយ! វាធ្វើឲ្យខ្ញុំគេចចេញពីគុណវិបត្តិធំៗ! សូមអរព្រះគុណព្រះជាម្ចាស់ ដែលនាំឲ្យខ្ញុំម្ចាស់រកឃើញ *"ភាពល្វីងជូរចត់នៃមិត្តភាពនៅលើលោកនេះ"* ។ ចិត្តដូចខ្ញុំ ងាយស្រួលនឹងជាប់អន្ទាក់របស់គេៗ កាត់ស្លាប តើខ្ញុំនឹង *"ហោះហើរ រួចទុំសម្រាក"* យ៉ាងណាទៅ? តើទឹកចិត្តពោរពេញដោយសេចក្តីស្រឡាញ់របស់សត្វលោក អាចរួបរួមយ៉ាងស្មោះស្ម័គ្រជាមួយព្រះជាម្ចាស់បានដែរឬទេ? ខ្ញុំគិតថា មិនអាចទៅរួចទេ។ ខ្ញុំមិនបានផឹកស្រាពុលនៃសេចក្តីស្រឡាញ់ ពោលវាលពុះកញ្ជ្រោលជ្រុលរបស់សត្វលោក ខ្ញុំគិតថាខ្ញុំមិនច្រលំទេ ព្រោះខ្ញុំបានឃើញព្រលឹងជាច្រើន ដែលលង់ដោយសារពន្លឺក្លែងក្លាយនេះ ដូចមេអំបៅហោះហើរទៅរកភ្លើង រលាកស្លាប រួចត្រលប់មករករស្មីស្រទន់នៃសេចក្តីស្រឡាញ់ពិតៗវិញ ដែលធ្វើឲ្យមេអំបៅដុះស្លាបថ្មី ស្រស់ស្អាតជាងមុន និងស្រាលជាងមុន ដើម្បីអាចហោះហើររហូត ទៅជួបព្រះយេស៊ូ។

ព្រះអង្គជាភ្លើងនៃព្រះជាម្ចាស់ ដែល *"ឆេះរលាក តែមិនវិនាស"* ។ អាហ៍! ខ្ញុំដឹងហើយ ព្រះយេស៊ូឈ្វេងយល់ថា ខ្ញុំទន់ខ្សោយពេក ព្រះអង្គមិនបណ្ដោយឲ្យខ្ញុំទោរទន់ទៅរកភ្លើងទេ បើមិនដូច្នេះ ប្រហែលជាខ្ញុំត្រូវរលាករលួយ ដោយសារពន្លឺបញ្ឆោតបោកប្រាសនោះពុំខាន។ (...) ខ្ញុំគ្មានបុណ្យកុសលអ្វី ឲ្យខ្ញុំមិនបានប្រគល់ខ្លួនក្នុងការស្រឡាញ់របស់សត្វលោកផងទាំងពួងទេ ពីព្រោះខ្ញុំត្រូវបានបម្រុងទុកសម្រាប់តែទទួលសេចក្ដីមេត្តាករុណាដ៏ថ្លៃថ្លារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ!... ខ្ញុំគិតថា បើគ្មានព្រះអង្គទេ ម្ល៉េះសមខ្ញុំធ្លាក់ចុះជ្រៅ ដូចសន្ដីម៉ារីម៉ាដាឡាដែរ។ ព្រះរាជឱង្ការរបស់ព្រះយេស៊ូទៅសន្ដៈ សិលា នៅតែលាន់ឮតិចៗក្នុងវិញ្ញាណខ្ញុំ... *"អ្នកដែលគេឲ្យតិច ស្រឡាញ់តិច"*។ ប៉ុន្តែ ខ្ញុំក៏ដឹងដែរថា ព្រះយេស៊ូប្រទានឲ្យខ្ញុំច្រើនជាងសន្ដីម៉ាដាឡា ព្រោះព្រះអង្គបានប្រទានឲ្យខ្ញុំទុកជាមុន ដើម្បីកុំឲ្យខ្ញុំធ្លាក់។ ខ្ញុំចង់ពន្យល់ប្រាប់នូវអ្វីៗដែលខ្ញុំគិតឃើញណាស់! នេះជាឧទាហរណ៍មួយ ដែលអាចបកស្រាយគំនិតខ្ញុំបានបន្តិច។ ឧបមាថា កូនប្រុសរបស់គ្រូពេទ្យដ៏ជំនាញម្នាក់ដើរជាន់ដុំថ្មមួយដួលបាក់ជើងម្ខាង។ ឪពុកដែលជាគ្រូពេទ្យមកជួយលើកថែទាំរបួសកូន ដោយសេចក្ដីស្រឡាញ់។ គាត់ប្រើគ្រប់ចំណេះដឹងដែលគាត់មាន រហូតកូនបានជាសះស្បើយ។ កូននោះ មានចិត្តកតញ្ញូចំពោះឪពុកណាស់។ មិនបាច់ឆ្ងល់ទេ កូននោះត្រូវតែស្រឡាញ់ឪពុក! ប៉ុន្តែ ខ្ញុំទាញឧទាហរណ៍មួយទៀត។ ឪពុកដឹងថា នៅលើផ្លូវមានថ្មមួយដុំ គាត់ប្រញាប់ប្រញាល់ទៅលើកដុំថ្មនោះចេញ ដោយគ្មាននរណាឃើញ។ កូនប្រុសដែលគាត់ស្រឡាញ់ថ្នាក់ថ្នម រក្សាការពារនោះ មិនបានដឹងថា ឪពុកបានរំដោះខ្លួនកូនអំពីគ្រោះថ្នាក់ទេ គេមិនបានសម្ដែងសេចក្ដីដឹងគុណចំពោះគាត់ឡើយ ហើយស្រឡាញ់គាត់តិចជាងកាលដែលគាត់ថែរបួសឲ្យ... ប៉ុន្តែ បើកូននោះដឹងអំពីគ្រោះថ្នាក់ដែលខ្លួនបានជៀសផុត កូននោះមុខជាស្រឡាញ់ឪពុកច្រើនជាងមុនពុំខានឡើយ។ គឺខ្ញុំនេះហើយ ជាកូនដែលមានឪពុកជាព្រះជាម្ចាស់ការពារមិនឲ្យមានគ្រោះថ្នាក់។ ព្រះអង្គមិនបានបញ្ជូនព្រះបន្ទូលមក ដើម្បីរំដោះអ្នកសុចរិត

ទេ គឺព្រះអង្គរំដោះអ្នកប្រព្រឹត្តអំពើបាប។ ព្រះអង្គប្រាថ្នាឲ្យខ្ញុំស្រឡាញ់ព្រះអង្គ ព្រះអង្គបានប្រទានសព្វគ្រប់ឲ្យខ្ញុំ។ ទ្រង់មិនរងចាំដល់ខ្ញុំស្រឡាញ់ខ្លាំង ដូចសន្ទីម៉ាជាឡាទេ ប៉ុន្តែ ព្រះអង្គចង់ឲ្យខ្ញុំដឹងថា ទ្រង់ស្រឡាញ់ខ្ញុំ រកអ្វីមកប្រៀបផ្ទឹមពុំបាន គឺជាសេចក្តីស្រឡាញ់ទុកជាមុន ដើម្បីដល់ពេលនេះ ខ្ញុំងប់ងុលនឹងព្រះអង្គ។ ខ្ញុំឮគេថា ប្រសិនបើទ្រង់មិនបានជួបព្រលឹងបរិសុទ្ធទេ... ព្រះអង្គនឹងកាន់តែស្រឡាញ់ព្រលឹង ដែលចេះសារភាពទទួលកំហុសជាងព្រលឹងបរិសុទ្ធទៀតផង។ ឱ! ខ្ញុំចង់តែឲ្យសម្តីនេះ ជាពាក្យកុហកទេ! ...។ (...)

# ក្រោយការប្រោសប្រណី
# ក្នុងឱកាសបុណ្យកំណើតនៃព្រះយេស៊ូ
## ( ១៨៨៦ - ១៨៨៧ )

ព្រះជាម្ចាស់ប្រទានការប្រោសប្រណីដល់ខ្ញុំ មិនមែនដោយខ្ញុំបានសាងបុណ្យកុសលបានច្រើនទេ ខ្ញុំមិនទាន់គ្រប់លក្ខណ៍នៅឡើយ។ ខ្ញុំចង់ប្រតិបត្តិតាមគុណធម៌ណាស់ ប៉ុន្តែខ្ញុំប្រតិបត្តិរបៀបចម្លែកជាងគេ។ នេះជាឧទាហរណ៍មួយ ដោយខ្ញុំជាប្អូនពៅ ខ្ញុំមិនទាន់មានទម្លាប់ធ្វើកិច្ចការខ្លួនឯងទេ សេលីន ជាអ្នករៀបចំបន្ទប់ ដែលយើងគេងរួមគ្នា ខ្ញុំមិនដែលធ្វើការផ្ទះទាល់តែសោះ។ ក្រោយពី ម៉ារី ចូលទៅនៅកាមែល ខ្ញុំធ្វើម្តងម្កាលដែរ ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ ខ្ញុំរៀបចំគ្រែគេង ឬបើសេលីនមិននៅ ខ្ញុំជាអ្នកយកជើងផ្កាចូលក្នុង ក៏ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់តែប៉ុណ្ណោះ។ ខ្ញុំមិនរង់ចាំការដឹងគុណរបស់សត្វលោកឡើយ។ ប៉ុន្តែមិនដូច្នោះទេ បើសេលីនមិនសូវសប្បាយចិត្ត ភ្ញាក់ផ្អើលនឹងការងារតិចតួចរបស់ខ្ញុំនេះ ខ្ញុំមិនត្រេកអរទេ ខ្ញុំយំ...។

កាលនោះ ខ្ញុំធ្វើឲ្យគេពិបាកទ្រាំណាស់ ដោយអារម្មណ៍ឆាប់រំភើបរបស់ខ្ញុំ ជួនកាលខ្ញុំធ្វើឲ្យអ្នកដែលខ្ញុំស្រឡាញ់តានតឹងក្នុងចិត្ត ដោយសារការយំបែបនេះ ពេលខ្លះខ្ញុំយំឥតឈប់ ដល់ខ្ញុំនឹងឃើញកំហុសខ្លួនឯងដែលមិនគួរយំ ខ្ញុំក៏យំទៀត។ ការត្រិះរិះពិចារណាឡើងវិញ សុទ្ធតែឥតប្រយោជន៍ ខ្ញុំមិនអាចកែប្រែ

កំហុសឆ្គងនេះបានឡើយ។ ខ្ញុំមិនដឹងថា ហេតុអ្វីខ្ញុំចូលអារាមកាមែលទេ ខ្លួនឯងនៅតូចណាស់ ប្រហែលជាព្រះជាម្ចាស់បង្កើតការអស្ចារ្យតូចនេះ ដើម្បីឲ្យខ្ញុំឆាប់ធំ តែក្នុងមួយរយៈពេល ហើយព្រះធ្វើការអស្ចារ្យនេះ ក្នុងថ្ងៃមិនគួរភ្លេចមួយគឺថ្ងៃបុណ្យដែលព្រះយេស៊ូប្រសូត  នាពេលរាត្រីដែលមានពន្លឺចែងចាំងរហូតដល់ព្រះត្រៃឯក គួរជាទីគ្រេកគ្រអាល។ ព្រះយេស៊ូ រាជកុមារដ៏ស្លូតបូតបានផ្លាស់ប្តូរព្រលឹងងងឹតងងល់របស់ខ្ញុំឲ្យទៅជាជ្រោះពន្លឺ... យប់នោះ ព្រះអង្គប្រែជាទន់ខ្សោយ ឈឺចាប់ ដើម្បីសេចក្តីស្រឡាញ់របស់ខ្ញុំ។ ព្រះអង្គបានប្រទានកម្លាំងឲ្យខ្ញុំរឹងប៉ឹង និងក្លាហាន ព្រះអង្គគ្របដណ្តប់ខ្ញុំដោយអាវុធរបស់ទ្រង់ ហើយចាប់ពីយប់នោះមក ខ្ញុំលែងចុះចាញ់ក្នុងការប្រយុទ្ធទៀតហើយ ផ្ទុយទៅវិញ ខ្ញុំឈ្នះហើយ ឈ្នះទៀត គឺជាការរត់ប្រណាំងរបស់មហាយក្ស! ប្រភពទឹកភ្នែកបានរីងស្ងួត ខ្ញុំលែងយំទៀតហើយ ដូចសម្តីដែលគេធ្លាប់ថាឲ្យខ្ញុំ៖ *"ឯងយំច្រើន ពេលនៅក្មេង បន្តិចទៀតឯងលែងមានទឹកភ្នែកហូរទៀតហើយ! ..."*។

ថ្ងៃនោះ ជាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៨៨៦ ជាថ្ងៃដែលខ្ញុំទទួលការប្រោសប្រណី ឲ្យចាកចេញពីកុមារភាព និយាយឲ្យចំទៅ គឺជាថ្ងៃដែលខ្ញុំផ្ញើជីវិតលើព្រះជាម្ចាស់។ យើងត្រលប់មកផ្ទះវិញ ក្រោយពិធីអភិបូជាកណ្តាលអាធ្រាត ជាពេលដែលខ្ញុំទទួលព្រះជាម្ចាស់ដ៏មានតេជានុភាព។ ដល់ផ្ទះភ្លាម ខ្ញុំសប្បាយចិត្តណាស់ ដើរទៅយកស្បែកជើងមក ដាក់ក្បែរឡកម្តៅ តាមទម្លាប់បុរាណដែលនាំឲ្យយើងរីករាយក្រៃលែង កាលពីក្មេង។ សេលីននៅតែទុកខ្ញុំជាកូនង៉ាធ្វើខ្ញុំតូចជាងគេ... ពុកចូលចិត្តឃើញខ្ញុំសប្បាយ ចូលចិត្តស្តាប់សំឡេងស្រែកហ៊ោរដោយអំណរ នៅពេលខ្ញុំទាញយកវត្ថុអំណោយចេញពីស្បែកជើង។ ភាពរីករាយរបស់ពុកកាន់តែធ្វើឲ្យខ្ញុំសប្បាយចិត្តក្រៃលែង ប៉ុន្តែ ព្រះយេស៊ូមានព្រះរាជបំណងឲ្យខ្ញុំលះបង់គុណវិបត្តិខ្លះៗពីកុមារភាព ដកហូតយកភាពរីករាយបែបឆោតល្ងង់ ព្រះអង្គបណ្តាលឲ្យពុកដែលនឿយហត់ បន្ទាប់អំពីពិធីអភិបូជាកណ្តាល

អាជ្រាត ឃើញស្បែកជើងខ្ញុំក្បែរឡេកម្តៅ ក៏និយាយចេញនូវពុញទ្រាន់ប៉ុន្មានម៉ាត់ ដែលមកចាក់ទម្លុះបេះដូងខ្ញុំថា៖ *"ទីបំផុតសំណាងល្អ គឺឆ្នាំចុងក្រោយហើយ!.."* ខ្ញុំឡើងទៅលើដោះមួក។ ដឹងថាខ្ញុំខឹង ដោយឃើញទឹកភ្នែកព្រៀបភ្នែក សេលីនក៏ចង់យំដែរ ព្រោះគាត់ស្រឡាញ់ខ្ញុំណាស់ គាត់យល់អំពីទុក្ខព្រួយរបស់ខ្ញុំ៖ *"ឱ! ថេរេសារបស់បងអើយ កុំចុះទៅអី ឯងមុខជាពិបាកចិត្តបើឯងមើលស្បែកជើងភ្លាមៗអញ្ចឹង!"*។ ប៉ុន្តែ មិនមែនជា ថេរេសា កាលពីមុនទេ ព្រះយេស៊ូបានប្តូរបេះដូងនាងហើយ! ដោយទប់ទឹកភ្នែកកុំឲ្យហូរ ខ្ញុំចុះជណ្តើរយ៉ាងលឿន ទប់ចិត្តកុំឲ្យញាប់ញ័រ ខ្ញុំយកស្បែកជើងដាក់ពីមុខពុក ខ្ញុំទាញយកវត្ថុជាច្រើនចេញមកយ៉ាងរីករាយដូចម្ចាស់ក្សត្រីយ៍។ ពុកសើច គាត់ក៏សប្បាយចិត្តដែរ សេលីនគិតថា ជាការយល់សប្តិ!... តែនេះជាការពិត។ ថេរេសា បានរកឃើញទឹកចិត្តក្លាហាន ដែលបាត់បង់អស់រយៈពេលបួនឆ្នាំកន្លះមកហើយៗ នាងត្រូវរក្សាទុកជារៀងរហូត!...។

យប់នៃពន្លឺនោះ បានចាប់ផ្តើមដំណាក់កាលទីបីនៃជីវិតខ្ញុំ ជាដំណាក់កាលប្រសើរជាងគេ ពោរពេញទៅដោយការប្រោសប្រណីរបស់ព្រះជាម្ចាស់។ តែមួយរយៈពេលខ្លីប៉ុណ្ណោះ ស្នាដៃដែលខ្ញុំមិនអាចបំពេញបានក្នុងរយៈពេលដប់ឆ្នាំ ព្រះយេស៊ូបានបំពេញទៅតាមបំណងល្អរបស់ខ្ញុំឥតល្អៀង។

ខ្ញុំអាចទូលព្រះអង្គ ដូចពួកសាវ័ករបស់ទ្រង់ដែរថា៖ *"ព្រះអង្គអើយ ទូលព្រះបង្គំបានរកពេញមួយយប់តែឥតបានត្រីសោះ"*។ ព្រះអង្គមេត្តាដល់ខ្ញុំ ជាងពួកសាវ័ករបស់ព្រះអង្គទៅទៀត។ ទ្រង់យកសំណាញ់មកបង់ដោយអង្គឯង បោះចូលទៅក្នុងទឹក ទាញមកវិញពេញទៅដោយត្រី...។ ទ្រង់ប្រោសប្រទានឲ្យខ្ញុំនេសាទ ព្រលឹងខ្ញុំចង់បំពេញកិច្ចការនេះ ដើម្បីកែប្រែគំនិតពួកអ្នកបាប ជាបំណងមួយដែលកន្លងមក ខ្ញុំមិនបានគិតឲ្យដិតដល់ឡើយ... ខ្ញុំដឹងថា ពាក្យមួយម៉ាត់ គឺសប្បុរសធម៌ បានជ្រៀតចូលក្នុងដួងចិត្តខ្ញុំៗ ត្រូវការបំភ្លេចខ្លួនឯង

ដើម្បីឲ្យគេរីករាយ ហើយចាប់ពីពេលនោះមក ខ្ញុំត្រេកអរណាស់...។ ថ្ងៃអាទិត្យមួយ ខ្ញុំកំពុងតែមើលរូបថតព្រះយេស៊ូលើឈើឆ្កាង ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើព្រះលោហិត ដែលហូរចេញពីព្រះហស្ដព្រះអង្គ ខ្ញុំពិបាកចិត្តយ៉ាងខ្លាំងនឹកគិតទៅដល់ព្រះលោហិត ដែលហូរធ្លាក់មកដី គ្មាននរណាហ៊ានចូលទៅត្រងហើយខ្ញុំប្ដេជ្ញាក្នុងចិត្តថា នឹងចូលទៅជិតឈើឆ្កាងដោយវិញ្ញាណ ដើម្បីត្រងយកព្រះលោហិតដែលស្រក់ចុះមក ដោយគិតថានឹងយកទៅប្រស់លើព្រលឹង... សម្រែកព្រះយេស៊ូនៅលើឈើឆ្កាង លាន់ឮជានិច្ចក្នុងបេះដូងខ្ញុំ *"ខ្ញុំស្រេកទឹក!"* ព្រះបន្ទូលនេះបានដុតរោលចិត្តខ្ញុំ ឲ្យខ្លោចផ្សាយ៉ាងខ្លាំង។ ខ្ញុំចង់យកទៅឲ្យអ្នកជាទីស្រឡាញ់របស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថា ខ្លួនខ្ញុំស្រេកព្រលឹងជាខ្លាំង...។ មិនមែនជាព្រលឹងរបស់បូជាចារ្យទេ តែជាព្រលឹងរបស់អ្នកបាប ខ្ញុំចង់នាំគេចចេញពីភ្លើងនរកខ្លាំងណាស់...។

ដើម្បីជំរុញការប្រឹងប្រែងរបស់ខ្ញុំ ព្រះជាម្ចាស់បង្ហាញថា ព្រះអង្គពេញព្រះហឫទ័យនឹងបំណងនេះ... ខ្ញុំឮគេនិយាយអំពីឧក្រិដ្ឋជនម្នាក់ ត្រូវបានកាត់ទោសប្រហារជីវិត ដោយបានប្រព្រឹត្តឧក្រិដ្ឋគួរឲ្យរន្ធត់។ គ្រប់គ្នាយល់ថា ឧក្រិដ្ឋជននោះ និងស្លាប់ដោយគ្មានស្ដាយកំហុស។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនចង់ឲ្យគាត់ធ្លាក់ទៅស្ថាននរកទេ។ ដើម្បីសម្រេចកិច្ចការនេះ ខ្ញុំបានប្រើគ្រប់មធ្យោបាយដែលនឹកឃើញ៖ ដោយយល់ថា ខ្លួនខ្ញុំគ្មានអ្វីសោះ ខ្ញុំបានថ្វាយបុណ្យកុសលច្រើនឥតគណនារបស់ព្រះយេស៊ូ ទ្រព្យសម្បត្តិព្រះសហគមន៍ដ៏វិសុទ្ធចំពោះព្រះជាម្ចាស់ ទីបំផុតខ្ញុំអង្វរសេលីនឲ្យថ្វាយអភិបូជាសម្រាប់ខ្ញុំផងដែរ។ ខ្ញុំមិនហ៊ាននិយាយត្រង់ៗប្រាប់សេលីនទេ ខ្ញុំខ្លាចគាត់បន្ទោស ព្រោះតាមការពិត ដើម្បីឧក្រិដ្ឋជនដ៏ល្បីឈ្មោះប្រង់ស៊ីនីទេ។ សេលីនជជីកសួរដោយទន់ភ្លន់ ខ្ញុំមិនអាចលាក់អាថ៌កំបាំងនេះទៀត ក៏សារភាពប្រាប់គាត់។ ក្រោយពីស្ដាប់សេចក្ដីសារភាពរបស់ខ្ញុំ សេលីនមិនបានសើចចំអក បន្ទោសខ្ញុំទេ ថែមសុំខ្លួន

ចូលរួមជួយកែប្រែចិត្តបាបជននោះថែមទៀតផង។ ខ្ញុំយល់ព្រមដោយរីករាយ ព្រោះខ្ញុំចង់ឲ្យសត្វលោកទាំងអស់រួបរួមគ្នាជាមួយខ្ញុំ ដើម្បីទូលអង្វរសុំការប្រោសប្រណីដល់អ្នកទោស។ ខ្ញុំជឿជាក់ក្នុងចិត្តថា បំណងយើងមុខជាបានសម្រេច។ ដើម្បីឲ្យបានសេចក្តីក្លាហាន ក្នុងការអធិដ្ឋានទូលអង្វរតទៅទៀត ខ្ញុំបានទូលសូមដល់ព្រះជាម្ចាស់ថា ខ្ញុំប្រាកដក្នុងចិត្ត ព្រះអង្គច្បាស់ជាលើកលែងទោសឲ្យបុរសទុរគតប្រង់ស៊ីនីនេះ ពុំខានឡើយ។ ទោះជាប្រង់ស៊ីនីមិនព្រមលន់តួ ឬបញ្ចេញសញ្ញាណាមួយថា ព្រមទទួលកំហុសលើបាបកម្មរបស់ខ្លួនក៏ដោយ ខ្ញុំនៅតែមានជំនឿលើសេចក្តីមេត្តាករុណាជាអនេករបស់ព្រះយេស៊ូជានិច្ច។ ខ្ញុំសុំតែម្យ៉ាងគត់ សូមព្រះអង្គបណ្តាលឲ្យប្រង់ស៊ីនីធ្វើ *"សញ្ញាមួយ"* ក្នុងការលន់តួរអំពើបាបរបស់ខ្លួន ដើម្បីឲ្យខ្ញុំអស់ចិត្ត...។ ការអធិដ្ឋានបន់ស្រន់របស់ខ្ញុំសម្រេចដូចបំណង! ទោះជាពុកហាមអានកាសែតសារព័ត៌មានណាមួយក៏ដោយ ខ្ញុំជឿថា យើងមិនបានប្រឆាំងនឹងគាត់ទេ ដោយគ្រាន់តែអានអត្ថបទខ្លះៗ ដែលទាក់ទងពីប្រង់ស៊ីនី។ មួយថ្ងៃក្រោយការពិឃាដ សារពត៌មាននិយាយថា ប្រង់ស៊ីនីមិនព្រមសារភាពកំហុសខ្លួនទេ ជននេះឡើងទៅកាន់ទីពិឃាដ ហៀបនឹងបញ្ចូលក្បាលទៅក្នុងរង្វង់ខ្សែពួរទៅហើយ ស្រាប់តែមានអ្វីមួយមកបណ្តាលចិត្តឲ្យអ្នកទោសងាកក្រោយ ស្រវាយកឈើឆ្កាងដែលបូជាចារ្យហុចមកឲ្យ ហើយថើបបីដង លើរបួសដ៏ពិសិដ្ឋរបស់ព្រះអង្គ!... បន្ទាប់មកព្រលឹងរបស់គេ ទៅទទួលសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ដែលប្រកាសទៅស្ថានបរមសុខថា ព្រះអង្គត្រេកអរនឹងទទួលព្រលឹងបាបជនតែម្នាក់ ដែលចេះស្តាយកំហុសរបស់ខ្លួន ជាជាងព្រលឹងជនសុចរិត ៩៩នាក់ ដែលមិនត្រូវការការសូមខមាទោស! ...។

ខ្ញុំបានទទួល *"សញ្ញា"* តាមសំណូមពរហើយៗ សញ្ញានេះ ជាការធ្វើត្រាប់តាមគតល្បៀងនៃការប្រោសប្រណីរបស់ព្រះយេស៊ូ ដែលទ្រង់បានណែនាំឲ្យខ្ញុំអធិដ្ឋានទូលអង្វរ ដើម្បីអ្នកប្រព្រឹត្តិអំពើបាបទាំងឡាយ។ តើនេះមិនដោយសារ

ឈាមហូរចេញពីស្នាមរបួសរបស់ព្រះយេស៊ូទេឬ ដែលបណ្តាលឲ្យខ្ញុំស្រេកព្រលឹង? ខ្ញុំឲ្យព្រលឹងទាំងនោះក្រេបព្រះលោហិតដ៏និមល ដើម្បីបន្សុតបាបរបស់ពួកគេ ហើយបបូរមាត់នៃ "កូនទីមួយ" របស់ខ្ញុំបានដាក់ពីលើដំបៅពិសិដ្ឋនេះ! ... នេះជាចម្លើយដ៏ផ្អែមល្ហែមពុំអាចថ្លែងបាន! ... ។ តាំងពីការប្រោសប្រណីនោះមក បំណងក្នុងការសង្គ្រោះព្រលឹង កាន់តែរីកធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃ ហាក់ដូចជាព្រះយេស៊ូមានព្រះបន្ទូលមកខ្ញុំ ដូចព្រះបន្ទូលទៅកាន់ជនជាតិសាម៉ារីដូច្នោះដែរ *"សូមឲ្យទឹកខ្ញុំផឹកផង!"* ។ ពិតជាការប្តូរផ្លាស់នៃសេចក្តីស្រឡាញ់មែន។ ខ្ញុំឲ្យព្រះលោហិតទៅព្រលឹងទាំងនោះ ហើយខ្ញុំថ្វាយព្រលឹងដែលបានបន្សុតដោយព្រះលោហិតទៅព្រះអង្គវិញ។ ធ្វើបែបនេះ ហាក់ដូចជាខ្ញុំបំបាត់សេចក្តីស្រេកឃ្លានរបស់ព្រលឹងទាំងនោះ កាលបើខ្ញុំឲ្យផឹកកាន់តែច្រើន គេកាន់តែស្រេក ការស្រេកខ្លាំងនេះហើយដែលព្រះអង្គប្រទានឲ្យខ្ញុំ នូវភេសជ្ជៈដ៏ឈ្ងុយឆ្ងាញ់នៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។ (...)

សេចក្តីពិតសំខាន់ៗទាំងអស់ក្នុងសាសនា អាចកំបាំងនៃស្ថានបរមសុខស្រូបយកព្រលឹងខ្ញុំ បញ្ជូលទៅក្នុងសុភមង្គលមួយ ដែលគ្មាននៅលើលោកនេះ... ខ្ញុំដឹងស្រេចទៅហើយថា ព្រះជាម្ចាស់បានទុកកន្លែងឲ្យអ្នកដែលស្រឡាញ់ព្រះអង្គ (មិនមែនតាមរូបភាពខាងក្រៅទេ តែតាមផ្លូវចិត្ត) ហើយដឹងថា រង្វាន់នៅស្ថានបរមសុខធំធេងជាងការបូជាតិចតួចក្នុងជីវិត នៅលើលោកនេះឆ្ងាយណាស់ ខ្ញុំចង់ស្រឡាញ់ព្រះយេស៊ូយ៉ាងងប់ងល់ ថ្វាយសេចក្តីស្រឡាញ់គ្រប់ជំពូកចំពោះព្រះអង្គទាន់ពេលដែលខ្ញុំអាចធ្វើកើត ខ្ញុំចម្លងអត្ថបទជាច្រើនស្តីពីសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ និងការទទួលអ្នកដែលព្រះអង្គជ្រើសរើស ក្នុងខណៈដែលព្រះអង្គផ្ទាល់ក្លាយជារង្វាន់អស់កល្បជានិច្ច សម្រាប់អ្នកទាំងនោះ។ ខ្ញុំទន្ទេញឥតឈប់ព្រះបន្ទូលនៃសេចក្តី ដែលធ្វើឲ្យខ្ញុំរំភើបរីករាយ។ (...)

ការប្រោសប្រណីដ៏ធំធេងបែបនេះ ត្រូវតែមានផ្លែផ្កាៗដ៏ច្រើនបរិបូរណ៍។

ការអនុវត្តគុណធម៌ នាំឲ្យយើងទៅជាមនុស្សស្លូតបូតសាមញ្ញ។ មុនដំបូងទឹកមុខខ្ញុំបង្ហាញភាពរឹងរូស ប៉ុន្តែបន្តិចម្តងៗ សភាពនេះចេះតែរលាយទៅហើយ ការលះបង់ក្លាយទៅជាងាយស្រួលតាំងពីដំបូងទៅ។ ព្រះយេស៊ូមានព្រះបន្ទូលថាៈ *"គេនឹងបន្ថែមឲ្យអ្នកដែលមានហើយ រហូតទាល់តែបានបរិបូរណ៍"* ។ ចំពោះការប្រោសប្រណី ដែលបានទទួលដោយស្មោះស្ម័គ្រ ព្រះអង្គបានប្រទានច្រើនទៀតមកខ្ញុំ... ទ្រង់បានប្រគល់ព្រះកាយដ៏វិសុទ្ធជាច្រើនលើក ច្រើនជាងការសង្ឃឹមទុករបស់ខ្ញុំ។ ខ្ញុំបានដាក់កំហិតខ្លួនឯងថា មិនត្រូវខកខានពិធីនេះ ម្តងណាឡើយ។ សម័យនោះ ខ្ញុំមិនសូវមានសេចក្តីអង់អាច ដូចឥឡូវនេះទេ បើមិនដូច្នោះ ប្រហែលជាខ្ញុំអាចធ្វើអ្វីៗផ្សេងទៀត ព្រោះខ្ញុំជឿជាក់ថា ព្រលឹងនីមួយៗ ត្រូវប្រាប់ទៅលោកបូជាចារ្យ នូវការទាក់ទាញរបស់ខ្លួនដែលបម្រុងទទួលព្រះជាម្ចាស់។ ព្រះអង្គមិនយាងចុះពីស្ថានបរមសុខ មិនមែនគ្រាន់តែសណ្ឋិតក្នុងពែងមាសប៉ុណ្ណោះទេ គឺដើម្បីស្វែងរកស្ថានបរមសុខមួយទៀត ដែលរឹតតែថ្លៃថ្លាជាងមុន ជាស្ថានបរមសុខនៃព្រលឹងរបស់យើង ដែលជាវិមានអស់កល្បជានិច្ចនៃព្រះត្រៃឯកជាទីគោរព។

នៅខែឧសភា ដោយយល់អំពីបំណងឥតងាករេ (ការតាំងចិត្ត) របស់ខ្ញុំ ព្រះយេស៊ូទ្រង់រាជានុញ្ញាតឲ្យលោកបូជាចារ្យប្រាប់ថា ខ្ញុំអាចទទួលព្រះកាយបួនដងក្នុងមួយសប្តាហ៍ លុះខែឧសភានេះកន្លងផុតទៅ គាត់បន្ថែមម្តងទៀតរាល់លើក នៅពេលមានពិធីបុណ្យ។ វេលាដែលខ្ញុំចេញពីកន្លែងស្រាយបាប ទឹកភ្នែកខ្ញុំហូរហាក់ដូចជាព្រះយេស៊ូផ្ទាល់ ដែលចង់រួបរួមជាមួយខ្ញុំ ព្រោះការស្រាយបាបមានពេលតិចណាស់ ខ្ញុំមិនដែលបាននិយាយអំពីមនោសញ្ចេតនាក្នុងខ្លួនមួយម៉ាត់ណាឡើយ មាគ៌ាដែលខ្ញុំបានដើរជាផ្លូវត្រង់ល្អ ភ្លឺព្រោងព្រាយ មិនបាច់មានអ្នកណែនាំ ក្រៅពីព្រះយេស៊ូឡើយ។ ខ្ញុំប្រដូចលោកបូជាចារ្យទៅនឹងកញ្ចក់ថ្លាច្បាស់ល្អ ចាំងឆ្លុះរូបភាពព្រះយេស៊ូ ក្នុងព្រលឹងទាំងអស់ ចំពោះរូបខ្ញុំ ព្រះអង្គ

មិនចាំបាច់មានអ្នកណែនាំទេ ព្រះអង្គយាងមកជួបដោយត្រង់ៗតែម្តង! ...។

កាលបើអ្នកថែចម្ការដំណាំម្នាក់ រុំផ្លែឈើមួយ ការពារកុំឲ្យសត្វល្អិតបំផ្លាញ មិនមែនសម្រាប់ទុកផ្លែនោះលើដើមវាទេ គឺសម្រាប់ដាក់លើតុបរិភោគ។ ដូចគ្នានេះដែរ ព្រះយេស៊ូប្រោសប្រណីផ្កាដ៏តូចរបស់ព្រះអង្គ...។ ថ្ងៃដែលគេសម្លាប់ព្រះអង្គបានស្រែកដោយអំណរថា៖ *"ព្រះបិតា ខ្ញុំម្ចាស់សូមអរព្រះគុណចំពោះអ្វីៗ ដែលទ្រង់លាក់លៀមចំពោះអ្នកប្រាជ្ញ និងអ្នកចេះដឹង ហើយព្រះអង្គបានប្រាប់អ្នកតូចតាចជាងគេឲ្យបានដឹង"* ។ ព្រះអង្គមានបំណងស្រោចស្រពខ្ញុំ ដោយសេចក្តីមេត្តាករុណា ព្រោះកាលនោះ ខ្ញុំតូច និងទន់ខ្សោយ ព្រះអង្គបន្ទាបព្រះកាយមករកខ្ញុំ បង្រៀនជាសម្ងាត់នូវអ្វីៗ ដែលជាសេចក្តីស្រឡាញ់របស់ព្រះអង្គ។ ឱ! ប្រសិនបើអ្នកប្រាជ្ញ ដែលខិតខំសិក្សាស្រាវជ្រាវអស់មួយជីវិតមកសាកសួរខ្ញុំ ពួកគាត់ច្បាស់ជាឆ្ងល់ពុំខាន ព្រោះមិនដែលមានសោះឡើយ កូនក្មេងអាយុ ១៤ឆ្នាំ យល់អាថ៌កំបាំងដ៏វិសេសវិសាល ដែលវិទ្យាសាស្ត្ររបស់ពួកគាត់ពុំអាចរកឃើញ ព្រោះដើម្បីយល់អាថ៌កំបាំងទាំងនោះ ទាល់តែអ្នកនោះជាមនុស្សចេះបន្ទាបខ្លួន!...។ (...)

ខ្ញុំមិនដឹងជម្រាបពុកបែបណាឡើយ (អំពីបំណងចង់បួសជាដូនជីក្នុងអារាមកាមែល) តើនិយាយដូចម្តេចទៅ ពុកបានលះបង់កូនស្រីច្បងបីនាក់រួចទៅហើយ?... ខ្ញុំត្រូវពុះពារតស៊ូក្នុងចិត្តខ្លាំងណាស់ ទម្រាំនឹងមានសេចក្តីក្លាហាននិយាយការនោះ! ទោះជាយ៉ាងណា ខ្ញុំត្រូវសម្រេចចិត្ត ខ្ញុំមានអាយុជិតដប់បួនឆ្នាំកន្លះហើយ។ បើរាប់ពីយប់ថ្ងៃបុណ្យព្រះយេស៊ូប្រសូតមក ទើបតែបានប្រាំមួយខែទេ ដែលខ្ញុំប្តេជ្ញាចិត្ត។ កាលពីឆ្នាំទៅ គឺម៉ោងនេះហើយ ដែលខ្ញុំបានទទួលការប្រោសប្រណី។ ដើម្បីជម្រាបពុក ខ្ញុំរើសយកថ្ងៃបុណ្យព្រះវិញ្ញាណយាងមក។ ពេញមួយថ្ងៃ ខ្ញុំបានទូលអង្វរដល់សន្តគ្រីស្តទូតទាំងអស់ សូមលោកជួយអធិដ្ឋានឲ្យខ្ញុំ សូមជួយដឹកនាំឲ្យនិយាយសម្តីដែលខ្ញុំត្រូវនិយាយ...

តើមិនមែនពួកគាត់ទេឬ ដែលព្រះជាម្ចាស់តម្រូវឲ្យមកជួយក្មេងមិនបានសម្ដី ឲ្យទៅជាគ្រីស្ដទូត ដោយសារការអធិដ្ឋាន និងការបូជារបស់គេ?... ថ្ងៃរសៀល វេលាដែលត្រឡប់មកពីសូត្រធម៌អធិដ្ឋាន ពេលល្ងាច ខ្ញុំមានឱកាសជម្រាបការ សម្រេចចិត្តនេះ ដល់ពុកជាទីស្រឡាញ់។ គាត់ដើរទៅអង្គុយលើគែមអាងទឹក ដាក់ដៃផ្តុំគ្នា កំពុងគយគន់ធម្មជាតិដ៏ស្រស់ស្អាត វេលាព្រះអាទិត្យជិតអស្ដង្គត រស្មីពណ៌មាសបំភ្លឺចុងរុក្ខជាតិធំៗ ជាកន្លែងដែលបក្សាបក្សីស្រែកច្រៀងទ្រហឹង អឺងកង។ ទឹកមុខស្រស់ថ្លាបង្ហាញថាគាត់មានចិត្តស្ងប់។ ខ្ញុំទៅអង្គុយក្បែរគាត់ ដោយឥតនិយាយស្ដី ពេញព្រៀបដោយទឹកភ្នែក។ គាត់មើលមកខ្ញុំដោយស្រទន់ ទាញក្បាលខ្ញុំផ្ដេកលើទ្រូងគាត់។ ខ្ញុំសារភាពទាំងទឹកភ្នែកនូវបំណងចង់ទៅនៅ អារាមកាមែល។ ពេលនោះទឹកភ្នែកគាត់ហូរលាយនឹងទឹកភ្នែកខ្ញុំ មិននិយាយ សម្ដីពង្វាងបំណងប្រាថ្នាខ្ញុំឡើយ គាត់គ្រាន់តែប្រាប់ថា ខ្ញុំនៅតូចពេក ដើម្បី សម្រេចកិច្ចការធំបែបនេះ។ ពេលនោះ ខ្ញុំបានប្រកែកការពារបុព្វហេតុរបស់ខ្ញុំ។ ដោយពុកជាមនុស្សមិនស្មុគស្មាញ និងស្មោះត្រង់ពីកំណើត គាត់យល់ព្រមដោយ គិតថា នេះជាបំណងរបស់ព្រះជាម្ចាស់ រួចគាត់ពោលដោយអំណរថា នេះជា កិត្តយសដ៏ខ្ពង់ខ្ពស់ណាស់ ដែលព្រះជាម្ចាស់សុំកូនៗពីគាត់។ យើងនាំគ្នាដើរ កំសាន្តបន្តទៅទៀត ខ្ញុំបានធូរស្រាលក្នុងចិត្ត ដោយឪពុកខ្ញុំចិត្តល្អ ស្លូតបូត គ្មានគូប្រៀប។ ពេលនោះ ពុកហាក់ដូចជាសប្បាយចិត្តណាស់ ដោយការបូជា បានសម្រេច ហើយគាត់និយាយរកខ្ញុំដូចសន្តបុគ្គលពិតៗ ប៉ុន្តែ ខ្ញុំមិនអាច សរសេរជម្រាបជូនទេ ដោយខ្ញុំខ្វះការចងចាំ។ អនុស្សាវរីយ៍ដែលខ្ញុំមិនអាច បំភ្លេចបាន គឺសកម្មភាពជានិមិត្តរូប ដែលពុកបានបំពេញដោយមិនបានដឹង ខ្លួន។ យើងដើរទៅជិតជញ្ជាំងទាបមួយ គាត់ចង្អុលទៅផ្កាសតូច ហើយយកផ្កា នោះ មកប្រគល់ឲ្យខ្ញុំ គាត់ប្រាប់ខ្ញុំថា ព្រះជាម្ចាស់បានបង្កើត ថែរក្សាផ្កាសនេះ យ៉ាងល្អ ទើបវារស់បានរហូតដល់ថ្ងៃនេះ។ ឮសម្ដីពុក ខ្ញុំហាក់ដូចជាស្ដាប់រឿង របស់ខ្ញុំ ដែលដូចគ្នានឹងការដែលព្រះយេស៊ូបានបំពេញចំពោះផ្កាតូច និងក្មេង



ស្រីថេរេសាដែរ... ខ្ញុំទទួលផ្កាដ៏តូចនេះដូចសារិកធាតុ។ ខ្ញុំបានឃើញថា ពេលបេះផ្កា ពុកបានដកមិនឲ្យដាច់ឫស ហាក់ដូចជាចង់យកទៅដាំកន្លែងផ្សេងទៀតដែលជាដីមានជីជាតិជាងនេះ។ សកម្មភាពពុកមួយស្របក់មុននេះ ជំរុញឲ្យខ្ញុំអាចឡើងភ្នំអារាមកាមែល ចាកចេញពីជ្រលងដែលជាទីកំណើតរបស់ខ្ញុំ។

ខ្ញុំដាក់ផ្កាតូចក្នុងសៀវភៅ ដែលខ្ញុំចូលចិត្តជាងគេ ត្រង់ជំពូក *"ត្រូវស្រឡាញ់ព្រះយេស៊ូលើសអ្វីៗទាំងអស់"*។ ផ្កានោះនៅរហូតដល់សព្វថ្ងៃនេះ ប៉ុន្តែ វាបាក់ទងក្បែរឫសទៅហើយ ហាក់ដូចជាព្រះជាម្ចាស់មានព្រះបន្ទូលថា ព្រះអង្គនឹងបំបែកផ្កាពីឫសគល់របស់វា មិនឲ្យស្ថិតស្រពោនលើលោកនេះទៀតទេ!

ក្រោយពីបានទទួលការយល់ព្រមពីពុក ខ្ញុំគិតហោះហើរដោយគ្មានញញើតនៅអារាមកាមែល ប៉ុន្តែទុក្ខលំបាកជាច្រើនទៀត មកសាកល្បងការត្រាស់ហៅរបស់ខ្ញុំ។ ខ្ញុំត្រូវជម្រាបឪពុកមា ដោយការភិតភ័យ។ គាត់បានលួងលោមខ្ញុំដោយវាចាផ្អែមល្ហែម ប៉ុន្តែគាត់មិនព្រមឲ្យខ្ញុំទៅទេ ផ្ទុយទៅវិញគាត់ហាមមិនឲ្យខ្ញុំនិយាយអំពីការត្រាស់ហៅនេះ មុនអាយុ ១៧ឆ្នាំឡើយ។ គាត់ថាមិនត្រឹមត្រូវទេដែលបណ្ដោយឲ្យក្មេងអាយុ ១៥ឆ្នាំ ទៅបួសដូច្នេះ។ អ្នកផងយល់ថា រស់នៅក្នុងអារាម ជាការពិបាកខ្លាំងណាស់ មិនគួរឲ្យក្មេងខ្វះបទពិសោធន៍បួសទេ... គេនឹងនិយាយគ្រប់គ្នា...។ គាត់ថែមទាំងនិយាយទៀតថា ទាល់តែមានការអស្ចារ្យទើបគាត់យល់ព្រមឲ្យខ្ញុំទៅ។ ដំណោះស្រាយទាំងនេះ សុទ្ធតែឥតប្រយោជន៍ដូច្នេះខ្ញុំដើរចេញដោយភាពល្វីងជូរចត់ក្រៃលែង។ ដើម្បីលួងលោមចិត្ត ខ្ញុំសូត្រធម៌ អធិដ្ឋាន ទូលអង្វរព្រះយេស៊ូ សូមព្រះអង្គប្រព្រឹត្តការអស្ចារ្យ ដើម្បីខ្ញុំបានបំពេញបំណងនេះ។ ពេលយូរបន្តិចមកទៀត ទើបខ្ញុំហ៊ានសុំលោកមាម្តងទៀត។ ខ្ញុំត្រូវជម្នះចិត្តទៅផ្ទះគាត់ៗ ហាក់ដូចជាលែងគិតគូរអំពីរូបខ្ញុំ ប៉ុន្តែក្រោយមកទើបខ្ញុំដឹងថា ទឹកមុខក្រៀមក្រំរបស់ខ្ញុំមានឥទ្ធិពលលើរូបគាត់។ មុននឹងផ្ដល់ពន្លឺដែលជាសេចក្ដីសង្ឃឹម ព្រះជាម្ចាស់បានឲ្យខ្ញុំរងទុក្ខលំបាកដ៏ឈឺចាប់មួយ

ទៀត អស់រយៈពេលបីថ្ងៃ។ ឱ! ខ្ញុំមិនដែលបានគិតថា ការសាកល្បងនេះ គឺជាការឈឺចាប់របស់ព្រះមាតា និងសន្តយូសែប ដែលស្វែងរកព្រះកុមារយេស៊ូទេ។ កាលនោះ ខ្លួនខ្ញុំហាក់ដូចជានៅកណ្ដាលវាលរហោស្ថាន ស្មារតីហាក់ដូចកូនទូកតូចឥតច្រវា គ្មានអ្នកអុំ អណ្ដែតទៅតាមខ្សែទឹក ត្រូវព្យុះព្យោមាបក់បោក... ខ្ញុំដឹងថា ព្រះយេស៊ូផ្ទំលក់នៅក្នុងកូនទូករបស់ខ្ញុំ ប៉ុន្ដែ ដោយយប់ងងឹតពេក ខ្ញុំមើលមិនឃើញព្រះអង្គទេ។ គ្មានពន្លឺ គ្មានទាំងផ្លេកបន្ទោរ បំភ្លឺដុំពពកខ្មៅ... តាមពិតទៅ ផ្លេកបន្ទោរជាពន្លឺតិចតួច តែទោះជាយ៉ាងណា ក៏ខ្ញុំអាចមើលឃើញព្រះយេស៊ូមួយភ្លែតដែរ... នេះគឺជាពេលយប់នៃព្រលឹង... ដូចព្រះយេស៊ូនៅពេលហៀបនឹងសុគត ហាក់ដូចជាកណ្ដោចកណ្ដែង គ្មានអ្នកលួងលោមសោះ ទោះជានៅលើលោកនេះ ឬនៅស្ថានបរមសុខ ព្រះជាម្ចាស់បោះបង់ខ្ញុំចោលហើយ!... ធម្មជាតិហាក់ដូចជាសោកសៅដូចខ្ញុំដែរ។ បីថ្ងៃនោះ ព្រះអាទិត្យមិនបញ្ចេញរស្មី ភ្លៀងធ្លាក់ដូចគេចាក់ទឹក (ខ្ញុំសម្គាល់ឃើញថា រាល់កាលៈទេសៈធ្ងន់ធ្ងរនៃជីវិតខ្ញុំ ធម្មជាតិតែងតែដូចព្រលឹងខ្ញុំជានិច្ច។ ថ្ងៃដែលខ្ញុំយំ មេឃក៏យំជាមួយខ្ញុំដែរ ថ្ងៃដែលខ្ញុំរីករាយ ព្រះអាទិត្យបញ្ចេញរស្មីភ្លឺថែងចាំង ផ្ទៃមេឃគ្មានពពក...)។

ថ្ងៃទីបួន ជួនជាថ្ងៃសៅរ៍ ថ្ងៃដែលត្រូវថ្វាយបង្គំព្រះមាតា ខ្ញុំបានទៅជួបលោកមា។ ពេលនោះ ខ្ញុំចម្លែកក្នុងចិត្តយ៉ាងខ្លាំង គាត់មើលមុខខ្ញុំ ហើយហៅខ្ញុំចូលក្នុងបន្ទប់ធ្វើការរបស់គាត់!... គាត់ចាប់ផ្ដើមបន្ទោសអំពីឫកពារញញើត ញញើមរបស់ខ្ញុំយ៉ាងទន់ភ្លន់ បន្ទាប់មកគាត់ប្រាប់ខ្ញុំថា មិនចាំបាច់មានការអស្ចារ្យទេ គាត់បានអធិដ្ឋានចំពោះព្រះជាម្ចាស់ សូមព្រះអង្គគ្រាន់តែជួយ *"បន្ទន់ចិត្តគាត់"*។ ពេលនោះ ព្រះអង្គបំពេញបំណងគាត់ហើយ... ឱ! ខ្ញុំមិនប្រាថ្នា សូមការអស្ចារ្យទេ ព្រោះពេលនេះវាកើតហើយ។ លោកមាមិនរឹងរូសដូចមុនទេ។ គាត់និយាយដោយគ្មានបញ្ចិតបញ្ចៀងថា ខ្ញុំជាផ្កាតូចមួយ ដែលព្រះជាម្ចាស់ចង់បេះ គាត់លែងឃាត់ទៀតហើយ!...

ចម្លើយចុងក្រោយនេះ សមនឹងឫកពារគាត់ណាស់។ លើកទីបីហើយ ដែលគ្រីស្តបរិស័ទវ័យចំណាស់រូបនេះ យល់ព្រមឲ្យកូនស្រីចិញ្ចឹមម្នាក់ដែលគាត់ស្រឡាញ់ពេញចិត្ត ទៅបង្កប់ខ្លួនឆ្ងាយពីគេឯង។ អ្នកមីងជាស្ត្រីទន់ភ្លន់ ប្រុងប្រយ័ត្ន គួរឲ្យស្រឡាញ់ណាស់ដែរ។ ខ្ញុំនៅចាំថា ពេលដែលខ្ញុំពិបាកចិត្ត គាត់មិនដែលពោលពាក្យបន្ថែមទុក្ខព្រួយខ្ញុំឡើយ គាត់តែងតែអាណិតអាសូរខ្ញុំជានិច្ច ដូច្នេះហើយ កាលដែលលោកមាយល់ព្រម គាត់ក៏យល់ព្រមដោយគ្មានបញ្ចេញកាយវិការស្តាយស្រណោះឡើយ... គួរឲ្យអាណិត! ឪពុកជាទីស្រឡាញ់របស់យើងមិនបានដឹងថា ត្រូវលះបង់របៀបនេះពីរដងទៀតទេ... ប៉ុន្តែ ព្រះជាម្ចាស់ដែលហុចព្រះហស្តមកសុំ មិនដែលហុចព្រះហស្តទទេទេ មិត្តភ័ក្តិជាទីស្រឡាញ់របស់ទ្រង់ អាចទទួលបាននូវកម្លាំងពលំ និងសេចក្តីក្លាហាន ជាប្រយោជន៍សម្រាប់ពួកគាត់... អ្នកម៉ែជ្រាបទេ ក្រោយពីទទួលបានចម្លើយរបស់លោកមា ខ្ញុំត្រលប់មកផ្ទះវិញ ដោយចិត្តត្រេកអរជាខ្លាំង *"ក្រោមមេឃភ្លឺស្រឡះ គ្មានពពក!"*... ក្នុងអារម្មណ៍ក៏ដូច្នោះដែរ លែងមានយប់ងងឹតទៀតហើយ ព្រះយេស៊ូលែងខ្ញុំផ្ទុំ នាំមកនូវសេចក្តីរីករាយ សំឡេងរលកក៏ស្ងប់ស្ងាត់។ លែងមានព្យុះនៃទុក្ខលំបាកទៀតហើយ មានតែខ្យល់បក់រំភើយៗ បំប៉ោងក្តោងរបស់ខ្ញុំៗជឿថា បន្តិចទៀត ខ្ញុំនឹងទៅដល់ត្រើយនៃសុភមង្គល ដែលមើលឃើញជិតៗនេះ។ ប៉ុន្តែ មានព្យុះមួយធំលើសមុន មកបោកបក់ បំបាំងមិនឲ្យឃើញពន្លឺសើន នាំឲ្យគេភិតភ័យថា ត្រូវទៅឆ្ងាយគ្មានពេលត្រលប់ មកជួបផ្នូកខ្សាច់ជាទីប្រាថ្នាទៀតឡើយ។

ប៉ុន្តែ ថ្ងៃក្រោយពីការព្រមព្រៀងរបស់លោកមា ខ្ញុំបានទៅជួបអ្នកម៉ែ ហើយនិយាយរៀបរាប់ដោយអំណរអំពីទុក្ខព្រួយដែលកន្លងផុតទៅ តែពេលនោះ ខ្ញុំភ្ញាក់ព្រើតដោយឮអ្នកម៉ែថា អ្នកគ្រប់គ្រងថ្នាក់លើ មិនយល់ព្រមឲ្យខ្ញុំចូលកាមែលមុនអាយុ ២១ឆ្នាំឡើយ។

គ្មាននរណាគិតដល់ការជំទាស់ ដែលមិនអាចជម្នះបាននេះទេ។ ផ្ទុយទៅ

វិញ ខ្ញុំមិនបានចុះញ៉មឡើយ ខ្ញុំទៅជួបលោកជាមួយពុក និងសេលីន ដើម្បីសាកល្បងធ្វើឲ្យគាត់រំភើប ដោយបង្ហាញថា ខ្ញុំពិតជាទទួលការត្រាស់ហៅមែន។ លោកទទួលយើងដោយមិនសូវរាក់ទាក់ ទោះជាពុកជួយនិយាយយ៉ាងណា ក៏មិនអាចប្តូរស្ថានភាពនេះបានដែរ។ គាត់ថា ខ្ញុំអាចរស់នៅតាមរបៀបអារាមកាមែលឯផ្ទះបាន ទោះជាមិនប្រតិបត្តិគ្រប់វិន័យ ក៏មិនថ្វីដែរ។ល។ និង ។ល។ ទីបំផុតគាត់បន្ថែមថា គាត់គ្រាន់តែជាប្រតិភូនៃលោកអភិបាលប៉ុណ្ណោះទេ ប្រសិនបើលោកយល់ព្រម គាត់មិនថាអ្វីឡើយ... ខ្ញុំចេញពីអារាមទាំងទឹកភ្នែកហូររហាមតែជាភ័ព្វល្អ ខ្ញុំលាក់មុខក្រោមឆ័ត្រ ព្រោះភ្លៀងដូចចាក់ទឹក។ ពុកមិនដឹងជាលួងលោមខ្ញុំបែបណាឡើយ។ គាត់សន្យាថា នឹងនាំខ្ញុំទៅបាយើ កាលណាខ្ញុំចង់ព្រោះខ្ញុំបានសម្រេចយ៉ាងដាច់ខាតថា ត្រូវតែទៅដល់ទីបញ្ចប់។ ខ្ញុំនឹងទៅរហូតដល់សម្តេចប៉ាប បើលោកអភិបាលមិនព្រមឲ្យខ្ញុំចូលអារាមកាមែល នៅអាយុ ១៥ឆ្នាំ...។ (...) ខ្ញុំធំឡើងក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ខ្ញុំដឹងថានៅក្នុងចិត្តខ្ញុំមានសន្ទុះចម្លែក មិនដែលមានពីមុនមក ជួនកាល ខ្ញុំមានមនោសញ្ចេតនាស្នេហាពិតៗ។ ល្ងាចមួយ ដោយមិនដឹងជាទូលព្រះយេស៊ូដូចម្តេចអំពីសេចក្តីស្រឡាញ់ចំពោះព្រះអង្គ ហើយចង់ឲ្យគេស្រឡាញ់ព្រះអង្គ និងលើកតម្កើងសិរីរុងរឿងព្រះអង្គគ្រប់ទីកន្លែង។ ខ្ញុំគិតដោយទុក្ខព្រួយថា ព្រះអង្គមិនអាចទទួលសេចក្តីស្នេហាបានទេ នៅស្ថាននរក ដូច្នេះ ខ្ញុំទូលអង្វរដល់ព្រះជាម្ចាស់ថាខ្ញុំសុខចិត្តចុះនរក ដើម្បីព្រះអង្គបានទទួលសេចក្តីស្រឡាញ់ ដែលមិនសាបសូន្យក្នុងកន្លែងទទួលបណ្តាសារនោះ បើដូច្នោះមែន ព្រះអង្គមិនអាចទទួលសិរីរុងរឿងទេ ព្រោះព្រះអង្គត្រូវការតែសុភមង្គលរបស់យើងមួយមុខ។ កាលណាគេស្រឡាញ់ គេចង់តែនិយាយពាក្យផ្តេសផ្តាស់ ខ្ញុំនិយាយដូច្នេះ មិនមែនព្រះជាម្ចាស់ជំរុញខ្ញុំទេ ប៉ុន្តែសម្រាប់ខ្ញុំ នៅស្ថានបរមសុខមានតែសេចក្តីស្រឡាញ់ប៉ុណ្ណោះខ្ញុំមានអារម្មណ៍ដូចសន្តប៉ូលដែរ គ្មានអ្វីអាចបំបែកខ្ញុំចេញពីព្រះជាម្ចាស់ ដែលខ្ញុំស្រឡាញ់បានឡើយ។



# ដំណើរទៅទីក្រុងរ៉ូម

**(១៨៨៧)**

ក្រោយពីទៅបាយើបីថ្ងៃ ខ្ញុំត្រូវធ្វើដំណើរឆ្ងាយជាងមុន គឺទៅទីក្រុងអមតៈ។ អាហ៍! អស្ចារ្យណាស់ ដំណើរនេះ!... វាបានបង្រៀនខ្ញុំច្រើនជាងការសិក្សារាប់ឆ្នាំកន្លងមកនេះ វាបានបង្ហាញអំពីអំនួតនៃប្រវត្តិសាស្ត្រ ដែលជាការហាត់នឿយរបស់មនុស្ស ក្រោមពន្លឺព្រះអាទិត្យ... វេលានោះ ខ្ញុំបានឃើញវត្ថុល្អៗ ខ្ញុំបានគយគន់អច្ឆរិយភាពនៃសិល្បៈ និងសាសនា ជាពិសេសខ្ញុំជាន់លើដី ដែលគ្រីស្តទូតដ៏វិសុទ្ធជាច្រើន បានជាន់លើទឹកដីដែលស្រោចស្រពដោយលោហិតរបស់មរណសាក្សីជាច្រើនរូប ហើយព្រលឹងខ្ញុំក៏បានរីកធំធាត់ ពេលជួបប្រទះវត្ថុពិសិដ្ឋទាំងនេះដែរ។

ខ្ញុំសប្បាយចិត្តណាស់ ដែលបានទៅទីក្រុងរ៉ូម ប៉ុន្តែមានមនុស្សជាច្រើននាក់ គិតថាពុកនាំខ្ញុំដើរកំសាន្តលំហើយខួរក្បាល ដើម្បីឲ្យខ្ញុំប្ដូរគំនិតលែងចង់បួស។ តាមពិតទៅដំណើរនេះ អាចរំជើបរំជួលដល់ការគ្រាស់ហៅមិនរឹងប៉ឹងដែរ។

ដោយយើងមិនដែលបានរស់នៅក្នុងមជ្ឈដ្ឋានមានយសសក្តិ សេលីន និងខ្ញុំ យើងបានចូលក្នុងចំណោមអភិជន ដែលស្ទើរតែជាបូជនីយេសរ។ គ្មានអ្វីគួរឲ្យភ្លឹកសោះឡើយ ងារសក្តិទាំងនោះ ហាក់ដូចជាផ្សែងសម្រាប់យើង... បើមើលពីចម្ងាយ ហាក់ដូចជាគួរឲ្យស្រវាំងភ្នែកបន្តិច តែពេលចូលទៅជិត អ្វីៗដែលចាំភ្នែក (ភ្លឺផ្លេក) មិនមែនជាមាសទេ ហើយខ្ញុំយល់សម្ដីក្នុងសៀវភៅ

Imitation ថា៖ "កុំរត់តាមស្រមោលអ្នកមានឈ្មោះល្បី កុំចង់ចងសម្ព័ន្ធភាព ឬមិត្តភាពពិសេសជាមួយនរណាម្នាក់"។

ខ្ញុំយល់ថា ភាពឧត្តុង្គឧត្តមពិតៗ ស្ថិតនៅលើព្រលឹង មិនមែននៅលើការដាក់ឈ្មោះទេ ដូចព្យាការីអេសាយបានថ្លែងថា៖ *"ព្រះអម្ចាស់ នឹងដាក់ឈ្មោះមួយទៀត ដល់អ្នកដែលព្រះអង្គជ្រើសរើស"* ហើយសន្តយ៉ូហានក៏ប្រសាសន៍ដែរ៖ *"សូមឲ្យអ្នកបានជោគជ័យ ទទួលបានថ្មសមួយដែលឆ្លាក់ឈ្មោះថ្មី ដែលគ្មាននរណាស្គាល់ក្រៅពីអ្នកទទួល"* ។ មានតែនៅស្ថានបរមសុខទេ ទើបយើងដឹងពីឋានន្តរសក្តិយើង។ ដូច្នេះ ម្នាក់ៗនឹងទទួលបានការកោតសសើរ ដែលខ្លួនត្រូវទទួលពីព្រះជាម្ចាស់ ហើយអ្នកដែលផែនដីនឹងប្រាថ្នាជាអ្នកក្របំផុត អ្នកត្រូវគេបំភ្លេចចោល ដើម្បីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ អ្នកនោះនឹងជាជនទីមួយ ជាអ្នកខ្ពង់ខ្ពស់បំផុត និងជាអ្នកមានបំផុត។

បទពិសោធន៍ទីពីរ ដែលខ្ញុំទទួលបាន សំដៅទៅលើបូជាចារ្យ។ ដោយខ្ញុំមិនដែលបានរស់នៅក្នុងចំណោមពួកលោក ខ្ញុំមិនអាចយល់អំពីគោលដៅចម្បងនៃការកែទម្រង់របស់អារាមកាមែលទេ។ ខ្ញុំចូលចិត្តអធិដ្ឋានឲ្យអ្នកប្រព្រឹត្តអំពើបាប ប៉ុន្តែអធិដ្ឋានដល់អស់លោកបូជាចារ្យដែលខ្ញុំជឿថា មានព្រលឹងបរិសុទ្ធជាងកែវចរណៃនោះ គួរឲ្យឆ្ងល់ណាស់... ។

ឱ! ខ្ញុំយល់ដឹងអំពីការគ្រាស់ហៅរបស់ខ្ញុំនៅអ៊ីតាលី មិនបាច់ទៅរកឯណាឆ្ងាយពេកទេ ចំណេះដឹងដ៏មានប្រយោជន៍នេះ...។

ខ្ញុំបានរស់នៅជាមួយបូជាចារ្យដ៏បរិសុទ្ធជាច្រើនរូប ក្នុងរយៈពេលមួយខែ ហើយខ្ញុំបានឃើញថា មុខងារដ៏ខ្ពង់ខ្ពស់នេះលើកតម្កើងពួកលោកខ្ពស់ជាងទេវទូត តែពួកលោកនៅតែជាអ្នកទន់ខ្សោយ និងផុយស្រួយជានិច្ច... ប្រសិនបើបូជាចារ្យដ៏វិសុទ្ធដែលព្រះយេស៊ូបានហៅនៅក្នុងដំណឹងល្អថាជា *"អំបិលលើផែនដី"* បូជាចារ្យទាំងនោះបង្ហាញថា ក្នុងការដឹកនាំ ពួកលោកត្រូវការសេចក្តីអធិដ្ឋានចាំបាច់

ណាស់។ តើត្រូវនិយាយបែបណាទៅ ចំពោះអស់លោកដែលមិនសូវរវីរវល់នឹងមុខងាររបស់គាត់? ព្រះយេស៊ូមានព្រះបន្ទូលបន្ថែមទៀតថា៖ *"បើអំបិលបាត់បង់រសជាតិប្រៃ តើគេបានអ្វីបង់សម្ល"?* (...)

ដោយបានគយគន់សោភ័ណភាពទាំងអស់នោះ (នៅរ៉ូម) គំនិតជាច្រើនបានកើតឡើងក្នុងព្រលឹងខ្ញុំ។ ខ្ញុំហាក់យល់ជាស្រេច នូវឧត្តមភាពរបស់ព្រះជាម្ចាស់ និងអច្ឆរិយវត្ថុនៃស្ថានភាពបរមសុខ... ចំពោះខ្ញុំជីវិតជាអ្នកបួស គឺការរស់នៅដូចសព្វថ្ងៃ និងការគោរពវិន័យ ការបូជាតូចតាច ដោយមិនចេញឈ្មោះ។ ខ្ញុំយល់ថា ជាការស្រួលបំភ្លេចចោលគោលបំណងនៃការត្រាស់ហៅដ៏ខ្ពង់ខ្ពស់ ហើយខ្ញុំនិយាយប្រាប់ខ្លួនឯងថា "បន្តិចទៀត ពេលរងលំបាក ជាប់ឃុំនៅកាមែលខ្ញុំអាចមើលឃើញស្ថានភាពបរមសុខ ដែលមានផ្កាយរះតែមួយជ្រុងតូចប៉ុណ្ណោះ ខ្ញុំនឹងចងចាំនូវអ្វីដែលខ្ញុំមើលឃើញថ្ងៃនេះ។ គំនិតនេះនឹងផ្តល់ សេចក្តីក្លាហានឲ្យខ្ញុំៗនឹងភ្លេចផលប្រយោជន៍តិចតួចយ៉ាងងាយរបស់ខ្ញុំ ដោយបានឃើញឧត្តមភាព និងមហិទ្ធិឫទ្ធិរបស់ព្រះជាម្ចាស់មួយអង្គគត់ ដែលខ្ញុំចង់ស្រឡាញ់។ ខ្ញុំមិនល្ងីល្ងើទៅជាប់ជំពាក់នឹងចំបើងទេ ព្រោះឥឡូវនេះ "ចិត្តខ្ញុំបានឲ្យដឹងជាមុននូវរង្វាន់ដែលព្រះយេស៊ូបម្រុងទុកឲ្យអ្នកស្រឡាញ់ព្រះអង្គ"។ (...)

យើងទស្សនាអច្ឆរិយវត្ថុនៃទីក្រុងរ៉ូម ប្រាំមួយថ្ងៃមកហើយ ថ្ងៃទីប្រាំពីរ ខ្ញុំបានឃើញអច្ឆរិយវត្ថុ ធំជាងគេបំផុតគឺ "សម្តេចប៉ាប លេអុង ទី XIII"...។ (...)

ថ្ងៃអាទិត្យ ទី២០ ខែវិច្ឆិកា យើងចូលបុរី វ៉ាទីកង់ ក្នុងព្រះវិហារតូចរបស់សម្តេចប៉ាប។ នៅម៉ោងប្រាំបី យើងរំភើបជាខ្លាំង ពេលឃើញព្រះអង្គយាងចូលមកប្រារព្ធពិធីអភិបូជា... ក្រោយពីប្រទានពរដល់បូជនិយេសក៏ជាច្រើនរូប ដែលប្រជុំគ្នាជុំវិញព្រះអង្គ ទ្រង់ឡើងកាំជណ្តើរទីសក្ការៈ និងបង្ហាញនូវការស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំង ដែលសក្តិសមជាតំណាងនៃព្រះយេស៊ូ ព្រះអង្គជា *"បិតាដ៏វិសុទ្ធ"* យ៉ាងពិតប្រាកដ។ បេះដូងខ្ញុំលាន់រណ្តំយ៉ាងខ្លាំង ហើយខ្ញុំអធិដ្ឋាន

អស់អំពីដួងចិត្ត ក្នុងពេលដែលព្រះយេស៊ូយាងចុះមកចន្លោះព្រះហស្តសម្តេច ប៉ុន្តែ ខ្ញុំប្រកបដោយទំនុកចិត្ត។ ថ្ងៃនេះ មានព្រះបន្ទូលដំណឹងល្អថា៖ *"ហ្វូងចៀមទាំងឡាយ ចូរអ្នករាល់គ្នាកុំខ្លាច ព្រោះព្រះបិតាខ្ញុំបានសព្វព្រះហឫទ័យនឹងព្រះរាជាណាចក្ររបស់ព្រះអង្គដល់អ្នករាល់គ្នា"* ។ ទេខ្ញុំមិនខ្លាចទេ ខ្ញុំមានបំណងឲ្យអាណាចក្រកាមែល ក្លាយមកជារបស់ខ្ញុំ ក្នុងពេលឆាប់ៗនេះ។ កាលនោះ ខ្ញុំនឹកឃើញដល់ព្រះបន្ទូលព្រះយេស៊ូទៀតថា៖ *"ខ្ញុំត្រៀមព្រះរាជ្យរបស់ខ្ញុំទុកឲ្យអ្នករាល់គ្នា ដូចជាព្រះបិតាត្រៀមទុកឲ្យខ្ញុំដែរ"* ។ មានន័យថា ខ្ញុំនឹងរៀបចំឈើឆ្កាង និងទុកលំបាក បម្រុងទុកឲ្យអ្នករាល់គ្នាយ៉ាងនេះហើយ ទើបសក្តិសមនឹងទទួលព្រះរាជ្យនេះ ដែលអ្នករាល់គ្នានឹងស្រឡាញ់ និងចង់បានយ៉ាងខ្លាំង។ ដោយព្រះគ្រីស្តត្រូវតែរងទុក្ខលំបាកជាចាំបាច់ ដើម្បីឲ្យព្រះអង្គទទួលសិរីរុងរឿង ប្រសិនបើអ្នករាល់គ្នាចង់នៅក្បែរទ្រង់ ចូរអ្នករាល់គ្នាផឹកពែងជាមួយព្រះអង្គទៅ!... ពែងនោះ បិតាដ៏វិសុទ្ធបានយកមកឲ្យខ្ញុំផឹក ទឹកភ្នែកខ្ញុំបានហូរលាយជាមួយទឹកល្វីងនៃភេសជ្ជៈ។ បន្ទាប់ពីពិធីអភិបូជា សវនាការក៏ចាប់ផ្តើម។ សម្តេចសម្រួលព្រះកាយលើកៅអីភ្នាក់ដៃធំមួយ ជុំវិញព្រះអង្គមានកាឌីណាល់ (Cardinaux) ប្រធានក្រុមអភិបាល និងអភិបាលព្រះសហគមន៍ជាច្រើនរូប ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ទេ ព្រោះខ្ញុំរវល់តែសម្លឹងមើលទៅសម្តេច។ យើងនាំគ្នាដើរពីមុខដង្ហែរជាក្បួនបូជនីយេសក៏ម្នាក់ៗលុតជង្គង់តាមវេនរបស់ខ្លួន ថើបព្រះបាទ និងព្រះហស្តទទួលពរជ័យពីព្រះអង្គ អង្គរក្សពីរនាក់យកដៃប៉ះជាសញ្ញាឲ្យក្រោក។ មុននឹងចូលទៅលំនៅសម្តេច ខ្ញុំសម្រេចចិត្តថា ដាច់ខាតត្រូវតែនិយាយ ប៉ុន្តែ ខ្ញុំបាត់សេចក្តីក្លាហាន ដោយមើលទៅខាងស្តាំសម្តេច ឃើញលោកបូជាចារ្យ *"វេរ៉េនី"* ។ គេហៀបតែហាមយើងមិនឲ្យនិយាយជាមួយសម្តេចទៅហើយ ព្រោះសវនាការអូសបន្លាយវែងពេក។ ខ្ញុំងាកទៅរកសេលីន ចង់ដឹងអំពីគំនិតគាត់៖ *"និយាយទៅ!"* សេលីប្រាប់។ មួយស្របក់ក្រោយមក ខ្ញុំចូលទៅជិតព្រះបាទសម្តេច ថើបស្បែកជើងព្រះអង្គៗ លើកព្រះហស្តមករកខ្ញុំ ប៉ុន្តែខ្ញុំមិនបានថើបទេ ខ្ញុំក្តោប

ព្រះហស្ថក្នុងដៃខ្ញុំ មើលចំទៅព្រះភក្ត្រព្រះអង្គ ដោយទឹកភ្នែកជោគជាំ ខ្ញុំនិយាយខ្លាំងៗថា៖ *"សម្ដេចជាទីគោរពដ៏ជ្រាលជ្រៅ សូមប្រទានឲ្យខ្ញុំម្ចាស់សួររឿងធំមួយ!..."* ព្រះអង្គឱនព្រះភក្ត្រមកជិតក្បែរមុខខ្ញុំ ហាក់ដូចជាចង់ចូលជ្រៅទៅក្នុងវិញ្ញាណខ្ញុំ។ "សម្ដេចជាទីគោរព ដើម្បីជាកិត្តិយសដល់ព្រះមហាករុណាទិគុណ សូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំម្ចាស់បានចូលទៅនៅក្នុងអារាមកាមែល ក្នុងអាយុដប់ប្រាំឆ្នាំផង!..."។

ការរំជួលចិត្តបានមកអង្រួនសំឡេងខ្ញុំ ហើយខ្ញុំងាកទៅលោក រេវេរ៉ូនី ដែលក្រលេកមើលមកខ្ញុំដោយចម្ងល់ និងមិនសូវសប្បាយចិត្ត។ សម្ដេចប៉ាបមានព្រះបន្ទូលថា *"ខ្ញុំយល់មិនច្បាស់ទេ"* ប្រសិនបើព្រះជាម្ចាស់បានសព្វព្រះហឫទ័យ ប្រហែលជាលោក រេវេរ៉ូនី អនុញ្ញាតតាមសំណូមពរខ្ញុំរួចទៅហើយ តែនេះជាឈើឆ្កាង មិនមែនជាការល្បួងលោមទេ។ ពេលនោះ លោកអភិបាលទូលព្រះអង្គ *"ក្រាបទូលព្រះអង្គ គឺជាក្មេងស្រីដែលចង់ចូលអារាមកាមែល ក្នុងអាយុ ១៥ឆ្នាំ។ ពេលនេះ ថ្នាក់លើកំពុងតែពិនិត្យ"* ។ ព្រះអង្គទតមើលមុខខ្ញុំ ហើយមានព្រះបន្ទូលថា៖ "បើអញ្ចឹងកូនធ្វើតាមថ្នាក់លើប្រាប់ទៅបានហើយ"។ ខ្ញុំច្រត់លើជង្គង់ព្រះអង្គ ខិតខំជាលើកចុងក្រោយបង្អស់ និយាយដោយសំឡេងអង្វរក៖ "ព្រះអង្គអើយ! បើទ្រង់ថាបាន ទាំងអស់គ្នាមុខជាសម្រេចតាមទ្រង់ពុំខានឡើយ!..."។ សម្ដេចសម្លឹងមើលមកមុខខ្ញុំ ហើយមានព្រះរាជឧង្ការសង្កត់លើពាក្យមួយម៉ាត់ៗថា៖ *"ទៅ...ទៅ... កូនទៅបាន បើជាបំណងរបស់ព្រះជាម្ចាស់"* ។ សំឡេងរបស់ព្រះអង្គ ហាក់ដូចជាជ្រាលជ្រៅ និងប្រាកដប្រជាណាស់។ ហាក់ដូចជាលាន់ឮក្នុងត្រចៀកខ្ញុំ រហូតដល់សព្វថ្ងៃ។

សប្បុរសធម៌របស់សម្ដេច បានលើកទឹកចិត្តខ្ញុំៗ ចង់និយាយបន្តទៅទៀត ប៉ុន្តែ រាជង្គរក្ស មកប៉ះខ្ញុំយ៉ាងគួរសម ដើម្បីឲ្យខ្ញុំក្រោក ដោយយល់ថាមិនគ្រប់គ្រាន់ ពួកគេទាញដៃខ្ញុំ ហើយសម្ដេច រេវេរ៉ូនី ជួយលើកខ្ញុំ ព្រោះដៃខ្ញុំនៅតែសំពះលើជង្គង់សម្ដេចប៉ាបលេអុង ទី XIII ហើយគេប្រើកម្លាំងទាញខ្ញុំចេញ។ (...)

ពេលចេញពីសវនាការ ឃើញទឹកភ្នែកខ្ញុំហូរ ពុកពិបាកចិត្តណាស់ គាត់ខិតខំលួងលោមខ្ញុំ តែមិនសម្រេច។ ខ្ញុំបានស្ងប់ចិត្តហើយ ខ្ញុំបានធ្វើគ្រប់យ៉ាងដែលអាចធ្វើទៅបាន ដើម្បីឆ្លើយតបនឹងសំណូមពររបស់ព្រះជាម្ចាស់។ សេចក្ដីស្ងប់នេះ ស្ថិតក្នុងទីជម្រៅ ហើយភាពល្វីងជូរចត់ ស្ថិតនៅក្នុងវិញ្ញាណខ្ញុំ ព្រោះព្រះយេស៊ូមិនមានព្រះបន្ទូល។ ហាក់ដូចជាគ្មានវត្តមានរបស់ព្រះអង្គទេ...។ ថ្ងៃនោះព្រះអាទិត្យមិនហ៊ានបញ្ចេញរស្មីឡើយ មេឃពណ៌ខៀវនៅ អ៊ីតាលី ផ្ទុកដោយពពកពណ៌ប្រផេះស្រអាប់ យំឥតឈប់ជាមួយខ្ញុំដែរ។ ឱ! ចប់ហើយ ទស្សនកិច្ចលែងទាក់ទាញខ្ញុំទៀតហើយ ព្រោះមិនបានទៅដល់ទីកំណត់។ ប៉ុន្តែ ព្រះបន្ទូលចុងក្រោយរបស់សម្ដេច គួរតែលួងលោមខ្ញុំបានខ្លះ។ តើមិនមែនជាទំនាយពិតប្រាកដទេឬ? ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ អ្វីៗដែលព្រះជាម្ចាស់តម្រូវមកត្រូវតែបានសម្រេច។ ព្រះអង្គមិនបណ្ដោយឲ្យសត្វលោកប្រព្រឹត្តតាមអំពើចិត្តទេ ប៉ុន្តែបំណងព្រះអង្គផ្ទាល់... យូរមកហើយ ខ្ញុំបានប្រគល់ខ្លួនថ្វាយព្រះកុមារយេស៊ូ ដើម្បីជាល្បែងលេងរបស់ព្រះអង្គ។ ខ្ញុំបានទូលព្រះអង្គថា មិនបាច់ទុកខ្ញុំជាល្បែងមានតម្លៃ ដែលក្មេងៗរក្សាទុកមើល មិនហ៊ានប៉ះពាល់ សូមទុកខ្ញុំជាកូនបាល់ឥតតម្លៃ ដែលអាចបោះចោល ទាត់នឹងជើង ចាក់ទម្លុះ បោះចោល កន្លៀតណាមួយ ឬយកមកឱបនឹងព្រះឱរា បើព្រះអង្គគាប់ព្រះហឫទ័យនិយាយឲ្យពិតទៅខ្ញុំមានបំណងឲ្យទ្រង់កំសាន្តសប្បាយរីករាយទៅតាមមាយាការរបស់ក្មេង... ព្រះអង្គព្រមតាមសេចក្ដីអធិដ្ឋានរបស់ខ្ញុំហើយ... ។

នៅរ៉ូម ព្រះយេស៊ូបានចោះបំបែកល្បែងលេងរបស់ព្រះអង្គ។ ទ្រង់ចង់ដឹងអ្វីៗ ដែលនៅខាងក្នុង កាលបើឃើញហើយ ព្រះអង្គត្រេកអរណាស់។ ព្រះអង្គទំលាយកូនបាល់ចុះ ហើយផ្ទុំលក់ទៅ... តើព្រះអង្គធ្វើអ្វីពេលផ្ទុំ ហើយកូនបាល់ទៅជាយ៉ាងណា? ព្រះយេស៊ូសុបិនឃើញទ្រង់កំពុងលេងកូនបាល់ទុកចោល ហើយរើសមកលេងទៀត បន្ទាប់ពីបោះវាទៅឆ្ងាយ ព្រះអង្គរើសបាល់មកឱបជាប់ព្រះឱរា មិនឲ្យវារមៀលទៅឆ្ងាយពីព្រះហស្ថឡើយ។

អ្នកម៉ែយល់ហើយមែនទេ តើកូនបាល់នៅលើដីក្រៀមក្រំយ៉ាងណា... ប៉ុន្តែខ្ញុំនៅមានសង្ឃឹមជានិច្ច។ (...)

បេះដូងខ្ញុំខ្ទេចខ្ទាំ ខណៈដែលខ្ញុំទៅធ្វើអភិបូជាពេលអាធ្រាត ខ្ញុំប៉ងប្រាថ្នានឹងចូលរួម ខាងក្រោយចម្រឹងនៃអារាមកាមែល!... គឺជាការសាកល្បងមួយយ៉ាងធំ សម្រាប់ជំនឿខ្ញុំ ប៉ុន្តែព្រះជាម្ចាស់ដែលមានព្រះហឫទ័យគាំពារ ទោះជានៅពេលផ្ទុំក៏ដោយ ទ្រង់បានឲ្យខ្ញុំយល់ថា ជំនឿដូចជាគ្រាប់ពូជដ៏ល្អិត ព្រះអង្គអាចធ្វើការអស្ចារ្យប្តូរទីតាំងភ្នំបាន ដើម្បីធ្វើឲ្យជំនឿដ៏តូចនេះរឹងមាំ។ ចំពោះអ្នកស្និទ្ធស្នាលនឹងព្រះអង្គ ចំពោះព្រះមាតា ព្រះអង្គមិនធ្វើការអស្ចារ្យ មុនពេលបញ្ជាក់ជំនឿរបស់ពួកគាត់ឡើយ។ ទោះជានាងម៉ាថា និងនាងម៉ារី ប្រាប់ឲ្យគេទូលដំណឹងអំពីជំងឺរបស់ឡាសាក៏ដោយ តើព្រះអង្គមិនទុកគាត់ចោលរហូតដល់ស្លាប់ទេឬ? ថ្ងៃជប់លៀងនៅកាណា ព្រះមាតាសុំឲ្យព្រះយេស៊ូជួយសង្គ្រោះម្ចាស់ផ្ទះ ប៉ុន្តែពេលនោះព្រះអង្គតបថា វេលានោះមិនទាន់ដល់ទេ។ ប៉ុន្តែក្រោយពីរងទុក្ខលំបាក គឺការទទួលរង្វាន់ ទឹកក្លាយទៅជាស្រាទំពាំងបាយជូរ... ឡាសារស់ឡើងវិញ!... ព្រះយេស៊ូបំពេញសកម្មភាពជាមួយថេរេសា ដូចរបៀបនេះដែរ ក្រោយពីការសាកល្បងយ៉ាងយូរ ព្រះអង្គបំពេញតាមបំណងរបស់នាងទាំងអស់...។ (...)

ថ្ងៃទីមួយនៃឆ្នាំ១៨៨៨ ព្រះយេស៊ូប្រទានអំណោយឈើឆ្កាងមកខ្ញុំម្តងទៀត ប៉ុន្តែម្តងនេះ ខ្ញុំត្រូវលីម្នាក់ឯង ព្រោះការឈឺចាប់ស្មើនឹងការមិនយល់គ្នា... សំបុត្រប៉ូលីនប្រាប់ថា ចម្លើយរបស់លោកអភិបាលបានមកដល់កាលពីថ្ងៃទី២៨ ជាថ្ងៃបុណ្យសន្តកុមារ (Saints Innocents) ប៉ុន្តែប៉ូលីនមិនបានឲ្យដឹងអំពីសេចក្តីសំបុត្រទេ គេសម្រេចឲ្យខ្ញុំចូលក្រោយបុណ្យរដូវសែសិបថ្ងៃឯណោះ។ ខ្ញុំមិនអាចទប់ទឹកភ្នែក ចំពោះការកំណត់ពេលដ៏វែងអន្លាយបែបនេះឡើយ។ នេះជាការសាកល្បងដ៏ពិសេសសម្រាប់ខ្ញុំ។ កាលនោះ ខ្ញុំបានកាត់ផ្តាច់ទំនាក់ទំនងជាមួយពិភពលោកនេះទៅហើយៗពេលនេះ សំពៅនៃព្រះជាម្ចាស់មិនព្រមឲ្យ

កូនព្រាបតូចនេះចុះទុំទេ ខ្ញុំចង់ជឿណាស់ថា ខ្ញុំហាក់ដូចជាបាត់បង់វិចារណញ្ញាណ ដោយមិនព្រមទទួលត្រេកអរនឹងទទួលការនិរទេសរយៈពេលបីខែ ប៉ុន្តែខ្ញុំក៏ជឿផងដែរថា ការសាកល្បងដែលហាក់ដូចគ្មាននេះ ឧត្តុង្គឧត្តម្ភណាស់ ដែលធ្វើឲ្យខ្ញុំធំធាត់រីកចម្រើនក្នុងការបោះបង់ចោល និងគុណធម៌ផ្សេងៗទៀត។

តើបីខែ ដែលបរិបូរណ៍ដោយការប្រោសប្រណីចំពោះខ្ញុំ ប្រព្រឹត្តទៅយ៉ាងណា?... មុនដំបូង ខ្ញុំមានគំនិតមួយ គឺលែងខ្វល់ខ្វាយអំពីជីវភាពប្រិតប្រៀបតាមក្បួនវិន័យដូចមុនទៀតហើយ ប៉ុន្តែបន្តិចក្រោយមក ខ្ញុំយល់អំពីតម្លៃនៃពេលវេលា ខ្ញុំសម្រេចថា រស់នៅរបៀបតឹងរ៉ឹងបំផុត និងពិន័យខ្លួនឯង។ ខ្ញុំនិយាយថា ពិន័យខ្លួនឯងមិនមែនមានន័យថា ខ្ញុំធ្វើបាបខ្លួន ដើម្បីលាងជម្រះបាបទេ ព្រោះខ្ញុំមិនដែលធ្វើការទារុណកម្មលើខ្លួនឯងណាមួយឡើយ។ មិនដូចអ្នកខ្លះ ធ្វើបាបខ្លួនឯងតាំងពីក្មេង ខ្ញុំមិនហ៊ានទេ ព្រោះខ្ញុំជាមនុស្សកំសាក ផ្ទុយទៅវិញ ខ្ញុំតែងតែបណ្តោយខ្លួនឲ្យគេបំបៅថ្នាក់ថ្នម ដូចនៅក្នុងទ្រាប់សំឡីបញ្ចុកចំណីដូចកូនបក្សី (...) ... ការដាក់ពិន័យខ្លួនឯងរបស់ខ្ញុំ នៅពេលនេះ គឺកាច់បំបាក់នូវបំណងដែលចង់តែបញ្ជាគេ លែងតមាត់ជាមួយគេ ជួយធ្វើការងារគេដោយគ្មានទារកម្រៃ ពេលអង្គុយលេង ផ្អែកខ្នងទៅនឹងកៅអី។ល។ និង។ល។ ដោយអនុវត្តកែប្រែទម្លាប់តូចតាចនេះ ខ្ញុំត្រៀមខ្លួនដើម្បីក្លាយទៅជាគូដណ្តឹងព្រះយេស៊ូ។ ខ្ញុំមិនអាចជម្រាបជូនថា ការរង់ចាំនេះបានទុកអនុស្សាវរីយ៍ល្អៗយ៉ាងណាឡើយ។ បីខែបានរសាត់ទៅយ៉ាងលឿន ទីបំផុត វេលាដែលខ្ញុំរង់ចាំដ៏អន្ទះសារនោះបានមកដល់។

# ឆ្នាំដំបូងនៅកាមែល

## ( ១៨៨៨ - ១៨៩០ )

ដោយប្រទះនឹងបុណ្យរដូវសែសិបថ្ងៃ គេក៏បានលើកថ្ងៃចូលរស់នៅក្នុងអារាមរបស់ខ្ញុំមកថ្ងៃទី៩ មេសាវិញ។ (...) ថ្ងៃនោះអារាមកាមែល ប្រារព្ធពិធីបុណ្យទេវទូត ជូនដំណឹងដល់នាងម៉ារី។ ខ្ញុំទន្ទេញក្នុងចិត្តថា៖ *"គឺជារៀងរហូត ខ្ញុំនៅទីនេះជារៀងរហូត!..."* ដោយសេចក្ដីរីករាយក្នុងជម្រៅចិត្ត។

សុភមង្គលនេះ មិនមែនកើតឡើងក្នុងរយៈពេលខ្លី ងាយបាត់បង់ទៅវិញទេ មិនត្រូវឲ្យវាហោះហើរចេញទៅដោយទុកការខកចិត្តនៅថ្ងៃដំបូងទេ។ នៅកាមែល ព្រះជាម្ចាស់ប្រោសប្រទានមិនឲ្យខ្ញុំខកចិត្តសោះឡើយ។ ខ្ញុំជួបជីវិតជាអ្នកបួស តាមដែលខ្ញុំបានគិតទុកមកពីមុន គ្មានការបូជាណាមួយដែលខ្ញុំមិនយល់ ប៉ុន្តែដូចអ្នកម៉ែជ្រាបស្រាប់ ជំហានដំបូងរបស់ខ្ញុំ ជួបបន្លាច្រើនជាងជួបផ្កាកុលាប! ...

ការឈឺចាប់ បានហុចដៃមកទទួលខ្ញុំ ហើយខ្ញុំទម្លាក់ខ្លួនចូលដោយសេចក្ដីស្រឡាញ់... បំណងខ្ញុំដែលមកទីនេះ ខ្ញុំបានទូលទៀបព្រះបាទព្រះយេស៊ូ នំតង្វាយរួចស្រេចហើយថា៖ *"ខ្ញុំម្ចាស់មកដើម្បីសង្គ្រោះព្រលឹងសំខាន់ គឺដើម្បីអធិដ្ឋានជូនដល់បូជាចារ្យទាំងអស់"*។ គេត្រូវប្រើមធ្យោបាយ ដើម្បីឈានទៅដល់គោលដៅ។ ព្រះយេស៊ូប្រទានឲ្យខ្ញុំយល់ថា ព្រះអង្គមានព្រះបំណងប្រទានព្រលឹងនោះដល់ខ្ញុំ តាមរយៈឈើឆ្កាង ហើយការទាក់ទាញចំពោះការឈឺចាប់ រឹតតែមានទំហំ

ធំឡើងៗ កាលបើបន្ថែមការឈឺចាប់ទៀត។ ខ្ញុំប្រកាន់យកមាគ៌ានេះ រយៈពេលប្រាំឆ្នាំ ដោយគ្មាននរណាដឹងឡើយ ក្រៅពីខ្លួនខ្ញុំ។ ឱ! គួរឲ្យភ្ញាក់ផ្អើលម្លេះទេ ពេលអវសាននៃពិភពលោក កាលបើយើងអានប្រវត្តិនៃព្រលឹង... មុខជាមានអ្នកឆ្ងល់នឹងមាគ៌ាដែលខ្ញុំប្រកាន់យកនេះពុំខាន....។ (...)

ដូនជីទទួលខុសត្រូវយើង ជាសន្តីពិតប្រាកដ គំរូសម្រាប់ដូនជីទាំងឡាយ។ ខ្ញុំនៅជាមួយគាត់ពេញមួយថ្ងៃ ព្រោះគាត់បង្រៀនខ្ញុំធ្វើការ។ គាត់ចិត្តល្អជាមួយខ្ញុំ ឥតព្រំដែន ប៉ុន្តែខ្ញុំពុំសូវពូកែទេ... ទាល់តែស្និតស្នាលណាស់ ទើបដឹកនាំខ្ញុំបាន។ ដោយខ្ញុំគ្មានទម្លាប់និយាយអំពីព្រលឹងខ្លួនឯង ខ្ញុំមិនចេះនិយាយប្រាប់គេទេ។ ថ្ងៃមួយដូនជីចំណាស់ម្នាក់យល់ចិត្តខ្ញុំ គាត់សើចហើយនិយាយប្រាប់ខ្ញុំនៅពេលចេញលេង៖ *"កូនស្រី មើលទៅឯងហាក់ដូចជាគ្មានពាក្យនិយាយជាមួយថ្នាក់លើឯងទេ"* *"ហេតុអ្វីក៏អ្នកម៉ែមានប្រសាសន៍ដូច្នេះ"...* *"ព្រោះព្រលឹងឯងមិនស្មុគ្រស្មាញសោះ ប៉ុន្តែ កាលបើឯងគ្រប់លក្ខណ៍ ឯងកាន់តែមិនស្មុគ្រស្មាញថែមទៀត កាលបើគេចូលកាន់តែកៀកព្រះជាម្ចាស់ គេកាន់តែលែងភាពស្មុគ្រស្មាញ"*។ (...)

ខ្ញុំយល់អំពីអ្វីដែលហៅថា សិរីរុងរឿងពិតប្រាកដ។ ព្រះជាម្ចាស់បានបង្ហាញខ្ញុំថា សិរីរុងរឿងពិតប្រាកដ គឺ *"ឲ្យយើងមានប្រាថ្នាកុំឲ្យគេស្គាល់ និងគ្មានទាមទារអ្វីទុកសេចក្តីរីករាយផ្ទាល់ខ្លួន ជាការប្រមាថខ្លួនឯង"*.... ឱ! ខ្ញុំប្រាថ្នាចង់ឲ្យបានដូចព្រះយេស៊ូណាស់ *"ខ្ញុំចង់លាក់មុខឲ្យបាត់ កុំឲ្យគេស្គាល់នៅលើផែនដីនេះ"* ខ្ញុំចង់រងការឈឺចាប់ និងឲ្យគេបំភ្លេចចោល។ (...)

ខែឧសភា ឆ្នាំមុន ពុកពិការជើង កម្រើកលែងរួច ពួកយើងព្រួយបារម្ភណាស់ ប៉ុន្តែ ចរិតរឹងប៉ឹងរបស់គាត់ ឈ្នះលើជំងឺ ពួកយើងក៏បានធូរចិត្ត។ កាលធ្វើដំណើរទៅរ៉ូម យើងសង្កេតឃើញថា គាត់ឆាប់អស់កម្លាំង មិនសូវស្រស់ស្រាយដូចធម្មតា ខ្ញុំបានសម្គាល់ជាពិសេសថា ពុកបានឈានទៅដល់កម្រិត

គ្រប់លក្ខណ៍ ដូចសន្តៈ ហ្វ្រង់ស័រ នៅសាលស៍ គាត់នៅតែម្ចាស់ការលើភាពរហ័សរហួនពីកំណើត ហើយក្លាយទៅជាមនុស្សស្លូតបូតជាងគេលើពិភពលោក... វត្ថុនានាលើផែនដីនេះ គាត់លែងយកភ្នែកមើលហើយ គាត់លែងទើសចិត្តចំពោះជីវិតនេះទៀតហើយ ទីបំផុតព្រះជាម្ចាស់លួងលោមរំសាយចិត្តគាត់។ រាល់ថ្ងៃគាត់ទៅលេងព្រះវិហារ គោរពព្រះកាយព្រះគ្រីស្ត ទឹកភ្នែកដក់ពេញរង្វង់ភ្នែក ទឹកមុខបង្ហាញនូវសុភមង្គលពិតប្រាកដនៃស្ថានបរមសុខ... កាលដែលលេអូនីចេញពីអារាម Visitation គាត់គ្មានកើតទុក្ខ គ្មានបន្ទោស ព្រះជាម្ចាស់ដែលមិនបានបំពេញតាមសេចក្តីអធិដ្ឋាន ដែលគាត់អង្វរសុំឲ្យកូនស្រីសម្លាញ់ បានទទួលការត្រាស់ហៅ គាត់ថែមទាំងទៅទទួលនាងដោយចិត្តត្រេកអរទៀតផង...។

ពុកទទួលការចាកចេញពីផ្ទះនៃម្ចាស់ក្សត្រីយ៍តូចរបស់គាត់ ដោយជំនឿជឿជាក់ គាត់និយាយប្រាប់មិត្តភក្តិនៅអាឡង់សុងថា៖ *"សំឡាញ់ទាំងអស់គ្នាថេរេសាកូនស្រីខ្ញុំ ចូលទៅអារាមកាមែលម្យ៉ាលមិញហើយ! មានតែព្រះជាម្ចាស់ទេ ដែលអាចទាមទារការបូជាបែបនេះ កុំបារម្ភអី ខ្ញុំត្រេកអរខ្លាំងណាស់"*។

ដល់ពេលអ្នកបម្រើមានភក្តីភាពបែបនេះ គាត់ទទួលរង្វាន់នៃការងារ គាត់ហើយ គាត់ជាអ្នកសុចរិត ប្រាក់បៀវត្សរ៍គាត់ស្មើនឹងបៀវត្សរ៍ដែលព្រះជាម្ចាស់ប្រទានដល់ព្រះបុត្រាមួយអង្គគត់របស់ទ្រង់... ពុកទើបតែថ្វាយដង្វាយមួយដល់ព្រះជាម្ចាស់ គាត់គឺជាដង្វាយដែលគេជ្រើសរើស ដើម្បីដុតបូជានៅទីនោះជាមួយកូនចៀមឥតមន្ទិល។ អ្នកម៉ែស្គាល់ ហើយភាពល្វីងជូរចត់នៃខែមិថុនាជាពិសេសថ្ងៃទី២៤ ឆ្នាំ១៨៨៨។ អនុស្សាវរីយ៍ទាំងនោះ បានចារឹកក្នុងជម្រៅចិត្តពួកយើង ដែលគួរតែសរសេររំឭកឡើងវិញ... អ្នកម៉ែ! កាលនោះ ពួកយើងឈឺចាប់ណាស់... ហើយនោះ គ្រាន់តែជាការចាប់ផ្តើមនៃទុក្ខលំបាកប៉ុណ្ណោះ...។ (...)

ដូចខ្ញុំបានជម្រាបរួចមកហើយ ថ្ងៃទី១០ ខែមករា ជាថ្ងៃជោគជ័យរបស់ពុក


1877.

ខ្ញុំប្រដូចទៅនឹងការយាងចូលទីក្រុង យេរូសាឡឹម របស់ព្រះយេស៊ូ ថ្ងៃអាទិត្យចុងក្រោយនៃរដូវត្រណម។ ដូចព្រះយេស៊ូជាម្ចាស់នៃយើងដែរ សិរីរុងរឿងមួយថ្ងៃទុក្ខលំបាក ការឈឺចាប់ តាមពីក្រោយជាបន្តបន្ទាប់។ ទុក្ខលំបាកនេះ មិនមែនសម្រាប់តែព្រះអង្គទេ ការឈឺចាប់របស់ព្រះយេស៊ូ ដូចដាវចាក់ទម្លុះបេះដូងរបស់ព្រះមាតាដូច្នោះដែរ។ យើងមានការឈឺចាប់ ស្តាយស្រណោះចំពោះអ្នកដែលយើងស្រឡាញ់បំផុតលើផែនដីនេះ...។ ខ្ញុំនឹកឃើញកាលពីខែមិថុនា ឆ្នាំ១៨៨៨ ពេលដែលយើងរងទុក្ខលំបាកដំបូង... ខ្ញុំបាននិយាយថា៖ *"ខ្ញុំឈឺចាប់ណាស់ ប៉ុន្តែខ្ញុំគិតថា ខ្ញុំអាចទ្រាំនឹងការលំបាកធំៗបានទៀត"* ។ កាលនោះ ខ្ញុំមិនបានគិតដល់ទុក្ខសោកទាំងនេះទេ... ខ្ញុំមិនដឹងថា ថ្ងៃទី១២ ខែកុម្ភៈ ក្រោយពីបួសបានមួយខែ ពុកជាទីស្រឡាញ់របស់យើងពិសារទឹកល្វីងជាងគេ និងអាមាស់ជាងគេឡើយ...។

ឱ! ថ្ងៃនោះ ខ្ញុំមិនបានថា ខ្ញុំអាចឈឺចាប់ជាងនេះទៀតបានទេ!... សម្តីមិនអាចបញ្ជាក់អំពីការតក់ស្លុតរបស់យើងឡើយ។ ថ្ងៃណាមួយនៅស្ថានបរមសុខយើងនឹងជជែកគ្នាអំពីទុក្ខលំបាកដ៏មានជោគជ័យរបស់យើង យើងរីករាយដោយទទួលការឈឺចាប់នោះហើយមែនទេ? បីឆ្នាំនៃការរងទុក្ខជាមណសាក្សីរបស់ពុក ហាក់ដូចជាគួរឲ្យស្រឡាញ់សម្រាប់ខ្ញុំ និងថ្លៃថ្លាបំផុតសម្រាប់ជីវិតយើង។ ខ្ញុំមិនព្រមដូចជាមួយការលង់ស្មារតី និងការបង្ហាញឲ្យដឹងរបស់សន្តបុគ្គលទេ។ ចិត្តពេញព្រៀបទៅដោយការដឹងគុណ បើគិតទៅដល់កំណាប់ដែលមិនអាចកាត់ថ្លៃបាននេះ ដែលធ្វើឲ្យទេវទូតនៅរាជវាំងនាស្ថានបរមសុខ ច្រណែនពុំខាន...។

បំណង់នៃការទទួលរងទុក្ខលំបាក បានបំពេញហើយ ប៉ុន្តែ ខ្ញុំនៅតែចង់បានទៀត ដូច្នេះព្រលឹងខ្ញុំចែករំលែកទុក្ខសោកនៃចិត្តខ្ញុំ។ ភាពសោះកក្រោះជាអាហារប្រចាំថ្ងៃរបស់ខ្ញុំ គ្មានការលួងលោម តែខ្ញុំជាមនុស្សរីករាយជាងគេព្រោះបំណងប្រាថ្នាទាំងអស់បានសម្រេច! ... (...)

វេលាភ្ជាប់ពាក្យបានកន្លងទៅហើយ... ហាក់ដូចជាយូរណាស់! នៅចុងឆ្នាំ ដូនជីប្រធានប្រាប់ខ្ញុំថា កុំអាលសួរពីរឿងបួសអី លោកអភិបាលមុខជាមិនទទួលពាក្យសុំរបស់ខ្ញុំទេ ត្រូវរង់ចាំប្រាំបីខែទៀត...។ មុនដំបូង ខ្ញុំពិបាកនឹងទទួលការលះបង់នេះណាស់ ប៉ុន្តែ ក្រោយនោះបន្តិច ខ្ញុំសញ្ជឹងគិតដល់ *"មូលដ្ឋានគ្រឹះនៃជីវិតផ្នែកវិញ្ញាណ"* របស់បូជាចារ្យម្នាក់។ ថ្ងៃមួយក្នុងពេលស្ញឹងស្ញាធ ខ្ញុំយល់ថា ចំណង់ចង់បួសខ្លាំងហួសរបស់ខ្ញុំលាយឡំជាមួយ និងការស្រឡាញ់ខ្លួនឯងជ្រុល។ ដោយខ្ញុំបានប្រគល់ខ្លួនថ្វាយព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គរីករាយ ដើម្បីលួងលោមទ្រង់ ខ្ញុំមិនត្រូវបង្ខំ តាមតែបំណងខ្ញុំទេ ត្រូវប្រតិបត្តិតាមបំណងព្រះអង្គវិញ។ លើសពីនេះ ខ្ញុំយល់ទៀតថា កូនក្រមុំត្រូវតែតុបតែងខ្លួន នៅថ្ងៃអាពាហ៍ពិពាហ៍ រីឯខ្ញុំវិញ ខ្ញុំមិនដែលបានធ្វើអ្វីសោះ ទើបខ្ញុំទូលទៅព្រះយេស៊ូថា៖ ឱ! ព្រះអង្គអើយ ខ្ញុំម្ចាស់មិនសូមព្រះអង្គប្រទានតាមសំណូមពររបស់ខ្ញុំម្ចាស់ទេ ខ្ញុំម្ចាស់នឹងរង់ចាំតាមបំណងរបស់ព្រះអង្គ ខ្ញុំម្ចាស់គ្រាន់តែមិនចង់ឲ្យការរួបរួមនេះ ត្រូវលើកពេលទៅថ្ងៃក្រោយ ដោយសារកំហុសរបស់ខ្ញុំម្ចាស់ឡើយ ដូច្នេះហើយខ្ញុំម្ចាស់នឹងខិតខំដេរសំពត់ដ៏ស្រស់ស្អាតមួយ រំលេចដោយត្បូងចំរុះពណ៌ កាលដែលព្រះអង្គគាប់ព្រះហឫទ័យហើយ ខ្ញុំម្ចាស់ជឿថា គ្មានសត្វលោកណាហ៊ានឃាត់ព្រះអង្គ មិនឲ្យយាងចុះមកទទួលខ្ញុំម្ចាស់ឡើយ។ ឱ! ព្រះអង្គជាទីស្រឡាញ់អើយ!...។ (...)

ជំនាន់នោះ ខ្ញុំចូលចិត្តតែវត្ថុអាក្រក់មើល ពិបាកប្រើ ដូច្នោះហើយខ្ញុំត្រេកអរនៅពេលគេយកក្អមទឹកល្អប្រណិតតូចមួយចេញពីបន្ទប់ យើងប្តូរជាមួយក្អមធំឆែបមាត់។ ខ្ញុំខិតខំទប់ចិត្តស្ដាយ តែមិនស្រួលប៉ុន្មានទេ ពិសេសជាមួយអ្នកគ្រូយើង ដែលខ្ញុំមិនចង់លាក់លៀម។ នេះជាជ័យជម្នះទីមួយរបស់ខ្ញុំ គ្មានអ្វីជាដុំកំភួនឡើយ តែខ្ញុំខំទប់ចិត្តណាស់។ ជើងតូចមួយ ដាក់ក្រោយបង្អួច បានបែក អ្នកគ្រូស្មានថាខ្ញុំជាអ្នកធ្វេសប្រហែស ទុកចោលផ្ដេសផ្ដាស់ គាត់ចង្អុលខ្ញុំហើយមានប្រសាសន៍ថា លើកក្រោយត្រូវប្រយ័ត្នប្រយែងផង។ ខ្ញុំឱនថើបដី

ដោយឥតចេញស្តី ហើយសន្យាថាថ្ងៃក្រោយ ត្រូវមានសណ្តាប់ធ្នាប់ជាងនេះ។ ដោយខ្ញុំមានគុណធម៌តិច ការអនុវត្តសីលធម៌តិចតួចបែបនេះ ក៏ត្រូវខិតខំដែរ ហើយខ្ញុំត្រូវគិតទៅដល់ការវិនិច្ឆ័យចុងក្រោយ មុខជាដឹងការពិតពុំខាន។ ដោយខ្ញុំមិនដែលសុំទោស គ្មាននរណាដឹងឡើយ ផ្ទុយទៅវិញ ភាពមិនគ្រប់លក្ខណ៍លេចចេញមកភ្លាមៗ...។

ដោយពិបាកអនុវត្តគុណធម៌ធំៗ ខ្ញុំអនុវត្តគុណធម៌តូចៗ ដូច្នេះ ខ្ញុំចូលចិត្តបត់អាវរងាដែលគេភ្លេច និងជួយធ្វើការគ្រប់ជំពូកដែលខ្ញុំអាចធ្វើបាន។ ខ្ញុំចូលចិត្តលត់ដំខ្លួន ប៉ុន្តែខ្ញុំមិនអាចធ្វើកើត។ ការលត់ដំ (ពិន័យបង្ខំខ្លួន) តែមួយគត់លើលោកនេះ គឺមិនផ្អែកខ្នងទៅលើកៅអីពេលខ្ញុំអង្គុយ ប៉ុន្តែគ្រូពេទ្យបានហាមព្រោះខ្នងខ្ញុំចង់កោង។ គួរឲ្យស្តាយ! (...)

ក្រោយពីទទួលសម្លៀកបំពាក់ (ជាអ្នកបួស) រោងបាយក៏ជាកន្លែងដែលផ្តល់ឱកាសឲ្យខ្ញុំទុកការស្រឡាញ់ខ្លួនឯងមួយកន្លែងដែរ គឺទុកក្រោមបាតជើង... ជាការពិតខ្ញុំបានទទួលការល្បួងលោម ដោយបានទៅធ្វើការជាមួយអ្នកម៉ែ ហើយខ្ញុំអាចមើលឃើញគុណធម៌របស់អ្នកយ៉ាងច្បាស់ ក៏ប៉ុន្តែ ការនៅជិតគ្នានេះ ជាការឈឺចាប់មួយ ខ្ញុំដឹងថា លែងដូចមុនទៀតហើយ កាលមុនយើងអាចនិយាយគ្នាតាមចិត្ត ឥឡូវនេះត្រូវគោរពវិន័យ ខ្ញុំមិនអាចបើកចិត្តជម្រាបអ្នកបានទេ ព្រោះខ្ញុំលែងនៅក្រោមដំបូលផ្ទះពុកទៀតហើយ ខ្ញុំនៅក្នុងអារាមកាមែល! ...

ព្រះមាតាបានជួយខ្ញុំរៀបចំសំពត់នៃព្រលឹងខ្ញុំ ពេលដែលរួចរាល់ហើយឧបសគ្គទាំងឡាយនឹងរលាយបាត់ទៅដោយខ្លួនឯង។ លោកអភិបាលបានផ្ញើសេចក្តីអនុញ្ញាតតាមការស្នើសុំរបស់ខ្ញុំ ព្រះសហគមន៍យល់ព្រមទទួល ហើយការបួសរបស់ខ្ញុំ ត្រូវកំណត់នៅថ្ងៃទី៨ កញ្ញា...

# ពីថ្ងៃបួស រហូតដល់ការថ្វាយដល់សេចក្ដីស្រឡាញ់
## (១៨៩០ - ១៨៩៥)

មុននឹងរៀបរាប់អំពីទុក្ខលំបាកនេះ ខ្ញុំគួរតែជម្រាបជូនអំពីសំណាក់ធម៌មុនបួស គឺខ្ញុំស្ថិតក្នុងភាពសោះកក្រោះ ដូចគេបំបរបង់ចោល។ ព្រះយេស៊ូផ្ទំលក់ក្នុងកូនទូកខ្ញុំជានិច្ច។ ព្រលឹងទាំងឡាយកម្រនឹងទុកឲ្យព្រះអង្គផ្ទំយ៉ាងស្ងប់ស្ងាត់យ៉ាងនេះណាស់ ព្រះអង្គហត់នឿយហើយ ដោយររវល់តែតម្រូវចិត្តគេ ទ្រង់រួសរាន់ឆ្លៀតពេលសម្រាក។ ប្រហែលជាទ្រង់មិនតើន មុនសំណាក់ធម៌ជារៀងរហូតរបស់ខ្ញុំឡើយ ប៉ុន្តែខ្ញុំមិនពិបាកចិត្តទេ ផ្ទុយទៅវិញ ខ្ញុំរីករាយខ្លាំងណាស់។

នោះជាសក្ខីភាពថា ខ្ញុំមិនទាន់ជាសន្តីទេ។ ខ្ញុំគួរតែចាត់ទុកថា ភាពសោះកក្រោះមកពីការមិនសូវយកចិត្តទុកដាក់នឹងភក្តីភាពរបស់ខ្ញុំ ជាជាងត្រេកអរសប្បាយ ខ្ញុំគួរតែសោកស្ដាយក្នុងការបណ្ដោយខ្លួនឲ្យដេកលក់ (តាំង៧ឆ្នាំមកហើយ) ក្នុងពេលអធិដ្ឋាន និងការថ្លែងអំណរព្រះគុណព្រះជាម្ចាស់ ប៉ុន្តែខ្ញុំមិនស្ដាយក្រោយទេ... ព្រោះខ្ញុំគិតថា ក្មេងតូចៗដេកធ្វើឲ្យឪពុកម្ដាយសប្បាយចិត្តពេលដេកលក់ ឬពេលភ្ញាក់ផង។ មុននឹងវះកាត់ គ្រូពេទ្យដាក់ថ្នាំសន្លំអ្នកជំងឺ។ ដូច្នេះហើយ ខ្ញុំគិតថា៖ *"ព្រះជាម្ចាស់ទតឃើញភាពផុយស្រួយរបស់យើង ទ្រង់នឹកឃើញថា យើងគ្រាន់តែជាធូលីប៉ុណ្ណោះ"*។

សំណាក់ធម៌ត្រៀមចូលបួស ដូចជាសំណាក់ធម៌ ដែលមានជាបន្តបន្ទាប់ទៀត គឺភាពសោះកក្រោះ ប៉ុន្តែដោយមិនបានចាប់ភ្លឹក ព្រះជាម្ចាស់បានបង្ហាញយ៉ាងច្បាស់នូវមធ្យោបាយ ដើម្បីឲ្យទ្រង់គាប់ព្រះហឫទ័យ និងដើម្បីអនុវត្តគុណធម៌ដ៏ខ្ពង់ខ្ពស់ជាងគេ។ ខ្ញុំបានសម្គាល់ឃើញជាច្រើនលើកមកហើយ ព្រះជាម្ចាស់គ្មានបំណងប្រទានចំណីអាហារដល់ខ្ញុំទេ ទ្រង់បំប៉នខ្ញុំនឹងចំណីថ្មី ខ្ញុំមិនដឹងថារសជាតិយ៉ាងណា...។ ខ្ញុំគ្រាន់តែជឿថា គឺព្រះយេស៊ូអង្គឯង មកពួនក្នុងជម្រៅបេះដូងខ្ញុំ ព្រះអង្គប្រោសប្រណីឲ្យខ្ញុំគិតថា អ្វីៗទាំងអស់គឺជាព្រះបំណងឲ្យខ្ញុំប្រតិបត្តិតាមនាបច្ចុប្បន្ននេះ។ មុនចូលបួសប៉ុន្មានថ្ងៃ ខ្ញុំទទួលបានការប្រទានពរអំពីសម្តេចប៉ាប។ តាមរយៈបូជាចារ្យមួយរូប ខ្ញុំសូមព្រះអង្គប្រទានពរដល់ពុកនិងខ្ញុំ ដែលជាការលួងលោមមួយយ៉ាងធំចំពោះលោកឪពុករបស់ខ្ញុំដែលបានជូនខ្ញុំទៅទីក្រុងរ៉ូម។

ទីបំផុតថ្ងៃដ៏ល្អនៃអាពាហ៍ពិពាហ៍ខ្ញុំបានមកដល់ ហើយប្រព្រឹត្តទៅយ៉ាងរលូន។ ប៉ុន្តែមុនថ្ងៃនោះមួយថ្ងៃ ចិត្តខ្ញុំហាក់ដូចជាជួបព្យុះសង្ឃរាមួយមិនដែលជួបប្រទះ ខ្ញុំគ្មានសង្ស័យលើការត្រាស់ហៅទេ ព្រោះខ្ញុំមិនបានគិតដល់ឡើយ។ ខ្ញុំត្រូវតែស្គាល់ការលំបាកនេះ។ ពេលល្ងាច ដោយប្រារព្ធពិធីគោរពទុក្ខលំបាករបស់ព្រះយេស៊ូ ការត្រាស់ហៅខ្ញុំ ប្រាកដឡើងដូចជាសុបិន ជាគំនិតចាក់ស្មុគ... ខ្ញុំឃើញជីវភាពនៅអារាមកាមែលប្រសើរណាស់ ប៉ុន្តែអារក្សបានបញ្ចុះបញ្ចូលខ្ញុំឲ្យជឿវាថា ជីវិតនៅអារាមនេះមិនសម្រាប់ខ្ញុំទេ ថាខ្ញុំនឹងបោកប្រាស់ដូនជីថ្នាក់លើ បើខ្ញុំនឹងបួស... ស្រមោលអន្ធការបានគ្របដណ្តប់ខ្ញុំ បណ្តាលឲ្យងងឹតស្លុត មើលមិនឃើញ គិតមិនដល់ ដឹងតែមួយមុខថា៖ ខ្ញុំគ្មានការត្រាស់ហៅទេ!... ឱ! តើរៀបរាប់អំពីព្រលឹងខ្ញុំយ៉ាងណាទៅ?... ខ្ញុំហាក់ដូចជាគិតថា បើខ្ញុំប្រាប់ការភ័យខ្លាចនេះដល់អ្នកគ្រូ គាត់ច្បាស់ជាឃាត់មិនឲ្យខ្ញុំចូលបួសទេ (គំនិតនេះ មកពីអារក្សមែន) ផ្ទុយទៅវិញ ខ្ញុំចង់ធ្វើតាមបំណងនៃព្រះជាម្ចាស់ត្រលប់

ទៅក្នុងលោកិយ៍វិញ ជាងរស់នៅក្នុងអារាម ពេលនោះអ្នកគ្រូដើរចេញដោយចិត្តច្របូកច្របល់ ខ្ញុំសារភាពអំពីសភាពស្មុគស្មាញនៃព្រលឹងខ្ញុំ... ជាសំណាងល្អ គាត់យល់ច្បាស់ជាងខ្ញុំ ហើយលួងលោមខ្ញុំ។ ការបន្ទាបខ្លួននេះ ធ្វើឲ្យអារក្សរត់ចេញទៅបាត់។ ប្រហែលវាស្មានថា ខ្ញុំមិនហ៊ាននិយាយជម្រាបអ្នកគ្រូទេមើលទៅ។ កាលបើខ្ញុំរ៉ាយរ៉ាប់ចប់ ការសង្ស័យក៏រលាយបាត់អស់រលីង បន្ទាប់មកខ្ញុំចង់និយាយជម្រាបគាត់បន្ថែមទៀត អំពីគំនិតចម្លែកនេះ ប៉ុន្តែគាត់គ្រាន់តែសើច។

ព្រឹកថ្ងៃទី០៨ ខែកញ្ញា ខ្លួនខ្ញុំហាក់ដូចជាបានស្រោចស្រប់ដោយទឹកទន្លេនៃសេចក្ដីស្ងប់ ហើយគឺក្នុងសេចក្ដីស្ងប់នេះ "លើសមនោសញ្ចេតនាទាំងអស់" ដែលខ្ញុំធ្វើពាក្យសច្ចៈ។ ការរួបរួមរវាងខ្ញុំ និងព្រះយេស៊ូបានប្រព្រឹត្តទៅដោយការប្រោសប្រណីដ៏អស្ចារ្យ គ្មានរន្ទះ គ្មានផ្លេកបន្ទោរ តែក្នុងខ្យល់បក់ស្រាលៗ ដូចខ្យល់ដែលលោកអេលីធ្លាប់ឮនៅលើភ្នំ... តើថ្ងៃនោះ ខ្ញុំមិនបានសូមការប្រោសប្រណីទេឬ? ខ្ញុំជាម្ចាស់ក្សត្រីយ៍ពិតៗ ដូច្នេះខ្ញុំឆ្លៀតឱកាសប្រើកិត្តិយសនេះ ទូលអង្វរព្រះមហាក្សត្រឲ្យព្រះអង្គរំដោះអ្នកទោស និងព្រលឹងទាំងអស់នៅស្ថាននរក ហើយកែប្រែចិត្តអ្នកបាប... ខ្ញុំបានអធិដ្ឋានច្រើន ដើម្បីម៉ែ និងបងស្រីទាំងអស់ គ្រួសារទាំងមូល និងពុកដ៏ជាទីស្រឡាញ់...។ ខ្ញុំបានថ្វាយខ្លួនចំពោះព្រះយេស៊ូ ព្រះអង្គអាចបំពេញតាមព្រះបំណង ដោយគ្មានសត្វលោកណាមករារាំងបានឡើយ...។ (...)

ឥឡូវនេះ តើមានអ្វីត្រូវជម្រាបទៀត? ឱមែន! ខ្ញុំគិតថាចប់ហើយ ប៉ុន្តែខ្ញុំមិនដែលបាននិយាយអំពីសុភមង្គល ដោយបានស្គាល់អ្នកម៉ែ សឺណឺវិយែរ ទេ។ គឺជាការប្រោសប្រណី ដែលមិនអាចកាត់ថ្លៃបាន។ ព្រះជាម្ចាស់ប្រទានអ្វីៗជាច្រើនដល់ខ្ញុំ ព្រះអង្គមានបំណងឲ្យខ្ញុំរស់នៅជាមួយសន្តីម្នាក់ ដែលអាចត្រាប់តាមបាន ជាសន្តីបុគ្គលម្នាក់ ដោយគ្មាននរណាដឹងពីភាពដ៏វិសុទ្ធ ដែលមានគុណធម៌ដ៏សាមញ្ញបំផុត... គាត់លួងលោមខ្ញុំ ជាញឹកញយ ជាពិសេសថ្ងៃអាទិត្យ

មួយ។ ជាធម្មតាខ្ញុំតែងតែទៅលេងគាត់ ថ្ងៃនោះខ្ញុំជួបជូនជីពីរនាក់ នៅជាមួយគាត់ ខ្ញុំញញឹមមើលទៅគាត់ ហើយប្រុងប្រៀបនឹងចេញមកវិញ ព្រោះគេមិនអាចនៅបីនាក់ជិតអ្នកជំងឺទេ។ គាត់មើលមកខ្ញុំ ទឹកមុខបង្ហាញនូវសេចក្តីស្រឡាញ់ ហើយនិយាយថា៖ "ឈប់សិនកូនស្រី ខ្ញុំនិយាយតែមួយម៉ាត់ទេ រាល់លើកដែលកូនមកលេងម៉ែ កូនតែងតែសុំពាក្យណែនាំមួយមាត់ អញ្ចឹងថ្ងៃនេះ ខ្ញុំផ្តល់ដំបូន្មានមួយ៖ "ចូរកូនបម្រើព្រះជាម្ចាស់ ដោយសេចក្តីសុខសាន្ត និងរីករាយ ចូរកូនចាំថា ព្រះជាម្ចាស់របស់យើង ជាព្រះនៃសេចក្តីសុខសាន្ត"។ ក្រោយពីថ្លែងអំណរគុណហើយ ខ្ញុំដើរចេញមក ដោយរំជួលចិត្តរហូតដល់ហូរទឹកភ្នែក ហើយជឿជាក់ថា ព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់ គាត់អំពីសភាពនៃស្មារតីខ្ញុំពុំខាន។ ថ្ងៃនោះខ្ញុំរន្ធត់ក្រៃលែង ស្ទើរតែក្រៀមក្រំដូចស្ថិតក្នុងយប់មួយដែលខ្ញុំលែងដឹងថា តើព្រះជាម្ចាស់ស្រឡាញ់ខ្ញុំឬទេ? ប៉ុន្តែការលួងលោម និងសេចក្តីរីករាយដែលមានក្នុងចិត្តអ្នកម៉ែ មុខជានឹកឃើញពុំខាន!...។

ថ្ងៃអាទិត្យក្រោយមកទៀត ខ្ញុំចង់ដឹងថា តើព្រះជាម្ចាស់បានបង្ហាញអ្នកម៉ែសីណឺរីយៃរអំពីខ្ញុំ តែគាត់ឆ្លើយថា គ្មានទេ ហេតុនេះហើយ ខ្ញុំកាន់តែស្ងើចសរសើរគាត់ថែមទៀត ដោយឃើញថា ព្រះយេស៊ូបានសណ្ឋិតលើខ្លួនគាត់ ក្នុងលំដាប់ខ្ពស់ ធ្វើឲ្យគាត់និយាយ និងបញ្ចេញសកម្មភាព។ ឱ! ពិតជាវិសុទ្ធភាពពិតមែន គាត់ជាសន្តីវិសុទ្ធជាងគេ ច្បាស់ណាស់ ខ្ញុំមិនច្រលំទេ ហើយខ្ញុំចង់បានដូចគាត់...។

ថ្ងៃដែលខ្ញុំចូលបួស គាត់បាននិយាយផ្ទាល់មាត់ លួងលោមខ្ញុំថា គាត់ក៏ធ្លាប់ទទួលការលំបាកដូចខ្ញុំដែរ មុនពេលធ្វើពាក្យសច្ចា។ អ្នកម៉ែនឹកឃើញទេពេលយើងពិបាក គឺគាត់ជាអ្នកលួងលោមយើង។ តាមពិតទៅ អនុស្សាវរីយ៍ទាំងអស់ ដែលអ្នកម៉ែសីណឺរីយៃរបានទុកឲ្យ គឺជាអនុស្សាវរីយ៍ដ៏ក្រអូបក្នុងដួងចិត្តខ្ញុំ... ថ្ងៃគាត់ធ្វើដំណើរទៅស្ថានបរមសុខ ខ្ញុំហាក់ដូចជារំជួលចិត្តជាងគេ គឺ

លើកទីមួយ ដែលខ្ញុំឃើញការស្លាប់ផ្ទាល់ភ្នែក ទស្សនីយភាពនេះ គួរឲ្យចាប់អារម្មណ៍ណាស់... កាលនោះខ្ញុំឈរនៅចុងគ្រែគាត់ ខ្ញុំឃើញគាត់កម្រើកតិចៗ។ ពីរម៉ោងចុងក្រោយ ដែលខ្ញុំនៅក្បែរគាត់ ខ្ញុំហាក់ដូចជាស្ពឹកមិនសូវរវល់ បាត់បង់អារម្មណ៍ ប៉ុន្តែវេលាដែលគាត់ទៅចាប់កំណើតនៅស្ថានបរមសុខ ទឹកចិត្តខ្ញុំប្តូរភ្លាម តែមួយប៉ប្រិចភ្នែកសោះ ខ្ញុំហាក់ដូចជារីករាយខ្លាំងក្លា ពុំអាចជម្រាបបាន ហាក់ដូចជាអ្នកម៉ែ សីណើរីយែរ រំលែកសុភមង្គលជាន់ខ្ពស់បំផុតរបស់គាត់ ឲ្យខ្ញុំមួយចំណែកដែរ ព្រោះខ្ញុំជឿថា គាត់បានទៅដល់ស្ថានបរមសុខហើយ...។ កាលគាត់នៅរស់មានម្តងនោះ ខ្ញុំនិយាយប្រាប់គាត់ថាៈ "អ្នកម៉ែអើយ! អ្នកម៉ែមិនបាច់ទៅជម្រះបាបទេ!... "ខ្ញុំក៏សង្ឃឹមដូច្នេះដែរ" គាត់ឆ្លើយតិចៗ... ពិតហើយ ព្រះជាម្ចាស់មិនអាចក្បត់នឹងសេចក្តីសង្ឃឹមពោរពេញទៅដោយចិត្តសុភាពរាបសារនេះទេ ការគាំពារដែលយើងបានទទួលជាសក្ខីភាព... ដូនជីម្នាក់ៗ ប្រញាប់ប្រញាល់ទាមទារសារិកធាតុខ្លះៗ។ អ្នកម៉ែជ្រាបទេ សារិកធាតុដែលខ្ញុំបានទទួល... ពេលគាត់ជិតរលត់ ខ្ញុំសម្គាល់ឃើញទឹកភ្នែកមួយតំណក់ភ្លឺចាំងជាប់នឹងត្របកភ្នែក ដូចពេជ្រមួយគ្រាប់ ជាទឹកភ្នែកចុងក្រោយបង្អស់ ដែលគាត់បានបង្ហូរ ខ្ញុំនៅតែនឹកឃើញក្នុងចិត្តជានិច្ច ដោយគ្មាននរណាចាប់ភ្លឹកឡើយ។ ពេលយប់ស្ងាត់ខ្ញុំយកស្បៃស្តើងតូចមួយ ចូលទៅផ្តិតយកមកទុកជាសារិកធាតុ ព្រោះជាទឹកភ្នែកចុងក្រោយនៃសន្តីម្នាក់... តាំងពីពេលនោះមក ខ្ញុំតែងតែដាក់តាមខ្លួនក្នុងកញ្ចប់តូចមួយ ជាមួយនឹងពាក្យសច្ចារបស់ខ្ញុំ...។ (...)

ខណៈដែលសហគមន៍ទាំងមូលកើតទុក្ខ ខ្ញុំអាចរំសាយពីទុក្ខសោកនេះ ដោយទទួលព្រះកាយជារៀងរាល់ថ្ងៃ... ឱ! ផ្អែមល្ហែមអ្វីម្ល៉េះទេ!... ព្រះយេស៊ូទម្រើសយ៉ាងយូរជាងអ្នកឯទៀត ព្រោះគេប្រគល់ព្រះអង្គមកឲ្យខ្ញុំ ដោយអ្នកឯទៀត គ្មានភ័ព្វវាសនានឹងទទួលព្រះអង្គបាន។ ខ្ញុំរីករាយជាខ្លាំង ដោយបានប៉ះពាល់ថាសដង្វាយ រៀបចំព្រះពស្ត្រសម្រាប់ព្រះអង្គ ខ្ញុំគិតថា ត្រូវតែមានចិត្ត

ខ្ទះខ្មែង ហើយខ្ញុំនឹកឃើញជារឿយៗ នូវព្រះបន្ទូលពោលទៅឧបដ្ឋាកដ៏វិសុទ្ធម្នាក់៖ *"ចូរអ្នកជាសន្តវិសុទ្ធ ព្រោះអ្នកបានកាន់ថាសបូជាព្រះជាម្ចាស់"*។

ខ្ញុំមិនអាចនិយាយថា ខ្ញុំបានទទួលការល្បួងលោមជាញឹកញយទេ វេលាដែលខ្ញុំថ្លែងអំណរព្រះគុណព្រះជាម្ចាស់ ប្រហែលជាខ្ញុំទទួលការល្បួងលោមតិចជាងមុនផង ក៏មិនដឹង... ខ្ញុំយល់ថា ជាការធម្មតា ព្រោះខ្ញុំបានប្រគល់ខ្លួនប្រាណនិងព្រលឹងដល់ព្រះយេស៊ូ ហើយមិនដូចអ្នកប្រាជ្ញចង់បានការយាងមករបស់ព្រះអង្គ ដើម្បីល្បួងលោមខ្លួនទេ ផ្ទុយទៅវិញ ខ្ញុំចង់ដោយព្រះអង្គគាប់ព្រះរាជហឫទ័យ។ ខ្ញុំប្រដូចព្រលឹងខ្ញុំទៅនឹងដីទំនេរមួយកន្លែង ហើយខ្ញុំទូលអង្វរព្រះមាតាសូមទ្រង់ដកហូតយកវត្ថុបាក់បែករាយប៉ាយ ដែលជាឧបសគ្គចំពោះសេរីភាពបន្ទាប់មកខ្ញុំទូលអង្វរដោយទទូច សូមទ្រង់តម្លើងរហាលធំមួយ ដោយអង្គឯងសក្តិសមនឹងព្រះកិត្តយស តុបតែងដោយគ្រឿងលំអ រួចហើយ ខ្ញុំនឹងអញ្ជើញសន្តបុគ្គល និងទេវទូតទាំងអស់ មកប្រគុំតន្ត្រីយ៉ាងពិរោះ។ ខ្ញុំហាក់យល់ថា កាលបើព្រះយេស៊ូយាងចូលមកសណ្ឋិតក្នុងបេះដូងខ្ញុំហើយ ព្រះអង្គនឹងគាប់ព្រះហឫទ័យចំពោះការទទួលទ្រង់នេះ ហើយខ្លួនខ្ញុំក៏រីករាយដែរ... តែទោះជាយ៉ាងណាក៏ខ្ញុំមិនអាចជៀសផុតពីភាពរាយមាយ និងការងុយងោកបានឡើយ ប៉ុន្តែក្រោយពីថ្លែងអំណរព្រះគុណចប់ហើយ ខ្ញុំយល់ថា ខ្ញុំធ្វើមិនល្អ ខ្ញុំក៏បន្តទៅទៀតពេញមួយថ្ងៃ... អ្នកម៉ែឃើញទេ ខ្ញុំមិនចេះខ្លាចឡើយ ខ្ញុំឆ្លៀតរកមធ្យោបាយ ដើម្បីឲ្យបានរីករាយកណ្តាលទុក្ខព្រួយបាន... មិនអីទេ ព្រះយេស៊ូមិនពិរោធឡើយ ហាក់ដូចជាព្រះអង្គជំរុញខ្ញុំ ឲ្យដើរតាមផ្លូវនេះ។ ថ្ងៃមួយ ផ្ទុយនឹងទម្លាប់ ខ្ញុំខ្វល់ខ្វាយក្នុងចិត្តបន្តិច ពេលដើរទៅទទួលព្រះកាយ ហាក់ដូចជាព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យនឹងខ្ញុំៗ ប្រាប់ខ្លួនឯងថា៖ *"បើថ្ងៃនេះ ខ្ញុំទទួលនំតង្វាយតែពាក់កណ្តាល ខ្ញុំពិបាកចិត្តណាស់ ខ្ញុំគិតថា ព្រះយេស៊ូយាងមកដោយបង្ខំព្រះទ័យ"*។ ពេលនោះ ខ្ញុំដើរចូលទៅជិត... ឱ ព្រះអើយ! ជាលើកទីមួយក្នុងជីវិតនេះ បូជាចារ្យហុចនំម្តងមួយៗ ឲ្យខ្ញុំ! ខ្ញុំបាននំពីរ! អ្នកម៉ែច្បាស់ជាយល់អំពីសេចក្តីរីករាយ

របស់ខ្ញុំ នៅពេលនោះ ទឹកភ្នែកអំណរហូរ ចុះមកដោយសារសេចក្ដីមេត្តាករុណាដ៏ធំធេងនេះ...។

បន្ទាប់ពីបួសបានមួយឆ្នាំ គឺពីរខែមុនមរណភាពរបស់អ្នកម៉ែ សីណឺរីយ៉ែរ ខ្ញុំបានទទួលការប្រោសប្រណីធំៗជាច្រើនក្នុងពេលសំណាក់ធម៌។

តាមធម្មតា សំណាក់ធម៌ដែលមានការទូន្មាន នាំឲ្យខ្ញុំពិបាកទ្រាំជាងសំណាក់ធម៌តែម្នាក់ឯងទៅទៀត ប៉ុន្តែឆ្នាំនោះមិនដូច្នោះទេ។ ខ្ញុំបានសូត្រធម៌ប្រាំបួនថ្ងៃ ត្រៀមទុកយ៉ាងក្លៀវក្លាបំផុត ទោះជាខ្ញុំមានអារម្មណ៍ជឿជាក់ក៏ដោយ ខ្ញុំដូចជាយល់ថា អ្នកប្រៀនប្រដៅមិនអាចយល់ពីខ្ញុំបានទេ ព្រោះលោកធ្លាប់តែប្រដៅបាបជនធំៗ មិនដែលប្រដៅព្រលឹងអ្នកបួសទេ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យបង្ហាញខ្ញុំថា មានតែព្រះអង្គទេ ទើបដឹកនាំព្រលឹងខ្ញុំបាន ហើយព្រះអង្គប្រើបូជាចារ្យនេះ ដែលមានតែខ្ញុំទេចូលចិត្តគាត់... កាលនោះខ្ញុំទទួលការលំបាកធំៗ ក្នុងចិត្តគ្រប់បែបយ៉ាង (រហូតដល់ជួនកាល ខ្ញុំសួរខ្លួនឯងថាតើមានស្ថានបរមសុខមែនឬទេ) ខ្ញុំតាំងចិត្តថា មិននិយាយអំពីសភាពក្នុងចិត្តទេ ព្រោះនិយាយមិនកើត។ គ្រាន់តែចូលដល់កន្លែងស្រាយបាបភ្លាម ខ្ញុំមានអារម្មណ៍ថា ព្រលឹងខ្ញុំរីកធំឡើងៗ ក្រោយពីនិយាយបន្តិចបន្តួច ខ្ញុំបានយល់យ៉ាងច្បាស់ និងយល់ធ្លុះទៀតផង... ព្រលឹងខ្ញុំពេលនោះ ដូចសៀវភៅមួយក្បាលដែលបូជាចារ្យអានច្បាស់ជាងខ្លួនខ្ញុំផ្ទាល់... គាត់ពោលពាក្យសរសើរអំពីការជឿទុកចិត្ត និងសេចក្ដីស្រឡាញ់ ដែលខ្ញុំមានចំពោះមុខខ្ញុំតែម្ដង... គាត់ថាកំហុសខ្ញុំ មិនធ្វើឲ្យព្រះជាម្ចាស់លំបាកព្រះហឫទ័យទេ តំណាងឲ្យព្រះជាម្ចាស់ គាត់មានប្រសាសន៍ថា ព្រះអង្គគាប់ព្រះហឫទ័យនឹងខ្ញុំណាស់...។

ខ្ញុំសប្បាយចិត្តម្ល៉េះទេ ដោយឮពាក្យសរសើរនេះ!... ខ្ញុំមិនដែលគេនិយាយថា កំហុសមិនអាចធ្វើឲ្យព្រះជាម្ចាស់ពិបាកព្រះហឫទ័យទេ ពាក្យសន្យានេះ នាំឲ្យខ្ញុំរីករាយក្រៃលែង។ ខ្ញុំអាចទ្រាំទ្រនឹងការនិរទេសខ្លួននេះ ខ្ញុំយល់ក្នុងជម្រៅ

ចិត្តថា ជាការពិត ព្រោះព្រះជាម្ចាស់ទន់ភ្លន់ជាងម្ដាយទៅទៀត ដូចអ្នកម៉ែតែងតែអត់ឱននូវកំហុសឆ្គងតូចតាច ដែលខ្ញុំប្រព្រឹត្តដោយឥតដឹងខ្លួន... គ្មានការស្ដីបន្ទោសណាឲ្យខ្ញុំរំជួលចិត្ត ជាងការបបោសអង្អែល ហើយខ្ញុំជាអ្នកឆាប់ខ្លាចតាំងពីកំណើត។ ជាមួយនឹងសេចក្ដីស្រឡាញ់ មិនគ្រាន់តែដើរទេ ខ្ញុំហោះទៅមុខ...។ (...)

ជិតបីឆ្នាំមកហើយ ខ្ញុំមានសំណាងបានគយគន់ភាពអស្ចារ្យជាច្រើន ដែលព្រះយេស៊ូប្រតិបត្តិតាមរយៈអ្នកម៉ែ... ខ្ញុំយល់ឃើញថា មានតែការរងទុក្ខលំបាកទេ ដែលអាចបង្កើតព្រលឹង ហើយព្រះបន្ទូលដ៏ខ្ពង់ខ្ពស់របស់ព្រះយេស៊ូបានលាតត្រដាងជម្រៅនៃការឈឺចាប់នោះ៖ "ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រាប់ស្រូវធ្លាក់ដល់ដី ហើយបើមិនងាប់ទេ គ្រាប់នោះនៅតែមួយដដែល។ ផ្ទុយទៅវិញ បើវាងាប់ វានឹងបង្កើតផលបានច្រើន" អ្នកក៏ធ្លាប់ច្រូតកាត់យកផលដ៏បរិបូរណ៍ដែរ!... អ្នកសាបព្រោះក្នុងទឹកភ្នែក ក្រោយនោះបន្តិច អ្នកនឹងឃើញផ្លែផ្កានៃការងាររបស់អ្នកៗ នឹងត្រលប់មកវិញយ៉ាងរីករាយ ដោយកាន់កណ្ដាប់ក្នុងដៃ... អ្នកម៉ែ! ក្នុងចំណោមបាច់ផ្កាទាំងអស់ ផ្កាតូចពណ៌ស លាក់ខ្លួននៅក្នុងនោះ ប៉ុន្តែនៅស្ថានបរមសុខ នាងនឹងមានសំឡេង ដើម្បីច្រៀងនូវភាពទន់ភ្លន់ និងគុណធម៌ ដែលអ្នកម៉ែអនុវត្តរាល់ថ្ងៃ ក្នុងទីកំបាំង និងស្ងប់ស្ងាត់ទៅតាមដំណើរជីវិតអ្នកនិរទេសលើផែនដីនេះ... (...)

ខ្ញុំតែងតែទុកអ្នកម៉ែជាគំរូ ខ្ញុំប្រាថ្នាឲ្យដូចអ្នកបេះបិទ ឃើញអ្នកម៉ែគូរគំនូរដ៏វិចិត្រ តែងកំណាព្យល្អៗ ខ្ញុំគិតក្នុងចិត្ត៖ "បើចេះគូរគំនូរ ខ្ញុំពិតជាត្រេកអរណាស់ ចេះបញ្ចេញគំនិតជាពាក្យកាព្យ និងប្រព្រឹត្តអំពើល្អដល់អ្នកឯទៀត..." ខ្ញុំមិនគួរប៉ងសុំអំណោយពីធម្មជាតិនេះទេ ចំណង់នេះកប់ជ្រៅក្នុងចិត្តខ្ញុំ ព្រះយេស៊ូពួនក្នុងបេះដូងនេះដែរ ទ្រង់ប្រាប់ថា វាជាអំនួត និងជាទុក្ខព្រួយរបស់សត្វលោកក្រោមព្រះអាទិត្យលើផែនដី ប៉ុន្តែ ពេលគេឲ្យខ្ញុំគូរ ខ្ញុំគួរបានព្រះជាម្ចាស់ប្រទានពរ

ឲ្យខ្ញុំ រៀនពីអ្នកម៉ែឆាប់ចេះចាំធ្វើឲ្យគេឆ្ងល់គ្រប់គ្នា។ ព្រះអង្គគាប់ព្រះហឫទ័យឲ្យខ្ញុំអាចធ្វើដូចអ្នកម៉ែ ចេះតែងកំណាព្យ គួរគំនូរល្អៗ។ ស្តេច សាឡូម៉ូង ក៏ដូច្នោះដែរ ព្រះអង្គងាកទៅរកស្នាដៃ ដែលកើតចេញពីព្រះហស្តព្រះអង្គផ្ទាល់ តែជាការខិតខំឥតប្រយោជន៍ ដែលព្រះអង្គគិតឃើញថា ជាអំនួត និងទុកព្រួយនៃព្រលឹង។ ដូចគ្នានេះដែរ តាមបទពិសោធន៍ ខ្ញុំយល់ថាសុភមង្គលកើតបានដោយការលាក់បំពួនមិនឲ្យគេដឹង។ ខ្ញុំយល់ថា បើគ្មានសេចក្តីស្រឡាញ់ ស្នាដៃទាំងអស់នឹងទៅទទេសោះសូន្យ ទោះជាល្បីល្បាញយ៉ាងណាក៏ដោយ ដូចជាព្រោះអ្នកស្លាប់ឲ្យរស់ឡើងវិញ ឬទៅប្រកាសដំណឹងល្អដល់ប្រជាជនទាំងឡាយ...។

(...) អំណោយទានដែលព្រះជាម្ចាស់ប្រទាន (ខ្ញុំមិនបានសុំព្រះអង្គ) នាំខ្ញុំទៅរកព្រះអង្គ ខ្ញុំយល់ថា មានតែព្រះអង្គទេ ដែលមិនចេះប្រែប្រួល មានតែព្រះអង្គទេ ដែលបំពេញបំណងដ៏ធំធេងរបស់ខ្ញុំបាន... (...)

ឥឡូវនេះ ខ្ញុំគ្មានចង់បានអ្វីទៀតទេ ក្រៅពីស្រឡាញ់ព្រះយេស៊ូវក់រីយ៉ាងខ្លាំងមែនទែន បំណងពីកុមារភាពរលាយបាត់អស់ហើយ។ ប៉ុន្តែខ្ញុំនៅតែចូលចិត្តតុបតែងលំអអសនៈព្រះកុមារយេស៊ូដោយផ្កា ប៉ុន្តែ តាំងពីព្រះអង្គប្រទានផ្កាដែលខ្ញុំចង់បានមក គឺសេលីនបងស្រីសម្លាញ់របស់ខ្ញុំ (សេលីនទើបចូលអារាមការមែល) ខ្ញុំលែងត្រូវការផ្កាណាទៀតហើយ សេលីនជាផ្កាដែលខ្ញុំថ្វាយព្រះអង្គ នាងជាបាច់ផ្កាល្អដាច់គេ...

ខ្ញុំក៏លែងចង់បានការឈឺចាប់ ឬមរណទុក្ខទៀតដែរ ដែលកាលមុនខ្ញុំចូលចិត្តទាំងពីរមុខ។ សេចក្តីស្រឡាញ់បានទាក់ទាញខ្ញុំ... ជាយូរយាមកហើយ ខ្ញុំចង់បានសេចក្តីស្រឡាញ់។ ខ្ញុំទទួលការឈឺចាប់ ហៀបតែទៅដល់ត្រើយស្ថានបរមសុខទៅហើយ ខ្ញុំជឿថា ផ្កាតូចត្រូវបានបេះទៅតាមរដូវរបស់វា... ឥឡូវនេះ គឺការបំបរបង់តែមួយគត់ ដែលអាចដឹកនាំខ្ញុំបាន ខ្ញុំគ្មានត្រីវិស័យផ្សេងទេ!... ខ្ញុំមិនអាចសុំអ្វីទៀតឡើយ លើកលែងតែបំពេញយ៉ាងម៉ត់ចត់ទៅ

តាមព្រះបំណងរបស់ព្រះជាម្ចាស់ លើព្រលឹងខ្ញុំប៉ុណ្ណោះ ដោយគ្មានសត្វលោកណាហ៊ានមករារាំងបានឡើយ។ ខ្ញុំអាចថា តាមសម្ដីនៅក្នុងបទចម្រៀងរបស់សន្តយ៉ូហាននៃឈើឆ្កាង៖ "ខ្ញុំបានផឹកស្រានៅក្នុងឃ្លាំងនៃសង្សារខ្ញុំ ពេលចេញមកវាលស្មៅវិញ ខ្ញុំលែងស្គាល់អ្វីទាំងអស់ ខ្ញុំបាត់ហ្វូងចៀមដែលខ្ញុំធ្លាប់ឃ្វាលព្រលឹងខ្ញុំបានបម្រើនាងអស់ពីកម្លាំងកាយចិត្ត ខ្ញុំលែងឃ្វាលចៀម ខ្ញុំគ្មានការងារព្រោះឥឡូវនេះ កិច្ចការរបស់ខ្ញុំ គឺស្រឡាញ់!..." ម្យ៉ាងទៀត "តាំងពីខ្ញុំមានការពិសោធន៍មក សេចក្ដីស្រឡាញ់មានស្នាដៃខ្លាំងក្លាណាស់ ចេះកេងចំណេញអំពីអ្វីៗទាំងអស់ អំពីអំពើល្អ និងអំពើអាក្រក់ ដែលមាននៅក្នុងខ្លួនខ្ញុំ ប្ដូរព្រលឹងខ្ញុំជាខ្លួនឯង"។ អ្នកម៉ែអើយ! មាគ៌ានៃសេចក្ដីស្រឡាញ់ ហាក់ដូចជាទន់ភ្លន់ណាស់។ គេអាចដួលរលំ គេអាចប្រែប្រួល សាវា ប៉ុន្តែ សេចក្ដីស្រឡាញ់ ចេះទាញយកផលកម្រៃគ្រប់យ៉ាង ចេះដុតកំលោចអ្វីៗទាំងអស់ ដែលព្រះយេស៊ូមិនគាប់ព្រះហឫទ័យ បន្សល់ទុកសេចក្ដីស្ងប់ គិចតួចក្នុងជម្រៅបេះដូងប៉ុណ្ណោះ...។

ឱ! គឺជាពន្លឺ ដែលខ្ញុំបានដកស្រង់ចេញពីស្នាដៃរបស់បូជាចារ្យដ៏វិសុទ្ធយ៉ូហាននៃឈើឆ្កាង! ... កាលពីអាយុ ១៧ទៅ ១៨ឆ្នាំ ខ្ញុំគ្មានចំណីវិញ្ញាណណាផ្សេងទេ ប៉ុន្តែក្រោយមក សៀវភៅទាំងអស់ទុកខ្ញុំចោល ក្នុងសភាពក្រៀមក្រោះឥឡូវនេះ ខ្ញុំនៅតែក្រៀមក្រោះដដែល។ បើខ្ញុំបើកសៀវភៅសរសេរដោយអ្នកនិពន្ធផ្នែកវិញ្ញាណ (ទោះជាសៀវភៅល្អជាងគេក៏ដោយ) ខ្ញុំមានអារម្មណ៍តឹងទ្រូង អានដោយគ្មានយល់ ប្រសិនបើយល់ ស្មារតីខ្ញុំគាំងស្ទួក មិនអាចត្រិះរិះពិចារណាឡើយ... មានតែព្រះគម្ពីរ និងសៀវភៅ Imitation ទេ ដែលអាចជួយខ្ញុំបាន ទាំងពីរនេះ ជាចំណីដែលជួយឲ្យឆាប់ឆ្អែត ហើយបរិសុទ្ធ។ ប៉ុន្តែ ដំណឹងល្អជាជំនួយល្អលើសគេ ក្នុងពេលអធិដ្ឋាន។ ក្នុងដំណឹងល្អ ខ្ញុំរកឃើញអ្វីៗ ដែលជាអត្ថប្រយោជន៍ដល់ព្រលឹងតូចរបស់ខ្ញុំជាពន្លឺថ្មីៗជានិច្ច ដែលមានន័យបង្កប់និងអាថ៌កំបាំង...។



ខ្ញុំយល់ដឹងតាមការពិសោធន៍ *"ព្រះរាជ្យរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងចិត្តយើង"* ព្រះយេស៊ូមិនត្រូវការសៀវភៅ ឬបណ្ឌិតមកបង្រៀនព្រលឹងទាំងអស់ទេ ព្រះអង្គជាបណ្ឌិតលើបណ្ឌិត ព្រះអង្គបង្រៀនដោយសម្ដីឥតសំឡេង ខ្ញុំមិនដែលឮព្រះអង្គមានព្រះបន្ទូលទេ ប៉ុន្តែខ្ញុំដឹងថា ព្រះអង្គស្ថិតនៅជាមួយខ្ញុំគ្រប់វេលា។ ទ្រង់ណែនាំឲ្យខ្ញុំបែកប្រាជ្ញា ចំពោះអ្វីៗដែលខ្ញុំត្រូវថា ឬធ្វើ។ ខ្ញុំរកឃើញពន្លឺនៅពេលដែលខ្ញុំត្រូវការបំភ្លឺ ទោះជាខ្ញុំពុំដែលដឹងក៏ដោយ។ មិនមែនមានតែរាល់ពេលអធិដ្ឋានប៉ុណ្ណោះ នៅពេលធ្វើការងារប្រចាំថ្ងៃ ក៏មានដែរ...។ (...)

ខ្ញុំគិតទៅដល់ព្រលឹង ដែលប្រគល់ខ្លួនជាដង្វាយបូជាចំពោះព្រះជាម្ចាស់ ដើម្បីពង្វាង និងទាក់ទាញទោស ទណ្ឌកម្មតម្រូវលើអ្នកប្រព្រឹត្តអំពើបាប មកលើខ្លួនឯងវិញ។ ការបូជានេះ ចំពោះខ្ញុំហាក់ដូចជាធំធេង និងសប្បុរសណាស់ ប៉ុន្តែ ខ្ញុំមិនចង់ធ្វើបែបនោះទេ។ ខ្ញុំស្រែកក្នុងជម្រៅចិត្តថា៖ "ឱ ព្រះជាម្ចាស់អើយ! តើមានតែយុត្តិធម៌របស់ព្រះអង្គទេ ឬដែលនឹងទទួលព្រលឹង ដុតខ្លួនបូជាជាដង្វាយ?... តើសេចក្តីស្រឡាញ់ប្រកបដោយមេត្តាករុណារបស់ព្រះអង្គ មិនត្រូវការព្រលឹងនោះដែរទេឬ? គ្រប់ទិសទី មានសត្វលោកខ្លះមិនស្គាល់សេចក្តីស្រឡាញ់របស់ព្រះអង្គទេ គេមិនព្រមទទួលស្គាល់ ហើយបែរទៅរកសេចក្តីស្រឡាញ់ពីមនុស្សគ្នាឯង ចង់បានសុភមង្គលតិចតួច មិនព្រមចូលក្នុងរង្វង់ព្រះហស្ត ហើយទទួលយកសេចក្តីស្រឡាញ់ឥតគណនារបស់ព្រះអង្គឡើយ...។ ឱព្រះជាម្ចាស់អើយ! សេចក្តីស្រឡាញ់ដែលគេមិនព្រមទទួលនោះ មាននៅក្នុងព្រះហឫទ័យទៀតទេ? ប្រសិនបើព្រះអង្គរកឃើញព្រលឹង ដែលប្រគល់ខ្លួនជាដង្វាយ បូជាចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គៗ នឹងទទួលយ៉ាងឆាប់រហ័ស ហាក់ដូចជាព្រះអង្គត្រេកអរ ហើយមិនលាក់ទុកសេចក្តីស្រឡាញ់ដ៏ទន់ភ្លន់ឡើយ... ប្រសិនបើយុត្តិធម៌របស់ព្រះអង្គ ហូរហៀរនៅលើផែនដីនោះ សេចក្តីមេត្តាករុណារបស់ទ្រង់ក៏ខ្ពស់ត្រដែត រហូតដល់ស្ថានបរមសុខ... ឱព្រះយេស៊ូអើយ! សូមឲ្យដង្វាយរស់ដ៏មានសំណាងនោះ ជារូបខ្ញុំម្ចាស់ សូមព្រះអង្គដុតដង្វាយនេះ

ទាំងមូល ដោយភ្លើងនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គផង!..."។

អ្នកម៉ែ! អ្នកបានអនុញ្ញាតឲ្យខ្ញុំថ្វាយខ្លួនចំពោះព្រះជាម្ចាស់ អ្នកជ្រាបទេ ទន្លេ ឬមហាសមុទ្រនៃការប្រោសប្រណី បានមកស្រោចស្រប់ព្រលឹងខ្ញុំ... តាំងពីថ្ងៃដ៏សែនរីករាយនោះមក សេចក្ដីស្រឡាញ់ហាក់ដូចជាជ្រួតជ្រាបចូល និងស្រោបជុំវិញខ្លួនខ្ញុំ សេចក្ដីស្រឡាញ់ប្រកបដោយក្ដីមេត្តាករុណានេះ ប្ដូររូបខ្ញុំជាថ្មី ធ្វើឲ្យព្រលឹងខ្ញុំបរិសុទ្ធ គ្មានស្លាកស្នាមអំពើបាប ដូច្នេះខ្ញុំគ្មានអ្វីត្រូវខ្លាចទីជម្រះបាបឡើយ... ខ្ញុំនឹងទៅដោយខ្លួនឯង ខ្ញុំមិនបាច់ចូលទីជម្រះបាបនោះទេ ព្រោះមានតែសន្តិវិញ្ញាណដ៏វិសុទ្ធទេ ដែលអាចទៅស្ថានបរមសុខបាន។ ខ្ញុំក៏ដឹងដែរថា ភ្លើងនៃសេចក្ដីស្រឡាញ់ ធ្វើឲ្យបរិសុទ្ធជាងទីជម្រះបាប ហើយព្រះយេស៊ូគ្មានបំណងឲ្យយើងរងទុក្ខទោសឥតប្រយោជន៍ទេ បើព្រះអង្គមិនត្រូវការ ទ្រង់នឹងមិនបញ្ចុះបញ្ចូលនូវចំណង់ដែលយើងគិតឃើញទេ...។

ឱ! មាគ៌ានៃសេចក្ដីស្រឡាញ់ ស្រទន់អ្វីម្លេះទេ ខ្ញុំនឹងយកចិត្តទុកដាក់អនុវត្តតាមមាគ៌ាដ៏ឧត្ដមនេះ ដោយការលះបង់ខ្ពស់ ស្របតាមបំណងរបស់ព្រះជាម្ចាស់! ...។

អ្នកម៉ែ នេះហើយជាអ្វីៗដែលខ្ញុំអាចជម្រាបជូន! អ្នកម៉ែស្គាល់ថេរេសាច្បាស់ និងដឹងអំពីសកម្មភាពរបស់ព្រះយេស៊ូចំពោះនាង ដូច្នេះសូមអភ័យទោសក្នុងការរៀបរាប់ដោយសង្ខេបនេះ...

តើប្រវត្តិនៃ "ផ្កាតូចពណ៌ស" នេះបញ្ចប់យ៉ាងដូច្នេះ? ប្រហែលជាត្រូវគេបេះ ឬដកយកទៅដាំកន្លែងផ្សេងទៀត... ខ្ញុំមិនដឹងទេ តែខ្ញុំប្រាកដក្នុងចិត្តថាសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ នឹងដឹកនាំនាងជានិច្ច។ នាងមិនដែលភ្លេចប្រទានពរជូនអ្នកម៉ែជាទីស្រឡាញ់ ដែលបានប្រគល់រូបនាងថ្វាយព្រះយេស៊ូឡើយ។ នាងរីករាយនឹងក្លាយទៅជាផ្កាមួយនៃម្កុដរបស់ព្រះអង្គ... នាងនឹងច្រៀងចម្រៀងថ្មីនៃសេចក្ដីស្រឡាញ់ ជាមួយមាតាជាទីស្រឡាញ់នេះ ជារៀងរហូត...។

## សំបុត្រសរសេរទៅដូនជី ម៉ារី នៃព្រះហឫទ័យដ៏វិសុទ្ធ

## សៀវភៅ "ខ"

# ការត្រាស់ហៅ៖ សេចក្ដីស្រឡាញ់

(១៨៩៦)

សូមបងកុំគិតថា ខ្ញុំស្ថិតនៅក្នុងការលួងលោមឡើយទេ! ការលួងលោមរបស់ខ្ញុំគ្មានទេលើផែនដីនេះ។ ព្រះយេស៊ូបានបង្រៀនខ្ញុំជាសម្ងាត់ ដោយមិនបញ្ចេញរូប គ្មានសំឡេង គ្មានសៀវភៅ ព្រោះខ្ញុំអានមិនយល់ទេ ប៉ុន្តែ ជួនកាលសម្ដីដែលខ្ញុំដកស្រង់ក្រោយអធិដ្ឋាន មកលួងលោមខ្ញុំ៖ "នេះជាម្ចាស់ ដែលខ្ញុំនាំមកឲ្យអ្នក គាត់បង្រៀនសព្វបែបយ៉ាងដែលអ្នកត្រូវធ្វើ ខ្ញុំចង់ឲ្យគាត់បង្រៀនអ្នកក្នុងសៀវភៅនៃជីវិត ក្នុងនោះមានវិទ្យាសាស្រ្តនៃសេចក្ដីស្រឡាញ់"។ វិទ្យាសាស្រ្តនៃសេចក្តីស្រឡាញ់ អូហ៍មែន! សម្ដីនេះនៅតែលាន់ឮពេញត្រចៀកខ្ញុំ ខ្ញុំចង់ចេះវិទ្យាសាស្រ្តនោះ ដើម្បីចេះខ្ញុំព្រមប្រគល់អ្វីៗទាំងអស់... ខ្ញុំយល់ថាមានតែសេចក្ដីស្រឡាញ់ទេ ដែលធ្វើឲ្យព្រះជាម្ចាស់ចូលចិត្តយើង។ សេចក្ដីស្រឡាញ់ជាមហិច្ឆតាតែមួយរបស់ខ្ញុំ។ ព្រះយេស៊ូគាប់ព្រះហឫទ័យបង្ហាញមាគ៌ាតែមួយគត់ ដែលនាំទៅដល់ភ្នក់ភ្លើងនៃព្រះជាម្ចាស់ មាគ៌ានេះ គឺជាការបណ្ដែតបណ្ដោយខ្លួននៃក្មេងតូចម្នាក់ ដេកលក់ដោយគ្មានបារម្ភ ក្នុងរង្វង់របស់ឪពុក

គឺព្រះបិតា... *"បើនរណាម្នាក់តូច សូមមករកខ្ញុំ"* នេះជាព្រះបន្ទូលនៃព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈព្រះឧស្មស្តេចសាឡូម៉ូន ហើយវិញ្ញាណដ៏វិសុទ្ធដដែលនេះ មានព្រះបន្ទូលទៀតថា៖ *"សេចក្ដីមេត្តាករុណាត្រូវប្រគល់ឲ្យអ្នកតូចទាប"* ។ ព្រះបន្ទូលតាមរយៈព្យាការីអេសាយ ប្រាប់ឲ្យយើងដឹងនៅថ្ងៃចុងក្រោយ *"ព្រះជាម្ចាស់នាំហ្វូងចៀមទៅក្នុងវាលស្មៅ ព្រះអង្គនឹងប្រមូលមកដាក់ផ្ទាប់លើព្រះឱរា"*។ ការសន្យានេះ ហាក់ដូចជាមិនគ្រប់គ្រាន់ដដែលនេះ បានស្រែកក្នុងនាមព្រះជាម្ចាស់ថា៖ *"ខ្ញុំនឹងលួងលោមអ្នក ដូចម្ដាយអង្អែលលួងកូន ខ្ញុំនឹងពរអ្នកលើទ្រូង ហើយខ្ញុំអង្អែលអ្នកលើភ្លៅ"* ។ ម៉ែធម៌ជាទីស្រឡាញ់! តាមព្រះបន្ទូលនេះ មានតែនៅស្ងៀមបង្ហូរទឹកភ្នែក ដើម្បីថ្លែងអំណរព្រះគុណ និងស្រឡាញ់ព្រះអង្គ។ ប្រសិនបើព្រលឹងទន់ខ្សោយ មិនគ្រប់លក្ខណ៍ យល់ដូចថេរេសា គ្មាននរណាបាត់បង់ក្ដីសង្ឃឹមទេ ពួកគេនឹងខំប្រឹងឡើងរហូតទៅដល់កំពូលភ្នំនៃសេចក្ដីស្រឡាញ់គ្រប់ៗគ្នា។ ព្រះយេស៊ូមិនទាមទារទង្វើធំៗទេ ព្រះអង្គត្រូវការការលះបង់ និងការដឹងគុណប៉ុណ្ណោះ ព្រោះព្រះអង្គមានព្រះបន្ទូលក្នុងទំនុកដម្កើង ៧៤ ថា៖ "យើងមិនត្រូវការចៀមឈ្មោល ក្នុងហ្វូងរបស់អ្នកទេ ព្រោះសព្វសត្វនៅក្នុងព្រៃ និងសត្វរាប់ពាន់ដែលស៊ីស្មៅតាមភ្នំ ជារបស់យើង យើងស្គាល់បក្សាបក្សីនៅលើភ្នំទាំងអស់... បើយើងឃ្លាន យើងមិនចាំបាច់ប្រាប់ទៅពួកអ្នកទេ ព្រោះផែនដី និងអ្វីៗនៅលើផែនដីនេះ ជារបស់យើង។ តើយើងត្រូវបរិភោគសាច់គោឈ្មោល និងផឹកឈាមពពែឈ្មោលឬ?..."

*"សូមដុតគ្រឿងបូជាលើកតម្កើង និងថ្លែងអំណរព្រះគុណដល់ព្រះជាម្ចាស់ទៅ"* ។ នេះហើយជាការទាមទាររបស់ព្រះយេស៊ូ ទ្រង់មិនត្រូវការស្នាដៃរបស់យើងទេ ព្រះអង្គត្រូវការតែសេចក្ដីស្រឡាញ់ ព្រោះព្រះជាម្ចាស់ ទ្រង់ប្រកាសថាទ្រង់មិនចាំបាច់ប្រាប់យើងថា ទ្រង់ឃ្លានឡើយ ព្រះអង្គមិនខ្លាចនឹងចូលទៅសុំទឹកបន្តិច អំពីស្ត្រីអ្នកស្រុកសាម៉ារីទេ។ ព្រះអង្គស្រេក តែដោយទ្រង់មាន

ព្រះបន្ទូលថា៖ *"ខ្ញុំសុំទឹកផឹកផង"* គឺជាសេចក្តីស្រឡាញ់របស់សត្វលោក ដែលព្រះអង្គបានសុំ។ ព្រះអង្គស្រេកឃ្លានសេចក្តីស្រឡាញ់... ឱ! ខ្ញុំដឹងថា ព្រះយេស៊ូស្រេកខ្លាំងណាស់ ព្រះអង្គជួបតែអ្នកមិនដឹងគុណ និងអ្នកព្រងើយកន្តើយ ក្នុងចំណោមពួកសាវ័កលើលោកនេះ ហើយនៅក្នុងចំណោមពួកសាវ័ករបស់ព្រះអង្គផ្ទាល់ មានតិចណាស់ដែលប្រគល់ខ្លួនទាំងស្រុង ហើយយល់អំពីសេចក្តីស្រឡាញ់ជាអនេករបស់ព្រះអង្គ...

**J.M.J.T ថ្ងៃ ៨ កញ្ញា ១៨៩៦**

# (ជូនចំពោះ បងស្រី ម៉ារី នៃព្រះហឫទ័យដ៏វិសុទ្ធ ជាទីស្រឡាញ់)

ពេលទៀបភ្លឺ ខ្ញុំយល់សប្តិឃើញថា៖ ខ្ញុំស្ថិតនៅក្នុងរូងក្រោមដីជាមួយអ្នកឯទៀតជាច្រើននាក់ ប៉ុន្តែខ្ញុំនៅឆ្ងាយពីគេ មានតែម៉ែយើងទេ ដែលនៅជិតខ្ញុំ។ រំពេចនោះ ខ្ញុំឃើញដូនជីនៅកាមែលបីរូប មិនដឹងជាចូលមកតាមណា ពាក់អាវរងាវែងហើយគ្របស្បៃមុខ។ ហាក់ដូចជាពួកគាត់ដើរមករកម៉ែ ប៉ុន្តែខ្ញុំយល់ច្បាស់ថា ពួកគាត់មកពីស្ថានបរមសុខ។ ខ្ញុំគិតក្នុងចិត្តថា ឱ! ខ្ញុំមិនដឹងជាត្រេកអរយ៉ាងណាទេ បើបានឃើញមុខរបស់ពួកគាត់។ គាត់ហាក់ដូចជាស្តាប់ឮការអធិដ្ឋានរបស់ខ្ញុំ សន្តីដែលធំជាងគេ ដើរតម្រង់មកខ្ញុំៗ ក៏លុតជង្គង់ចុះ។ ឱ! ជាសុភមង្គលអ្វីម្លេះទេ ដូនជីនោះបើកស្បៃគ្របមុខ ឬបើកស្បៃយកមកគ្របឲ្យខ្ញុំ... ដោយគ្មានរុញរា ខ្ញុំមើលស្គាល់ជាអ្នកម៉ែអាននៃព្រះយេស៊ូ អ្នកបង្កើតអារាមកាមែលនៅប្រទេសបារាំង។ មុខគាត់ស្រស់ស្អាត សោភ័ណភាពអរូបី គ្មានកាំរស្មីបំភ្លឺទេ ប៉ុន្តែទោះជាមានស្បៃគ្របមុខយើងទាំងពីរនាក់ ខ្ញុំមើលឃើញមុខរបស់អ្នកម៉ែ បំភ្លឺដោយពន្លឺស្រាលៗ មិនអាចពិពណ៌នាបាន មិនមែនជាពន្លឺដែលគេបំភ្លឺទេ តែជាពន្លឺចេញពីរាងកាយគាត់...។

ខ្ញុំដឹងនិយាយអំពីបីតិសោមនស្សរបស់ព្រលឹងខ្ញុំយ៉ាងណាទេ គេអាចដឹង តែនិយាយប្រាប់មិនកើត... សុបិននោះ កន្លងទៅជាច្រើនខែមកហើយ ប៉ុន្តែ ខ្ញុំនៅចាំឥតភ្លេច ហាក់នៅថ្មីៗ សម្ផស្សនៃស្ថានបរមសុខ...។ ខ្ញុំនៅចាំក្រសែភ្នែក និងភាពញញឹមពោរពេញទៅដោយសេចក្តីស្រឡាញ់នៃអ្នកម៉ែ។ ខ្ញុំហាក់ដូចជានៅចាំការបបោសអង្អែលស្រាលៗរបស់គាត់។

ឃើញគាត់ស្រឡាញ់ខ្ញុំយ៉ាងនេះ ខ្ញុំហ៊ានបញ្ចេញសម្តីថា៖ អ្នកម៉ែអើយ! ខ្ញុំសូមអង្វរ សូមម៉ែប្រាប់ខ្ញុំផង តើព្រះជាម្ចាស់ទុកឲ្យខ្ញុំនៅលើផែនដីនេះយូរទៀតទេ?... ព្រះអង្គយាងចុះមករកខ្ញុំ ក្នុងពេលឆាប់ៗនេះទេ? គាត់ញញឹមយ៉ាងស្រទន់ ហើយនិយាយខ្សឹបៗថា៖ *"ចាស ជិតហើយ... ជិតហើយ... សន្យា..."* ខ្ញុំសួរបន្ថែមទៀត៖ *"អ្នកម៉ែ តើព្រះជាម្ចាស់មិនត្រូវការអ្វីទៀត ក្រៅពីទង្វើតូចតាច និងចំណង់ខ្ញុំទេឬ? តើព្រះអង្គគាប់ព្រះហឫទ័យនឹងខ្ញុំទេ?"* វង់ភក្ត្ររបស់សន្តី ប្រែទៅជាស្រទន់ជាងមុន មិនអាចរកពាក្យប្រដូចបាន។ ខ្សែភ្នែក និងការអង្អែល មានសភាពស្លូតបូត ទន់ភ្លន់ គាត់ប្រាប់ថា៖ "ព្រះជាម្ចាស់គ្មានត្រូវការអ្វីពីកូនទៀតទេ ព្រះអង្គរីករាយ គាប់ព្រះហឫទ័យ... គាប់ព្រះហឫទ័យណាស់!..."។ ក្រោយពីអង្អែលខ្ញុំថែមទៀត យ៉ាងទន់ភ្លន់បំផុត គាត់ក៏ដើរចេញទៅ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ហើយខ្ញុំនឹកទៅដល់បងស្រីទាំងអស់ ខ្ញុំចង់សូមសេចក្តីប្រោសប្រណីខ្លះៗ សម្រាប់ពួកគាត់ ប៉ុន្តែគួរឲ្យស្តាយ... ខ្ញុំភ្ញាក់ដឹងខ្លួន! ...។

ឱ ព្រះយេស៊ូអើយ! គ្មានព្យុះភ្លៀងទៀតទេ មេឃស្ងប់ ស្រលះល្អ ខ្ញុំជឿ ខ្ញុំដឹងថា មានស្ថានបរមសុខ ហើយទីនោះ មានព្រលឹងជាច្រើនស្ថិតនៅ ហើយស្រឡាញ់ទុកខ្ញុំដូចកូន... អារម្មណ៍នេះ ស្ថិតក្នុងចិត្តខ្ញុំ ស្មើនឹងអារម្មណ៍ដែលខ្ញុំមានចំពោះអ្នកម៉ែអាននៃព្រះយេស៊ូដែរ។ តាំងពីដើមមក ខ្ញុំមិនដែលបានអធិដ្ឋានជូនគាត់ទេ ព្រោះខ្ញុំស្គាល់គាត់ តាមសម្តីគេម្តងម្កាល។ កាលបើខ្ញុំយល់ថាគាត់

ស្រឡាញ់ខ្ញុំៗ នឹកឃើញគាត់ ចិត្តខ្ញុំត្រូវរំលាយដោយសេចក្ដីស្រឡាញ់ និងដឹងគុណចំពោះសន្តិរូបនេះ ដែលបានមកនឹងខ្ញុំ និងចំពោះអ្នកដែលមានសំណាងរស់នៅស្ថានបរមសុខទាំងអស់ផងដែរ ។ (...)

ព្រះយេស៊ូអើយ ក្រោយពីមានរួបរួមជាមួយព្រះអង្គ ខ្ញុំម្ចាស់ជាព្រះមហេសីជាដូនជីនៅអារាមកាមែល ជាម្ដាយនៃព្រលឹង គួរតែគ្រប់គ្រាន់សម្រាប់ខ្ញុំម្ចាស់ហើយ ប៉ុន្តែមិនដូច្នោះទេ អាទិភាពទាំងបីនេះ ជាការត្រាស់ហៅចំពោះខ្ញុំ ប៉ុន្តែខ្ញុំដឹងថា មានការត្រាស់ហៅផ្សេងៗទៀត គឺជាអ្នកចម្បាំង ជាបូជាចារ្យ ជាគ្រីស្តទូត ជាបណ្ឌិត ជាមរណសាក្សី ទីបំផុតខ្ញុំមានបំណងបំពេញកិច្ចការទាំងនោះ ដែលជាស្នាដៃដ៏មានវីរភាពជាងគេ ដើម្បីព្រះអង្គ ខ្ញុំដឹងក្នុងចិត្តនូវសេចក្ដីក្លាហានរបស់ទ័ពព្រះ ជាទាហានរបស់សម្ដេចប៉ាប ខ្ញុំសុខចិត្តបូជាជីវិតលើទីលានប្រយុទ្ធ ដើម្បីការពារព្រះសហគមន៍...

ខ្ញុំដឹងខ្លួនថា មានការត្រាស់ហៅជាបូជាចារ្យ ព្រះយេស៊ូអើយ ខ្ញុំម្ចាស់នឹងលើកព្រះអង្គដោយក្តីស្រឡាញ់ ជាទីបំផុត ពេលខ្ញុំម្ចាស់នឹងហៅ ព្រះអង្គនឹងយាងចុះមក ខ្ញុំលើកព្រះអង្គឲ្យទៅព្រលឹងឯទៀត ដោយសេចក្ដីស្រឡាញ់! គួរឲ្យស្ដាយ! ដោយចង់ក្លាយទៅជាបូជាចារ្យ ខ្ញុំកោតសរសើរ និងច្រណែននឹងការបន្ទាបខ្លួនរបស់សន្តៈ ហ្វ្រង់ស្វ័រ ហើយខ្ញុំដឹងថា មានការត្រាស់ហៅឲ្យធ្វើត្រាប់តាមគាត់ ដោយមិនព្រមទទួលងារដ៏ខ្ពង់ខ្ពស់នៃបូជាចារ្យ។

ព្រះយេស៊ូ! ជាទីស្រឡាញ់របស់ខ្ញុំម្ចាស់អើយ ជីវិតខ្ញុំម្ចាស់... តើភាពផ្ទុយគ្នាចងសម្ព័ន្ធនឹងគ្នាដូចម្ដេចទៅ? តើត្រូវធ្វើដូចម្ដេច ដើម្បីសម្រេចបំណងរបស់ព្រលឹងដ៏តូចកម្សត់នេះបាន?

ទោះបីជាខ្លួនខ្ញុំតូច ខ្ញុំមានបំណងបំភ្លឺព្រលឹង ដូចព្យាការី បណ្ឌិតដែរ ខ្ញុំមានការត្រាស់ហៅជាគ្រីស្តទូត... ខ្ញុំចង់ធ្វើដំណើរគ្រប់ទិសទី ដើម្បីប្រកាសប្រៀនប្រដៅអំពីព្រះនាមរបស់ព្រះអង្គ និងដាំឈើឆ្កាងដ៏មានសិរីរុងរឿង លើទឹកដី

របស់ជនគ្មានសាសនា ប៉ុន្តែ ព្រះអង្គអើយ បេសកកម្មតែមួយ មិនគ្រប់គ្រាន់សម្រាប់ខ្ញុំម្ចាស់ទេ ជាមួយគ្នានេះ ខ្ញុំម្ចាស់ចង់ប្រកាសដំណឹងល្អ ក្នុងទ្វីបទាំងប្រាំ លើភពផែនដី និងកោះដ៏សែនឆ្ងាយដាច់ស្រយាល... ខ្ញុំម្ចាស់ចង់ជាសាសនទូត មិនមែនតែពីរបីឆ្នាំទេ គឺចាប់តាំងពីលោកុប្បត្តិករហូតដល់ច្រើនសតវត្ស។ ព្រះអង្គជាទីស្រឡាញ់ ជាព្រះសង្គ្រោះរបស់ខ្ញុំម្ចាស់អើយ បំណងធំបំផុតរបស់ខ្ញុំម្ចាស់ គឺចង់បង្ហូរឈាមរហូតដំណាក់ចុងក្រោយ... ដើម្បីព្រះអង្គ...

មរណសាក្សីនេះហើយជាក្តីស្រមៃរបស់ខ្ញុំ កាលនៅក្មេង ក្តីស្រមៃនេះបានរីកធំធាត់ជាមួយខ្ញុំ នៅក្នុងអារាមកាមែល ប៉ុន្តែកាលនោះ ខ្ញុំគិតថាជាក្តីស្រមៃដ៏ឆ្កួតលីលា ព្រោះខ្ញុំម្ចាស់មិនចេះកំណត់បំណងប្រាថ្នាថា ជាមរណសាក្សីបែបណាមួយ។ ខ្ញុំម្ចាស់ពេញចិត្តទាំងអស់... ដូចព្រះអង្គដែរ ខ្ញុំម្ចាស់ចង់ឲ្យគេវាយវាត់ហើយឆ្កាង ខ្ញុំម្ចាស់ចង់ស្លាប់ គ្មានសម្លៀកបំពាក់ដូចសន្តៈ បារតេលេមី... ខ្ញុំម្ចាស់ចង់ឲ្យគេបោះចូលខ្លាញ់ដាំពុះ ដូចសន្តៈ យ៉ូហាន ខ្ញុំម្ចាស់ចង់ទទួលទុក្ខទោសទាំងអស់ ដែលគេធ្វើបាបមរណសាក្សី ខ្ញុំម្ចាស់ចង់ឲ្យគេកាត់ក ដូចសន្តីអាញែស និងសន្តី សេស៊ីលដែរ ខ្ញុំម្ចាស់ចង់ឲ្យគេដុតទាំងរស់ ដូចសានដាក (Jeanne d'Arc) បងស្រីសម្លាញ់របស់ខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់ នឹងខ្សឹបហៅព្រះនាមព្រះអង្គ ឱព្រះយេស៊ូ... បើគិតដល់ការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ក្នុងសម័យប្រឆាំងនឹងព្រះគ្រីស្ត ចិត្តខ្ញុំម្ចាស់ញ័ររន្ធត់ណាស់ ហើយខ្ញុំម្ចាស់ចង់ឲ្យទុក្ខសោកនោះ ធ្លាក់មកលើខ្ញុំម្ចាស់តែម្នាក់ឯង... ព្រះយេស៊ូអើយ! បើខ្ញុំម្ចាស់ចង់កត់ត្រាបំណងទាំងអស់ ខ្ញុំម្ចាស់ត្រូវខ្ចីសៀវភៅស្តីពីជីវិតរបស់ព្រះអង្គ ជាសៀវភៅដែលកត់គ្រប់សកម្មភាពរបស់សន្តបុគ្គលទាំងអស់ ហើយដើម្បីព្រះអង្គ ខ្ញុំម្ចាស់ចង់អនុវត្តតាមសកម្មភាពទាំងអស់នោះ...

ព្រះយេស៊ូអើយ តើព្រះអង្គឆ្លើយតបនឹងអំពើឆ្កួតលីលារបស់ខ្ញុំម្ចាស់ដូចម្តេចទៅ? តើមានព្រលឹងណាដែលតូច ទន់ខ្សោយជាងទូលព្រះបង្គំជាខ្ញុំទេ! ...

ប៉ុន្តែ ព្រះអង្គចូលចិត្តភាពទន់ខ្សោយរបស់ខ្ញុំម្ចាស់ ព្រះអង្គបំពេញបំណងតូចតាចរបស់កូនក្មេង ហើយឥឡូវនេះ ព្រះអង្គមានបំណងបំពេញចំណង់ធំជាងសកលលោកទៀតផង។

ពេលអធិដ្ឋាន ចំណង់ខ្ញុំធ្វើឲ្យរងទុក្ខដូចជាមរណសាក្សីពិតៗ ខ្ញុំបើកមើលសំបុត្ររបស់សន្តៈ ប៉ូល ដើម្បីរកចម្លើយខ្លះៗ។ ជំពូកទី១២ និង១៣ ក្នុងលិខិតមួយផ្ញើទៅពួកគ្រីស្តបរិស័ទនៅកូរិនថូស បានទាក់ចិត្តខ្ញុំ... លិខិតទីមួយរៀបរាប់ថាៈ ទាំងអស់គ្នាមិនអាចជាគ្រីស្តទូត ព្យាការី បណ្ឌិត។ល។ ទេ ព្រះសហគមន៍កើតចេញពីការរួមផ្សំនៃសរីរាង្គខុសៗគ្នា ភ្នែកមិនអាចជាដៃផងទេ។

ចម្លើយហាក់ដូចជាច្បាស់លាស់ហើយ ប៉ុន្តែ មិនអាចបំពេញបំណងខ្ញុំទេ ខ្ញុំនៅតែមិនស្ងប់... ដូចម៉ារីម៉ាដាឡា ឈ្ងោកមើលផ្នូរទទេរាល់ថ្ងៃ ទីបញ្ចប់ គាត់បានរកឃើញដូចបំណង។ ខ្ញុំក៏ដូច្នោះដែរ ខ្ញុំឱនសម្លឹងទៅក្នុងទីជម្រៅនៃភាពទទេស្អាតរបស់ខ្ញុំ ងើយខ្ពស់រហូតរកមិនឃើញទិសដៅ... ខ្ញុំអានលិខិតបន្តទៅទៀត ដោយឥតធុញទ្រាន់ ហើយមានឃ្លាមួយនេះធ្វើឲ្យខ្ញុំធូរចិត្ត... "ចូរប៉ងប្រាថ្នាចង់បានព្រះអំណោយទានណាដែលសំខាន់ជាងគេ។ ក៏ប៉ុន្តែ ខ្ញុំចង់ប្រាប់បងប្អូនអំពីមាគ៌ាមួយទៀតដែលប្រសើរលើសលប់បំផុត"។ គ្រីស្តទូតពន្យល់ថាព្រះអំណោយទានសុក្រឹតជាងគេ ក៏ឥតប្រយោជន៍ បើគ្មានសេចក្ដីស្រឡាញ់... សេចក្តីស្រឡាញ់ជាមាគ៌ាល្អបំផុត ដែលពិតជាអាចនាំទៅដល់ព្រះជាម្ចាស់។ ទីបំផុត ខ្ញុំបានស្ងប់ចិត្តហើយ។ ពិនិត្យមើលរចនាសម្ព័ន្ធព្រះសហគមន៍ទៅ ខ្លួនខ្ញុំមិនស្ថិតនៅក្នុងចំណោមសរីរាង្គណាមួយដែលសន្តៈ ប៉ូលរៀបរាប់ទេ... ឬខ្ញុំចង់ប្រដូចខ្លួនទៅសរីរាង្គទាំងនោះ... សេចក្តីស្រឡាញ់ផ្តល់កូនសោរមកឲ្យខ្ញុំបើកទ្វារទៅរកការត្រាស់ហៅ។ បើព្រះសហគមន៍ជាអង្គភាពប្រមូលផ្តុំសរីរាង្គខុសៗគ្នា អ្នកដែលចាំបាច់ អ្នកដែលសមរម្យជាងគេ មិនខ្វះទេ។ ព្រះសហគមន៍មានបេះដូងៗ នេះកំពុងតែដុតរោលដោយសេចក្តីស្រឡាញ់។ ខ្ញុំយល់ថា មាន

តែសេចក្តីស្រឡាញ់ទេ ដែលធ្វើឲ្យសរីរាង្គព្រះសហគមន៍មានសកម្មភាព បើសេចក្តីស្រឡាញ់រលត់ គ្រីស្តទូតលែងប្រកាសដំណឹងល្អ មរណសាក្សីមិនព្រមបូជាជីវិតទៀតទេ... ខ្ញុំយល់ថា សេចក្តីស្រឡាញ់ផ្ទុកទៅដោយការត្រាស់ហៅទាំងអស់ សេចក្តីស្រឡាញ់ជាអ្វីៗទាំងអស់ដែលគ្របដណ្តប់គ្រប់ពេល និងគ្រប់ទីកន្លែង និយាយដោយខ្លីទៅ សេចក្តីស្រឡាញ់ស្ថិតនៅអស់កល្បជានិច្ច...។

ដោយសប្បាយចិត្តជ្រុល ខ្ញុំស្រែកហ៊ោរក្នុងចិត្តថា៖ ឱព្រះយេស៊ូជាទីស្រឡាញ់អើយ ទីបំផុតខ្ញុំម្ចាស់រកឃើញការត្រាស់ហៅហើយ ការត្រាស់ហៅរបស់ខ្ញុំម្ចាស់ គឺសេចក្តីស្រឡាញ់! ... ។

មែនហើយ ខ្ញុំរកកន្លែងបានហើយនៅក្នុងព្រះសហគមន៍ ឱព្រះជាម្ចាស់អើយ! ព្រះអង្គជាអ្នកប្រទានកន្លែងនោះ... នៅក្នុងបេះដូងព្រះសហគមន៍។ អ្នកម៉ែ... ខ្ញុំនឹងជាសេចក្តីស្រឡាញ់... ដូច្នេះខ្ញុំនឹងជាអ្វីៗទាំងអស់... ក្តីស្រមៃរបស់ខ្ញុំនឹងមានរូបរាងហើយ! ... (...)

ព្រះអង្គជាទីស្រឡាញ់ នេះហើយជាការដុតកំលោចជីវិតរបស់ទូលព្រះបង្គំ... ទូលព្រះបង្គំជាខ្ញុំគ្មានមធ្យោបាយផ្សេង ដើម្បីបញ្ជាក់អំពីសេចក្តីស្រឡាញ់របស់ខ្ញុំម្ចាស់ទេ ក្រៅពីបាចផ្កា មានន័យថា មិនបោះបង់ការបូជាតូចតាចណាមួយឡើយ។ មិនបាច់គិតច្រើន ខ្ញុំម្ចាស់បំពេញគ្រប់កិច្ចការទាំងអស់ ទោះតិចតួចក្តីដោយសេចក្តីស្រឡាញ់... ទូលបង្គំចង់រងទុក្ខ និងរីករាយដោយសេចក្តីស្រឡាញ់ ខ្ញុំម្ចាស់នឹងបាចផ្កាពីមុខបល្លង្ករបស់ព្រះអង្គ ខ្ញុំម្ចាស់បានបកស្រទាប់ផ្កាទាំងអស់ថ្វាយព្រះអង្គ ហើយបាចផ្កាផង ច្រៀងផង (តើគេអាចយំដោយអំណរបានទេ?) ខ្ញុំម្ចាស់នឹងច្រៀង ទោះជាត្រូវបេះផ្កាក្នុងបន្លាក៏ដោយ ចម្រៀងនេះនឹងកាន់តែពីរោះឡើងៗ ក្នុងគ្រាដែលបន្លាកាន់តែវែង និងមុតស្រួច។ (...)

ព្រះយេស៊ូអើយ! ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ ខ្ញុំម្ចាស់ស្រឡាញ់ព្រះសហគមន៍ដែលជាមាតា ខ្ញុំនៅចាំថា៖ "កាយវិការតូចមួយនៃសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ

មានប្រយោជន៍ជាងស្នាដៃផ្សេងៗទៀតផ្តុំគ្នា..." ប៉ុន្តែ តើសេចក្តីស្រឡាញ់ដ៏បរិសុទ្ធនោះ មាននៅក្នុងបេះដូងខ្ញុំម្ចាស់ឬទេ?... បើបំណងដ៏ធំធេងរបស់ខ្ញុំម្ចាស់មិនមែនជាការស្រមៃឆ្កួតលីលាទេឬ? បើដូច្នោះ សូមព្រះអង្គបំភ្លឺខ្ញុំម្ចាស់ផង... ព្រះអង្គទ្រង់ជ្រាបហើយ... ខ្ញុំម្ចាស់ស្វែងរកសេចក្តីពិត... បើខ្ញុំម្ចាស់ហ៊ានជ្រុល សូមព្រះអង្គបំបាត់ចោលទៅ ព្រោះចំណង់ទាំងនោះជាមរណសាក្សីធំបំផុត ចំពោះខ្ញុំម្ចាស់... ប៉ុន្តែទូលព្រះបង្គំដឹងក្រោយពីឈានដល់តំបន់ខ្ពស់បំផុតនៃសេចក្តីស្រឡាញ់ ប្រសិនបើខ្ញុំម្ចាស់មិនត្រូវបានទៅដល់ទេ ថ្ងៃណាមួយខ្ញុំម្ចាស់នឹងរីករាយទទួលទុក្ខលំបាកជាមរណសាក្សីក្នុងអំពើឆ្កួតលីលារបស់ខ្ញុំម្ចាស់ នោះខ្ញុំម្ចាស់នឹងមិនបានទទួលសេចក្តីរីករាយនៃមាតុប្រទេសទេ លើកលែងតែមានអស្ចារ្យ សូមព្រះអង្គកុំដកហូតយកអនុស្សាវរីយ៍នៃសេចក្តីសង្ឃឹមលើផែនដីរបស់ខ្ញុំម្ចាស់ឡើយ។ ដូច្នោះ សូមទុកឲ្យខ្ញុំម្ចាស់បានរីករាយត្រេកត្រអាលនឹងសេចក្តីស្រឡាញ់ ក្នុងវេលានៃការនិរទេសខ្លួនផង។ សូមព្រះអង្គទុកឲ្យខ្ញុំម្ចាស់ក្រេបយកភាពល្វីងជូរចត់នៃមរណៈសាក្សីផង...។

ព្រះយេស៊ូអើយ ប្រសិនបើចំណង់នៃសេចក្តីស្រឡាញ់ចំពោះព្រះអង្គ មានរសជាតិឈ្ងុយឆ្ងាញ់យ៉ាងនេះ តើអ្វីទៅដែលហៅថាវង្វេងវង្វាន់ ត្រេកត្រអាលនឹងសេចក្តីស្រឡាញ់?

តើព្រលឹងមិនគ្រប់លក្ខណ៍ ដូចខ្ញុំម្ចាស់អាចទាក់ទាញយកសេចក្តីស្រឡាញ់ដ៏ពេញលេញដូចម្តេចទៅ? ព្រះយេស៊ូអើយ! ព្រះអង្គជាមិត្តដំបូង និងតែម្នាក់គត់របស់ខ្ញុំម្ចាស់ ខ្ញុំស្រឡាញ់តែព្រះអង្គ តើអ្វីទៅជាអាថ៌កំបាំងនេះ? ហេតុអ្វីបានជាទ្រង់មិនបម្រុងទុកការទាក់ទាញនេះសម្រាប់ព្រលឹងធំៗ ដូចសត្វឥន្ទ្រី ដែលហើរសំកាំងខាងលើ?... ខ្ញុំម្ចាស់ជាកូនបក្សីតូចទើបតែញាស់ មិនមែនជាសត្វឥន្ទ្រីទេ ប៉ុន្តែភ្នែក និងបេះដូងជាឥន្ទ្រី ទោះជាខ្ញុំម្ចាស់តូចក៏ពិតមែន ប៉ុន្តែហ៊ានសម្លឹងព្រះអាទិត្យនៃព្រះជាម្ចាស់ ដែលជាព្រះអាទិត្យនៃសេចក្តីស្រឡាញ់ ហើយ



បេះដូងខ្ញុំម្ចាស់ ទាក់ទាញព្រះអាទិត្យ ដូចបេះដូងឥន្ទ្រីដែរ...។ កូនបក្សីចង់ហើរ ហេតុដល់ព្រះអាទិត្យ ដ៏មានស្មើចែងចាំងនេះ ដែលទាក់ទាញភ្នែកបក្សីៗ ចង់ធ្វើត្រាប់តាមឥន្ទ្រីជាបងប្អូន ដែលអាចហើរខ្ពស់រហូតដល់លំនៅនៃព្រះជាម្ចាស់នៃព្រះត្រៃឯក... ប៉ុន្តែគួរឲ្យស្តាយ បក្សីតូចអាចធ្វើបានត្រឹមតែទទះស្លាប មិនអាចហើររួច តើបក្សីនឹងទៅជាអ្វី? ត្រូវស្លាប់ដោយដឹងខ្លួនថាឥតសមត្ថភាព? ទេ! កូនបក្សីមិនព្រួយឡើយ។ គេបោះបង់បំណងនេះដោយសេចក្តីក្លាហាន គេគ្រាន់តែចង់សម្លឹងព្រះអាទិត្យនៃព្រះជាម្ចាស់ គេមិនខ្លាចអ្វីឡើយ ទោះជាមានភ្លៀងខ្យល់ក៏ដោយ។ ប្រសិនបើពពកខ្មៅមកបិទបាំងតារានៃសេចក្តីស្រឡាញ់ កូនបក្សីមិនប្តូរទីតាំងទេ វាដឹងថាក្រោយពពកនោះ ព្រះអាទិត្យនៅតែភ្លឺចែងចាំងជានិច្ច។ ជួនកាលបេះដូងកូនបក្សីត្រូវបក់បោកដោយព្យុះសង្ឃរា វាហាក់ដូចមិនជឿថា មានអ្វីៗក្រៅពីពពកដែលហ៊ុំព័ទ្ធវាឡើយ ដូច្នេះហើយ ទើបវាត្រេកអរយ៉ាងខ្លាំង។ ជាសុភមង្គលសម្រាប់កូនបក្សី ដែលអាចឈរនៅទីនោះ សម្លឹងមើលពន្លឺដែលមើលមិនឃើញ បិទបាំងជំនឿរបស់វា!... ព្រះយេស៊ូអើយ រហូតដល់ពេលនេះ ខ្ញុំម្ចាស់យល់អំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ចំពោះកូនបក្សីដោយវាមិនទៅណាឆ្ងាយពីព្រះអង្គឡើយ... ខ្ញុំម្ចាស់ដឹងថា ព្រះអង្គក៏ដឹងដែរ ជារឿយៗសត្វលោកមិនគ្រប់លក្ខណ៍នេះ ភ្លេចខ្លួន ចឹកឆ្វេងចឹកស្តាំ រត់តាមដង្កូវ... រួចប្រទះថ្លុកទឹកតូចមួយ ធ្វើឲ្យវាទទឹកស្លាបដែលទើបនឹងដុះ វាឃើញផ្កាមួយទងគួរឲ្យស្រឡាញ់ ស្មារតីដ៏តូចរបស់វា គិតទៅដល់ផ្កា... ទីបំផុត ដោយវាមិនអាចហើរសំកាំងដូចឥន្ទ្រីបាន បក្សីកម្សត់គិតគូរតែរឿងកំប៉ិកកំប៉ុកលើផែនដីនេះតទៅទៀត... ក្រោយពីបានប្រព្រឹត្តកំហុសឆ្គងហើយ កូនបក្សីមិនចូលពួនកន្លែងណាមួយ ដើម្បីយំសោកបោកខ្លួនទេ គេងាកទៅរកព្រះអាទិត្យជាទីស្រឡាញ់ត្រដាងស្លាប បែរទៅរកកាំរស្មី ដែលផ្តល់ភាពកក់ក្តៅដល់កូនស្លាបទទឹករបស់គេៗ គេថ្ងូចថ្ងូរដូចសត្វត្រចៀកកាំ សារភាពរៀបរាប់យ៉ាងលំអិត អំពីចិត្តសាវាគ្មានភក្តីភាព គិតថាខ្លួនចិត្តធំជ្រុល ហ៊ានបំបរបង់ខ្លួន ចង់បានអាណាចក្រនឹង

ទាក់ទាញសេចក្តីស្រឡាញ់នៃព្រះជាម្ចាស់ ដែលមិនបានមករកអ្នកសុចរិតទេ បែរជារកអ្នកប្រព្រឹត្តអំពើបាបទៅវិញ... ប្រសិនបើតារាជាទីស្រឡាញ់ ធ្វើជាមិនឮសំឡេងត្អូញត្អែររបស់សត្វដែលទ្រង់បង្កើតមកទេ ឬក៏មិនព្រមបញ្ចេញរស្មីនោះ កូនបក្សីនៅតែទទឹកស្លាប រងារញ័រញាក់ រីករាយនឹងទទួលទុក្ខលំបាកដែលខ្លួនបានធ្វើ... ព្រះយេស៊ូអើយ! សូមឲ្យកូនបក្សីរបស់ព្រះអង្គបានរីករាយក្នុងភាពទន់ខ្សោយ និងតូចទាបនេះផង តើគេធំឡើងនឹងក្លាយជាអ្វី?... គេគ្មានចិត្តអង់អាចហ៊ានបង្ហាញខ្លួន ឬងុយងោកចំពោះព្រះភក្ត្រព្រះអង្គទេ នេះហើយជាភាពទន់ខ្សោយរបស់កូនបក្សី។ កាលបើគេក្រលេកមើលចំទៅព្រះអាទិត្យនៃព្រះជាម្ចាស់ដែលមានពពកបាំងជិតពន្លឺ ទោះជាគេខិតខំយ៉ាងណាក៏ដោយ ភ្នែកតូចរបស់គេបិទជិត លាក់ក្បាលក្រោមកូនស្លាប ដេកលក់ ដោយគិតថាខ្លួនកំពុងសម្លឹងមើលទៅតារាជាទីស្រឡាញ់។ ពេលដឹងខ្លួនគេមិនស្តាយក្រោយទេ បេះដូងដ៏តូចរបស់គេស្ងប់ គេក៏ចាប់ផ្តើមច្រៀងសេចក្តីស្រឡាញ់ គេបន់ស្រន់ចំពោះទេវទូត និងសន្តបុគ្គលនានា ដែលបានឡើងទៅលើ ដូចឥន្ទ្រីឆ្ពោះទៅស្ថានបរមសុខដែលគេប្រាថ្នា។ ឥន្ទ្រីទាំងនោះនឹងអាណិតដល់ប្អូនតូច ក៏ការពារគេ ដេញពួកត្មាតដែលប្រាថ្នាខាំត្របាក់កូនបក្សី ឲ្យរត់ប្រាសអាយុ។ ត្មាតជាពួកអារក្ស កូនបក្សីមិនខ្លាចពួកវាទេ គេមិនមែនជាចំណីរបស់ពួកត្មាតឡើយ ប៉ុន្តែជាចំណីឥន្ទ្រីដែលគេគយគន់ក្នុងមណ្ឌលព្រះអាទិត្យជាទីស្រឡាញ់។ ឱព្រះបុត្រានៃព្រះជាម្ចាស់អើយ ព្រះអង្គជាឥន្ទ្រីដែលខ្ញុំម្ចាស់គោរព និងស្រឡាញ់ ព្រះអង្គបានទាក់ទាញចិត្តខ្ញុំម្ចាស់ គឺព្រះអង្គបានហោះហើរហូតដល់ទីនិរទេសខ្លួន ដើម្បីរងទុក្ខលំបាក និងសោយទិវង្គត ដើម្បីឲ្យព្រលឹងទាំងអស់ ដែលទៅតាមព្រះអង្គរហូតដល់ស្ថានបរមសុខ ជាលំនៅនៃព្រះត្រៃឯក ដែលជាទីរីករាយក្រៃលែង។ ទ្រង់បានពុះពាររហូតទាល់តែឆ្លងដល់ស្ថាននៃពន្លឺ ដែលជាស្ថានរបស់ព្រះអង្គៗ ជាអ្នកស្នាក់នៅក្នុងជ្រលងភ្នំទឹកភ្នែក លាក់ព្រះកាយក្នុងនំតង្វាយ ឥន្ទ្រីនៃព្រះជាម្ចាស់ សូមព្រះអង្គផ្តល់អាហារដែលមានរសជាតិ ឲ្យខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់ជាសត្វលោក

ដ៏កម្សត់ បើព្រះអង្គមិនបែរព្រះនេត្រ មកទតមើលជីវិតរបស់ខ្ញុំម្ចាស់ទេ នោះខ្ញុំម្ចាស់នឹងត្រលប់ទៅកន្លែងសោះសូន្យជាមិនខាន... ឱព្រះយេស៊ូ! ខ្ញុំម្ចាស់សូមថ្លែងអំណរព្រះគុណជាពន្លឹក សូមទុកឲ្យខ្ញុំម្ចាស់ពោលថា ខ្ញុំម្ចាស់វង្វេងវង្វាន់ព្រោះព្រះអង្គ... តើព្រះអង្គមានបំណងដូចម្ដេច ចំពោះការវង្វេងវង្វាន់នេះ? តើបេះដូងខ្ញុំម្ចាស់មិនរត់ទៅរកព្រះអង្គទេឬ? ការទុកចិត្តរបស់ខ្ញុំម្ចាស់ មានទីកំណត់យ៉ាងណា...។ ឱ ខ្ញុំម្ចាស់ដឹងហើយ! ចំពោះព្រះអង្គ សន្តបុគ្គលក៏ធ្លាប់វង្វេងវង្វាន់ដែរ ពួកលោកបានបំពេញសកម្មភាពធំៗ ព្រោះពួកលោកជាឥន្ទ្រី...។

ព្រះយេស៊ូ ខ្ញុំម្ចាស់តូចទាបណាស់ មិនអាចបំពេញកិច្ចការធំបានទេ... ភាពវង្វេងរបស់ខ្ញុំម្ចាស់ សង្ឃឹមលើសេចក្ដីស្រឡាញ់របស់ព្រះអង្គ ដែលព្រមទទួលរូបខ្ញុំម្ចាស់ជាដង្វាយ... អំពើវង្វេងវង្វាន់របស់ខ្ញុំម្ចាស់ គឺអង្វរសូមឲ្យឥន្ទ្រីដែលជារៀមច្បងទាំងអស់ ប្រគល់សិទ្ធិឲ្យខ្ញុំបានហោះហើរទៅរកព្រះអាទិត្យនៃសេចក្ដីស្រឡាញ់ ដោយស្លាបឥន្ទ្រីព្រះជាម្ចាស់ផ្ទាល់ផង...

ពេលណាក៏បានដែរ តាមតែព្រះហឫទ័យព្រះអង្គជាទីស្រឡាញ់អើយ! កូនបក្សីរបស់ព្រះអង្គ នៅតែគ្មានកម្លាំង គ្មានស្លាប គេនៅតែបើកភ្នែកសម្លឹងទៅព្រះអង្គជានិច្ច គេចង់ជាប់ស្នេហ៍ព្រះនេត្ររបស់ព្រះអង្គ គេចង់ក្លាយទៅជាចំណីនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ...។ ខ្ញុំម្ចាស់នៅមានសង្ឃឹមថា ថ្ងៃណាមួយ ឥន្ទ្រីជាទីស្រឡាញ់ព្រះអង្គនឹងយាងមករកកូនបក្សី ហើយហើរនាំគេទៅស្ថានបរមសុខនៃសេចក្ដីស្រឡាញ់ ព្រះអង្គនឹងបោះគេចូលទៅក្នុងជ្រោះភ្លើងនៃសេចក្ដីស្រឡាញ់នេះជារៀងរហូត ដែលគេប្រគល់ខ្លួនជាតង្វាយ...

ព្រះយេស៊ូអើយ! ទូលព្រះបង្គំមិនអាចប្រាប់ទៅព្រលឹងតូចៗឯទៀតថា ធម៌មេត្តារបស់ព្រះអង្គ មិនអាចថ្លែងពន្យល់បានទេ ខ្ញុំម្ចាស់ដឹងថា ប្រសិនបើព្រះអង្គរកមិនបានព្រលឹងទន់ខ្សោយ និងតូចជាងខ្ញុំម្ចាស់ទៀតនោះ ព្រះអង្គ

មុខជាគាប់ព្រះហឫទ័យ ផ្តល់អំណោយធំជាងមុនថែមទៀត បើព្រលឹងនេះលះបង់ខ្លួន ផ្ញើជីវិតទាំងស្រុងលើសេចក្តីមេត្តាករុណាជាអនេករបស់ព្រះអង្គ។ ប៉ុន្តែ ហេតុអ្វីបានជាព្រះអង្គប្រាថ្នាប្រគល់អាថ៌កំបាំងនៃសេចក្តីស្រឡាញ់នេះ? ព្រះអង្គអើយ មិនមែនព្រះអង្គទេឬ ដែលបង្រៀនខ្ញុំម្ចាស់ ហើយហេតុដូចម្តេចបានជាព្រះអង្គមិនអាចប្រាប់អ្នកឯទៀតឲ្យដឹងផង?... មែនហើយខ្ញុំម្ចាស់ដឹង ខ្ញុំម្ចាស់ប្តេជ្ញាថា នឹងបំពេញកិច្ចការនេះទាល់តែបានសម្រេច សូមព្រះអង្គមេត្តាបន្ទាបព្រះនេត្រទតមកព្រលឹងតូចៗមួយចំនួយធំ ខ្ញុំម្ចាស់សូមអង្វរ សូមព្រះអង្គរើសយកតង្វាយតូចៗ ដែលសក្តិសមនឹងសេចក្តីស្រឡាញ់របស់ព្រះអង្គ ឲ្យបានច្រើនផង! ...

**សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និង ព្រះភក្ត្រដ៏វិសុទ្ធ**

**សៀវភៅសរសេរជូនចំពោះ អ្នកម៉ែ ម៉ារីដឺកុងសាក**

**សៀវភៅ "គ"**

# ភាពងងឹតនៃជំនឿ

**( ១៨៩៦ - ១៨៩៧ )**

ឱ អ្នកម៉ែ! ខ្ញុំដឹងថា ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈអ្នកម៉ែជានិច្ច។ មានដូនជីជាច្រើន គិតថា អ្នកម៉ែទម្រើសខ្ញុំ ថាតាំងពីខ្ញុំចូលមកនៅក្នុងអារាម នេះ អ្នកម៉ែលួងលោម និងសរសើរខ្ញុំឥតដាច់។ តាមពិតទៅ មិនដូច្នោះទេ សូម អ្នកម៉ែអានសៀវភៅកំណត់អនុស្សាវរីយ៍អំពីកុមារភាពរបស់ខ្ញុំ អ្នកម៉ែនឹងឃើញ នូវអ្វីៗ ដែលខ្ញុំគិតអំពីការអប់រំដ៏តឹងរឹង និងមាតុភាព ដែលខ្ញុំបានទទួលពីអ្នក។ ខ្ញុំសូមថ្លែងអំណរគុណអស់ពីដួងចិត្ត ចំពោះអ្នកម៉ែ ដែលមិនបានទម្រើសខ្ញុំ។ ព្រះយេស៊ូទ្រង់ស្គាល់ច្បាស់ថា ផ្កាតូចរបស់ព្រះអង្គ ទឹកលើកកម្លាំងនៃការចេះ ដាក់ខ្លួន ព្រោះផ្កានៅទន់ខ្សោយណាស់ មិនអាចចាក់ឫស ដោយគ្មានការសង្គ្រោះ នេះទេ ហើយព្រះអង្គផ្សាយមេត្តាធម៌នេះ តាមរយៈអ្នកម៉ែ។

មួយឆ្នាំកន្លះមកនេះ ព្រះយេស៊ូមានបំណងផ្លាស់ប្តូររបៀបដាំផ្កាតូច ព្រះអង្គឈ្វេងយល់ថា ការស្រោចល្មមគ្រប់គ្រាន់ហើយ ដល់វេនព្រះអាទិត្យជាអ្នកធ្វើឲ្យលូតលាស់ម្តង។ ទ្រង់លែងចង់ប្រទានភាពញញឹម លួងលោមតាមរយៈអ្នកម៉ែទៀតហើយ។ កម្តៅដ៏ស្រទន់របស់ព្រះអាទិត្យនេះ មិនបានធ្វើឲ្យផ្កាស្វិតស្រពោនទេ ផ្ទុយទៅវិញ ផ្កាលូតលាស់យ៉ាងល្អ។ តំណក់ទឹកដក់ក្នុងស្រទាប់ផ្កាអ្វីឲ្យនាងគិតថា ខ្លួននៅតូចទន់ខ្សោយជានិច្ច... សត្វលោកអាចបន្ទាបខ្លួនគយគន់មើលផ្កា ពោលពាក្យសរសើរ ខ្ញុំមិនដឹងថាព្រោះអ្វីទេ ប៉ុន្តែនោះគ្រាន់តែជាការបន្ថែមការរីករាយ ក្លែងក្លាយបន្តិចបន្តួចទៅលើសេចក្តីរីករាយពិតប្រាកដដែលមាននៅក្នុងចិត្ត ព្រោះផ្កាយល់ថា ខ្លួនគ្រាន់តែជាភាពទទេតូចមួយ ចំពោះព្រះនេត្រព្រះជាម្ចាស់ប៉ុណ្ណោះ ដែលផ្កាត្រូវបានការពារមិនឲ្យទទួលការសរសើរគ្រប់ពេល ទើបត្របកផ្កាគ្មានដក់សន្សើមនៃចិត្តសុភាពរាបសាគ្រប់គ្រាន់ពិតមែនទេឬ? ឥឡូវនេះ គ្មានអ្វីគួរឲ្យបារម្ភឡើយ ផ្កាតូចយល់ថា សន្សើមដែលដក់ជាប់ត្របករបស់ខ្លួននេះ ប្រសើរជាងទឹកភ្លាវនៃការសរសើរ។

អ្នកម៉ែ! ខ្ញុំមិនបាច់ជម្រាបជូនអំពីសេចក្តីស្រឡាញ់ និងការជឿទុកចិត្តដែលអ្នកធ្លាប់មានចំពោះកូនឡើយ កូនមិនភ្លេចទេ ប៉ុន្តែឥឡូវនេះ គ្មានអ្វីគួរបារម្ភឡើយ ផ្ទុយទៅវិញ ខ្ញុំរីករាយនឹងតបស្នងទៅព្រះជាម្ចាស់វិញ ដោយព្រះអង្គបានប្រទាននូវអ្វីៗដែលល្អចំពោះខ្ញុំ តែបើព្រះអង្គប្រទានឲ្យខ្ញុំកាន់តែប្រសើរថែមទៀត តាមតែព្រះហឫទ័យព្រះអង្គទៅចុះ... អ្នកម៉ែ! មាគ៌ាដែលព្រះជាម្ចាស់ដឹកនាំព្រលឹងទាំងអស់ មិនដូចគ្នាទេ! ជីវិតសន្តបុគ្គលខុសពីយើងឆ្ងាយណាស់ ក្រោយពីស្លាប់ ពួកលោកមិនបានទុកអនុស្សាវរីយ៍ ឬសំណេរអ្វីឡើយ ប៉ុន្តែសន្តបុគ្គលជាច្រើនបានធ្វើឲ្យព្រះសហគមន៍យើងបានទទួលការសម្តែងឲ្យដឹងដ៏ខ្ពង់ខ្ពស់ តាមរយៈសន្តី ថេរេសា (នៃអាវីឡា) ជាដើម ព្រះអង្គមិនខ្លាចនឹងសម្តែងប្រាប់ឲ្យគេដឹងអំពីអាថ៌កំបាំងរបស់ព្រះមហាក្សត្រទេ ដើម្បីឲ្យគេស្គាល់

និងស្រឡាញ់ព្រះអង្គកាន់តែច្រើន។ សន្តបុគ្គលទាំងពីរប្រភេទនេះ តើព្រះអង្គគាប់ព្រះហឫទ័យ និងសន្តបុគ្គលប្រភេទណា? បើតាមខ្ញុំ ខ្ញុំយល់ថាទ្រង់គាប់ព្រះហឫទ័យទាំងអស់ ព្រោះពួកលោកបានដើរតាមមាគ៌ានៃព្រះវិញ្ញាណដ៏វិសុទ្ធ ហើយព្រះជាម្ចាស់មានព្រះបន្ទូលៈ ចូរប្រាប់ទៅអ្នកសុចរិតថា អ្វីៗទាំងអស់ប្រសើរហើយ។ មែនហើយ ប្រសើរលុះត្រាដែលគេមិនស្វែងរកអ្វីៗ ក្រៅពីបំណងរបស់ព្រះយេស៊ូ ដូច្នេះហើយខ្ញុំដែលជាកូនផ្កាតូច ខិតខំគោរពតាមព្រះយេស៊ូដើម្បីឲ្យអ្នកម៉ែបានសប្បាយចិត្ត។

អ្នកម៉ែជ្រាបទេ ខ្ញុំតែងតែចង់ក្លាយជាសន្តីមួយរូប ប៉ុន្តែគួរឲ្យស្តាយ កាលបើខ្ញុំប្រៀបធៀមខ្លួនឯងទៅសន្តបុគ្គលម្តងមួយ ខ្ញុំយល់ថា ខុសគ្នាដូចភ្នំ និងគ្រាប់ខ្សាច់ តែខ្ញុំមិនអស់សង្ឃឹមទេ ហើយប្រាប់ខ្លួនឯងថាៈ ព្រះជាម្ចាស់មិនណែនាំនូវចំណង់ដែលមិនអាចធ្វើកើតទេ ទោះជាខ្ញុំតូចទន់ខ្សោយក៏ដោយ ខ្ញុំនឹងអាចទៅជាសន្តីដ៏វិសុទ្ធបាន បើចង់ក្លាយជាធំ ទៅមិនរួចទេ ខ្ញុំត្រូវតែទ្រាំទ្រទៅតាមលក្ខណៈខ្វះខាតរបស់ខ្លួន តែខ្ញុំចង់រកមធ្យោបាយឲ្យបានទៅដល់ស្ថានបរមសុខតាមមាគ៌ាដ៏ត្រង់តូចមួយ មាគ៌ាតូចដែលខ្លី ហើយថ្មី ខុសប្លែកពីគេ។ យើងរស់ក្នុងសម័យកត្តកម្ម (សម័យកាលបង្កើតឆ្នៃប្រឌិត) ឥឡូវនេះ នៅតាមផ្ទះអ្នកមានទ្រព្យច្រើន គេប្រើជណ្តើរយន្ត មិនចាំបាច់លំបាកឈានឡើងជណ្តើរដូចមុនឡើយ។ ខ្ញុំក៏ចង់រកជណ្តើរយន្តជិះឡើងទៅព្រះយេស៊ូដែរ ព្រោះខ្ញុំតូច មិនអាចឡើងជណ្តើរចោតនៃភាពគ្រប់លក្ខណ៍បានឡើយ។ ដូច្នោះហើយខ្ញុំស្វែងរកសៀវភៅសន្តបុគ្គល ដែលអាចចង្អុលបង្ហាញជណ្តើរយន្ត ដែលខ្ញុំប្រាថ្នា ហើយខ្ញុំបានឃើញសម្តីទាំងនេះ ដែលចេញពីព្រះឧស្ឋនៃបណ្ឌិតដែលរស់នៅអស់កល្បជានិច្ចថាៈ បើអ្នកណាតូច (ទន់ខ្សោយ) សូមមករកខ្ញុំ។ ឱ ព្រះជាម្ចាស់អើយ! ដោយគិតថា ទូលព្រះបង្គំជាខ្ញុំ បានរកឃើញវត្ថុជាទីប្រាថ្នា ហើយខ្ញុំម្ចាស់ក៏មករកព្រះអង្គ រួចខ្ញុំម្ចាស់បន្តការស្រាវជ្រាវតទៅទៀត ហើយរកឃើញថាៈ ខ្ញុំនឹង

ល្បួងលោមអ្នក ដូចម្ដាយបបោសអង្អែលកូន ខ្ញុំនឹងឱបអ្នកជាប់ដើមទ្រូង នឹងយោលអ្នកលើជង្គង់របស់ខ្ញុំ! គ្មានសម្ដីណាស្រទន់ពិរោះរណ្ដំ មកធ្វើឲ្យខ្ញុំម្ចាស់ពេញចិត្តជាងនេះទេ។ ជណ្ដើរយន្តដែលត្រូវនាំខ្ញុំម្ចាស់ទៅស្ថានបរមសុខ គឺព្រះហស្ដទាំងទ្វេរបស់ព្រះអង្គ ឱព្រះយេស៊ូអើយ! ខ្ញុំម្ចាស់មិនចង់ធំទេ ខ្ញុំម្ចាស់ចង់នៅតូចជានិច្ច។ ព្រះជាម្ចាស់អើយ! ព្រះអង្គបានជួយខ្ញុំម្ចាស់ច្រើនហួសសេចក្ដីប្រាថ្នារបស់ខ្ញុំម្ចាស់ទៅហើយៗ ខ្ញុំម្ចាស់ចង់ច្រៀងលើកតម្កើងធម៌មេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ។ *"ព្រះអង្គបង្រៀនខ្ញុំម្ចាស់តាំងពីក្មេង រហូតដល់សព្វថ្ងៃនេះ ខ្ញុំម្ចាស់បានប្រកាសប្រាប់គេឯងអំពីស្នាព្រះហស្ដដ៏អស្ចារ្យរបស់ព្រះអង្គ ខ្ញុំម្ចាស់នឹងបន្តប្រកាសរហូតដល់ចាស់"* (ទក ១២០)។ តើវ័យចាស់របស់ខ្ញុំម្ចាស់យ៉ាងណាទៅ? ប្រហែលជាពេលនេះហើយ ព្រោះសម្រាប់ព្រះអង្គ ២០០០ឆ្នាំ មិនគាប់ព្រះហឫទ័យជាង ២០ឆ្នាំ ឬ ១ថ្ងៃទេ... សូមអ្នកម៉ែកុំគិតថាកូនចង់ចោលម៉ែឡើយ... កុំគិតថាកូនទុកការស្លាប់នៅពេលព្រឹកព្រលឹម មានតម្លៃជាងវេលាថ្ងៃរៀបលិចអី។ តម្លៃដែលជាបំណងតែមួយគត់របស់កូន គឺផ្គាប់ព្រះហឫទ័យនៃព្រះយេស៊ូ។ ឥឡូវនេះ ព្រះអង្គហាក់ដូចជាខិតមកជិត ដើម្បីទាក់ទាញកូនទៅកាន់ស្ថាននៃសិរីរុងរឿងរបស់ព្រះអង្គ ហើយកូនត្រេកអរណាស់។ តាំងពីយូរមកហើយ កូនយល់ថា ព្រះជាម្ចាស់មិនត្រូវការនរណាម្នាក់ (ព្រះអង្គកាន់តែមិនត្រូវការកូនជាងអ្នកឯទៀតផង) ដើម្បីធ្វើអំពើល្អលើផែនដីទេ។ (...)

អ្នកម៉ែជាទីស្រឡាញ់ ម៉ែមិនខ្លាចនិយាយថា ព្រះជាម្ចាស់បានបំភ្លឺព្រលឹងខ្ញុំថា ព្រះអង្គបានប្រទានបទពិសោធន៍យូរអង្វែងមកឲ្យខ្ញុំ... អ្នកម៉ែអើយ! ឥឡូវនេះ ខ្ញុំនៅក្មេងខ្ចីពេក ដើម្បីមានអំនួត ក្មេងពេក ដើម្បីរៀបចំឃ្លាល្បះ ដើម្បីឲ្យអ្នកម៉ែជឿថា ខ្ញុំមិនលើកកំពស់ខ្លួនឯង ខ្ញុំគ្រាន់តែសូមឲ្យព្រះជាម្ចាស់ដ៏មានឫទ្ធានុភាព ប្រទានអ្វីៗធំល្មមនឹងព្រលឹងបុត្រារបស់ព្រះមាតា ធំជាងនេះទៅទៀត គឺបង្ហាញប្រាប់ព្រះអង្គនូវភាពតូចទន់ខ្សោយ អសមត្ថភាពរបស់ខ្ញុំ។ ដូច

អ្នកម៉ែជ្រាបស្រាប់មកហើយ ព្រះជាម្ចាស់ប្រទានការលំបាកជាច្រើនលើកច្រើនសារមកឲ្យខ្ញុំៗ ទទួលការឈឺចាប់យ៉ាងច្រើន តាំងពីខ្ញុំមានកំណើតលើភពផែនដីនេះ ប៉ុន្តែទោះជាកុមារភាពរបស់ខ្ញុំពោរពេញទៅដោយទុក្ខក្រៀមក្រំយ៉ាងណាក៏ដោយ ឥឡូវនេះ ខ្ញុំមិនរងទុក្ខលំបាកដូចមុនទេ ខ្ញុំសប្បាយនឹងរងទុក្ខលំបាក ដោយសេចក្ដីរីករាយ និងស្ងប់ៗ អ្នកម៉ែ! ទាល់តែម៉ែស្គាល់អាថ៌កំបាំងទាំងអស់នៃព្រលឹងខ្ញុំ ទើបម៉ែមិនអស់សំណើច ក្នុងការអានសំនេរនេះ តើមានព្រលឹងណាដែលរំភើបជាងខ្ញុំ បើគេវិនិច្ឆ័យតាមរូបភាពខាងក្រៅ? ឱ! បើសិនជាការលំបាកដែលខ្ញុំបានទទួលតាំងពីមួយឆ្នាំមកនេះ លេចចេញមកខាងក្រៅ តើគួរឲ្យឆ្ងល់ទេ?... (...)

ឆ្នាំមុន ព្រះជាម្ចាស់ទ្រង់ប្រទានការល្បួងលោម ដោយពិនិត្យលើការតមអាហារនៃបុណ្យរដូវសែសិបថ្ងៃ តាំងតឹងរ៉ឹង ខ្ញុំមិនដែលមានអារម្មណ៍ថា មានកម្លាំងខ្លាំងដូចលើកនេះទេ ថាមពលនេះនៅស្ថិតស្ថេររហូតដល់បុណ្យចម្លងៗ ប៉ុន្តែ នៅថ្ងៃសុក្រពិសិដ្ឋ ព្រះយេស៊ូមានបំណងប្រទានសេចក្ដីសង្ឃឹមឲ្យខ្ញុំទៅជួបព្រះអង្គនៅស្ថានបរមសុខ ក្នុងពេលឆាប់ៗនេះ... អនុស្សាវរីយ៍នេះ ផ្អែមល្ហែមណាស់សម្រាប់ខ្ញុំ!... ក្រោយពីស្មឹងស្មាធក្បែរព្រះផ្នូរ រហូតដល់ពាក់កណ្ដាលអាធ្រាត ខ្ញុំក៏ចូលទៅក្នុងបន្ទប់ៗ គ្រាន់តែដាក់ក្បាលដល់ខ្នើយ ខ្ញុំមានអារម្មណ៍ថា ទឹកជន់ឡើងៗរហូតដល់បបូរមាត់ៗ កាលនោះ ខ្ញុំមិនដឹងថាជាអ្វីទេ តែខ្ញុំគិតថា ប្រហែលជាខ្ញុំជិតស្លាប់ហើយៗ ខ្ញុំត្រេកអរណាស់... ដោយយើងបានផ្លុំចង្កៀងពន្លត់រួចស្រេចទៅហើយ ខ្ញុំគិតថា ចាំព្រឹកសឹមគិតតទៅទៀត ព្រោះខ្ញុំហាក់ដូចជាដឹងថាខ្ញុំក្អួតឈាមៗ ពេលព្រឹកឡើង កាលបើដឹងខ្លួនភ្លាម ក៏នឹកទៅដល់រឿងសប្បាយដែលគួរនិយាយប្រាប់គេឯង ខ្ញុំដើរទៅក្បែរបង្អួច ទើបខ្ញុំដឹងថា... មិនខុសទេ... ឱ! វេលានោះ ព្រលឹងខ្ញុំពោរពេញទៅដោយការល្បួងលោម ព្រះយេស៊ូយាងមកហៅខ្ញុំលើកទីមួយ នៅថ្ងៃខួបនៃការសុគតរបស់ព្រះអង្គ ខ្ញុំ

ជឿជាក់។ ហាក់ដូចជាមានសំឡេងខ្សឹបតិចៗពីចម្ងាយប្រាប់ថា ព្រះស្វាមីយាង មកហើយ... ខ្ញុំបានចូលរួមសូត្រអធិដ្ឋានពេលព្រឹក (...) ប្រកបដោយចិត្តពុះពោរយ៉ាងខ្លាំង។ កាលនោះ ខ្ញុំទន្ទឹងរង់ចាំវេនខ្ញុំ ដើម្បីជម្រាបជូនអ្នកម៉ែអំពីសេចក្តីសង្ឃឹម និងសុភមង្គលរបស់ខ្ញុំ ប៉ុន្តែខ្ញុំបន្ថែមថា ខ្ញុំឥតមានការឈឺចាប់ទេ មិនបាច់ព្យាបាលឡើយ។ តាមការពិតខ្ញុំបានធូរស្រាលចិត្ត ដោយចូលរួមថ្ងៃសុក្រពិសិដ្ឋដូចបំណង។ ភាពតឹងរ៉ឹងនៅកាមែលកន្លងមក ហាក់ដូចជាមិនដែលផ្តល់ការរីករាយជាពន្លឺកដូចពេលនេះឡើយ សេចក្តីសង្ឃឹមថាបានទៅស្ថានបរមសុខ បានលើកខ្ញុំទៅដាក់កន្លែងគួររីករាយយ៉ាងខ្លាំង។ ល្ងាចនៃប្រកបដោយសុភមង្គលនោះបានមកដល់ ត្រូវតែសម្រាក ប៉ុន្តែដូចយប់មុនដែរ ព្រះយេស៊ូប្រទានសញ្ញាថា ការចូលទៅរស់នៅស្ថានបរមសុខមិនយូរទេ...

ពេលនោះ ខ្ញុំត្រេកអរ និងមានជំនឿយ៉ាងខ្លាំងក្លា ច្បាស់លាស់ថា ព្រះជាម្ចាស់មានបំណងធ្វើអ្វីៗទាំងអស់ ដើម្បីសុភមង្គលខ្ញុំៗ មិនយល់សោះថា ហេតុអ្វីក៏មានអ្នកប្រមាថសាសនា គ្មានជំនឿលើព្រះអង្គ។ ខ្ញុំជឿថា ពួកគេនិយាយផ្ទុយនឹងគំនិត ដោយមិនព្រមទទួលថា មានស្ថានបរមសុខ ជាស្ថានដែលព្រះជាម្ចាស់ មានព្រះបំណងផ្តល់ជារង្វាន់ដែលមិនសាបសូន្យ ដោយព្រះអង្គផ្ទាល់។ នៅថ្ងៃបុណ្យចម្លងដ៏រីករាយ ព្រះយេស៊ូត្រាស់ឲ្យដឹងថា ពិតជាមានអ្នកឥតជំនឿ ដែលបាត់បង់កំណាប់ដ៏មានតម្លៃនេះ ជាប្រភពនៃសេចក្តីរីករាយដ៏បរិសុទ្ធ និងពិតប្រាកដ។ ព្រះអង្គអនុញ្ញាតឲ្យព្រលឹងខ្ញុំ ត្រូវរាគត្បាតដោយស្បៃអន្ធការក្រាសឃ្មឹក ហើយគំនិតនៃព្រះជាម្ចាស់ ដែលស្លូតស្រទន់ក្លាយទៅជាប្រធានបទនៃការប្រយុទ្ធ និងវិបល្លាស... ការសាកល្បងនេះ មានរយៈពេលតែពីរបីថ្ងៃ ពីរបីសប្តាហ៍ វាអាចរលាយបាត់ទៅតាមព្រះបំណងរបស់ព្រះជាម្ចាស់... ប៉ុន្តែពេលនោះមិនទាន់មកដល់ទេ... ខ្ញុំចង់រៀបរាប់ទៅតាមការដែលខ្ញុំដឹង ប៉ុន្តែគួរឲ្យស្តាយ ខ្ញុំនិយាយមិនកើត។ គេត្រូវធ្វើដំណើរតាមរូងក្រោមដី ងងឹតសូន្យសុងនេះសិន ទើបយល់អំពីភាពងងឹតនោះ។ ប៉ុន្តែ ខ្ញុំអាច



សាកល្បងពន្យល់ដោយការប្រៀបធៀប។

ឧបមាថា ខ្ញុំកើតក្នុងប្រទេសមួយដែលហ៊ុំព័ទ្ធដោយអ័ព្ទក្រាសឃ្មឹក ខ្ញុំមិនដែលបានគយគន់មើលធម្មជាតិស្រស់ញញឹម ផ្លាស់ប្តូរដោយពន្លឺព្រះអាទិត្យឡើយ។ តាំងពីក្មេងមក ខ្ញុំឮគេនិយាយអំពីអច្ឆរិយវត្ថុទាំងនោះ ខ្ញុំដឹងថាប្រទេសដែលខ្ញុំរស់នៅមិនមែនជាមាតុប្រទេសទេ ខ្ញុំតែងតែនឹកដល់កន្លែងមួយទៀតឥតស្រាកស្រាន្ត។ មិនមែនជារឿងប្រឌិត ដោយប្រជាជនម្នាក់នៃប្រទេសដ៏ក្រៀមក្រំដែលខ្ញុំរស់នៅទេ គឺជាការពិតប្រាកដមួយ ព្រោះព្រះរាជានៃប្រទេសដែលបំភ្លឺដោយព្រះអាទិត្យ មករស់នៅ ៣៣ឆ្នាំ ក្នុងប្រទេសងងឹត។ គួរឲ្យស្តាយភាពងងឹតមិនយល់ថា ព្រះរាជានោះជាពន្លឺនៃពិភពលោកទេ... ប៉ុន្តែ ព្រះជាម្ចាស់អើយ! បុត្រីរបស់ព្រះអង្គយល់ច្បាស់អំពីពន្លឺនៃព្រះជាម្ចាស់នេះហើយ នាងសូមព្រះអង្គលើកលែងទោសដល់បងប្អូននាងៗ សុខចិត្តទទួលទុក្ខលំបាកតាមតែព្រះរាជហឫទ័យ នាងមិនព្រមងើបចេញពីភាពល្វីងជូរចត់ ដែលបាបជនត្រូវទទួលមុនថ្ងៃកំណត់ឡើយ... ដូច្នេះនាងសូមអង្វរ ក្នុងនាមខ្លួនឯង និងជំនួសឲ្យបងប្អូននាង៖ ព្រះអង្គអើយ! សូមមេត្តាដល់ពួកយើងផង ព្រោះយើងជាបាបជនដ៏កម្សត់!... ព្រះជាម្ចាស់! សូមបញ្ជូនពួកយើងទៅពន្យល់ បង្ហាញសេចក្តីសុចរិតផង... សូមអ្នកដែលមិនបានទទួលពន្លឺនៃជំនឿ បានបំភ្លឺដោយចន្លុះជំនឿផង... ព្រះយេស៊ូអើយ! សូមឲ្យពួកគេចាកផុតពីភាពមន្ទិល ដោយសារព្រលឹងដែលស្រឡាញ់ព្រះអង្គផង ខ្ញុំម្ចាស់សុខចិត្តរងទុក្ខលំបាកតែម្នាក់ឯង រហូតដល់ពេលដែលព្រះអង្គគាប់ព្រះហឫទ័យបញ្ជូលខ្ញុំម្ចាស់ទៅព្រះរាជាណាចក្រដ៏មានពន្លឺត្រចះត្រចង់របស់ព្រះអង្គ។ ទូលព្រះបង្គំជាខ្ញុំ ទូលសុំការប្រោសប្រណីតែមួយមុខគត់ គឺមិនជំទាស់ជាដាច់ខាតជាមួយព្រះអង្គ...។ (...)

ឱ! ប្រសិនបើខ្ញុំម្ចាស់ធ្វើព្រះអង្គមិនគាប់ព្រះហឫទ័យ សូមព្រះយេស៊ូមេត្តាលើកលែងទោសឲ្យខ្ញុំម្ចាស់ផង ប៉ុន្តែទ្រង់ជ្រាបហើយថា បើមិនបានរីករាយ

នឹងជំនឿទេ ទោះជាយ៉ាងណាក៏ខ្ញុំម្ចាស់នៅតែបង្កើតស្នាដៃជានិច្ច។ មួយឆ្នាំកន្លងមកហើយ ខ្ញុំម្ចាស់គិតថាបានបង្ហាញពីជំនឿច្រើនជាងពេលណាទាំងអស់ក្នុងជីវិតនេះ។ រាល់ការប្រយុទ្ធថ្មីៗ កាលបើសត្រូវមករំខាន ខ្ញុំម្ចាស់ខិតខំយ៉ាងមោះមុត ដើម្បីបែរខ្នង គេចចេញពីមុខសត្រូវ ដើរសំដៅទៅរកព្រះអង្គ ព្រោះការប្រយុទ្ធតទល់គ្នា ជាអំពើកំសាក។ ខ្ញុំម្ចាស់តស៊ូរត់ទៅរកព្រះយេស៊ូ រហូតដល់តំណាក់ឈាមចុងក្រោយ ដើម្បីប្រកាសថា ពិតជាមានស្ថានបរមសុខប្រាកដមែន។ ខ្ញុំម្ចាស់សូមទូលព្រះអង្គថា ខ្ញុំម្ចាស់ត្រេកអរ ដោយមិនបានត្រេកត្រអាលចំពោះស្ថានសួគ៌នៅលើផែនដីនេះ ដើម្បីឲ្យព្រះអង្គបើកទ្វារចំហរជារៀងរហូតទទួលអ្នកគ្មានជំនឿដ៏គួរឲ្យអាណិតទាំងនោះផង។

ដូច្នេះហើយ ទោះជាការលំបាកនេះ ធ្វើឲ្យខ្ញុំម្ចាស់បាត់បង់ភាពត្រេកត្រអាលទាំងអស់ក៏ដោយ ខ្ញុំម្ចាស់អាចស្រែកថា៖ "ព្រះអម្ចាស់អើយ ព្រះអង្គប្រទានសេចក្តីរីករាយចំពោះខ្ញុំម្ចាស់ ទោះជាបែបណាក៏ដោយ" (ទក ១៦)។ តើមានសេចក្តីរីករាយណាធំធេងជាងសេចក្តីរីករាយ ក្នុងការរងទុក្ខលំបាក ដើម្បីទទួលសេចក្តីស្រឡាញ់ទេ?... ការឈឺចាប់ក្នុងជម្រៅចិត្តមានសភាពខ្លាំងក្លា តែមិនបញ្ចេញមកខាងក្រៅ កាន់តែគាប់ព្រះរាជហឫទ័យ ឱ! ព្រះជាម្ចាស់អើយ ប្រសិនបើព្រះអង្គមិនបានដឹងអំពីការឈឺចាប់របស់ខ្ញុំម្ចាស់ៗ រឹតតែត្រេកអរថែមទៀត ប្រសិនបើការឈឺចាប់នេះអាចឃាត់ ឬជួសជុលកំហុសតែមួយគត់ ប្រឆាំងនឹងជំនឿ...។

អ្នកម៉ែជាទីស្រឡាញ់ ប្រហែលជាអ្នកម៉ែគិតថា ខ្ញុំបំផ្លើសទុក្ខលំបាកដែលខ្ញុំទទួលតែតាមការពិត ប្រសិនបើអ្នកម៉ែវិនិច្ឆ័យទៅតាមមនោសញ្ចេតនា ដែលខ្ញុំសម្តែងចេញតាមរយៈកំណាព្យតូចៗ ដែលខ្ញុំសរសេរឆ្នាំនេះ អ្នកម៉ែមុខជាយល់ថា ខ្ញុំជាអ្នកបានទទួលការល្បួងលោម ដែលនាំឲ្យស្បៃគ្របមុខនៃជំនឿស្ទើរតែរហែកដាច់ចេញពីគ្នា តែតាមការពិតទៅសម្រាប់ខ្ញុំមិនមែនជាស្បៃគ្រប

មុខទេ តែជាជញ្ជាំងខ្ពស់ដល់មេឃ បិទបាំងតារានានា... កាលបើខ្ញុំច្រៀងចម្រៀងសុភមង្គលនៃស្ថានបរមសុខ ដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ខ្ញុំឥតរីករាយសោះ ព្រោះខ្ញុំគ្រាន់តែច្រៀងតាមតែអ្វីៗដែលខ្ញុំចង់ជឿ។ តាមការពិត ជួនកាលមានកាំរស្មីព្រះអាទិត្យដ៏តូចមួយ មកបំភ្លឺពិភពងងឹតរបស់ខ្ញុំ ពេលនោះ ការរងទុក្ខលំបាក បានធូរស្រាលមួយស្របក់ បន្ទាប់មកការនឹកឃើញអំពីកាំរស្មីនេះមិនបាននាំសេចក្ដីរីករាយមកទេ ប៉ុន្តែពិភពងងឹតនោះ កាន់តែក្រាស់ថែមទៀត។

អ្នកម៉ែអើយ! តាំងពីដើមមក ខ្ញុំមិនដែលដឹងថា ព្រះយេស៊ូស្ងួតបូត មានព្រះហឫទ័យមេត្តាករុណាយ៉ាងនេះទេ ព្រះអង្គបញ្ជូនទុកលំបាកនេះមកចំពេលដែលខ្ញុំមានកម្លាំងទប់ទល់ បើមុននេះខ្ញុំច្បាស់ជាធ្លាក់ក្នុងសេចក្ដីអស់សង្ឃឹមពុំខានឡើយ។ ឥឡូវនេះ ការលំបាកដកហូតយកសេចក្ដីសប្បាយរីករាយពីកំណើត ក្នុងចំណង់ដែលបានមកពីស្ថានបរមសុខ... អ្នកម៉ែ ឥឡូវនេះ ហាក់ដូចជាគ្មានអ្វីមកបង្អាក់ការហោះហើររបស់ខ្ញុំទេ ខ្ញុំលែងចង់បានអ្វីទៀតហើយ ក្រៅពីស្រឡាញ់រហូតដល់ស្លាប់ ព្រោះសេចក្ដីស្រឡាញ់... (៩ មិថុនា)។ (...)

ឱ! ខ្ញុំមិនខ្លាចនឹងរស់នៅយូរអង្វែង ខ្ញុំមិនបដិសេធការតស៊ូទេ ព្រោះព្រះយេស៊ូជាផ្ទាំងថ្ម ជាកន្លែងដែលរស់នៅ បង្ហាត់បង្រៀនដៃខ្ញុំឲ្យប្រយុទ្ធម្រាមដៃសម្រាប់ធ្វើសង្គ្រាម។ ព្រះអង្គជាខែលរបស់ខ្ញុំៗ សង្ឃឹមលើព្រះអង្គជានិច្ច ដូច្នេះហើយ ខ្ញុំមិនដែលទូលអង្វរ សុំស្លាប់ពីក្មេងទេ តែខ្ញុំតែងតែសង្ឃឹមថាជាបំណងព្រះអង្គ។ តាមធម្មតា ព្រះជាម្ចាស់គាប់ព្រះហឫទ័យបំពេញកិច្ចការ ដើម្បីសិរីរុងរឿងរបស់ព្រះអង្គ។ អ្នកម៉ែជ្រាបហើយថា ចំណង់របស់ខ្ញុំធំធេងណាស់ ព្រះយេស៊ូបានហុចទឹកល្វីងជាច្រើនដង តែព្រះអង្គតែងតែដកព្រះហស្តចេញពេលដែលខ្ញុំហៀបនឹងក្រេប ដើម្បីឲ្យខ្ញុំដឹងក្លិនរសជាតិល្វីង។ ម៉ែជាទីស្រឡាញ់ ព្រះបាទដាវីឌ ទ្រង់ព្រះតម្រិះបានត្រឹមត្រូវ ព្រះអង្គច្រៀងថា៖ ល្អណាស់ចំពោះបងប្អូនបានរស់នៅជាមួយគ្នា សាមគ្គីគ្នាជាធ្លុងមួយ។ ជាការពិត ខ្ញុំដឹងថា គឺក្នុង

រង្វង់នៃការលះបង់យ៉ាងច្រើន ទើបការរួមជាមួយគ្នានេះ នឹងស្ថិតនៅលើផែនដី។ ខ្ញុំមករស់នៅក្នុងអារាមកាមែលនេះ មិនមែនមកដើម្បីជួបជុំជាមួយបងស្រីទេ គឺមកតាមការត្រាស់ហៅរបស់ព្រះយេស៊ូប៉ុណ្ណោះ។ ខ្ញុំបានគិតទុកជាមុនថា ការមករស់នៅជុំគ្នា ជាប្រភពនៃការឈឺចាប់ឥតឈប់ឈរ បើគេមិនព្រមសម្របខ្លួនទៅតាមធម្មជាតិ។ តើគេអាចថា ការចាកចេញឆ្ងាយពីក្រុមគ្រួសារ បានល្អប្រសើរដូចម្ដេចខ្លះទៅ?... តើគេមិនដែលស្ដីបន្ទោសបងប្អូនដែលប្រយុទ្ធលើសមរភូមិតែមួយទេឬ? តើគេបន្ទោសបងប្អូនដែលលួចបេះផ្លែល្មើនៃទុក្ខលំបាកជាមួយគ្នាទេ? មិនបាច់ឆ្ងល់ទេ គេមុខជាវិនិច្ឆ័យថា អ្នកទាំងនោះបានលើកទឹកចិត្តគ្នាទៅវិញទៅមក ហើយទុក្ខលំបាករបស់ម្នាក់ៗ គឺជាទុក្ខលំបាកនៃទាំងអស់គ្នា។ ដូច្នេះហើយ នៅក្នុងសាសនា ទេវវិទូតហៅថា មរណសាក្សី។ កាលណាគេបូជាខ្លួនប្រាណចំពោះព្រះជាម្ចាស់ ទឹកចិត្តមិនបាត់បង់ភាពទន់ភ្លន់ពីធម្មជាតិទេ ផ្ទុយទៅវិញ ភាពទន់ភ្លន់នេះ កាន់តែរីកធំឡើងៗ បរិសុទ្ធ និងខ្ពង់ខ្ពស់ជាងមុន។ (...)

អ្នកម៉ែបានប្រាប់ខ្ញុំថា ដើម្បីនៅអារាមកាមែលនៃប្រទេសក្រៅ ត្រូវការមានការត្រាស់ហៅជាពិសេស តែតាមការពិត គ្មានសោះ។ អ្នកម៉ែក៏បានប្រាប់ខ្ញុំដែរថា ខ្ញុំបានទទួលការត្រាស់ហៅពិសេសនេះ ប៉ុន្តែសុខភាពតែមួយគត់ ជាឧបសគ្គ។ ខ្ញុំដឹងថាឧបសគ្គនេះនឹងបាត់បង់ ប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំទៅឆ្ងាយ ហេតុនេះហើយខ្ញុំគ្មានបារម្ភទេ។ បើថ្ងៃណាមួយ ខ្ញុំត្រូវចាកចេញពីអារាមជាទីស្រឡាញ់នេះ ពិតជាគួរឲ្យស្ដាយណាស់។ ព្រះយេស៊ូមិនបានផ្ដល់បេះដូងមិនចេះរំភើបឲ្យខ្ញុំទេ ដោយសារវាមានការឈឺចាប់ ដូច្នេះហើយ ទើបខ្ញុំចង់ឲ្យបេះដូងនោះ ថ្វាយចំពោះព្រះយេស៊ូ នូវអ្វីៗដែលវាអាចថ្វាយព្រះអង្គបាន។ នៅទីនេះ ខ្ញុំមើលឃើញការថែទាំរបស់ផែនដីដ៏កម្សត់នេះ ដោយគ្រាន់តែបំពេញបេសកកម្មស្លូតបូត និងងាយៗ ដែលអ្នកម៉ែដាក់ឲ្យ។ អ្នកម៉ែបានដាស់តឿនរំឭកខ្ញុំទុកជាមុន ខ្ញុំមិនដែលខ្វះខាតអ្វីសោះឡើយ ជាពិសេសនៅទីនេះ គេស្រឡាញ់ខ្ញុំគ្រប់គ្នា។ សេចក្ដីស្រឡាញ់នេះ បំពេញចិត្តខ្ញុំរាល់វេលា។ ដូច្នេះហើយ

ខ្ញុំស្រមៃទៅរកអារាមណាដែលគ្មានអ្នកស្គាល់ ដែលខ្ញុំត្រូវរងទុក្ខលំបាកក្នុងការខ្វះខាត ខ្វះសេចក្តីស្រឡាញ់ គឺជាការនិរទេសនៃបេះដូង ឬគឺជាការចាកចេញពីអ្នកដែលខ្ញុំស្រឡាញ់។

ឱ! មិនមែនក្នុងបំណងជួយជ្រោមជ្រែងអារាមកាមែល ដែលបានទទួលយកខ្ញុំទេ គឺខ្ញុំនឹងធ្វើដើម្បីខ្លួនខ្ញុំ ប៉ុន្តែ ខ្ញុំគ្មានសមត្ថភាព ទោះជាខិតខំយ៉ាងណាក៏ដោយ ខ្ញុំនៅតែធ្វើមិនបានល្អ ព្រោះដូចខ្ញុំបានជម្រាបមកហើយ ថាខ្ញុំគ្មានចំណេះដឹងនៅលើផែនដីនេះទេ។ ដូច្នេះគោលដៅតែមួយគត់របស់ខ្ញុំ គឺប្រព្រឹត្តទៅតាមឆន្ទៈរបស់ព្រះជាម្ចាស់ បូជាខ្លួនថ្វាយព្រះអង្គ តាមតែទ្រង់គាប់ព្រះហឫទ័យ។

ខ្ញុំដឹងថា ខ្ញុំនឹងមិនស្តាយក្រោយទេ ព្រោះកាលបើគេរង់ចាំការឈឺចាប់មួយឥតឧបមា សេចក្តីរីករាយតូចមួយ ក្លាយទៅជាការភ្ញាក់ផ្អើល ដែលគេមិនស្មានដល់ ដូចអ្នកម៉ែជ្រាបស្រាប់ ការឈឺចាប់ក៏ក្លាយទៅជាសេចក្តីរីករាយ ធំជាងគេបង្អស់ កាលណាគេខិតខំស្វែងរក ដូចរកកំណប់ដ៏មានតម្លៃដូច្នោះដែរ។

ការចាកចេញនេះមិនមែនក្នុងបំណងទទួលយកផ្លែផ្កានៃការងាររបស់ខ្ញុំទេ។ តាំងពីយូរមកហើយ ខ្លួនខ្ញុំលែងជាកម្មសិទ្ធិរបស់ខ្ញុំទៀត ហើយខ្ញុំថ្វាយខ្លួនទាំងស្រុងចំពោះព្រះយេស៊ូ តាមតែព្រះហឫទ័យព្រះអង្គទៅចុះ។ ព្រះអង្គប្រទានឲ្យខ្ញុំចូលចិត្តការនិរទេសខ្លួន។ ព្រះអង្គបណ្តាលឲ្យខ្ញុំយល់ពីការឈឺចាប់ទាំងអំបាលម៉ានដែលខ្ញុំអាចជួយ ព្រះអង្គចោទសួរថា តើខ្ញុំចង់ផឹកពែងនៃទុក្ខលំបាក ភ្លាមនោះ ខ្ញុំចង់តែស្រវាយកពែង ដែលព្រះអង្គប្រទាន ប៉ុន្តែ ទ្រង់ដកព្រះហស្តចេញ ឲ្យខ្ញុំយល់ថា ការទទួលយក ធ្វើឲ្យព្រះអង្គគាប់ព្រះហឫទ័យហើយ។

អ្នកម៉ែអើយ! តើមានអ្វីគួរឲ្យបារម្ភ បើគេសន្យាគោរពតាមទៅហើយនោះ! ទោះជាជូនជីសាមញ្ញបំផុតក៏សប្បាយចិត្តដែរ ត្រីវិស័យរបស់គេ គឺបំណងរបស់ថ្នាក់លើ ព្រោះសុទ្ធតែជាបំណងល្អ គ្មានអ្វីគួរឲ្យបារម្ភទេ ទោះជាថ្នាក់លើភ័ន្តច្រលំក៏ដោយ។ ប៉ុន្តែ កាលបើគេលែងមើលត្រីវិស័យ គេមុខជាដើរងាកចេញ

ពីផ្លូវ ដោយយកលេសថា តាមបំណងព្រះជាម្ចាស់ បន្តិចក្រោយមកព្រលឹងគេវង្វេង ដើរតាមផ្លូវស្ងួតក្រៀមក្រោះ គ្មានទឹកផឹក គឺទឹកនៃការប្រោសប្រណីរបស់ព្រះជាម្ចាស់។ (...)

ក្នុងឆ្នាំនេះ ព្រះជាម្ចាស់ប្រោសប្រណីខ្ញុំ ឲ្យយល់អំពីសប្បុរសធម៌។ កាលពីមុន ខ្ញុំមិនដែលបានពិចារណាព្រះបន្ទូលឲ្យបានជ្រៅជ្រះ៖ *"វិន័យទីពីរ ដូចទីមួយដែរ ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចស្រឡាញ់ខ្លួនឯងដែរ"*។ ជាសេចក្តីស្រឡាញ់ ដែលមាននៅក្នុងជម្រៅចិត្ត មិនមែនគ្រាន់តែត្រឹមបបូរមាត់ទេ ព្រោះព្រះបន្ទូលថា៖ *"អ្នកណាទៅស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែនិយាយថា ព្រះអម្ចាស់អើយ ព្រះអម្ចាស់អើយ ប៉ុណ្ណោះទេ ប៉ុន្តែ គឺជាអ្នកធ្វើតាមបំណងព្រះជាម្ចាស់"* ។ ព្រះយេស៊ូបានប្រោសឲ្យស្គាល់ព្រះបន្ទូលនេះជាច្រើនដង ប៉ុន្តែក្នុងពិធីជប់លៀងចុងក្រោយបង្អស់ ព្រះអង្គជ្រាបថា សាវ័កទាំងអស់ស្រឡាញ់ព្រះអង្គ ដូចជាព្រះអង្គស្រឡាញ់ពួកគេដែរ ក្នុងពិធីថ្លែងអំណរព្រះគុណព្រះជាម្ចាស់ ព្រះអង្គមានព្រះហឫទ័យប្រទានក្តីវិន័យថ្មីមួយទៀត។ ទ្រង់មានព្រះបន្ទូលថា៖ ខ្ញុំផ្តល់វិន័យមួយទៀត គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដើម្បីជាសញ្ញាឲ្យមនុស្សលើលោកនេះ ស្គាល់ថា អ្នករាល់គ្នាជាសាវ័ករបស់ខ្ញុំ។

ហេតុដូចម្តេចបានជាព្រះយេស៊ូស្រឡាញ់សាវ័ករបស់ព្រះអង្គ ហើយពួកសាវ័កក៏ស្រឡាញ់ព្រះអង្គវិញដែរ? រវាងព្រះអង្គ និងពួកសាវ័ក មានគម្លាតឆ្ងាយពីគ្នាជាអនេក ព្រះអង្គជាវិទ្យាសាស្ត្រ ជាអ្នកប្រាជ្ញា ដែលស្ថិតនៅអស់កល្បជានិច្ច សាវ័កទាំងនោះជាអ្នកនេសាទត្រីល្ងង់ខ្លៅ (មានគំនិតជាមនុស្សលើផែនដី)។ ព្រះអង្គបានទុកពួកគេជាមិត្ត ជាបងប្អូន។ ទ្រង់មានព្រះបំណងឲ្យពួកគេទៅសោយរាជ្យនៅស្ថានរបស់ព្រះរាជ្យរបស់ព្រះបិតា ជាមួយព្រះអង្គ ហើយដើម្បីបើកទ្វារព្រះរាជ្យនោះ ទ្រង់មានបំណងសុគតលើឈើឆ្កាង ព្រោះព្រះអង្គមាន

ព្រះបន្ទូលថា៖ គ្មានសេចក្តីស្រឡាញ់ណា ធំជាងសេចក្តីស្រឡាញ់ដែលគេហ៊ាន បូជាជីវិតចំពោះអ្នកដែលគេស្រឡាញ់ឡើយ។

ដោយបានពិចារណាព្រះបន្ទូលនេះ ខ្ញុំយល់ថា ការស្រឡាញ់បងស្រីរបស់ខ្ញុំ មិនទាន់គ្រប់លក្ខណ៍ទេ ខ្ញុំមិនស្រឡាញ់ពួកគាត់ ដូចព្រះជាម្ចាស់ស្រឡាញ់ពួកគាត់ឡើយ។ ឥឡូវនេះខ្ញុំយល់ហើយ សប្បុរសធម៌គ្រប់លក្ខណ៍ គឺទ្រាំទ្រនឹងគុណវិបត្តិរបស់អ្នកដទៃ មិនខ្វល់នឹងភាពទន់ខ្សោយរបស់ពួកគេ ត្រូវសរសើរគុណធម៌របស់គេ តិចតួចក៏ដោយ ជាពិសេសមិនត្រូវលាក់សប្បុរសធម៌ទុកក្នុងខ្លួនទេ ព្រះយេស៊ូមានព្រះបន្ទូលថា៖ គ្មាននរណាម្នាក់អុជចន្លុះ ដើម្បីដាក់ក្រោមបាច់អុសទេ ប៉ុន្តែគេអុជដាក់លើជើងទៀន ដើម្បីបំភ្លឺអ្នកនៅក្នុងផ្ទះ។ ខ្ញុំហាក់ដូចជាយល់ថា ចន្លុះតំណាងឲ្យសប្បុរសធម៌ ដែលត្រូវបំភ្លឺធ្វើឲ្យអ្នកនៅក្នុងផ្ទះសប្បាយទាំងអស់គ្នា ដោយគ្មានរើសមុខ។

កាលដែលព្រះអម្ចាស់បញ្ជាឲ្យប្រជាជនរបស់ព្រះអង្គស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង កាលនោះ ព្រះអង្គមិនទាន់យាងមកដល់ផែនដីយើងទេ។ ព្រះអង្គទ្រង់យល់ច្បាស់ថា សត្វលោកស្រឡាញ់ខ្លួនឯងខ្លាំងណាស់ ដូច្នេះហើយព្រះអង្គមិនអាចសុំឲ្យពួកគេស្រឡាញ់អ្នកដទៃច្រើនជាងខ្លួនឯងឡើយ។ កាលដែលព្រះយេស៊ូដាក់បញ្ញត្តិថ្មីដល់ពួកសាវ័ក ទ្រង់មានព្រះបន្ទូលថា៖ ត្រូវស្រឡាញ់អ្នកដទៃ ដូចព្រះអង្គស្រឡាញ់ពួកគេដែរ ព្រះអង្គនឹងស្រឡាញ់ពួកគេជារៀងរហូត...

ព្រះអង្គអើយ! ខ្ញុំម្ចាស់ដឹងថា ព្រះអង្គមិនដាក់បញ្ជាអ្វីដែលមិនអាចអនុវត្តទេ ព្រះអង្គស្គាល់ភាពទន់ខ្សោយ និងភាពខ្វះខាត (មិនគ្រប់លក្ខណ៍) របស់ខ្ញុំម្ចាស់ ជាងខ្លួនខ្ញុំម្ចាស់ផ្ទាល់។ ខ្ញុំម្ចាស់មិនអាចស្រឡាញ់បងស្រី ដូចព្រះអង្គស្រឡាញ់ពួកគាត់ទេ។ ព្រះអង្គប្រោសប្រទានសេចក្តីស្រឡាញ់នេះ ទើបព្រះអង្គបញ្ញាត្តិវិន័យថ្មី។ ខ្ញុំម្ចាស់ចូលចិត្តបទបញ្ជានេះ ហើយគោរពតាមជានិច្ច! ...។

ខ្ញុំដឹងខ្លួនថាព្រះយេស៊ូប្រោសប្រណីឲ្យខ្ញុំធ្វើអំពើសប្បុរសធម៌ កាលបើខ្ញុំ

រួបរួមជាមួយព្រះអង្គ ខ្ញុំកាន់តែស្រឡាញ់បងស្រីទាំងអស់ ហើយខ្ញុំចង់បន្ថែមសេចក្តីស្រឡាញ់ចំពោះពួកគាត់ទៀតផង ទោះជាមានពួកអារក្សមករំខានសាកល្បង ដោយលើកយកគុណវិបត្តិរបស់ពួកគាត់ មកលាតត្រដាងដាក់មុខខ្ញុំក៏ដោយ ខ្ញុំប្រញាប់ស្ទុះស្ទាររកគុណធម៌ និងបំណងល្អៗរបស់ពួកគាត់ ហើយគិតថា បើឃើញគាត់បរាជ័យម្តង ប្រហែលជាគាត់ទទួលជ័យជម្នះច្រើនដងជាងនេះជាមិនខាន តែពួកគាត់លាក់ដោយដាក់ខ្លួន ហើយកំហុសតិចតួចតែងតែមានជាធម្មតា ព្រោះតែបំណងល្អ។ មានថ្ងៃមួយ ខ្ញុំធ្វើការពិសោធន៍ ដែលអាចបកស្រាយថា មិនត្រូវវិនិច្ឆ័យភ្លាមៗទេ។ កាលនោះ ជាពេលចេញលេង អ្នកយាមទ្វាររោទិ៍កណ្តឹងពីរដង គេត្រូវបើកទ្វារធំដើម្បីឲ្យកម្មករលើកដើមឈើមកតុបតែងស្នូកសត្វ។ ពេលចេញលេងនោះ មិនសប្បាយទេ ព្រោះអ្នកម៉ែមិននៅ ខ្ញុំគិតថា បើមានគេប្រើខ្ញុំទៅបម្រើពេលសូត្រធម៌ម៉ោងប្រាំបួន (Tierce) ប្រហែលជាសប្បាយជាងនេះ។ ចំពេលនោះ ដូនជីក្រោមបង្គាប់អ្នកម៉ែក៏ប្រើខ្ញុំ ឬដូនជីម្នាក់ទៀត នៅក្បែរនោះឲ្យទៅ។ ភ្លាមនោះខ្ញុំស្រាយអៀមយឺតៗ ដើម្បីឲ្យដូនជីនៅជិតខ្ញុំបានទៅមុន ព្រោះខ្ញុំចង់ឲ្យគាត់សប្បាយចិត្ត។ ដូនជីម្នាក់ទៀត ឈរជិតនោះមើលមកខ្ញុំសើចហើយនិយាយថា ខ្ញុំគិតហើយឯងទៅមិនរួចទេ ព្រោះឯងយឺតពេក...។

អ្នកនៅក្នុងសហគមន៍ទាំងអស់យល់ថា ជាទម្លាប់ពីកំណើតរបស់ខ្ញុំ តែខ្ញុំមិនដឹងជាជម្រាបយ៉ាងណាទេ សម្រាប់ខ្ញុំ ការយោគយល់គ្នាបន្តិចបន្តួចចំពោះអ្នកទន់ខ្សោយនេះ ជាអំពើល្អដែលនាំឲ្យខ្ញុំសប្បាយចិត្ត ធ្វើឲ្យខ្ញុំមានអំនួតខ្លះដែរ កាលណាខ្ញុំពិចារណាឃើញថាគួរ ព្រោះខ្ញុំប្រាប់ខ្លួនឯងថា៖ គេយល់ថាអំពើជាគុណធម៌តិចតួចរបស់ខ្ញុំ ជាភាពមិនគ្រប់លក្ខណ៍ គេក៏អាចច្រលំដែរ ដោយគិតថា សីលធម៌ជាអ្វីៗដែលមិនគ្រប់លក្ខណ៍។ ដូច្នេះ ខ្ញុំយល់ស្របជាមួយសន្ត: ប៉ូល ខ្ញុំមិនរវល់នឹងការវិនិច្ឆ័យរបស់មនុស្សលោកទេ ខ្ញុំវិនិច្ឆ័យខ្លួនឯង អ្នកវិនិច្ឆ័យខ្ញុំ គឺព្រះអម្ចាស់។ ដូច្នេះហើយ ដើម្បីឲ្យការវិនិច្ឆ័យនោះបានចំនេញ ឬ មិនបាច់វិនិច្ឆ័យទាល់តែសោះ ខ្ញុំចង់បានគំនិតជាសប្បុរសធម៌ជានិច្ច ដូចព្រះ

បន្ទូលព្រះយេស៊ូ កុំវិនិច្ឆ័យទោសគេ អ្នកក៏មិនត្រូវគេវិនិច្ឆ័យដែរ។

អ្នកម៉ែ អាចយល់ថា ការអនុវត្តសប្បុរសធម៌ មិនពិបាកសម្រាប់ខ្ញុំទេ។ ពីរបីខែមកហើយ ខ្ញុំមិនបាច់ប្រឹងប្រែងទេ ខ្ញុំធ្វើបានយ៉ាងល្អ មិនមែនគ្មានកំហុសទេ ប៉ុន្តែខ្ញុំឆាប់ដឹងខ្លួន កែលំអវិញភ្លាមៗ។

ក្នុងសហគមន៍ មានដូនជីម្នាក់ ដែលចូលចិត្តរករឿងខ្ញុំគ្រប់បែបយ៉ាង។ ពាក្យសម្ដី និងអកប្បកិរិយាមិនគួរឲ្យចូលចិត្ត តែគាត់ស្រឡាញ់ព្រះជាម្ចាស់ណាស់។ ខ្ញុំប្រាប់ខ្លួនឯងថា សប្បុរសធម៌មិនស្ថិតលើមនោសញ្ចេតនាប៉ុណ្ណោះទេ ប៉ុន្តែគុណធម៌នេះ ស្ថិតនៅលើកិច្ចការ។ ខ្ញុំអនុវត្តលើដូនជីនេះ ដូចជនដែលខ្ញុំស្រឡាញ់ជាងគេ។ រាល់លើកដែលខ្ញុំជួបគាត់ ខ្ញុំតែងតែអធិដ្ឋានដល់ព្រះជាម្ចាស់ សូមព្រះអង្គជួយគាត់ ខ្ញុំទូលព្រះអង្គអំពីគុណធម៌ និងកុសលធម៌របស់គាត់។ ខ្ញុំដឹងថា ព្រះយេស៊ូចូលចិត្តកិច្ចការនេះណាស់ ព្រោះព្រះអង្គក៏ចូលចិត្តពាក្យសរសើរអំពីស្នាព្រះហស្ដដែរ ព្រះអង្គជាអ្នកច្នៃព្រលឹង ទ្រង់គាប់ព្រះហឫទ័យកាលបើគេដើរចូលរហូតដល់បូជនីយដ្ឋាន ហើយគយគន់ស្ងើចសរសើរសោភ័ណភាពលំនៅរបស់ព្រះអង្គ។ ខ្ញុំមិនគ្រាន់តែអធិដ្ឋានជូនគាត់ទេ ខ្ញុំតែងតែជួយសម្រាលការងារណា ដែលខ្ញុំអាចធ្វើបាន ហើយខ្ញុំឆ្លើយតបនឹងគាត់ ដោយញញឹមរាក់ទាក់មិនពង្វាងការសន្ទនា ព្រោះនៅក្នុងសៀវភៅ Imitation គេសរសេរថា៖ គួរតែបណ្ដោយទៅតាមមនោសញ្ចេតនារបស់គេ ជាជាងប្រកែកប្រឆាំង។

ជារឿយៗ រាល់ពេលធ្វើការ បើមានទំនាក់ទំនងការងារជាមួយគាត់ ខ្ញុំតែងតែគេចចេញ កាលណាខ្ញុំទ្រាំលែងបាន។ គាត់គ្មានសង្ស័យលើអកប្បកិរិយាខ្ញុំទេ នៅតែគិតថា ខ្ញុំចូលចិត្តគាត់។ ថ្ងៃមួយ នៅពេលចេញលេង គាត់និយាយដោយសប្បាយចិត្តយ៉ាងខ្លាំង៖ *"ប្អូនស្រីថេរេសា សូមជួយប្រាប់ផង តើអ្នកចូលចិត្តខ្ញុំកន្លែងណា រាល់លើកអ្នកញញឹមដាក់ខ្ញុំជានិច្ច?"* ។ ឱ! គឺព្រះយេស៊ូដែលពួនក្នុងព្រលឹងគាត់ទេ ដែលទាក់ទាញខ្ញុំនោះ... ព្រះអង្គប្រោសភាពល្វីងជូរចត់

ឲ្យក្លាយទៅជាផ្អែមល្ហែម... ខ្ញុំឆ្លើយថា ខ្ញុំញញឹម ព្រោះខ្ញុំចូលចិត្តគាត់ (តាមពិតទៅ ខ្ញុំចូលចិត្តគាត់ខាងវិញ្ញាណទេ)។

ខ្ញុំបានជម្រាបអ្នកម៉ែហើយថា មធ្យោបាយចុងក្រោយបំផុតកុំឲ្យបរាជ័យទាន់ គឺដកខ្លួនចេញ។ ឧទាហរណ៍មួយទៀត ដែលអាចឲ្យអ្នកម៉ែញញឹម។ កាលនោះ អ្នកម៉ែគ្រុនរលាកទងសួត ខ្ញុំត្រូវចាក់សោរបើកទ្វារបន្ទប់អធិដ្ឋាន ព្រោះខ្ញុំជាអ្នកថែទាំ រួចខ្ញុំត្រូវប្រគល់កូនសោរជូនម៉ែ។ តាមពិត ខ្ញុំចង់ទៅសួរសុខទុក្ខអ្នកម៉ែណាស់ តែខ្ញុំមិនបញ្ចេញឲ្យគេដឹង។ ដូនជីម្នាក់ ឃើញខ្ញុំដើរចូល ក៏គិតថាខ្ញុំទៅដាស់អ្នកម៉ែ គាត់ចង់ទទួលកូនសោរពីខ្ញុំ តែខ្ញុំរបិលរប៉ូច មិនព្រមឲ្យគាត់ ខ្ញុំជម្រាបគាត់ដោយគួរសមបំផុតថា ខ្ញុំគ្មានបំណងដាស់អ្នកម៉ែទេ ខ្ញុំគ្រាន់តែប្រគល់កូនសោរឲ្យដល់ដៃប៉ុណ្ណោះ... ឥឡូវនេះ ទើបខ្ញុំយល់ថា ពេលនោះ ខ្ញុំគួរតែប្រគល់កូនសោរទៅដូនជីនោះវិញទើបប្រសើរ ទោះជាគាត់នៅក្មេងពិតមែន តែគាត់មករស់នៅក្នុងអារាមនេះមុនខ្ញុំ។ កាលនោះ ខ្ញុំមិនយល់ប្រការនេះទេ ខ្ញុំនៅតែចចេសចូលតាមក្រោយខ្នងគាត់ ទោះជាគាត់រារាំងក៏ដោយ។ សំឡេងយើងបានដាស់អ្នកម៉ែឲ្យភ្ញាក់... ហេតុនេះហើយ កំហុសធ្លាក់មកលើរូបខ្ញុំ។ ដូនជីនោះនិយាយឥតឈប់ គឺដូនជីថេរេសា ធ្វើឲ្យមានសំឡេង... ព្រះអើយមិនគួរឲ្យចូលចិត្តសោះ...។ល។ កាលនោះ ខ្ញុំចង់ការពារខ្លួនដែរ តែខ្ញុំមានគំនិតភ្លឺស្វាងមួយថា ប្រសិនបើខ្ញុំការពារខ្លួនខ្ញុំៗ មិនអាចស្ងប់ចិត្តបានទេ ប៉ុន្តែ ខ្ញុំគ្មានគុណធម៌គ្រប់គ្រាន់ល្មមទុកឲ្យគេចោទប្រកាន់ ដោយគ្មានហេតុផលឡើយ មានតែរត់គេចចេញ ទើបអាចជួយខ្លួនបាន។ ភ្លាមនោះ ខ្ញុំដើរចេញទុកឲ្យគាត់បន្តនិយាយតែម្នាក់ឯង។ ទ្រូងខ្ញុំញ័រចំប្រប់ ខ្ញុំដើរមិនរួច ក៏អង្គុយលើកាំជណ្តើរដើម្បីទទួលអំណរ បានមកពីជ័យជម្នះនោះ។ នេះមិនមែនជាសេចក្តីអង់អាចទេ ប៉ុន្តែប្រសើរជាងនៅតស៊ូ បើដឹងថាគង់តែចាញ់ដែរ មែនទេអ្នកម៉ែ? បើក្រលេកមើលមកក្រោយវិញ កាលខ្ញុំជាសាមណេ ខ្ញុំមានការផ្តាំផ្តងជាច្រើន នឹកឃើញពេលណា ខ្ញុំអស់សំណើច! ព្រះជាម្ចាស់សប្បុរសណាស់ ព្រះអង្គប្រោស

ឲ្យព្រលឹងខ្ញុំឲ្យរឹងមាំ និងប្រទានស្លាបមកខ្ញុំ... ខ្ញុំមិនខ្លាចអន្ទាក់របស់ព្រានទេ ព្រោះ *"បង់សំណាញ់ពីមុខអ្នកមានស្លាប ជាការឥតប្រយោជន៍"* ។ ប្រហែលជាថ្ងៃក្រោយ ខ្ញុំអាចឆ្កាំឆ្កងខ្លះ ប៉ុន្តែឥឡូវនេះ ខ្ញុំលែងកើតទុក្ខអំពីភាពទន់ខ្សោយរបស់ខ្ញុំទៀតហើយ ផ្ទុយទៅវិញ ភាពទន់ខ្សោយនេះ ធ្វើឲ្យខ្ញុំបានជោគជ័យ ហើយរាល់ថ្ងៃខ្ញុំខិតខំរកឲ្យឃើញភាពមិនគ្រប់លក្ខណ៍នេះ។ ខ្ញុំនៅចាំថា សប្បុរសធម៌គ្របដណ្តប់លើអំពើបាបយ៉ាងច្រើន ព្រោះព្រះយេស៊ូជាអ្នកបង្ហាញ។ ព្រះអង្គពន្យល់វិន័យថ្មីក្នុងដំណឹងល្អ ទ្រង់មានព្រះបន្ទូលតាមរយៈសន្តៈ ម៉ាថាយថាៈ "អ្នករាល់គ្នាធ្លាប់ឮគេនិយាយថាៈ ចូរស្រឡាញ់បងប្អូនអ្នក ហើយស្អប់ខ្មាំងសត្រូវរបស់អ្នក។ ចំណែកឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់ពួកអ្នកបៀតបៀនអ្នករាល់គ្នាផង"។ នៅកាមែល គ្មានខ្មាំងសត្រូវទេ មានតែការស្រឡាញ់ចូលចិត្ត គេអាចស្រឡាញ់ដូនជីនេះ ជាងដូនជីនោះ ជួនកាល អ្នកដើរវាងមិនឲ្យជួបមុខ អ្នកដែលខ្លួនមិនចូលចិត្ត ដោយមិនដឹងខ្លួន ដែលអាចក្លាយទៅជាការបៀតបៀនទៀតផងក៏មានពិតហើយ!... ព្រះយេស៊ូមានព្រះបន្ទូលប្រាប់ខ្ញុំថា ត្រូវស្រឡាញ់ដូនជីនោះ ហើយត្រូវទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យគាត់ផង ប៉ុន្តែអកប្បកិរិយាគាត់បង្ហាញថា គាត់មិនចូលចិត្តខ្ញុំទេ។ *"បើអ្នករាល់គ្នាស្រឡាញ់តែអ្នកដែលស្រឡាញ់ពួកអ្នក តើនឹងមានគុណបំណាច់អ្វី? សូម្បីតែមនុស្សបាប ក៏ចេះស្រឡាញ់គ្នាដែរ"* (សន្តៈ លូកា ៦)។ ស្រឡាញ់តែមាត់មិនគ្រប់គ្រាន់ទេ ត្រូវបង្ហាញឲ្យឃើញផង។ ធម្មតាគេសប្បាយចិត្ត ដោយបានជូនអំណោយដល់មិត្តភក្តិ ជាពិសេសដោយគេមិនដឹងមុន ធ្វើឲ្យគេភ្ញាក់ផ្អើល ប៉ុន្តែនោះមិនមែនជាសប្បុរសធម៌ទេ ព្រោះអ្នកបាបក៏ធ្វើដូច្នោះដែរ។ ព្រះយេស៊ូបានបង្រៀនខ្ញុំថាៈ "ចូរអ្នកធ្វើអំណោយដល់អ្នកដទៃ បើគេយកអ្វីៗជារបស់អ្នក ចូរកុំទារមកវិញ។ ឲ្យដល់អស់អ្នកសុំ មិនសូវមានន័យដូចគេឲ្យដោយសុទ្ធចិត្តទេ។ បើគេសុំដោយសម្តីទន់ភ្លន់ មិនគួរកំណាញ់ឡើយ តែបើមិនទន់ភ្លន់ ភ្លាម

នោះ ចិត្តមនុស្សក៏ប្រឆាំងឲ្យភ្លាម បើចិត្តនោះមិនសូវមានសប្បុរសធម៌។ គេអាចរកលេសមកបដិសេធ ឬឲ្យទាំងទើសទាល់ ឬបន្តិចបន្តួច ដើម្បីសម្រាលសេចក្តីត្រូវការប៉ុណ្ណោះ។ បើគេយកដោយគ្មានសុំនោះ ជាការពិបាកទ្រាំណាស់។ អ្នកម៉ែ! ខ្ញុំថាពិបាក តាមពិតខ្ញុំគួរថា ហាក់ដូចជាពិបាកទៅវិញ ព្រោះនឹមរបស់ព្រះយេស៊ូស្រាលណាស់ កាលណាគេព្រមឲ្យ ដូចពាក្យក្នុងទំនុកតម្កើង៖ "ខ្ញុំម្ចាស់រត់តាមផ្លូវដែលព្រះអង្គត្រាស់បង្គាប់ តាំងពីពេលដែលព្រះអង្គពង្រីកបេះដូងខ្ញុំម្ចាស់មក"។ ព្រះយេស៊ូអើយ មានតែព្រះអង្គទេ ដែលអាចពង្រីកបេះដូងខ្ញុំម្ចាស់បាន ចាប់តាំងអណ្តាតភ្លើងដ៏ស្រទន់របស់ព្រះអង្គបានឆេះរំលាយបេះដូងខ្ញុំម្ចាស់មក ខ្ញុំម្ចាស់រីករាយនឹងរត់តាមផ្លូវនៃវិន័យថ្មី... ខ្ញុំម្ចាស់ចង់រត់រហូតដល់ថ្ងៃសុគមង្គលដែលបញ្ចូលខ្ញុំម្ចាស់ទៅក្នុងក្បួនដង្ហែរដ៏បរិសុទ្ធ ទៅតាមព្រះអង្គគ្រប់ទីកន្លែង និងច្រៀងទំនុកថ្មី ថ្លែងអំពីសេចក្តីស្រឡាញ់។

ខ្ញុំតែងនិយាយថា៖ ព្រះយេស៊ូមិនចង់បានអ្វីពីខ្ញុំទេ នោះហាក់ដូចជាងាយណាស់សម្រាប់ខ្ញុំ ទ្រព្យធននាលោកីយនេះ ខ្ញុំគ្មានសោះ ខ្ញុំជាអ្នកក្រ។ កាលពីមុន ខ្ញុំហាក់ដូចជាមិនបានគិតឲ្យដិតដល់ ប៉ុន្តែតាំងពីខ្ញុំយល់ព្រះបន្ទូល ខ្ញុំដឹងថា ខ្ញុំនៅមិនគ្រប់លក្ខណ៍ ឧទាហរណ៍ ពេលប្រើថ្នាំពណ៌សម្រាប់គំនូរ ខ្ញុំដឹងច្បាស់ថា វត្ថុទាំងនោះមិនមែនជារបស់ខ្ញុំទេ ប៉ុន្តែពេលឃើញជក់ និងថ្នាំពណ៌ឥតសណ្តាប់ធ្នាប់ បន្ទាត់ ឬកូនកាំបិតបាត់ពីកន្លែង ស្ទើរតែទ្រាំលែងបាន ប៉ុន្តែខ្ញុំខំទប់ចិត្តខ្លាំងណាស់ ក្នុងការសួរនាំរកវត្ថុទាំងនោះ បើចាំបាច់ ខ្ញុំសួរដោយសុភាពរាបសា តាមការណែនាំរបស់ព្រះយេស៊ូ ឬធ្វើត្រាប់តាមអ្នកក្រខ្សត់ គឺហុចដៃសុំ។ បើតាំងចិត្តជម្នះអារម្មណ៍ពីធម្មជាតិនេះបាន សេចក្តីស្ងប់នឹងកើតមានហើយ... ប៉ុន្តែមិនស្មើនឹងអ្នកមានស្មារតីទន់ខ្សោយពិតប្រាកដទេ បើគាត់សុំវត្ថុចាំបាច់មួយ ដោយភាពព្រងើយកន្តើយ ហើយគេមិនព្រមឲ្យ រួចគេសាកល្បងយកអ្វីដែលគាត់មានវិញ នោះគាត់នឹងធ្វើតាមដំបូន្មានរបស់ព្រះយេស៊ូ៖



ចូរអ្នកបោះបង់អាវរងារក្រៅរបស់អ្នក ឲ្យទៅអ្នកសុំសំពត់អ្នកទៅ...។ បោះបង់អាវរងារ គឺលែងគិតគូរអំពីកម្មសិទ្ធិចុងក្រោយ គឺទុកខ្លួនជាអ្នកបម្រើ ជាទាសកររបស់អ្នកឯទៀត។ កាលណាគេដោះអាវរងារក្រៅចេញ គេស្រួលដើរ ស្រួលរត់ដូច្នោះហើយ ព្រះអង្គមានព្រះបន្ទូលបន្ថែមទៀតថា៖ បើមានគេបង្ខំឲ្យអ្នកដើរមួយពាន់ជំហាន ចូរអ្នកដើរលើសពីរពាន់ជំហានជាមួយគេទៅ។ ដូច្នេះមិនត្រឹមតែឲ្យដល់អ្នកសុំទេ ត្រូវលះបង់កំណាញ់បរិច្ចាកដោយទន់ភ្លន់ ស្មោះស្ម័គ្រជួយគេ បើគេយកវត្ថុអ្វីមួយ មិនត្រូវនឹកស្តាយទេ ត្រូវត្រេកអរ ព្រោះលែងទើសទែង។

អ្នកម៉ែ! ខ្ញុំមិនបានអនុវត្តតាមការយល់របស់ខ្ញុំទេ ប៉ុន្តែចំណង់នោះធ្វើឲ្យចិត្តខ្ញុំស្ងប់។

ថ្ងៃនេះ ខ្ញុំពន្យល់មិនបានច្បាស់លាស់ទេ ព្រោះពេលនេះ គិលានុដ្ឋាកយិកាកំពុងតែតាមដានដើរក្រវែលជុំវិញខ្ញុំ នេះហើយជាសកម្មភាពសប្បុរសធម៌! ព្រលឹងខ្ញុំត្រូវអប់ដោយក្លិនក្រអូប ស្មារតីហាក់ដូចជាពិការបន្តិច ហើយដងប៉ាកា ហាក់ដូចជាធ្ងន់ណាស់។ ដើម្បីងាយស្រួលក្នុងការបកស្រាយគំនិត គួរតែទុកខ្ញុំឲ្យនៅម្នាក់ឯង។ ប៉ុន្តែគ្រាន់តែខ្ញុំចាប់ដងប៉ាកាភ្លាម ដូនជីម្នាក់មកឈរ ដាក់ដៃពីលើស្មាខ្ញុំ ដោយគិតថា កុំឲ្យខ្ញុំអផ្សុក។ មានអំណោយជាច្រើន បានមកពីការសួរសុខទុក្ខ ក្នុងនោះមានផ្កាមួយបាច់ដែលគេយកមកដាក់លើភ្លៅខ្ញុំ ប៉ុន្តែ ខ្ញុំចង់ឲ្យផ្កាទាំងនោះនៅជាប់ទង យោលយោគតាមកម្លាំងខ្យល់បក់វិញទេ។ គេតែងតែមករំខានខ្ញុំជានិច្ច ប៉ុន្តែដើម្បីព្រះជាម្ចាស់ និងដូនជីជាបងប្អូន (ដែលមានចិត្តសប្បុរស) ខ្ញុំត្រូវតែខិតខំធ្វើជាសប្បាយចិត្ត... ដើម្បីបង្ហាញអ្នកម៉ែ ខ្ញុំនឹងបញ្ចប់ដោយការពន្យល់អំពីសប្បុរសធម៌ផ្នែកវិញ្ញាណម្តង។

នៅអារាមកាមែល ការអនុវត្តព្រះបន្ទូលតាមដំណើងល្អ មិនអាចគ្រប់លក្ខណ៍បានទេ ជួនកាលគេត្រូវបង្ខំចិត្ត បដិសេធក្នុងការជួយអ្នកឯទៀត ព្រោះមានការងារច្រើន។ ប៉ុន្តែ សប្បុរសធម៌ក្នុងវិញ្ញាណ បង្ហាញចេញមកខាងក្រៅ គេមិនអាច

បដិសេធបានឡើយ។ មានវិធីមួយ ដើម្បីបដិសេធយ៉ាងសមរម្យ ហើយការបដិសេធនោះ នាំមកនូវសេចក្តីរីករាយដែរ។ តាមពិតទៅ គេមិនសូវទើសទាល់ទេ ដើម្បីពឹងពាក់អ្នកធ្លាប់ជួយធ្វើការងារខ្លួន។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ចូរកុំដើរគេចពីអ្នកដែលចង់សុំខ្ចីអ្វីៗពីអ្នក"។ ដូច្នេះ ត្រូវយកលេសថា គេបដិសេធដោយបង្ខំចិត្ត មិនត្រូវដើរគេចចេញទេ។ ហើយក៏មិនត្រូវជួយក្នុងបំណងឲ្យគេជួយវិញដែរ ព្រោះព្រះអង្គមានព្រះបន្ទូលទៀតថា៖ "បើអ្នករាល់គ្នាឲ្យគេខ្ចី ក្នុងបំណងបានចំណេញ តើអ្នកនឹងបានរង្វាន់អ្វី? ព្រោះសូម្បីតែអ្នកប្រព្រឹត្តអំពើបាបក៏ឲ្យខ្ចី ដើម្បីបានចំណេញដែរ។ ប៉ុន្តែអ្នកវិញចូរប្រព្រឹត្តតែអំពើល្អ ឲ្យខ្ចីដោយមិនចង់បានចំណេញ ហើយអ្នកនឹងទទួលរង្វាន់ជាទីគាប់ចិត្ត"។ មែនហើយ ពិតជារង្វាន់ជាទីគាប់ចិត្តមែន ទោះជានៅលើផែនដីនេះក៏ដោយ... ប៉ុន្តែមាគ៌ានេះពិបាកដើរខ្លាំងណាស់ ជាពិសេសនៅជំហ៊ានដំបូង។ ឲ្យខ្ចីដោយមិនគិតកម្រៃជាតិជាមនុស្ស ហាក់ដូចជាពិបាកអនុវត្តតាម។ ឲ្យដាច់តែម្តងស្រួលជាង ព្រោះអ្វីៗដែលគេឲ្យ លែងជារបស់គេហើយ។ បើគេមកប្រាប់ដោយទឹកមុខប្រាកដប្រជាថា៖ "បងស្រីសូមជួយធ្វើការខ្ញុំពីរបីម៉ោងផង តែកុំបារម្ភខ្ញុំបានការអនុញ្ញាតពីអ្នកម៉ែហើយៗ ចាំខ្ញុំសងវិញ ព្រោះខ្ញុំដឹងអ្នកក៏ប្រញាប់ដែរ"។ ទោះជាគេដឹងច្បាស់ថា មិនដែលបានសងក៏ដោយ គេនៅតែឆ្លើយ៖ មានអីឲ្យជួយបាន។ នោះជាការស្រឡាញ់កិត្តិយសមួយ ព្រោះការឲ្យជាសកម្មភាពសប្បុរសជាងការឲ្យខ្ចី ។ ឱ! ការប្រៀនប្រដៅរបស់ព្រះយេស៊ូ មានសភាពផ្ទុយពីមនោសញ្ចេតនារបស់ធម្មជាតិមនុស្ស បើគ្មានការប្រោសប្រណីពីព្រះអង្គទេ គេមិនអាចអនុវត្តបានទេ ហើយមិនយល់ទៀតផង។

# "អស់អ្នកដែលព្រះអង្គប្រទានមកទូលបង្គំ"

## ( ១៨៩៦ - ១៨៩៧ )

អ្នកម៉ែ! ព្រះយេស៊ូបានប្រោសប្រណីចំពោះកូន ឲ្យយល់អំពីជម្រៅនៃអាថ៌កំបាំងរបស់សប្បុរសធម៌ ប៉ុន្តែ គួរឲ្យស្តាយ កូនមិនអាចនិយាយជម្រាបជូនម៉ែទេ បើសិនជាគ្មានព្រះបន្ទូលទេ ម្ល៉េះសមខ្ញុំដាក់ដងប៉ាកាចុះពុំខានឡើយ...

ម្សិលមិញ ខ្ញុំបានសរសេរថា ទ្រព្យសម្បត្តិលើលោកនេះ មិនមែនជារបស់ខ្ញុំទេ សម្បត្តិស្ថានបរមសុខ រឹតតែមិនមែនរបស់ខ្ញុំទៅទៀត គឺព្រះជាម្ចាស់ឲ្យខ្ញុំខ្ចី ព្រះអង្គអាចយកពេលណាក៏បាន ខ្ញុំគ្មានសិទ្ធទាមទារឡើយ។ ប៉ុន្តែ ទ្រព្យដែលព្រះអង្គប្រទានផ្ទាល់ គឺប្រាជ្ញា និងទឹកចិត្តគំនិតជ្រៅជ្រះ ជាសម្បត្តិដែលគេហួងហែង ថែរក្សាមិនឲ្យនរណាប៉ះពាល់ទេ... ឧទាហរណ៍ ក្នុងអង្គប្រជុំមួយ មានដូនជីម្នាក់ រកឃើញគំនិតភ្លឺស្វាងមួយ ក៏និយាយប្រាប់ទៅដូនជីម្នាក់ទៀត ដូនជីនេះយកគំនិតនេះ ទៅប្រាប់គេថា ជាគំនិតខ្លួនឯង ឬឧទាហរណ៍មួយទៀត ពេលឈប់សម្រាក គេនិយាយខ្សឹបៗ ពាក្យសម្ងាត់ទៅម្នាក់ទៀត ហើយអ្នកនេះយកសម្តីនេះនិយាយខ្លាំងឲ្យគេឮ ដោយគ្មានប្រាប់អំពីប្រភពដែលសម្តីនេះចេញមក ហាក់ដូចជាលួចយករបស់គេ។ ម្ចាស់សម្តីមិនទាមទារសិទ្ធិទេ ប៉ុន្តែគេរិះរកឱកាសល្អ ដើម្បីមកអាក្រាតការលួចនេះ។

ខ្ញុំស្មានថា មានតែខ្ញុំទេ ដែលមានមនោសញ្ចេតនាដ៏ក្រៀមក្រំនេះ សាមណេរឯទៀត ក៏មានដូចគ្នាដែរ បើតាមសម្តីអ្នកម៉ែប្រាប់ខ្ញុំ។

ខ្ញុំរៀនបានច្រើន លើភារកិច្ចដែលម៉ែដាក់ឲ្យ ជាពិសេសខ្ញុំបង្ខំខ្លួនឲ្យអនុវត្ត តាមអ្វីៗដែលខ្ញុំបង្រៀនដល់អ្នកដទៃ។ ឥឡូវនេះ ខ្ញុំអាចនិយាយថា ព្រះយេស៊ូ ទ្រង់ប្រោសប្រណីមិនឲ្យខ្ញុំជាប់ជំពាក់នឹងសម្បត្តិផ្នែកវិញ្ញាណ និងចិត្តជាងសម្បត្តិ លើលោកនេះ។ បើគេយកគំនិតខ្ញុំ ទុកជាសម្បត្តិផ្ទាល់ខ្លួនគេ ខ្ញុំគិតថាជាការ ធម្មតា ព្រោះគំនិតនេះ ជាកម្មសិទ្ធិរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ មិនមែនជារបស់ ខ្ញុំទេ ព្រោះសន្តៈ ប៉ូលបានពោលថា បើគ្មានព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់ទេ យើងមិនអាចដាក់ឈ្មោះ *"បិតា"* ដល់ព្រះបិតារបស់យើងដែលគង់នៅស្ថានបរមសុខ បានឡើយ។ ព្រះអង្គមានសេរីភាពពេញលេញក្នុងការប្រើខ្ញុំ ដើម្បីឲ្យផ្សព្វផ្សាយ គំនិតល្អៗទៅអ្នកឯទៀត។ បើសិនជាខ្ញុំនៅតែគិតថា គំនិតនោះជារបស់ខ្ញុំៗ ខ្ញុំនឹងក្លាយទៅជា *"សត្វលាដឹកសារីកធាតុ"* ដែលស្មានថា គារវកិច្ចចំពោះសន្ត បុគ្គល សំដៅមកលើខ្លួនជាអ្នកដឹក។

ខ្ញុំមិនប្រមាថដល់គំនិតជ្រៅជ្រះ ដែលទ្រទ្រង់ព្រលឹង និងបង្រួបបង្រួម ព្រលឹងជាមួយព្រះជាម្ចាស់ទេ ប៉ុន្តែ ជាយូរមកហើយ ខ្ញុំយល់ថា មិនត្រូវសង្កត់ ធ្ងន់លើគំនិត ឲ្យគ្រប់លក្ខណ៍ ដើម្បីទទួលពន្លឺកាន់តែច្រើនទេ។ គំនិតល្អៗ បើ មិនយកមកអនុវត្តទេ ជាការឥតប្រយោជន៍។ ជាការពិត អ្នកខ្លះអាចទាញយក ផលកម្រៃយ៉ាងច្រើនអំពីគំនិតនោះ បើគេចេះដាក់ខ្លួនសុភាពរាបសា ហើយ ដឹងគុណចំពោះព្រះជាម្ចាស់ ដែលរាជាអនុញ្ញាតឲ្យគេចែករំលែកចំណី ព្រលឹង ដែលព្រះអង្គគាប់ព្រះហឫទ័យប្រោសប្រទាន ប៉ុន្តែបើព្រលឹងនោះ យកគំនិត ល្អៗនោះ ទៅបម្រើពួកផារីស៊ី អ្នកនោះក្លាយដូចមនុស្សម្នាក់កំពុងស្លាប់ ដោយ សេចក្តីស្រេកឃ្លាន ចំពោះមុខតុចំណីអាហារពោរពាស ដែលពួកភ្ញៀវរបស់ គាត់កំពុងបរិភោគ ហើយក្រលេកមើលទៅម្ចាស់ទ្រព្យដ៏សម្បូរបែបនេះ ដោយ ចំណង់។ មានតែព្រះជាម្ចាស់មួយអង្គគត់ដែលស្គាល់ជម្រៅចិត្ត... សត្វលោក មានគំនិតខ្លីពេកហើយ!... បើបានឃើញព្រលឹងមួយភ្លឺច្បាស់ជាងគេក៏សន្មតថា ព្រះយេស៊ូស្រឡាញ់ខ្លួនតិចជាងគេ ខ្លួនមិនអាចទទួលការប្រោសប្រណីដូចគេទេ។

ព្រះជាម្ចាស់មានសិទ្ធិប្រើសត្វលោក ដែលព្រះអង្គបង្កើតឲ្យចែកចំណីចាំបាច់ចំពោះព្រលឹងដទៃ។ នៅសម័យផារ៉ោន ព្រះអង្គមានព្រះបន្ទូលទៅព្រះរាជាអង្គនេះថា៖ "ខ្ញុំបានលើកតម្កើងអ្នក ក្នុងគោលបំណងឲ្យអ្នកបង្ហាញនូវមហិទ្ធិឫទ្ធិរបស់ខ្ញុំ ដើម្បីឲ្យគេស្គាល់ឈ្មោះខ្ញុំគ្រប់ទីកន្លែងនៅលើផែនដីនេះ"។ ជាច្រើនសតវត្សរ៍មកហើយ ដែលព្រះអង្គមានព្រះបន្ទូលពាក្យទាំងនេះ ហើយតាំងពីពេលនោះមក ព្រះអង្គឥតប្រែប្រួលទេ ព្រះអង្គប្រើសត្វលោកជាឧបករណ៍ ដើម្បីអនុវត្តស្នាព្រះហស្តព្រះអង្គជានិច្ច។

ប្រសិនបើក្រណាត់សំពត់គំនូរ អាចនិយាយ និងគិតបាន នោះគេមិនត្អូញត្អែរថា ជក់លាបពណ៌ប៉ះពាល់គេឥតឈប់ឈរ ហើយមិនច្រណែននឹងជក់ទេ ព្រោះអ្នកប្រើជក់នោះ គឺសិល្បៈករ ជាអ្នកកែច្នៃផ្ទាំងសំពត់ឲ្យមានសោភ័ណភាព។ ចំណែកឯជក់វិញ មិនអាចអួតសរសើរស្នាដៃខ្លួនទេ ព្រោះសិល្បៈករមិនរារែកនឹងប្រើជក់ផ្សេងៗទៀត ទោះជាពិបាកប្រើក៏ដោយ។

អ្នកម៉ែ! ខ្ញុំនេះហើយជាជក់តូច ដែលព្រះយេស៊ូជ្រើសរើស ដើម្បីលាបពណ៌រូបភាពព្រះអង្គ ក្នុងព្រលឹងទាំងអស់ ដែលម៉ែប្រគល់ឲ្យខ្ញុំ។ សិល្បៈករមិនប្រើជក់តែមួយទេ គេត្រូវការយ៉ាងតិចក៏ពីរដែរ។ ជក់ទីមួយសំខាន់ជាងគេ ព្រោះគេយកវាលាបពណ៌ទូទៅ ពាសពេញផ្ទាំងក្រណាត់យ៉ាងរហ័ស ចំណែកឯជក់តូចសម្រាប់គូររំលេចរូប។

ចំពោះខ្ញុំ អ្នកម៉ែជាជក់មានតម្លៃ ដែលព្រះយេស៊ូកាន់ប្រើដោយសេចក្តីស្រឡាញ់ ដើម្បីអនុវត្តកិច្ចការធំៗ ក្នុងព្រលឹងកូនៗរបស់ម៉ែ ឯខ្ញុំវិញជាកូនជក់តូច ដែលទ្រង់ប្រើផាត់ពណ៌លំអិត។

ព្រះអង្គប្រើជក់តូចលើកទីមួយ ក្នុងអំឡុងថ្ងៃទី៨ ធ្នូ ១៨៩២។ ខ្ញុំនៅចាំថាពេលនោះ ជាវេលានៃការប្រោសប្រណី។ ខ្ញុំនឹងជម្រាបជូននូវអនុស្សាវរីយ៍ដ៏ផ្អែមល្ហែមទាំងនោះ។

កាលដែលខ្ញុំចូលអារាមនេះ នៅអាយុ ១៥ឆ្នាំ ខ្ញុំបានជួបមិត្តភក្តិជាសាមណេរដូចគ្នាម្នាក់ ដែលចូលមុនខ្ញុំ តែប៉ុន្មានខែប៉ុណ្ណោះ។ គាត់មានអាយុលើសខ្ញុំប្រាំបីឆ្នាំ ចរិតដូចកូនក្មេង ដែលធ្វើឲ្យភ្លេចអាយុខុសគ្នានេះ។ កាលនោះ អ្នកម៉ែពេញចិត្តនឹងយើងទាំងពីរនាក់ណាស់។ យើងទៅណា ឬធ្វើអ្វីៗជាមួយគ្នាជានិច្ច ដើម្បីឲ្យសេចក្តីស្រឡាញ់ ដែលទើបនឹងកើតថ្មីៗនេះមានផលល្អ អ្នកម៉ែអនុញ្ញាតឲ្យពួកយើងសន្ទនាអំពីជំនឿម្តងម្កាល។ ខ្ញុំចូលចិត្តចរិតស្លូតបូត ឥតលាក់លៀមរបស់មិត្តខ្ញុំ ប៉ុន្តែ ខ្ញុំឆ្ងល់ជាខ្លាំង ហេតុអ្វីក៏គាត់មិនស្រឡាញ់ម៉ែ ដូចស្រឡាញ់ខ្ញុំ។ ម្យ៉ាងទៀត អកប្បកិរិយាគាត់ជាមួយដូនជីឯទៀត មិនសូវល្អទេ។ ខ្ញុំចង់ឲ្យគាត់ប្តូរចរិតអាក្រក់នេះចេញ។ តាំងពីពេលនោះមក ព្រះជាម្ចាស់ប្រទានឲ្យខ្ញុំយល់ថា ព្រះជាម្ចាស់ប្រទានពន្លឺដល់ព្រលឹងខ្លះ ទៅតាមកម្រិត តាមពេលវេលា ដូច្នោះហើយ ខ្ញុំក៏ត្រូវរង់ចាំវេលានោះ ដោយអំណត់ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ។

ថ្ងៃមួយ យើងនាំគ្នាពិចារណា ដើម្បីសន្ទនាតាមដែលអ្នកម៉ែអនុញ្ញាត សមស្របទៅតាមវិន័យ ដើម្បីឲ្យសេចក្តីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូ កាន់តែខ្លាំងក្លាថែមទៀត។ ខ្ញុំបារម្ភខ្លាចការសន្ទនារបស់យើងមិនអាចឈានទៅដល់គោលដៅ ស្រាប់តែពេលនោះ ព្រះជាម្ចាស់ប្រទានឲ្យខ្ញុំដឹងខ្លួនថា វេលាដល់ហើយៗ កុំភ័យនិយាយ ដូចជាការជជែកគ្នារវាងមិត្តភក្តិធម្មតា។ ថ្ងៃសៅរ៍នោះ ជាថ្ងៃបន្ទាប់ពីខ្ញុំបានថ្លែងអំណរព្រះគុណព្រះជាម្ចាស់ ខ្ញុំបានទូលអង្វរ សូមឲ្យព្រះអង្គបណ្តាលមាត់ខ្ញុំ ឲ្យពោលពាក្យផ្អែមល្ហែម និងគួរឲ្យជឿទុកចិត្ត ឬក៏ព្រះអង្គមានព្រះបន្ទូលផ្ទាល់តាមរយៈខ្ញុំ។ ពេលនោះទ្រង់ទទួលពាក្យទូលអង្វររបស់ខ្ញុំ ទ្រង់បណ្តាលឲ្យបានលទ្ធផលល្អ សមដូចបំណង ព្រោះអ្នកបែរមុខទៅរកព្រះអង្គ នឹងទទួលបានការបំភ្លឺ ហើយពន្លឺនោះ នឹងភ្លឺរហូតដល់ទីងងឹត សម្រាប់អ្នកសុចរិត។

ព្រះបន្ទូលទីមួយសម្រាប់ខ្លួនខ្ញុំ ព្រះបន្ទូលទីពីរសម្រាប់មិត្តខ្ញុំ ដែលជាអ្នកសុចរិតពិតៗ...។

ពេលសន្មតមកដល់ ដូនជីកម្សត់មើលចំមុខខ្ញុំ ឃើញថាខ្ញុំខុសធម្មតា គាត់អង្គុយជិតខ្ញុំ មុខក្រហមអៀនប្រៀន ខ្ញុំទាញក្បាលគាត់មកដាក់លើទ្រូងខ្ញុំ ខ្ញុំនិយាយដោយទឹកភ្នែក នូវអ្វីៗដែលខ្ញុំគិតពីគាត់ ដោយសម្តីទន់ភ្លន់ ពោរពេញដោយសេចក្តីស្រឡាញ់ បន្តិចក្រោយមក ទឹកភ្នែកយើងទាំងពីរនាក់ រលាយចូលគ្នា។ គាត់ព្រមទទួលដោយស្មោះសថា សម្តីខ្ញុំជាការពិត ហើយសន្យាថានឹងចាប់ផ្តើមជីវិតថ្មីមួយទៀត ព្រមទាំងសុំឲ្យជួយប្រាប់កំហុសឆ្គង ដែលគាត់ធ្វើឲ្យគាត់បានដឹងផង។ ក្រោយពីបំបែកគ្នាមក សេចក្តីស្រឡាញ់របស់យើងក្លាយជាសេចក្តីស្រឡាញ់នៃវិញ្ញាណ លែងជារបស់មនុស្សលោកទៀតហើយ ដូចឃ្លាមួយនៃព្រះគម្ពីរចែងថា៖ *"ប្អូនប្រុសដែលមានបងប្រុសជួយ ដូចទីក្រុងដែលមានកំពែងជាបន្ទាយ"*។

បើគ្មានអ្នកម៉ែទេ គំនូរដែលព្រះយេស៊ូគូរ ដោយសារជក់គូច នឹងត្រូវរលុបបាត់បង់មិនខាន។ ការលំបាកនេះហាក់ដូចជាជូរចត់ណាស់ ចំពោះចិត្តក៏កម្សត់របស់ខ្ញុំ ប៉ុន្តែចរិតម៉ឺងម៉ាត់របស់ម៉ែ បានទទួលជ័យជម្នះ ដូច្នេះទើបខ្ញុំអាចលួងលោម ពន្យល់គាត់អំពីសេចក្តីស្រឡាញ់ពិតប្រាកដ។ ខ្ញុំបានពន្យល់ឲ្យគាត់ស្រឡាញ់ខ្លួនគាត់ផ្ទាល់ មិនមែនអ្នកម៉ែទេ។ ខ្ញុំនិយាយប្រាប់គាត់ថា ខ្ញុំស្រឡាញ់អ្នកម៉ែដូចម្តេច និងការលះបង់ជាច្រើន ដែលខ្ញុំត្រូវធ្វើតាំងពីថ្ងៃដំបូងនៃជីវិតជាអ្នកបួសរបស់ខ្ញុំ ដើម្បីកុំឲ្យជាប់ចិត្តនឹងអ្នកម៉ែ តាមរបៀបសម្ភារៈនិយមដូចឆ្កែស្រឡាញ់ម្ចាស់។ សេចក្តីស្រឡាញ់ត្រូវការការលះបង់ កាលណាព្រលឹងបដិសេធមិនព្រមទទួលការពេញចិត្ត តាមបែបធម្មជាតិនោះ ឥរិយាបទទន់ភ្លន់ក្លាយជារឹងមាំ និងគ្មានគិតប្រយោជន៍ផ្ទាល់ខ្លួន។

ខ្ញុំនៅចាំបានថា កាលខ្ញុំចូលអារាមដំបូង ខ្ញុំចង់ចូលទៅកន្លែងអ្នកម៉ែខ្លាំងណាស់ គឺគ្រាន់តែបានសប្បាយចិត្តមួយភ្លែតប៉ុណ្ណោះ ខ្ញុំត្រូវដើរកាត់ឃ្លាំង ហើយ

គោងព្យួរខ្លួនទៅបង្កាន់ដៃជណ្ដើរ។ កាលនោះ ខ្ញុំខំរកមធ្យោបាយជាច្រើន ដើម្បីសម្រេចបំណងនេះ... ឥឡូវខ្ញុំត្រេកអរដោយពុំបានធ្វើតាមទំនើងចិត្ត ហើយខ្ញុំបានទទួលរង្វាន់ដែលជាកិច្ចសន្យាចំពោះអ្នកប្រយុទ្ធយ៉ាងក្លាហាន។ ខ្ញុំយល់ថាគ្មានប្រយោជន៍អ្វីនឹងបដិសេធការប្រលោមចិត្តទេ ព្រោះព្រលឹងខ្ញុំបានរឹងប៉ឹងក៏ដោយសារព្រះជាម្ចាស់មួយអង្គគត់ ដែលខ្ញុំស្រឡាញ់។ ដោយចិត្តរីករាយ ខ្ញុំគិតឃើញថា ពេលខ្ញុំស្រឡាញ់ព្រះអង្គ ចិត្តខ្ញុំកាន់ខ្ពង់ខ្ពស់ ហើយព្រះអង្គអាចប្រទានសេចក្ដីទន់ភ្លន់ឥតប្រៀបផ្ទឹមបាន ចំពោះអ្នកស្រឡាញ់ព្រះអង្គច្រើនជាងអ្នកដែលមានសេចក្ដីស្រឡាញ់ប្រមូលផ្ដុំទុកដូចអត្តទត្ថបុគ្គល។

ខ្ញុំបានរៀបរាប់ជូនអ្នកម៉ែអំពីការងារដំបូង ដែលព្រះយេស៊ូនឹងអ្នកម៉ែប្រគល់ឲ្យខ្ញុំ។ កាលដែលខ្ញុំចូលទៅដល់ទីសក្ការបូជានៃព្រលឹង ខ្ញុំយល់ថា ជាការងារមួយហួសកម្លាំង ដូច្នេះយើងខ្ញុំប្រគល់ខ្លួនក្នុងព្រះហស្ដព្រះអង្គ ដូចក្មេងតូចលាក់មុខក្នុងព្រះកេសារបស់ព្រះអង្គ ខ្ញុំទូលព្រះអង្គថា៖ ព្រះអម្ចាស់អើយ! ទូលព្រះបង្គំជាខ្ញុំនៅតូចណាស់ មិនអាចបំប៉នចំណីដល់បុត្រធីតាព្រះអង្គបានទេ បើព្រះអង្គចង់ឲ្យខ្ញុំម្ចាស់ធ្វើតាមតម្រូវការរបស់ពួកគេ សូមព្រះអង្គដាក់ចំណីនោះ លើបាតដៃខ្ញុំម្ចាស់មក ហើយកុំដកព្រះហស្ដចេញ កុំបែរព្រះភ័ក្ត្រចេញ ខ្ញុំម្ចាស់នឹងផ្ដល់ទ្រព្យរបស់ព្រះអង្គ ចំពោះព្រលឹងដែលមកសុំនោះ។ បើគេពេញចិត្ត ខ្ញុំម្ចាស់នឹងប្រាប់គេថា ជាចំណីរបស់ព្រះអង្គ តែបើគេមិនពេញចិត្តទេ គេយល់ថាល្វីងខ្ញុំម្ចាស់នឹងណែនាំពន្យល់គេថា ជាចំណីរបស់ព្រះអង្គ ហើយខ្ញុំម្ចាស់មិនយកចំណីផ្សេងមកផ្ដល់ឲ្យគេទេ ទង្វើនេះមិនរំខានដល់សេចក្ដីស្ងប់របស់ខ្ញុំម្ចាស់ឡើយ។

តាំងពីខ្ញុំយល់ថា ត្រូវធ្វើអ្វីៗដោយខ្លួនឯង កិច្ចការដែលម៉ែដាក់ ហាក់ដូចជាលែងពិបាកហើយ ខ្ញុំដឹងថា ការចាំបាច់តែមួយគត់ គឺត្រូវរួបរួមបន្តិចម្ដងៗជាមួយព្រះយេស៊ូ ហើយវត្ថុសំណល់នឹងបានមកលើខ្ញុំ។ តាមការពិតសេចក្ដី

សង្ឃឹមរបស់ខ្ញុំ មិនដែលខុសទេ ព្រះជាម្ចាស់មានមេត្តាបំពេញបាតដៃដ៏តូចរបស់ខ្ញុំ រៀងរាល់លើកដែលខ្ញុំចាំបាច់ត្រូវបំប៉នព្រលឹងដូនជីឯទៀត។ អ្នកម៉ែខ្ញុំសូមសារភាពថា ប្រសិនបើខ្ញុំពឹងលើកម្លាំងផ្ទាល់ខ្លួន ប្រហែលជាខ្ញុំសុំចុះចាញ់ទៅហើយ... ដើម្បីឲ្យព្រលឹងទាំងអស់នោះ ប្រព្រឹត្តអំពើល្អ ឬធ្វើឲ្យគេកាន់តែស្រឡាញ់ព្រះជាម្ចាស់ ដើម្បីប្រែក្លាយពួកគេទៅតាមទស្សនៈ និងគំនិតផ្ទាល់របស់ព្រះអង្គ មើលពីចម្ងាយហាក់ដូចជាងាយណាស់ ប៉ុន្តែបើពិនិត្យឲ្យជិតទៅមិនដូច្នោះទេ... គេគិតថាបើព្រះជាម្ចាស់មិនជួយទេ គេមិនអាចធ្វើអំពើល្អឡើយ។ គេគិតថា ត្រូវបំភ្លេចចោលចំណង់ចំណូលចិត្ត និងការយល់ហើយផ្ទាល់ខ្លួន ហើយដឹកនាំព្រលឹងទៅតាមមាគ៌ាដែលព្រះយេស៊ូបានត្រួសត្រាយទុក ដោយមិនចាំបាច់សាកល្បងដើរតាមចិត្តចង់ទេ។ ប៉ុន្តែរឿងនោះ មិនជាពិបាកណាស់ណាទេសម្រាប់ខ្ញុំកិច្ចការលំបាក គឺពិនិត្យរកកំហុសការខ្វះខាតបន្តិចបន្តួច ហើយត្រូវប្រយុទ្ធប្រឆាំងរហូតដល់វិនាសអស់។ កាលនោះខ្ញុំគិតថា ជាសំណាងអាក្រក់។ តាំងពីខ្ញុំប្រគល់ខ្លួនក្នុងរង្វង់ព្រះហស្តនៃព្រះយេស៊ូ ខ្ញុំក្លាយជាអ្នកចាំយាមត្រួតពិនិត្យរកសត្រូវពីលើប៉មដ៏ខ្ពស់នៃវិមានមួយ។ គ្មានអ្វីគេចចេញពីក្រសែភ្នែកខ្ញុំឡើយ ជួនកាលខ្ញុំឆ្ងល់នឹងខ្លួនឯង ដែលមើលឃើញច្បាស់ល្អ ហើយខ្ញុំគិតថាមិនគួរប្រកាន់ទោសព្យាការី យ៉ូណាស (Jonas) ដែលរត់គេចចេញ មិនព្រមប្រាប់អ្នកស្រុកពីការបាក់បែកទីក្រុងនីនីវេឡើយ។ ខ្ញុំចូលចិត្តទទួលការស្តីបន្ទោសជាជាងបន្ទោសគេ ប៉ុន្តែចាំបាច់ណាស់ ត្រូវរងទុក្ខលំបាក ព្រោះធម្មតាព្រលឹងដែលគេចាប់កំហុស មិនស្គាល់កំហុសខ្លួនឯងឡើយ ហើយតែងតែគិតថា៖ ដូនជីអ្នកដឹកនាំខឹងខ្ញុំធ្វើអ្វីក៏ខុស ខំយ៉ាងណាក៏មិនត្រូវចិត្តដែរ។

ខ្ញុំដឹងច្បាស់ថា ពួកគេគិតថាខ្ញុំតឹងរ៉ឹងពេក។ ប្រសិនបើពួកគេដឹងថា ខ្ញុំខិតខំយ៉ាងណា ដើម្បីឲ្យគេបានល្អ ព្រោះខ្ញុំស្រឡាញ់ពួកគេ ដោយសេចក្តីស្រឡាញ់ពិតប្រាកដ។ ខ្ញុំមិនមែនជាអ្នកស៊ីឈ្នួលឃ្វាលចៀម ពេលឃើញឆ្កែ

ចចក មកដល់រត់យករួចខ្លួន បោះបង់ហ្វូងចៀមចោលទេ ខ្ញុំបម្រុងនឹងបូជាជីវិត ដើម្បីការពារពួកគេ ដោយសេចក្តីស្រឡាញ់បរិសុទ្ធ។ បេសកកម្មខ្ញុំ គឺដឹកនាំគេ ទៅរកព្រះជាម្ចាស់ហើយ ឲ្យពួកគេយល់ថា អ្នកម៉ែជាព្រះយេស៊ូវរស់នៅលើ លោកនេះ ដែលពួកគេត្រូវស្រឡាញ់ និងគោរព។

ក្នុងការបង្រៀនអ្នកដទៃ ខ្ញុំចេះចាំបានច្រើន ហើយខ្ញុំយល់ឃើញថា ព្រលឹង ស្ទើរតែទាំងអស់ មានការពុះពារដូចៗគ្នា ប៉ុន្តែពីម្នាក់ទៅម្នាក់ មានសភាពខុស គ្នាឆ្ងាយណាស់។ បូជាចារ្យម្នាក់មានប្រសាសន៍ថា៖ "ព្រលឹងនីមួយៗ ខុសគ្នា ខ្លាំងជាងមុខម្នាក់ៗទៅទៀត គេមិនអាចបង្រៀនព្រលឹងទាំងអស់តាមរបៀប តែមួយឡើយ។ ជាមួយ (ព្រលឹង) អ្នកខ្លះ ខ្ញុំត្រូវធ្វើខ្លួនតូចទាប មិនញញើតនឹង បន្ទុះបង្អាប់ខ្លួនឯង ដោយសារភាពអំពីកំហុស នឹងបរាជ័យរបស់ខ្ញុំ។ ដោយ ឃើញថា ខ្ញុំក៏មានចំណុចខ្សោយដែរ ដូនជីទាំងនោះហ៊ានសារភាពកំហុសឆ្គង ស្តីបន្ទោសខ្លួនឯង ហើយត្រេកអរនឹងការឃោគយល់ដល់ពួកគេ។ ផ្ទុយទៅវិញ ដើម្បីឲ្យគេបានល្អ អ្នកខ្លះត្រូវការភាពតឹងរ៉ឹង មិនចាំបាច់និយាយច្រើនដងទេ។ ព្រោះគេយល់ថា ឱនលំទោនមិនមែនសុភាពរាបសាឡើយ តែជាភាពទន់ខ្សោយ។ ព្រះជាម្ចាស់ទ្រង់ប្រោសប្រណីមិនឲ្យខ្ញុំខ្លាច ទោះជាយ៉ាងណាខ្ញុំត្រូវបំពេញ កាតព្វកិច្ចឲ្យបានល្អ។ ជាច្រើនលើកមកហើយ ខ្ញុំបានឮពាក្យនេះ៖ "បើចង់ បានអ្វីៗពីខ្ញុំ ត្រូវធ្វើឲ្យទន់ភ្លន់ បើប្រើកម្លាំងកុំសង្ឃឹម"។ គ្មាននរណាជាចៅក្រម ល្អ ក្នុងការកាត់ក្តីខ្លួនឯងទេ កូនក្មេងដែលគ្រូពេទ្យវះកាត់ឲ្យឈឺចាប់ មុខជា ស្រែកខ្លាំងៗថា ការព្យាបាលឈឺជាងជំងឺទៅទៀត ប៉ុន្តែ ប៉ុន្មានថ្ងៃក្រោយមក គេជាសះស្បើយ គេរីករាយ ហើយរត់លេងបាន។ ព្រលឹងក៏ដូច្នោះដែរ ក្រោយ មកគេទទួលស្គាល់ថា ភាពល្វីងជូរចត់បន្តិចបន្តួច ជួនកាលគ្រាន់បើជាងស្ករ ហើយមិនខ្លាចនឹងសារភាពទេ។ មានពេលខ្លះ ខ្ញុំមិនអាចទប់សេចក្តីរីករាយ បានទេ ដោយឃើញការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ អស្ចារ្យណាស់... គេមក ប្រាប់ខ្ញុំថា "ការតឹងតែងរបស់អ្នកពីម្សិលមិញ ពិតជាត្រឹមត្រូវ... ពីដំបូង ខ្ញុំខឹង

តែក្រោយមកខ្ញុំគិតឡើងវិញ ឃើញថាអ្នកសុចរិតណាស់... អ្នកដឹងទេ ពេលចេញដើរ ខ្ញុំគិតទៅជម្រាបអ្នកម៉ែថា ខ្ញុំលែងទៅជាមួយដូនជី ថេរេសា ទៀតហើយ។ ប៉ុន្តែខ្ញុំយល់ថា អារក្សបានបណ្តាលចិត្តខ្ញុំ រួចខ្ញុំយល់ថា អ្នកបានទូលអង្វរឲ្យខ្ញុំៗ នៅស្ងៀម ពន្លឺក៏ភ្លឺចែងចាំងឡើង។ ខ្ញុំមកនេះ សូមអ្នកជួយបំភ្លឺខ្ញុំឲ្យបានច្បាស់ផង"។ ការសន្ទនាក៏បានចាប់ផ្តើមភ្លាម។ ខ្ញុំត្រេកអរណាស់ដោយអាចដើរតាមលំអាននៃចិត្តខ្ញុំបាន មិនចាំបាច់ប្រើម្ហូបល្បីង ពាក្យតែមួយម៉ាត់អាចផ្តួលសំណាង់ ដែលសង់ឡើងក្នុងទឹកភ្នែក។ ឱ! គឺការអធិដ្ឋាន និងការលះបង់ដែលជួយខ្ញុំ ជាអាវុធមិនដែលចាញ់ ដែលព្រះយេស៊ូប្រទានឲ្យខ្ញុំ។ កិច្ចការនេះធ្វើឲ្យរំជួលវិញ្ញាណជាងពាក្យសម្តី តាមការពិសោធន៍ច្រើនដងរបស់ខ្ញុំ។ ក្នុងនោះមានបទពិសោធន៍មួយ ដែលនាំឲ្យអារម្មណ៍ខ្ញុំធូរស្រាល និងជ្រាលជ្រៅ។

ពេលនោះ ជាបុណ្យរដូវ ៤០ថ្ងៃ ដូច្នេះ ខ្ញុំទទួលខុសត្រូវលើដូនជីតែម្នាក់ទេ។ ព្រឹកមួយ គាត់មករកខ្ញុំ ដោយទឹកមុខស្រស់ស្រាយ ហើយនិយាយថា៖ "អ្នកដឹងទេយប់មិញ ខ្ញុំយល់សប្តិឃើញថា ខ្ញុំនៅក្បែរប្អូនស្រីខ្ញុំដែលចូលចិត្តអួត ហើយខ្ញុំចង់ជម្រះអំនួតរបស់គេ ខ្ញុំបានពន្យល់កំណាព្យមួយឃ្លានេះ៖ រស់ដោយសេចក្តីស្រឡាញ់ អ្នកស្រឡាញ់ព្រះយេស៊ូ គឺបាត់បង់ភាពសម្បូរណ៍សប្បាយ ទឹកអប់ទាំងអស់បងឲ្យឯង បងមិនយកវិញទេ។ ខ្ញុំដឹងថា សម្តីខ្ញុំជ្រាបចូលព្រលឹងគេ ហើយខ្ញុំរីករាយណាស់។ ព្រឹកនេះ ពេលភ្ញាក់ពីដំណេក ខ្ញុំគិតថាព្រះជាម្ចាស់មានបំណងឲ្យខ្ញុំផ្តល់ព្រលឹងនេះឲ្យទ្រង់។ ខ្ញុំចង់សរសេរសំបុត្ររៀបរាប់ពីការយល់សប្តិនេះ ផ្ញើទៅគេក្រោយបុណ្យ ប្រាប់គេថា ព្រះយេស៊ូចង់បានគេមករួបរួមជាមួយព្រះអង្គ ភ្លាមនោះ ខ្ញុំឆ្លើយថា គាត់អាចសាកល្បងបាន ប៉ុន្តែត្រូវសុំការអនុញ្ញាតពីអ្នកម៉ែសិន។ ដោយបុណ្យនោះវែង អ្នកម៉ែឆ្ងល់នឹងការសុំទុកយូរពេក ព្រះជាម្ចាស់បណ្តាលចិត្តអ្នកម៉ែឲ្យឆ្លើយថា អ្នកបួសនៅកាមែលសង្គ្រោះព្រលឹងដោយការអធិដ្ឋាន មិនមែនដោយសំបុត្រទេ។

ការសម្រេចចិត្តរបស់អ្នកម៉ែ គឺការសម្រេចរបស់ព្រះយេស៊ូ ហើយខ្ញុំទូលទៅព្រះមាតានៃព្រះត្រៃឯកៈ "ចូរយើងអធិដ្ឋានឲ្យបានច្រើន! មិនដឹងជាសប្បាយចិត្តយ៉ាងណាទេ បើចប់បុណ្យ យើងបានសម្រេច!"។ ឱ! ព្រះមហាករុណាទិគុណនៃព្រះអម្ចាស់អើយ សូមព្រះអង្គសណ្ដាប់ពាក្យអង្វររបស់បុត្រធីតារបស់ព្រះអង្គផង... ចប់បុណ្យ ព្រលឹងមួយទៀតមករួបរួមជាមួយព្រះយេស៊ូ។ គឺពិតជាអស្ចារ្យនៃការប្រោសប្រណីរបស់ព្រះអង្គ ដែលកើតឡើងអំពីជំនឿយ៉ាងខ្លាំងក្លារបស់សាមណេរដ៏ទន់ខ្សោយម្នាក់!

មហិទ្ធិឫទ្ធិនៃការអធិដ្ឋាន ឧត្តុង្គឧត្តមណាស់! ហាក់ដូចជារាជនីមួយអង្គមានបុព្វសិទ្ធ អាចយាងជួបព្រះមហាក្សត្របានគ្រប់ពេល ហើយអាចទទួលគ្រប់យ៉ាង តាមសំណូមពររបស់ព្រះនាង។ ដើម្បីទទួលការប្រោសប្រទាន មិនចាំបាច់ថាតាមរូបមន្តក្នុងសៀវភៅឡើយ បើមិនដូច្នោះទេ... គឺខ្ញុំជាអ្នកគួរឲ្យអាណិត... ក្រៅពីសូត្រធម៌ឧទ្ទិសដល់ព្រះជាម្ចាស់ ខ្ញុំមិនសូវថ្នឹក ខ្ញុំមិនចាំទេ... ខ្ញុំឈឺក្បាលព្រោះមានច្រើនពេក មិនដឹងរើសយកមួយណាទេ ខ្ញុំធ្វើដូចកូនក្មេងមិនចេះអានខ្ញុំទូលទៅព្រះជាម្ចាស់តាមតែខ្ញុំចង់ទូល ដោយមិនបានរៀបចំឃ្លាឲ្យល្អឡើយតែព្រះអង្គយល់អំពីខ្ញុំ។ ការអធិដ្ឋាន គឺជាសន្ទុះចិត្ត គឺជាការក្រលេកមើលជាធម្មតា ទៅស្ថានបរមសុខ ជាសម្រែកនៃការថ្លែងអំណរព្រះគុណ និងសេចក្ដីស្រឡាញ់ក្នុងរង្វង់ទុក្ខព្រួយ និងរង្វង់សេចក្ដីរីករាយ និយាយឲ្យចំ គឺអ្វីៗដែលខ្ពង់ខ្ពស់ជាអច្ឆរិយៈ ដែលពង្រីកវិញ្ញាណ និងបង្រួបបង្រួមខ្ញុំទៅព្រះយេស៊ូ។

ប៉ុន្តែ រាល់ការអធិដ្ឋានរួមជាក្រុម ឬក្នុងបូជនីយដ្ឋាន ខ្ញុំមិនសូត្រឲ្យរួចពីមាត់ទេ ហើយខ្ញុំចូលចិត្តការអធិដ្ឋានរួមគ្នា ព្រោះព្រះយេស៊ូបានសន្យាថា ព្រះអង្គនឹងយាងមកចូលរួម ក្នុងចំណោមអ្នកប្រជុំគ្នា រឭកដល់ព្រះនាមព្រះអង្គ ដូច្នេះហើយខ្ញុំគិតថា ជំនឿដ៏ខ្លាំងក្លារបស់ដូនជីទាំងអស់រួមទាំងខ្ញុំផង នឹងកាន់តែប្រសើរ។ បើសូត្រផ្ដាំម្នាក់ឯង ជាការលំបាកណាស់សម្រាប់ខ្ញុំ (ខ្ញុំអៀនណាស់)...

ខ្ញុំថាមិនចំពាក្យ ទោះជាខិតខំប្រមូលអារម្មណ៍ក៏ដោយ។ ខ្ញុំឆ្ងល់នឹងខ្លួនឯង ខ្ញុំស្រឡាញ់ព្រះមាតាណាស់ គួរតែខ្ញុំចេះរំឭកដល់ព្រះកិត្តិនាម ដែលធ្វើឲ្យព្រះនាងគាប់ព្រះហឫទ័យ។ ឥឡូវនេះ ខ្ញុំគិតថា ព្រះមាតាជាម្ដាយរបស់ខ្ញុំ ព្រះនាងយល់ពីបំណងរបស់ខ្ញុំ ព្រះនាងគាប់ព្រះហឫទ័យហើយ។

ជួនកាលស្មារតីខ្ញុំហាក់ដូចជារីងស្ងួត ខ្ញុំរិះគិតមិនយល់ មិនដឹងយកគំនិតណាមួយមករួបរួមជាមួយព្រះជាម្ចាស់បាន ខ្ញុំក៏សូត្រធម៌ "ព្រះបិតាអើយ" យឺតៗមួយៗ ស្រាប់តែភ្លាមនោះ ហាក់ដូចជាព្រះអង្គយាងមកសង្គ្រោះខ្ញុំ ព្រះធម៌នេះមកឆក់យកខ្ញុំទៅបំប៉នវិញ្ញាណខ្ញុំ ច្រើនលើសពីសូត្រញាប់មួយរយដងទៅទៀត។

ព្រះមាតាបង្ហាញថា ព្រះនាងមិនពិរោធនឹងខ្ញុំទេ ព្រះនាងតែងតែរក្សាការពារ នៅពេលដែលខ្ញុំឧទ្ទិសដល់ព្រះនាង។ បើខ្ញុំមានកង្វល់គិតមិនលេច ខ្ញុំងាកទៅរកព្រះនាងភ្លាម ព្រះនាងជួយខ្ញុំជានិច្ច ព្រោះព្រះមាតាជាម្ដាយដ៏ស្លូតបូតទន់ភ្លន់បំផុត។ រាល់ពេលសន្ទនាជាមួយពួកសាមណេ ខ្ញុំតែងតែឧទ្ទិសដល់ព្រះនាង ហើយខ្ញុំមានអារម្មណ៍ថា ទ្រង់តាមថែរក្សាខ្ញុំ ដូចម្ដាយគ្រប់រូប។

ជាញឹកញយ ពួកសាមណេប្រាប់ខ្ញុំថា៖ "អ្នកឆ្លើយបានគ្រប់សំណួរ តើអ្នករកបានចម្លើយពីណាមក?" បើខ្ញុំឆ្លើយថា ខ្ញុំមើលក្នុងព្រលឹងពួកគេ ហាក់ដូចជាត្រង់ពេក ព្រោះខ្ញុំធ្លាប់ទាយទុក្ខជាមុននូវគំនិតពួកគេ។ មានយប់មួយនោះ ដូនជីម្នាក់ដែលរស់នៅជាមួយខ្ញុំ បានលាក់ទុក្ខលំបាកដែលធ្វើឲ្យគាត់ឈឺចាប់ជាខ្លាំង។ លុះព្រឹកឡើងពេលជួបគ្នា គាត់និយាយដោយទឹកមុខញញឹម។ ពេលនោះ ខ្ញុំមិនឆ្លើយនឹងសំណួរគាត់ទេ ខ្ញុំសួរគាត់ដោយប្រាកដក្នុងចិត្តថា៖ អ្នកកើតទុក្ខអ្វី? គាត់មើលមកខ្ញុំដោយឆ្ងល់។ ភាពស្រឡាំងកាំងរបស់គាត់ ធ្វើឲ្យខ្ញុំខ្លាចមែនទែន។ ខ្ញុំដឹងច្បាស់ថា គ្មានឧបនិស្ស័យ មើលវិញ្ញាណមនុស្សទេ ខ្ញុំក៏ឆ្ងល់ខ្លួនឯងដែរ ហេតុអ្វីខ្ញុំថាត្រូវម៉្លេះ។ ខ្ញុំគិតថា ព្រះជាម្ចាស់នៅក្បែរៗនោះ តែខ្ញុំមើលមិនឃើញព្រះអង្គ ខ្ញុំនិយាយដូចកូនក្មេង មិនមែនជាសម្ដីខ្ញុំទេ តែជាព្រះបន្ទូលរបស់ព្រះអង្គ។

ដូចអ្នកម៉ែជ្រាបស្រាប់ហើយ ពួកសាមណេជាអ្នកសម្តីច្រើន មិនសូវដឹងរាក់ជ្រៅ។ នោះជាការងារស្រួល ព្រោះពួកគេមិនចង់ឱនលំទោនចំពោះខ្ញុំដូចគ្រូឯទៀត។ ខ្ញុំមិនអាចនិយាយថា ព្រះយេស៊ូមានបំណងឲ្យខ្ញុំដាក់ខ្លួន ឬយ៉ាងណាទេ។ ព្រះអង្គគាប់ព្រះហឫទ័យឲ្យខ្ញុំដាក់ខ្លួនចំពោះភ្នែកសត្វលោក ខ្ញុំបានជោគជ័យគ្រប់យ៉ាង ខ្ញុំជាផ្លូវនាំទៅរកកិត្តិយស ផ្នែកសាសនាក៏ដូច្នោះដែរ។ ខ្ញុំដឹងថា ព្រះអង្គចង្អុលផ្លូវដែលប្រកបដោយគ្រោះថ្នាក់ឲ្យខ្ញុំដើរ មិនមែនដើម្បីខ្ញុំទេ តែសម្រាប់អ្នកឯទៀត។ ប្រសិនបើខ្ញុំជាដូនជីម្នាក់សំបូរគុណវិបត្តិ អសមត្ថភាព អន់ប្រាជ្ញា ឥតវិចារណញ្ញាណ ប្រហែលជាអ្នកម៉ែមិនព្រមឲ្យខ្ញុំជួយទេ។ ព្រះជាម្ចាស់បានបោះស្បៃគ្របគុណវិបត្តិទាំងអស់របស់ខ្ញុំ ហើយជួនកាលស្បៃនោះអាចទាក់ទាញពាក្យសរសើផងដែរ ប៉ុន្តែខ្ញុំចង់ឮពាក្យផ្សេងៗទៀត ក្រៅពីពាក្យសរសើរ។ អ្នកម៉ែជ្រាបទេ ខ្ញុំចូលចិត្តទឹកខ្មេះជាងស្ករ។ ព្រលឹងខ្ញុំក៏ដូច្នោះដែរ ធុញទ្រាន់នឹងចំណីផ្អែមជ្រុល ដូច្នេះហើយ ទើបព្រះយេស៊ូអនុញ្ញាតឲ្យគេញាំជ្រក់ដាក់ទឹកខ្មេះ និងគ្រឿងទេស។ ក្នុងជ្រក់មានគ្រឿងផ្សំច្រើនមុខ លើកលែងតែប្រេង។ ពួកសាមណេបានធ្វើជ្រក់ដ៏ឆ្ងាញ់លើកមកឲ្យខ្ញុំ ដោយមិនបានដឹងមុន។ ព្រះជាម្ចាស់បើកស្បៃគ្របភាពមិនគ្រប់លក្ខណ៍របស់ខ្ញុំ ដូច្នេះសាមណេតូចៗ ក៏មើលឃើញរូបរាងពិតរបស់ខ្ញុំ។ គេធ្វើឲ្យខ្ញុំចូលចិត្ត ដោយសម្តីសំដៅ និងអកប្បកិរិយាសាមញ្ញ គេហ៊ាននិយាយប្រាប់ខ្ញុំអំពីការប្រយុទ្ធ ដែលខ្ញុំដាក់ឲ្យពួកគេ និងអំពីអ្វីៗដែលគេមិនចូលចិត្តខ្ញុំ គេលែងទើសទាល់ ទោះជាសួរពីអ្វីផ្សេងទៀតក៏ដោយ ព្រោះគេដឹងថា ខ្ញុំចូលចិត្តរបៀបនេះ។ ឱ! ខ្ញុំសប្បាយចិត្តណាស់ នេះជាការជប់លៀងអាហារដ៏ឆ្ងាញ់ពិសារមួយ ចំពោះព្រលឹងរបស់ខ្ញុំ។ ខ្ញុំមិនអាចពន្យល់ថាហេតុដូចម្តេចបានជាវត្ថុមួយដែលគេមិនពេញចិត្ត អាចនាំសុភមង្គលដ៏ធំមួយបាន បើសិនជាខ្ញុំមិនបានពិសោធន៍ ខ្ញុំមិនអាចជឿទេ។ (...)

កាលពីមុន បើឃើញដូនជីធ្វើអ្វីមួយមិនបានត្រឹមត្រូវ ឯងតែងចង់និយាយ

ប្រាប់ឲ្យគាត់កែកំហុស។ តែឥឡូវនេះ មនោសញ្ចេតនាខ្ញុំផ្លាស់ប្តូរអស់ហើយ។ កាលបើឃើញដូនជីម្នាក់ប្រព្រឹត្តអំពើផ្តាំផ្តុង ខ្ញុំដកដង្ហើមធំ ធូរស្រាលក្នុងចិត្ត ហើយគិតថាមានសុភមង្គលណាស់! ព្រោះខ្ញុំមិនបាច់ធ្វើបន្តទៀតទេ។ តាំងពីខ្ញុំឈឺមក អ្នកម៉ែជួយថែទាំខ្ញុំៗ កាន់តែយល់អំពីសប្បុរសធម៌ថែមទៀត។ អ្នកមិនដែលគិតអំពីតម្លៃថ្នាំពេទ្យទេ អ្នកតែងតែដាស់តឿនខ្ញុំឲ្យចេះថៃខ្លួន។ ខ្ញុំមិនអាចរៀបរាប់អស់គុណបំណាច់របស់អ្នកម៉ែឡើយ។

ខ្ញុំសម្គាល់ឃើញថា តាមធម្មតាដូនជីដែលវិសុទ្ធ មានគេស្រឡាញ់រាប់អានចូលចិត្តជជែកលេងជាមួយ ចូលចិត្តជួយធ្វើការងារ ដោយមិនបាច់ពឹង ហើយព្រលឹងគាត់អាចទ្រាំទ្រនឹងការមើលងាយមិនចេះគួរសម អាចប្រដូចទៅនឹងសម្តីសន្តៈ យូហាននៃឈើឆ្កាង៖ ខ្ញុំទទួលបានទ្រព្យសម្បត្តិទាំងអស់ កាលណា ខ្ញុំស្វែងរកដោយមិនគិតពីមុខមាត់។

ចំណែកឯព្រលឹង មិនទាន់គ្រប់លក្ខណ៍វិញ គេមិនសូវចូលចិត្ត គេគោរពទៅតាមកិច្ចគួរសម រួចគេដើរចេញ ព្រោះគេខ្លាចនិយាយជ្រុលជ្រួស នាំឲ្យគាត់មិនសប្បាយចិត្ត។ ព្រលឹងមិនគ្រប់លក្ខណ៍ ខ្វះការពិចារណា ខ្វះការអប់រំ ខ្វះបុគ្គលិកលក្ខណៈខ្លះៗ ដែលនាំឲ្យពិបាករស់នៅ មិនចុះសម្រុងនឹងគេ។ ពិការភាពខាងផ្លូវចិត្តនេះជាសភាពរ៉ាំរ៉ៃ គ្មានសង្ឃឹមនឹងជាសះស្បើយ។ ដូច្នេះហើយទើបរាល់ពេលចេញលេង ខ្ញុំតែងតែស្វែងរកដូនជីដែលខ្ញុំមិនសូវចូលចិត្ត រួចអធិដ្ឋានឲ្យព្រលឹងរបួសនេះ ដោយសប្បុរស។ ការញញឹមរាក់ទាក់ សម្តីមួយម៉ាត់ គ្រប់គ្រាន់សម្រាប់ឲ្យគាត់ ស្រាយទឹកមុខក្រញ៉ូវទៅជាស្រស់ថ្លាបាន។ និយាយឲ្យចំទៅ ខ្ញុំចង់ធ្វើល្អចំពោះមនុស្សគ្រប់រូប ដើម្បីឲ្យព្រះយេស៊ូគាប់ព្រះហឫទ័យ ស្របតាមដំបូន្មានរបស់ព្រះអង្គ ដែលមាននៅក្នុងដំណឹងល្អ៖ "បើអ្នកជប់លៀង កុំអញ្ជើញញាតិមិត្ត ដោយខ្លាចពួកគេអញ្ជើញអ្នកវិញ ធ្វើបែបនេះ អ្នកបានទទួលរង្វាន់។ ប៉ុន្តែសូមអ្នកអញ្ជើញជនក្រីក្រ ជនពិការ នោះអ្នក



នឹងរីករាយ ដោយពួកគេគ្មានអ្វីតបស្នងអ្នកវិញទេ ប៉ុន្តែព្រះបិតាដែលស្ថិតនៅទីសម្ងាត់ ប្រទានរង្វាន់ដល់អ្នក"។

នៅកាមែល គ្មានពិធីជប់លៀងណា ដែលអាចអញ្ជើញដូនជីឯទៀតទេ មានតែការជប់លៀងវិញ្ញាណ ដែលមានមុខម្ហូបសប្បុរសធម៌ សេចក្ដីស្រឡាញ់ នឹងភាពរីករាយ។ ខ្ញុំមិនស្គាល់អ្វីក្រៅពីនេះទេ ហើយខ្ញុំចង់ធ្វើគ្រាប់តាមសន្ទះ ប៉ូលដ៏វិសុទ្ធដែលរីករាយជាមួយអ្នកដែលគាត់ជួបក្នុងពេលកំពុងសប្បាយ តាមពិតទៅ គាត់ក៏យំជាមួយអ្នកមានទុក្ខលំបាកដែរ ទឹកភ្នែកអាចហូរនៅពេលជប់លៀងនោះបាន ប៉ុន្តែខ្ញុំៗនឹងសាកល្បងធ្វើឲ្យទឹកភ្នែកនោះ ប្រែទៅជាសេចក្ដីរីករាយព្រោះព្រះអម្ចាស់គាប់ព្រះហឫទ័យ អ្នកធ្វើទានដោយសប្បាយចិត្ត។

កាលខ្ញុំនៅជាសាមណេ ព្រះជាម្ចាស់ទ្រង់បណ្ដាលចិត្តខ្ញុំឲ្យធ្វើអំពើសប្បុរសមួយ។ ព្រះបិតានៃយើង ព្រះអង្គទតមើលចេតនាជាជាងទំហំនៃអំពើព្រះអង្គមានព្រះនេត្រទិព្វ ព្រះអង្គប្រទានរង្វាន់ឲ្យខ្ញុំរួចទៅហើយ មិនបាច់ចាំជីវិតខាងក្រោយទេ។ កាលនោះ ជាពេលដែលដូនជីសន្ទះ សិលា អញ្ជើញចូលទីសក្ការបូជានិងទៅអាហារដ្ឋាន។ ក្នុងពិធីអធិដ្ឋានពេលល្ងាច គាត់អង្គុយខាងមុខខ្ញុំដប់នាទីមុនម៉ោងប្រាំមួយ ត្រូវមានដូនជីម្នាក់គ្រាហ៍ គាត់ទៅអាហារដ្ឋាន ព្រោះគិលានុប្បដ្ឋាយិកាមានអ្នកជំងឺច្រើនពេក មិនអាចមកទទួលគាត់បានទេ។ ជាការពិបាកដើម្បីជានាកិច្ចការនេះ ព្រោះគាត់ឈឺ ហើយគាត់មិនចូលចិត្តប្ដូរអ្នកគ្រាហ៍ទេ ប៉ុន្តែខ្ញុំចង់ធ្វើកិច្ចការនេះណាស់។ ព្រះយេស៊ូមានព្រះបន្ទូលថាៈ អ្វីៗដែលអ្នកធ្វើចំពោះអ្នកតូចតាចជាងគេរបស់ខ្ញុំៗ នឹងធ្វើចំពោះអ្នកវិញ។ ដូច្នេះ ខ្ញុំក៏ធានាខ្លួនគ្រាហ៍គាត់។

រាល់ល្ងាច ពេលឃើញគាត់រលាស់កែវខ្សាច់ មានន័យថា ត្រូវចេញដំណើរគឺជារឿងអំពល់ទុក្ខមួយ ជាពិសេស ពេលចាប់ផ្ដើម ខ្ញុំត្រូវរើរួចកាន់ជើងម៉ាតាមបែបបទមិនត្រូវប្រញាប់ប្រញាល់ពេកទេ ត្រូវកាន់គាត់នៅត្រង់ខ្សែក្រវ៉ាត់។ ខ្ញុំទ្រគាត់ថ្នម់ៗតាមដែលអាចធ្វើបាន បើគ្រាហ៍គាត់មិនត្រូវទំនង គាត់ច្បាស់ជាដួល

ពុំខានឡើយ។ *"ឱ! ព្រះអើយឯង ដើរលឿនពេក ខ្ញុំដួលបាក់ឆ្អឹងឥឡូវហើយ"* ប៉ុន្តែបើខ្ញុំដើរយឺតជាងនេះ "ដើរឲ្យទាន់ខ្ញុំមក ឯងលែងដៃខ្ញុំដួលឥឡូវហើយ! ខ្ញុំថាហើយថា ឯងក្មេងពេក នាំខ្ញុំមិនកើតទេ"។ ទីបំផុតយើងមកដល់អាហារដ្ឋានដោយគ្មានគ្រោះថ្នាក់។ នៅទីនោះក៏មានការលំបាកច្រើនដែរៈ ត្រូវដាក់ឲ្យគាត់អង្គុយដោយប្រុងប្រយ័ត្ន រួចមូរដៃអាវឲ្យគាត់ (តាមបែបបទ) ទើបខ្ញុំអាចចេញទៅបាន។ គាត់ដាក់នំប៉័ងចូលពែងទាំងលំបាក។ ខ្ញុំមិនដាច់ចិត្តដើរចោលគាត់ទេ គាត់មិនដែលពឹងខ្ញុំឡើយ ប៉ុន្តែរាល់ល្ងាចខ្ញុំតែងតែជួយកាច់នំប៉័ងឲ្យគាត់មុនពេលដើរចេញទៅ។ ក្រោយមក ទើបខ្ញុំដឹងថា គាត់រំជួលចិត្ត និងរាប់អានខ្ញុំយ៉ាងខ្លាំង។

ប្រហែលជាអ្នកម៉ែឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំរៀបរាប់អំពើសប្បុរសកំប៉ិកកំប៉ុក ដែលកន្លងហួសជាយូរមកហើយទៅវិញ? ខ្ញុំសរសេរ ព្រោះខ្ញុំចង់ថ្លែងអំណរព្រះគុណព្រះអម្ចាស់ ព្រះអង្គប្រទានអនុស្សាវរីយ៍នេះដូចទឹកមន្ត ដើម្បីអប់រំបេះដូងខ្ញុំ។ ជួនកាលរឿងតូចតាចដែលកន្លងទៅ បានធ្វើឲ្យព្រលឹងខ្ញុំរីករាយហាក់ដូចជាបានទទួលជំនោររដូវផ្ការីកដូច្នោះដែរ។ នេះជារឿងតូចមួយទៀតល្ងាចមួយនៃសិសិររដូវ (រដូវរងា) តាមធម្មតា ខ្ញុំសូត្រធម៌អធិដ្ឋាន។ យប់ងងឹតហើយរងា... ស្រាប់តែខ្ញុំឮសំឡេងភ្លេងយ៉ាងគ្រលួចពីចម្ងាយ ខ្ញុំក៏នឹកស្រមៃដល់បន្ទប់ទទួលភ្ញៀវមួយ ភ្លឺព្រោងព្រាយ ប្រកបដោយក្បាច់រចនាពណ៌ទឹកមាស យុវនារីច្រើននាក់ ក្នុងសម្លៀកបំពាក់ស្រស់សង្ហារ កំពុងតែនិយាយលេងសរសើរគ្នាទៅវិញទៅមក និងគោរពឱនលំទោនយ៉ាងទាន់សម័យ។ បន្ទាប់មកខ្ញុំក្រលេកមើលឃើញជូនជីដែលខ្ញុំគ្រាហ៍។ ពេលនោះ មិនមែនជាសំឡេងពិរោះរណ្តំទេ ខ្ញុំបែរជាឮសំឡេងថ្ងូរត្អូញត្អែររបស់គាត់យូរម្តងៗ ចំណែកឯក្បាច់ពណ៌មាស ក៏ក្លាយជាឥដ្ឋជាញ្ជាំង បន្ទប់តូចដ៏ក្រៀមក្រំរបស់យើង បំភ្លឺដោយកូនចង្កៀងទៅវិញ។ ខ្ញុំមិនអាចនិយាយពីវិញ្ញាណខ្ញុំពេលនោះបានទេ អ្វីៗ គឺព្រះអម្ចាស់បំភ្លឺវិញ្ញាណនេះ ដោយរស្មីនៃសេចក្តីពិត ដែលឈ្នះលើពន្លឺព្រោងព្រាយក្នុង

ឱកាសបុណ្យធំៗលើផែនដីនេះទៅទៀត។ ឱ! នេះហើយជាសុភមង្គលដែលមិននឹកស្មានដល់... ខ្ញុំមិនប្តូរការបំពេញសប្បុរសធម៌ដប់នាទី ជាមួយការសប្បាយមួយពាន់ឆ្នាំនៃពិធីបុណ្យលើលោកនេះទេ...

នៅពេលរងទុក្ខលំបាក សុភមង្គលមួយស្របក់មានតម្លៃជាងសុភមង្គលលើផែនដីនេះ។ បើគិតថាព្រះជាម្ចាស់នាំយើងចេញពីលោកនេះទៅដល់ស្ថានបរមសុខជាលំនៅព្រះអង្គ ដែលជាកន្លែងស្ងប់អស់កល្បជានិច្ច ប្រកបដោយការប្រោសប្រណីនោះ តើយើងនឹងមានបីតិសោមនស្សយ៉ាងណាទៅ?

ខ្ញុំប្រព្រឹត្តសប្បុរសធម៌ មិនសំដៅទៅលើការរីករាយសុទ្ធសាធទេ ប៉ុន្តែព្រះយេស៊ូប្រាថ្នាយល់ចិត្ត ព្រះជាយារបស់ព្រះអង្គ ដូច្នេះហើយ កាលដែលខ្ញុំគ្រាហ៍ដូនជីនោះ ខ្ញុំបានខិតខំអស់ពីចិត្តពីថ្លើម ហាក់ដូចជាគ្រាហ៍ព្រះយេស៊ូផ្ទាល់។ ធ្វើអំពើសប្បុរស មិនស្រួលរហូតទេ ខ្ញុំនឹងរៀបរាប់ជូននៅទំព័រខាងមុខនេះ។ យូរមកហើយ រាល់ពេលអធិដ្ឋាន ខ្ញុំតែងតែអង្គុយខាងមុខដូនជីម្នាក់ដែលមានទម្លាប់ចម្លែក ដែលខ្ញុំគិតថា... គាត់ចេះដឹងច្រើន ព្រោះគាត់កម្រប្រើសៀវភៅ។ ពេលគាត់មកដល់ភ្លាម ខ្ញុំសម្គាល់ឃើញថា គាត់ផ្តើមធ្វើឲ្យមានសំឡេងចម្លែកមួយ ដូចគេកកិតសំបកលៀសពីរ។ មានតែខ្ញុំទេ ដែលចាប់អារម្មណ៍ ព្រោះខ្ញុំមានត្រចៀកវៃណាស់។ កាលនោះ ខ្ញុំចង់ងាកមើលគាត់ ព្រោះគាត់មិនដឹងខ្លួនទេ។ ប៉ុន្តែ ខ្ញុំតាំងចិត្តមិនងាក ស៊ូទ្រាំដើម្បីព្រះជាម្ចាស់ កុំឲ្យគាត់ពិបាកចិត្ត។ ខ្ញុំនៅស្ងៀម ខិតខំស្ទឹងស្ទាធ ប្រមូលអារម្មណ៍នឹកទៅរកព្រះជាម្ចាស់បំភ្លេចសំឡេងនោះ... តែជាការឥតប្រយោជន៍ ញើសហូរជោកខ្លួន ហើយខ្ញុំបង្ខំចិត្តសូត្រអធិដ្ឋានអំពីការរងទុក្ខលំបាករបស់ព្រះយេស៊ូយ៉ាងពិបាក។ ខ្ញុំរិះរកមធ្យោបាយបំភ្លេចសំឡេងនោះ ដោយសេចក្តីស្ងប់ និងរីករាយ មិនមែនដោយចិត្តគ្នាន់ក្នាញ់ទេ យ៉ាងហោចណាស់ក៏ស្ងប់អារម្មណ៍ដែរ។ ខ្ញុំខិតខំស្រឡាញ់សំឡេងគួរឲ្យស្អប់នោះ ដោយស្តាប់យ៉ាងប្រុងប្រយ័ត្ន ហាក់ដូចជាស្តាប់ការ

ប្រគុំតន្ត្រី បន្ទាប់មកការអធិដ្ឋានរបស់ខ្ញុំ ប្រព្រឹត្តទៅដោយមានតន្ត្រីកំដរ ថ្វាយព្រះយេស៊ូផង។

មានម្ដងទៀត នៅកន្លែងបោកគក់ ខ្ញុំឈរទល់មុខដូនជីម្នាក់ ដែលចេះតែជផុះទឹកកខ្វក់មកលើមុខខ្ញុំរាល់លើក ដែលគាត់លើកកន្សែងបោកទៅលើក្ដារ។ មុនដំបូង ខ្ញុំថយក្រោយជូតមុខ ដើម្បីឲ្យគាត់ដឹងខ្លួន ប៉ុន្តែភ្លាមនោះ ខ្ញុំនឹកឃើញថា ខ្ញុំដូចជាឆោតពេក មិនព្រមទទួលកំណាប់ដែលគេឲ្យ ហើយខ្ញុំខំធ្វើមិនដឹងខ្លួន។ ទីបំផុតខ្ញុំលែងខ្ពើមរអើមទឹកកខ្វក់នោះទៀតហើយ។ ខ្ញុំសន្យាក្នុងចិត្តថា លើកក្រោយខ្ញុំមកកន្លែងនេះទៀត។

អ្នកម៉ែឃើញទេ ខ្ញុំជាព្រលឹងតូចមួយ ដែលអាចបូជាបានតែអំពើតូចៗប៉ុណ្ណោះ ជួនកាលខ្ញុំបានធ្វើឲ្យបាត់បង់ការបូជានេះដែរ ប៉ុន្តែ ខ្ញុំមិនដែលអស់សង្ឃឹមទេ ខ្ញុំនៅតែព្យាយាមធ្វើឲ្យខ្លាំងក្លាជាងមុន។

ព្រះជាម្ចាស់ល្អជាមួយខ្ញុំណាស់ ព្រះអង្គតែងតែប្រទានទៅតាមបំណងរបស់ខ្ញុំ តែតាមពិតទៅ គឺព្រះអង្គទេ ដែលបណ្ដាលចិត្តខ្ញុំឲ្យចង់បាន។ ពីមុនខ្ញុំគិតថា៖ ខ្ញុំពិតជាពុំដែលបានទទួលការលំបាកធំដុំផ្នែកខាងក្រៅទេ ឯការលំបាកខាងក្នុង ទាល់តែព្រះជាម្ចាស់ផ្លាស់ប្ដូរមាគ៌ាដែលខ្ញុំប្រកាន់យក ប៉ុន្តែខ្ញុំមិនជឿថាព្រះអង្គប្ដូរឡើយ តែខ្ញុំមិនអាចរស់នៅក្នុងសភាពសម្រាកលំហែ ដូច្នេះរហូតទេ... តើព្រះអង្គសាកល្បងខ្ញុំបែបណា? ចម្លើយឆ្លើយថា ព្រះអង្គមិនខ្វះមធ្យោបាយទេ ហើយមិនបាច់ប្ដូរមាគ៌ាផង ព្រះអង្គបញ្ជូនការលំបាកដែលសំបូរដោយភាពល្វីងជូរចត់លាយឡំដោយសេចក្ដីរីករាយ។ មិនគ្រាន់តែចង់លំបាកប៉ុណ្ណោះទេ ព្រះអង្គប្រទានប្រផ្នូល និងចំណង់ដល់ខ្ញុំ។ តាំងពីយូរមកហើយ ខ្ញុំចង់បានបងប្រុសម្នាក់ជាបូជាចារ្យ តែមិនអាចទៅរួច។ ខ្ញុំតែងតែគិតថា បើបងប្រុសខ្ញុំមិនស្លាប់អស់ទេ ប្រហែលជាខ្ញុំមានសុភមង្គលដោយឃើញពួកគេឡើងមកកាន់

ទីសក្ការបូជា ប៉ុន្តែពួកគេត្រូវព្រះជាម្ចាស់ចាត់តាំងឲ្យធ្វើជាទេវទូតតូចៗ អស់ទៅហើយ ក្តីស្រមៃរបស់ខ្ញុំ មិនអាចក្លាយជាការពិតបានទេ។ ប៉ុន្តែព្រះអង្គមិនគ្រាន់តែប្រទានពរតាមបំណងខ្ញុំទេ ទ្រង់បង្រួបបង្រួមខ្ញុំដោយចំណងវិញ្ញាណជាមួយនឹងសាវ័ករបស់ព្រះអង្គ ពីគាត់ដែលក្លាយជាប្អូនប្រុសខ្ញុំ...។

កាលនោះ អ្នកម៉ែថេរេសាដ៏វិសុទ្ធរបស់យើង បានបញ្ជូនប្អូនប្រុសទីមួយមកឲ្យខ្ញុំ ជំនួសឲ្យបាច់ផ្កាសម្រាប់ពិធីបុណ្យឆ្នាំ១៨៩៥។ ពេលនោះ ខ្ញុំនៅកន្លែងបោកគក់កំពុងធ្វើការងារ ស្រាប់តែអ្នកម៉ែអាញែសនៃព្រះយេស៊ូ នាំខ្ញុំទៅឆ្ងាយពីគេ ហើយអានសំបុត្រមួយឲ្យខ្ញុំស្តាប់។ គឺជានិស្សិតទេវវិទ្យាល័យមួយរូប ទទួលការណែនាំអំពីសន្តី ថេរេសា (នៃអាវីឡា) រកជូនជីអ្នកស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះវិញ្ញាណនិស្សិតនេះជាពិសេស ហើយជួយបង្រៀនគេអធិដ្ឋាន និងបូជាព្រោះគេត្រូវចេញទៅបំពេញបេសកកម្មជាសាសនទូត ដើម្បីសង្គ្រោះព្រលឹងជាច្រើនទៀត។ គេសន្យាមិនបំភ្លេចបងស្រីគេទេ បើគេអាចថ្វាយអភិបូជា។ អ្នកម៉ែអាញែសនៃព្រះយេស៊ូ ប្រាប់ថាគាត់ចង់ឲ្យខ្ញុំក្លាយជាបងស្រីរបស់សាសនទូតនេះ។

អ្នកម៉ែអើយ! ខ្ញុំមិនអាចពិពណ៌នាអំពីសុភមង្គលរបស់ខ្ញុំពេលនោះទេ។ បំណងខ្ញុំបានសម្រេច ខ្ញុំត្រេកអរដូចកូនក្មេង អារម្មណ៍នឹកភ្នកទៅដល់អនុស្សាវរីយ៍ពីកុមារភាព។ ច្រើនឆ្នាំកន្លងមកហើយ ខ្ញុំមិនដែលបានទទួលសុភមង្គលបែបនេះឡើយ ខ្ញុំមានអារម្មណ៍ដូចជាគេពាល់ខ្សែឧបករណ៍ភ្លេងជាលើកដំបូង។

ខ្ញុំយល់អំពីការចាំបាច់ដែលត្រូវប្រតិបត្តិតាម ដូច្នេះ ខ្ញុំក៏ខិតខំបង្កើនសេចក្តីក្លាហានទ្វេដង។ មុនដំបូងខ្ញុំមិនសូវខ្មះខ្មែងប៉ុន្មានទេ ព្រោះក្រោយពីសរសេរសំបុត្រថ្លែងអំណរចំពោះអ្នកម៉ែអាញែសនៃព្រះយេស៊ូមក ប្អូនប្រុសខ្ញុំបាត់ដំណឹងសូន្យ រហូតដល់ខែកក្កដាក្រោយ លើកលែងតែប័ណ្ណប្រៃសនីយ៍មួយនៅខែវិច្ឆិការៀបរាប់ថា គេចូលបន្ទាយបំពេញកាតព្វកិច្ចយោធា។ ព្រះជាម្ចាស់ប្រោសប្រទាន

ឲ្យអ្នកម៉ែបង្កើតស្នាដៃ ដោយការអធិដ្ឋានទូលអង្វរ និងបូជា ដែលអាចជួយសាសនទូតបាន។ ជួនកាលព្រះយេស៊ូគាប់ព្រះហឫទ័យបង្រួបបង្រួមព្រលឹងពីរ ដើម្បីសិរីរុងរឿងរបស់ព្រះអង្គៗ អនុញ្ញាតឲ្យព្រលឹងទាំងពីរនេះអាចសាសង គំនិតគ្នា លើកទឹកចិត្តគ្នា ឲ្យកាន់តែស្រឡាញ់ព្រះអង្គ។ ការសរសេរឆ្លងឆ្លើយនេះ ទោះជានៅឆ្ងាយក៏អាចបំពេញចន្លោះខ្វះខាតរបស់ស្មារតីគេបានដែរ។

កាលពីឆ្នាំទៅ ចុងខែឧសភា កាលនោះអ្នកម៉ែបានឲ្យគេមកហៅខ្ញុំទៅអាហារដ្ឋាន។ ពេលដើរទៅជួបអ្នកម៉ែ ទ្រូងខ្ញុំញាប់ញ័រជាខ្លាំង ព្រោះជាលើកដំបូងដែលអ្នកប្រើគេមកហៅ។ បន្ទាប់ពីអង្គុយចុះ អ្នកម៉ែសួរខ្ញុំថា៖ "តើអ្នកចង់ទទួលអប់រំវិញ្ញាណសាសនទូតម្នាក់ទេ គាត់ត្រូវគេចាត់តាំងជាបូជាចារ្យ ត្រូវចេញដំណើរក្នុងពេលឆាប់ៗនេះ" បន្ទាប់មក អ្នកម៉ែអានសំបុត្ររបស់គេឲ្យខ្ញុំស្ដាប់។ អារម្មណ៍ដំបូង គឺសេចក្ដីរីករាយ រួចគឺការភ័យព្រួយ។ ដូចខ្ញុំបានជម្រាបរួចមកហើយ ខ្ញុំទទួលអប់រំអនាគតសាវ័កមួយរូបរួចទៅហើយ មិនអាចទទួលម្នាក់ទៀតទេ ព្រោះមានដូនជីជាច្រើននាក់ដែលគ្រាន់បើប្រសើរជាងខ្ញុំ ហើយអាចឆ្លើយតបនឹងសំណើរនេះបាន។ អ្នកម៉ែឆ្លើយថា គេអាចមានបងប្អូនប្រុសច្រើននាក់។ កាលនោះ ខ្ញុំសួរថា តើខ្ញុំបានកុសលពីរដងឬទេ។ ម៉ែឆ្លើយថា ពិតមែនហើយ ម៉ែនាំនិយាយពីនេះពីនោះ ដើម្បីឲ្យខ្ញុំទទួលប្អូនប្រុសម្នាក់ទៀត។ ខ្ញុំក៏គិតដូចអ្នកម៉ែដែរ "ការខិតខំប្រឹងប្រែងរបស់អ្នកនៅអារាមកាមែលម្នាក់ត្រូវបំភ្លឺពិភពលោក"។ ខ្ញុំសង្ឃឹមថា ការប្រោសប្រណីរបស់ព្រះជាម្ចាស់ នឹងមានប្រយោជន៍ដល់សាសនទូតជាច្រើន ហើយខ្ញុំមិនភ្លេចបន់ស្រន់ជូនពួកគាត់ទេ។ ខ្ញុំក៏មិនភ្លេចបូជាចារ្យ (សាមញ្ញ) ដែលទៅបំពេញបេសកកម្មទីឆ្ងាយ ជួនកាលជួបការលំបាកដូចគ្នានឹងពួកសាវ័កជំនាន់ព្រះយេស៊ូ ទៅទេសនាឲ្យអ្នកគ្មានជំនឿស្ដាប់ដែរ។ ទីបំផុតខ្ញុំចង់ទៅជាកូនស្រីរបស់ព្រះសហគមន៍ ដូចអ្នកម៉ែសន្តី ថេរេសា (អាវីឡា) កាលគាត់នៅរស់ និងអធិដ្ឋានទូលអង្វរតាមបំណងសម្ដេចប៉ាប ព្រោះព្រះអង្គប្រាថ្នាចង់ឲ្យសកលលោកនេះមានពន្លឺត្រចេះត្រចង់។

នេះហើយជាគោលបំណងនៃជីវិតខ្ញុំ ប៉ុន្តែខ្ញុំមិនភ្លេចអធិដ្ឋាន និងរួបរួមជាពិសេសជាមួយទេវទូតតូចៗរបស់ខ្ញុំបានទេ។ នេះហើយជាការរួបរួមវិញ្ញាណរបស់ខ្ញុំជាមួយនឹងសាវ័ក ដែលព្រះយេស៊ូប្រទានមកជាប្អូនប្រុសខ្ញុំ។ អ្វីៗដែលជាកម្មសិទ្ធិរបស់ខ្ញុំ គឺជារបស់ពួកគេ ព្រះជាម្ចាស់សប្បុរសណាស់ ព្រះអង្គមិនបែងចែកទេ។ ព្រះអង្គសំបូរធនធានណាស់ ទ្រង់ប្រទានគ្មានកំណត់ តាមបំណងរបស់ខ្ញុំ... តាំងពីខ្ញុំមានប្អូនប្រុសពីរ និងប្អូនស្រីដែលជាសាមណេមក បើខ្ញុំសុំឲ្យគេរៀបរាប់លំអិតអំពីបំណងប្រាថ្នារបស់ពួកគេនោះ ប្រហែលជាមួយថ្ងៃទាល់ល្ងាច រាប់មិនអស់ផង។ អ្នកដែលមិនសូវមានប្រាជ្ញា មិនត្រូវការមធ្យោបាយសាំញ៉ាំទេ ខ្លួនខ្ញុំក៏នៅក្នុងចំណោមពួកនោះដែរ។ នៅព្រឹកមួយ ពេលអធិដ្ឋានសុំការប្រោសប្រណី ព្រះយេស៊ូប្រើមធ្យោបាយងាយស្រួលមួយ ដើម្បីបំពេញបេសកកម្ម។ ព្រះអង្គបណ្តាលឲ្យខ្ញុំយល់ពាក្យពេចន៍ក្នុងបទចម្រៀង៖ *"សូមទាក់ទាញខ្ញុំទៅ ខ្ញុំនឹងរត់តាមក្លិនក្រអូបរបស់អ្នក"* ។ ព្រះយេស៊ូអើយ! ព្រះអង្គមិនចាំបាច់មានព្រះបន្ទូលថា៖ បើអ្នកទាក់ទាញខ្ញុំ សូមទាក់ទាញវិញ្ញាណដែលខ្ញុំស្រឡាញ់ទេ គ្រាន់តែថា៖ *"ចូរព្រះអង្គទាក់ទាញខ្ញុំ"* បានហើយ។ ខ្ញុំម្ចាស់យល់ហើយ កាលណាព្រលឹងមួយបណ្តោយឲ្យលង់ខ្លួនតាមក្លិនក្រអូប ដែលនាំឲ្យស្រវឹង (ឈ្លក់វង្វេង) របស់ព្រះអង្គ ព្រលឹងនោះមិនទៅតែម្នាក់ឯងទេ គេដឹកនាំអ្នកឯទៀតដង្ហែរតាមក្រោយព្រះអង្គ ដោយគ្មានការបង្ខិតបង្ខំ មិនចាំបាច់ប្រឹង ដូចទឹកជ្រោះធ្លាក់ចុះមក ហើយហូរចាក់ទៅក្នុងមហាសមុទ្រ នាំទៅជាមួយនូវអ្វីៗទាំងអស់តាមផ្លូវដែលវាឆ្លងកាត់ យ៉ាងណាមិញ ព្រះយេស៊ូអើយ ព្រលឹងដែលមុជជ្រៅទៅក្នុងមហាសមុទ្រនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ មុខជាទាក់ទាញទៅជាមួយនូវរតនវត្ថុដែលគេស្រឡាញ់មិនខានឡើយ... ព្រះអម្ចាស់មានព្រះនេត្រទិព្វស្រាប់ហើយ ខ្ញុំម្ចាស់គ្មានរតនវត្ថុអ្វីក្រៅអំពីព្រលឹង ដែលព្រះអង្គមេត្តារួបរួមជាមួយខ្ញុំម្ចាស់ឡើយ។ នេះជាកំណាប់ដែលព្រះអង្គប្រទានមកឲ្យខ្ញុំម្ចាស់ ដូច្នេះខ្ញុំម្ចាស់ហ៊ានខ្ចីពាក្យពេចន៍ដែលព្រះអង្គមានព្រះបន្ទូល នៅល្ងាចថ្ងៃចុងក្រោយ



បង្អស់ កាលព្រះអង្គមានព្រះជន្មនៅឡើយ ទៅព្រះបិតានាស្ថានបរមសុខដល់អ្នកដំណើរ និងមនុស្សលោក... ខ្ញុំម្ចាស់មិនដឹងថា ការនិរទេសខ្លួនរបស់ខ្ញុំម្ចាស់ចប់នៅពេលណាទេ... ខ្ញុំម្ចាស់រស់នៅបានមួយល្ងាចទៀតហើយ ដើម្បីច្រៀងសរសើរព្រះមហាករុណាទិគុណរបស់ព្រះអង្គ ទីបំផុតល្ងាចចុងក្រោយនោះ នឹងមកដល់ពុំខាន។ ខ្ញុំម្ចាស់មានបំណងក្រាបទូលព្រះអង្គថា "ទូលបង្គំលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គលើផែនដីនេះ ទូលបង្គំបានបំពេញកិច្ចការដែលព្រះអង្គដាក់ហើយៗ ទូលបង្គំបានធ្វើឲ្យអ្នកដែលព្រះអង្គប្រទាន ស្គាល់ព្រះនាមព្រះអង្គ។ ឥឡូវនេះ ពួកគេដឹងហើយថា អ្វីដែលព្រះអង្គប្រទាន ជារបស់ព្រះអង្គ ព្រោះទូលបង្គំបានប្រកាសព្រះបន្ទូល ហើយពួកគេជឿថា ជាព្រះបន្ទូលព្រះអង្គពិតមែន សូមព្រះអង្គប្រទានពរដល់ពួកគេផង។ ទូលបង្គំនឹងលែងនៅលើលោកនេះទៀតហើយ ហើយទូលបង្គំនឹងទៅជួបព្រះអង្គ។ ឱព្រះបិតាដ៏វិសុទ្ធអើយ ក្នុងបរមនាមរបស់ព្រះអង្គ សូមទ្រង់ថែរក្សាពួកគេ ដែលព្រះអង្គប្រទានឲ្យទូលបង្គំ និងជួយការពារពួកគេអំពីអំពើអាក្រក់ផង។ ទូលបង្គំក៏សូមទូលអង្វរឲ្យព្រះអង្គជួយថែរក្សា អ្នកមានជំនឿចំពោះព្រះអង្គ និងអ្នកនាំព្រះបន្ទូលទៅប្រាប់ផងដែរ។

បើទូលបង្គំទៅដល់ទីណា សូមឲ្យអ្វីៗដែលព្រះអង្គប្រទាន បានទៅជាមួយទូលបង្គំផង សូមឲ្យលោកទាំងមូលដឹងថាព្រះអង្គស្រឡាញ់ពួកគេ ដូចស្រឡាញ់ទូលបង្គំដែរ។"

ព្រះអម្ចាស់អើយ! នេះហើយជាពាក្យពេចន៍ ដែលខ្ញុំម្ចាស់ចង់ថាតាមព្រះអង្គ មុននឹងខ្ញុំម្ចាស់ត្រូវហោះហើរទៅក្នុងព្រះហស្តព្រះអង្គ។ តើនេះជាការហ៊ានជ្រុលឬ? មិនមែនទេ ព្រោះជាយូរមកហើយ ព្រះអង្គតែងតែកម្លាចិត្តទូលព្រះអង្គឲ្យហ៊ាននិយាយ ព្រះអង្គមានព្រះបន្ទូលថា៖ "អ្វីៗជារបស់ទូលបង្គំ គឺជារបស់ព្រះអង្គ "ព្រះបន្ទូលនៅជាមួយខ្ញុំម្ចាស់ ដូច្នេះខ្ញុំម្ចាស់អាចប្រើព្រះបន្ទូលនោះ

ដើម្បីទាក់ទាញព្រលឹងឯទៀត ដែលមករួបរួមជាមួយខ្ញុំម្ចាស់ ទៅតាមព្រះបំណង របស់ព្រះបិតានៅស្ថានបរមសុខ។ ព្រះអម្ចាស់អើយ! កាលដែរខ្ញុំម្ចាស់សុំឲ្យអ្នក ដែលព្រះអង្គប្រទានទៅតាមខ្ញុំម្ចាស់ដែរនោះ គឺខ្ញុំម្ចាស់មិនហ៊ានទាមទារឲ្យពួកគេ ឈានទៅដល់ជោគជ័យ ខ្ពង់ខ្ពស់ជាងការប្រទានមកខ្ញុំម្ចាស់ទេ គ្រាន់តែសូមឲ្យ យើងជួបគ្នានៅស្ថានបរមសុខប៉ុណ្ណោះ។ ខ្ញុំម្ចាស់មិនលោភលន់ចង់បានជោគជ័យ អ្វីទៀតទេ ក្រៅពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ សេចក្ដីស្រឡាញ់នោះ បាន នៅជាមួយខ្ញុំម្ចាស់តាំងពីក្មេងមក ឥឡូវនេះ គឺជាជ្រោះជ្រៅមួយដែលខ្ញុំម្ចាស់ មិនអាចវាស់បាន។ សេចក្ដីស្រឡាញ់ទាក់ទាញសេចក្ដីស្រឡាញ់ ដូច្នេះហើយ សេចក្ដីស្រឡាញ់របស់ខ្ញុំម្ចាស់ចង់បំពេញជ្រោះជ្រៅដែលទាក់ទាញវា ប៉ុន្តែគួរឲ្យ ស្ដាយ! នោះជាទឹកសន្សើមមួយតំណក់រមៀលធ្លាក់ទៅក្នុងមហាសមុទ្រ! ដើម្បី ស្រឡាញ់ព្រះអង្គ ដូចព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ ត្រូវតែគិតដល់ការស្រឡាញ់ កិត្តិយសរបស់ព្រះអង្គ ទើបខ្ញុំម្ចាស់ស្ងប់ចិត្ត។ ខ្ញុំម្ចាស់ក័ន្តច្រលំទេដឹងថា ព្រះអង្គ ស្រឡាញ់ខ្ញុំម្ចាស់ ជាងព្រលឹងឯទៀត។ ថ្ងៃណាមួយនៅស្ថានបរមសុខ បើខ្ញុំម្ចាស់ ឃើញព្រះអង្គស្រឡាញ់ពួកអ្នកដែលព្រះអង្គប្រទានច្រើនជាងខ្ញុំម្ចាស់ៗ នឹងរីក រាយបំផុត។ ប៉ុន្តែនៅលើផែនដីនេះ ខ្ញុំម្ចាស់មិនអាចវាស់ទំហំនៃសេចក្ដីស្រឡាញ់ របស់ព្រះអង្គបានឡើយ។

អ្នកម៉ែ! យើងវិលមករកប្រវត្តិនៃប្អូនប្រុសខ្ញុំវិញ។ ខ្ញុំសូមជម្រាបថា ខ្ញុំមិន ដែលបង្រៀនដំណឹងល្អដល់ពួកគេទេ ប៉ុន្តែប្អូនស្រីវិញ ខ្ញុំបង្រៀនអំពីព្រះបន្ទូល ដំបូង ខ្ញុំបង្រៀនពួកគេ តាមដែលអ្នកម៉ែបង្រៀនខ្ញុំ។ ខ្ញុំមិនជឿថា ខ្ញុំអាចប្រៀន ប្រដៅសាសនទូតទេ ចំណែកឯប្អូនស្រីវិញ ខ្ញុំគ្រាន់តែឲ្យដំបូន្មានខ្លះៗប៉ុណ្ណោះ បើគ្មានអ្នកម៉ែទេ ខ្ញុំធ្វើមិនកើតឡើយ។

ចំណែកឯប្អូនប្រុសទាំងពីរនាក់ ខ្ញុំនឹកពួកគេ ហើយខ្ញុំសរសេរព្រះបន្ទូល ផ្ញើដូចតទៅនេះ៖ "ទូលបង្គំមិនសុំឲ្យព្រះអង្គយកគេចេញពីលោកនេះទេ... ទូល

បង្ខំសូមអង្វរព្រះអង្គថែមទៀត ដើម្បីអ្នកដែលមានជំនឿលើព្រះអង្គ ក្រោយពីឮគេប្រាប់ "បេសកកម្មរបស់ប្អូនប្រុសទាំងពីរត្រូវទៅឆ្ងាយ ពួកគេនឹងរងទុក្ខលំបាកក្នុងការទៅទេសនា ប្រៀនប្រដៅ អ្នកមិនទាន់មានជំនឿ ហេតុអ្វីបានជាខ្ញុំមិនទូលអង្វរឲ្យព្រលឹងពួកគេ?

ខ្ញុំគិតថា ចាំបាច់ត្រូវជម្រាបអ្នកម៉ែបន្ថែមទៀតអំពីវគ្គខ្លះនៃបទចម្រៀង៖ "សូមព្រះអង្គទាក់ទាញខ្ញុំទៅ យើងរត់តាម" ព្រោះខ្ញុំហាក់ដូចជាមិនសូវយល់។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "គ្មាននរណាអាចមកតាមក្រោយខ្ញុំទេ បើព្រះបិតាដែលបញ្ជូនខ្ញុំមកមិនទាក់ទាញ" បន្ទាប់មក តាមរយៈរឿងនិទាន ឬជួនកាលព្រះអង្គបង្រៀនពួកយើងថា គ្រាន់តែគោះទ្វារទៅ គេនឹងបើកឲ្យហើយ គ្រាន់តែស្វែងរកឲ្យឃើញ និងហុចដៃយ៉ាងសុភាពរាបសា ដើម្បីទទួលអ្វីៗដែលគេសុំទៅបានហើយ... ព្រះអង្គមានព្រះបន្ទូលទៀតថា៖ អ្វីៗដែលគេសុំទៅព្រះបិតាតាមរយៈព្រះនាមព្រះអង្គនោះ ព្រះបិតាមិនបដិសេធទេ។ មុនព្រះយេស៊ូប្រសូតព្រះវិញ្ញាណដ៏វិសុទ្ធបានត្រាស់បង្គាប់ឲ្យសរសេរសេចក្ដីអធិដ្ឋាន ដែលជាការព្យាករណ៍នេះទុក ចូរទាក់ទាញខ្ញុំ ពួកយើងនឹងរត់តាម។

តើអ្វីទៅដែលហៅថា សូមឲ្យទាក់ទាញ បើមិនមែនជាការរួបរួមយ៉ាងជិតស្និទ្ធជាមួយនឹងវត្ថុដែលជាប់ចិត្តទេឬ? ប្រសិនបើភ្លើង និងដែកត្រូវគ្នា ហើយដែកប្រាប់ទៅភ្លើងថា៖ ចូរទាក់ទាញខ្ញុំទៅ តើនេះមិនបង្ហាញថា ដែកចង់ប្រដូចខ្លួនជាមួយភ្លើង ដើម្បីជ្រាបចូល និងរលាយជាមួយភ្លើង ដូចវត្ថុធាតុតែមួយ។ អ្នកម៉ែ នេះជាការទូលអង្វររបស់ខ្ញុំៗ សូមឲ្យព្រះយេស៊ូទាក់ទាញខ្ញុំ ចូលទៅក្នុងអណ្ដាតភ្លើងនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ បង្រួបបង្រួមខ្ញុំនឹងព្រះអង្គ សូមព្រះអង្គស្ថិតនៅក្នុងខ្លួនខ្ញុំ។ បើភ្លើងនៃសេចក្ដីស្រឡាញ់កាន់តែឆេះក្នុងចិត្តខ្ញុំ ខ្ញុំកាន់តែថា៖ សូមព្រះអង្គទាក់ទាញខ្ញុំម្ចាស់ និងព្រលឹងដែលនៅជិតខ្ញុំម្ចាស់ផង ពួកគេនឹងរត់យ៉ាងលឿន តាមក្លិនក្រអូបនៃព្រះជាទីស្រឡាញ់របស់គេ ព្រោះ

ព្រលឹងដែលឆាបឆេះដោយសេចក្ដីស្រឡាញ់ មិនអាចនៅស្ងៀមបានទេ ដូច សន្ដី ម៉ារី ឈរក្បែរព្រះបាទាព្រះយេស៊ូ ស្ដាប់ព្រះបន្ទូលដ៏ស្លូតបូត ពោរពេញទៅដោយសេចក្ដីស្រឡាញ់។ មើលទៅហាក់ដូចជាគ្មានផ្ដល់អ្វីសោះ តែតាមការពិត នាងផ្ដល់ច្រើនជាងម៉ាថា ដែលច្រាសច្រាលគិតពីនេះពីនោះ ហើយចង់ឲ្យបងស្រីធ្វើគ្រាប់តាមទៀតផង។ ព្រះយេស៊ូមិនបន្ទោសម៉ាថាទេ ព្រះមាតាព្រះអង្គបានធ្វើការបម្រើគ្រួសារនេះអស់មួយជីវិត។ ព្រះអង្គគ្រាន់តែចង់កែប្រែអាការៈព្រួយបារម្ភរបស់ម្ចាស់ផ្ទះនេះប៉ុណ្ណោះ។ សន្ដបុគ្គលទាំងអស់បានយល់។ សន្ដៈ ប៉ូល សន្ដៈ អូគូស្ដាំង សន្ដៈ យូហាននៃឈើឆ្កាង សន្ដៈ តូម៉ាសដាកកាំង (Thomas d'Aquin) សន្ដៈ ហ្វ្រង់ស័រ សន្ដៈ ដូមីនីក និងអ្នកល្បីល្បាញឯទៀត ដែលជាមិត្ដសម្លាញ់របស់ព្រះជាម្ចាស់ បានដកស្រង់សេចក្ដីអធិដ្ឋានយកពីវិទ្យាសាស្ត្រនៃទេវវិទ្យា។ អ្នកប្រាជ្ញម្នាក់បាននិយាយថា៖ "ចូរអ្នកឲ្យឃ្នាស់មួយចំនុចសង្កត់មួយ ខ្ញុំនឹងគាស់លើកពិភពលោក"។ អ្នកប្រាជ្ញអាកស៊ីមែត (Archimède) នេះមិនអាចធ្វើកើត ព្រោះគាត់មិនបានសុំទៅព្រះជាម្ចាស់ គាត់ជាអ្នកសម្ភារនិយម។ ចំណែកឯសន្ដបុគ្គលវិញ អាចធ្វើបានយ៉ាងពេញលេញ។ ព្រះជាម្ចាស់ប្រទានចំនុចសង្កត់មួយឲ្យពួកលោក៖ គឺខ្លួនព្រះអង្គផ្ទាល់។ សេចក្ដីអធិដ្ឋានគឺជាឃ្នាស់ ព្រោះការអធិដ្ឋានបញ្ឆេះឲ្យកើតភ្លើងនៃសេចក្ដីស្រឡាញ់ គេអាចគាស់លើកពិភពលោកបាន។ ដូច្នេះហើយសន្ដបុគ្គលជាអ្នកតស៊ូប្រយុទ្ធលើកពិភពលោក ហើយសន្ដបុគ្គលឯទៀតនឹងតស៊ូបន្ដទៅទៀត រហូតដល់អវសាននៃពិភពលោក។

អ្នកម៉ែ ខ្ញុំចង់ជម្រាបជូននូវអ្វីៗដែលខ្ញុំឮតាមព្រះកិត្ដិនាមដ៏ក្រអូបរបស់ព្រះជាទីស្រឡាញ់ ដោយព្រះអង្គយាងទៅកាន់ស្ថានបរមសុខវិញហើយ ខ្ញុំអាចដើរតាមស្នាមព្រះបាទដែលព្រះអង្គប្រទានទុក ស្នាមទាំងនោះមានពន្លឺ ក្លិនក្រអូប! ខ្ញុំអាចស្រូបយកក្លិនក្រអូបនៃជីវិតព្រះអង្គក្នុងដំណឹងល្អ ហើយខ្ញុំដឹងភ្លាមថា ត្រូវ

រត់តាមទិសណាហើយ... ខ្ញុំមិនបាននាំមុខគេទេ តែមិនដើរតាមពួកផារីស៊ីដែរ គឺរត់ដោយយកចិត្តទុកដាក់សុភាពរាបសា តាមការអធិដ្ឋានរបស់អ្នកទារពន្ធដារ។ ខ្ញុំធ្វើត្រាប់តាមសន្តី ម៉ារី ឥរិយាបថចម្លែក និងសេចក្តីស្រឡាញ់យ៉ាងខ្លាំងក្លារបស់គាត់ បានសេពមន្តស័ន្តព្រះហឫទ័យព្រះយេស៊ូ និងចិត្តខ្ញុំ។ ប្រហែលជាខ្ញុំបានធ្វើបាបខ្លះ ខ្ញុំនឹងទៅសារភាពកំហុសទាំងនោះ ក្នុងព្រះហស្តព្រះអង្គ ព្រោះព្រះអង្គស្រឡាញ់កូនខ្ជះខ្ជាយ ដែលចេះកែកំហុស។ មិនមែនដោយសារព្រះហឫទ័យមេត្តាករុណាទេ ដែលព្រះជាម្ចាស់ការពារខ្ញុំពីបាបកម្មនានា រហូតដល់ខ្ញុំអាចឡើងទៅស្ថានព្រះអង្គ គឺដោយសារការជឿទុកចិត្ត និងសេចក្តីស្រឡាញ់។

# អវសានបទ

## "...ដោយការជឿទុកចិត្ត និងសេចក្តីស្រឡាញ់"

ដល់ត្រង់នេះ ខ្មៅដៃបានធ្លាក់ពីដៃថេរេសាហើយ។ កំណាត់សរសេរដោយដៃនេះ ពេញទៅដោយជួរអក្សរ សរសេរដោយដៃញ័រ បង្ហាញនូវកម្លាំងឆន្ទះជម្នះលើការឈឺចាប់។ ទោះជាប្រឹងយ៉ាងណា ក៏ថេរេសាមិនអាចបញ្ចប់សៀវភៅខ្មៅនេះបាន គាត់ក៏បោះបង់ចោល... គាត់រស់មិនបានបីខែទៀតទេ។

ដោយសារសំណេរពោរពេញទៅដោយគតិបណ្ឌិត និងសេចក្តីស្ងប់នេះ យើងអាចជឿថា អ្នកនិពន្ធមានជំងឺជាទម្ងន់ តាំងពីច្រើនសប្តាហ៍មកហើយ។ ក្រៅអំពីឈើគូសប៉ុន្មានគ្រាប់ បើគ្មានកំណាត់ ដែលថេរេសាសរសេរទុកឲ្យបងស្រីនេះទេ យើងប្រហែលជាមិនបានដឹងល្អិតល្អន់អំពីជំងឺ ការជិតស្លាប់ និងមរណភាពរបស់ដូនជីថេរេសានៃព្រះកុមារយេស៊ូ និងព្រះភក្ត្រដ៏វិសុទ្ធទេ។ ប៉ុន្តែតាមការរៀបរាប់របស់សាក្សី យើងអាចដើរតាមមួយជំហ៊ានម្តងៗ និងអាចមើលឃើញជីវិតរបស់សន្តីរូបនេះ តាមរយៈសំណេររបស់គាត់។

កាលដែលដូនជីថេរេសាលែងសរសេរ ព្រោះគាត់ទៅសម្រាកព្យាបាលពីរបីថ្ងៃមកហើយ ក្នុងគិលានដ្ឋានជាន់ផ្ទាល់ដី។ ជំងឺបានចាប់ផ្តើមជាច្រើនខែមកហើយ ប៉ុន្តែគេទើបតែដឹង ក្រោយបុណ្យរដូវសែសិបថ្ងៃប៉ុណ្ណោះ គាត់មានអាការៈគ្រុនក្តៅ ក្អក ច្រៀងឃឹតជាងគេ។ គាត់លែងធ្វើការអ្វីទាំងអស់ លើកលែងតែការអធិដ្ឋានរួម និងពេលចេញលេង។ នៅខែមិថុនា ឆ្នាំ១៨៩៧ នោះ

គាត់ត្រូវសម្រាកក្នុងបន្ទប់ និងចេញទៅយកខ្យល់អាកាស ហាលពន្លឺថ្ងៃក្នុងសួនច្បារនៅរដូវក្ដៅ សរសេរអនុស្សាវរីយ៍ទាំងប៉ុន្មានដែលដូនជីថ្នាក់លើបង្គាប់ នៅថ្ងៃទី៣ ខែមិថុនា ស្របទៅតាមសំណូមពរដូនជីអាញែស។ "កាតព្វកិច្ច" ចុងក្រោយនេះ មិនបានចប់ចុងដើមនេះទេ។ "ដើម្បីសរសេរអំពីជីវិតដ៏តូចរបស់ខ្ញុំនេះ ខ្ញុំមិនចាំបាច់ប្រឹងទេ ងាយដូចទៅស្ទូចស្រី ឱ! សរសេរតាមបែបនឹកឃើញ"។

ថ្ងៃទី៦ ខែកក្កដា ជំងឺកាន់តែដុនដាប មានការក្អកធ្លាក់ឈាម ជួនតិចជួនច្រើន រហូតដល់ថ្ងៃទី៥ សីហា។ រោគនេះបណ្តាលឲ្យមានអាការៈស្ទះដង្ហើម ក្អួតឈាម "ដូចធ្លាក់ថ្លើម" គ្រុនក្តៅខ្លាំង។ វេជ្ជបណ្ឌិតបានប្រាប់ថា ជំងឺនេះមិនអាចជាសះស្បើយទេ ក្នុងករណីបែបនេះ មានតែ ២% ទេ ដែលអាចគេចផុត។

ថេរេសា សុំទទួលអគ្គសញ្ញាលើលែងទោស ចំពោះបូជាចារ្យ និងសុំអគ្គសញ្ញាលាបប្រេងដែលគាត់ប្រាថ្នាយ៉ាងខ្លាំង "ពោរពេញទៅដោយសេចក្តីរីករាយ"។ ល្ងាចថ្ងៃទី៨ ខែកក្កដា គេយកគាត់ចេញពីបន្ទប់ចុះមកគិលានដ្ឋាន។

តាំងពីពេលនោះមក គាត់លែងបានចេញពីកន្លែងនោះហើយ។ គាត់សម្រាកលើគ្រែដែក ដាក់ក្បែរជ្រុងមួយនៃបន្ទប់ ខណ្ឌដោយវាំងននពណ៌ត្នោត ដែលគាត់បង្គាប់ ឲ្យគេខ្ទាស់រូបភាពដែលគាត់ចូលចិត្ត (ព្រះភ័ក្ត្រព្រះគ្រីស្ត ព្រះមាតា និងរូបសន្តៈ តេអូផាន វេណា (Théophane Vénard)។ល។ ខាងឆ្វេងមានរូបបដិមាព្រះមាតាញញឹម ដែលគេយកមកដាក់នៅថ្ងៃដែលគាត់ចូលសម្រាក កៅអីភ្នាក់ដៃមួយ សម្រាប់អង្គុយពេលគេលើកគាត់។ គាត់អាចមើលសួនច្បារដែលមានផ្ការីកស្គុះស្គាយតាមមាត់បង្អួច។

ថ្ងៃទី៩ ខែកក្កដា នាយិកានៃអារាមកាមែល យល់ឃើញថា ថេរេសាមិនទាន់ឈឺធ្ងន់ ក៏លើកថ្ងៃអគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺទៅថ្ងៃក្រោយ។ ជាការពិតណាស់ គាត់នៅតែមានអាការៈខុសពីអ្នកជំងឺផងទាំងពួង ធ្វើឲ្យដូនជីឯទៀត

ងឿងឆ្ងល់យ៉ាងខ្លាំង ដោយសារការរីករាយរបស់គាត់។ គាត់រស់នៅក្នុងការរង់ចាំ "ចោរ" ដ៏ល្បី ជាចោរដែលនឹង "ហែកផ្តាច់ស្បៃនៃការជួបគ្នា"។ "ស្លាប់ព្រោះសេចក្តីស្រឡាញ់" តាមការពិពណ៌នារបស់សន្តៈ យ៉ូហាននៃឈើឆ្កាង គឺជាសេចក្តីសង្ឃឹមដែលគាត់ប្រាថ្នា។ ដូនជីអាញ៉េសបានកត់ការសន្ទនានេះ ចូលក្នុងសៀវភៅមួយ៖ "សេចក្តីស្លាប់ចូលមកកាន់តែកៀកហើយ តើអ្នកខ្លាចទេ? ឱ! ខ្លាចកាន់តែតិចឡើងៗ! តើអ្នកខ្លាចចោរទេ? ឥឡូវវាមកដល់មាត់ទ្វារហើយ! ទេ វាមិនមែននៅមាត់ទ្វារទេ វាចូលមកហើយ។ តើអ្នកម៉ែមានប្រយោជន៍ពីអ្វី! តើខ្ញុំខ្លាចចោរ! ឲ្យខ្ញុំខ្លាចអ្នកដែលខ្ញុំស្រឡាញ់ដូចម្តេចកើត?!"

គាត់នៅតែធ្លាក់ឈាម ឈឺចាប់ក្នុងក្បាល ឈឺចំហៀងខ្លួន ក្អួតអស់ទឹកដោះគោ ដែលគ្រូពេទ្យបញ្ជាក់អាការៈកាន់តែខ្សោយទៅៗ។

អំឡុងខែកក្កដានេះ ថេរេសានៅមានកម្លាំងឆ្លើយតបនឹងសំណួររបស់ដូនជីអាញ៉េស និងដូនជីឯទៀត៖ គេបានសុំឲ្យគាត់បញ្ជាក់លំអិតអំពីអតីតកាល គេសុំដំបូន្មានពីគាត់។ អ្នកជំងឺរូបនេះ ចង់ឲ្យសំណេរគាត់មានប្រយោជន៍ ដើម្បីចាត់ចែងជាសារាចរដំណឹងមរណភាព សម្រាប់ផ្ញើទៅគ្រប់អារាមកាមែលនានាទៅតាមទម្លាប់។ ក្រោយមកមានការបោះពុម្ពផ្សាយអនុស្សាវរីយ៍របស់គាត់យ៉ាងទូលំទូលាយ។ ថេរេសាបានប្រគល់ភារកិច្ចនេះ ដោយបង្ខំឲ្យដូនជីអាញ៉េសសរសេរបំពេញសៀវភៅ ដោយប្រវត្តិនៃស្ត្រីជាបាបជនម្នាក់ ស្លាប់ព្រោះសេចក្តីស្រឡាញ់។ "ព្រលឹងទាំងអស់ មុខជាយល់ភ្លាមៗមិនខាន ព្រោះជាឧទាហរណ៍មួយគួរឲ្យចាប់អារម្មណ៍ ក្នុងកំណាត់នោះ គាត់បន្ថែមទៀតថា៖ "ក្នុងនោះមានគ្រប់រសជាតិ លើកលែងតែអច្ឆរិយភាព"។

គាត់គិតទុកមុនថា សកម្មភាពក្រោយពេលស្លាប់របស់គាត់ និងសាយភាយទៅហួសពីសៀវភៅទៅទៀត ហើយគាត់នឹងបំពេញកិច្ចការសម្រាប់ពិភពលោកទាំងមូល។ "បើខ្ញុំមិនអាចបង្កើតសេចក្តីរីករាយឲ្យអ្នកដែលខ្ញុំស្រឡាញ់នៅលើ



ផែនដីនេះបាន សូមឲ្យខ្ញុំរងទុក្ខលំបាកនៅស្ថានបរមសុខទៅចុះ!"។ គាត់បានសន្យាយ៉ាងអាថ៌កំបាំងជាច្រើន "ខ្ញុំនឹងត្រលប់មកវិញ... ខ្ញុំនឹងចុះមកវិញ..." បន្ទាប់មក ថ្ងៃទី១៧ ខែកក្កដា សម្ដីនេះក្លាយទៅជាល្បីល្បាញ៖ "ខ្ញុំដឹងជាពិសេសថា បេសកកម្មរបស់ខ្ញុំនឹងចាប់ផ្ដើម ជាបេសកកម្មធ្វើឲ្យស្រឡាញ់ព្រះជាម្ចាស់ដូចខ្ញុំស្រឡាញ់ពីព្រះអង្គដែរ ដោយបង្ហាញផ្លូវតូចមួយឲ្យព្រលឹងឯទៀតដឹង។ បើព្រះជាម្ចាស់ប្រោសប្រទានតាមបំណងរបស់ខ្ញុំ ស្ថានបរមសុខនឹងមកដល់ផែនដីនេះ រហូតដល់អវសាននៃពិភពលោក។ ខ្ញុំចង់ឲ្យស្ថានបរមសុខ សាបព្រោះអំពើល្អលើផែនដីពិតមែន"។

ថ្ងៃទី២៨ ខែកក្កដា ជំងឺកាន់តែខ្លាំងឡើង៖ បើតាមសម្ដីអ្នកជំងឺគឺ "ជាការចាប់ផ្ដើមនៃការឈឺចាប់ខ្លាំង"។ គ្រូពេទ្យប្រមាណទុកថា គាត់មិនអាចឆ្លងផុតពីយប់នេះបានទេ។ ក្នុងបន្ទប់តូច ជាប់គិលានដ្ឋាន (កន្លែងដែលគិលានដ្ឋាយិកាសម្រាក) គេរៀបចំវត្ថុចាំបាច់សម្រាប់បញ្ចុះសព ម៉ោង ៦ល្ងាច ថ្ងៃទី៣០ ខែកក្កដា បូជាចារ្យលាបប្រេងអគ្គសញ្ញាជូនគាត់ និងពិធីទទួលព្រះកាយព្រះគ្រីស្ដសម្រាប់អ្នកស្លាប់។

ផ្ទុយពីការគិតទុក (សម្ដីគាត់៖ "ខ្ញុំមិនយល់ពីជំងឺខ្ញុំសោះ") គាត់ឆ្លងផុតម្ដងទៀត។ អាការៈនេះធ្វើឲ្យទាល់គំនិត ប៉ុន្តែគាត់លែងរវីរវល់ទៀតហើយ៖ "ល្ងាចនេះគ្រូពេទ្យគិតថា ខ្ញុំអាចរស់បានមួយខែ ឬលើសទៀតផង ខ្ញុំមិនខ្វល់ទេ ខុសស្រឡះពីម្សិលមិញ ដែលគាត់ថាត្រូវលាបប្រេងឲ្យខ្ញុំ! ប៉ុន្តែវាធ្វើឲ្យខ្ញុំស្ងប់ចិត្ត" "ខ្ញុំមិនចង់ស្លាប់ជាងរស់ទេ គឺអ្វីដែលព្រះអង្គប្រទានដែលខ្ញុំស្រឡាញ់"។

រោគក្អកធ្លាក់ឈាម ក៏បាត់ស្រេលះនៅថ្ងៃទី៥ ខែសីហា អ្នកជំងឺបានធូរស្រាលបន្តិច គ្រូពេទ្យត្រូវសម្រាកវិស្សមកាល។ ក្រោយពីបានពិនិត្យឃើញថាសួតខាងឆ្វេងត្រូវផ្ទុះធ្លាយ គាត់បញ្ជាឲ្យប្រើថ្នាំខ្លះៗ។ ការធូរស្បើយនេះ មានរយៈពេល ១៥ថ្ងៃ ថេរេសាទទួលការឈឺចាប់ម្ដងទៀត នៅពេលបុណ្យគោរព

ព្រះជាម្ចាស់ លើកព្រះនាងម៉ារីទៅស្ថានបរមសុខ ពេលគ្រូពេទ្យមិននៅ។ ក្អកស្ទះ (ថប់ដង្ហើម) ឈឺចាប់ចន្លោះឆ្អឹងជំនី ហើមជើង គ្រុនក្តៅសន្ធំ... ចន្លោះថ្ងៃទី២២ ទៅ ២៣ ខែសីហា ការឈឺចាប់បានឡើងដល់កម្រិតអតិប្បរមា។ រោគរបេង (សម្តីគ្រូពេទ្យ ជាបងថ្លៃជីដូនមួយរបស់ថេរេសា) រាលដាលដល់ពោះវៀនះ រាងកាយស្គមស្គាំង រាល់ពេលដកដង្ហើម មានការឈឺចាប់យ៉ាងខ្លាំង ប្រហែលជាសរីរាង្គណាមួយហើមរលួយ។ ថេរេសានិយាយថាៈ "អញ្ចឹងក៏ស្រួលដែរ ឈឺគ្រប់មុខតែម្តងទៅ កុំឲ្យពិបាកយូរ"។ ក្រោយមកទៀត ដោយហេវហត់ខ្លាំង គាត់និយាយថាៈ *"តើខ្ញុំនឹងទៅជាយ៉ាងណា បើព្រះជាម្ចាស់មិនប្រទានកម្លាំងឲ្យខ្ញុំ? គ្មាននរណាដឹងថា ឈឺពិបាកយ៉ាងនេះទេ ទាល់តែឈឺខ្លួនឯងទើបដឹង"*។ គាត់ថ្ងូរតិចៗ សុំអភ័យទោស *"ជាការប្រោសប្រទានធម៌ណាស់ ដែលផ្តល់ជំនឿឲ្យខ្ញុំម្ចាស់ បើគ្មានជំនឿទេ ខ្ញុំម្ចាស់មិនខ្លាច និងបញ្ចប់ជីវិតដោយខ្លួនឯងឡើយ!..."*។

នៅចុងខែសីហា រហូតដល់ថ្ងៃទី១៣ ខែកញ្ញា អាការៈរោគហាក់ដូចជាធូរស្រាល។ លោកគ្រូពេទ្យពិនិត្យឃើញថា ប្អូនជីដូនមួយរបស់គាត់នៅសល់សួតពាក់កណ្តាលសម្រាប់ដកដង្ហើម។ គាត់អាចរស់បានមួយខែទៀត។

ការវិវឌ្ឍន៍នៃជំងឺ និងប្រតិកម្មរបស់ដូនជីថេរេសា យើងអាចដឹងតាមរយៈបុគ្គលិកលក្ខណៈរបស់គាត់ ដែលលេចចេញមកពីការសន្ទនា និងសំបុត្រ (គាត់លែងសរសេរកើត ចាប់ពីថ្ងៃទី១០ ខែសីហា)។ គ្មានការផ្លាស់ប្តូរណាមួយរវាងកំណាត់ចុងក្រោយដែលគាត់សរសេរទុក នឹងការសម្រាកព្យាបាលនៅគិលានដ្ឋានទេ។

គាត់នៅតែអ្នកជំងឺធម្មតាម្នាក់ "ដែលគ្មានគិតអ្វីច្រើន" "ប្អូនស្រីទាំងអស់គ្នា សូមប្អូនអធិដ្ឋានទូលអង្វរឲ្យអ្នកជំងឺហៀបនឹងស្លាប់ផង បើសិនជាប្អូនៗដឹងអំពីរឿងនោះ! ... កាលពីមុនខ្ញុំក៏មិនដែលដឹងដែរ"។ គេសួរគាត់ថាៈ

"តើដូនជីរៀបចំជីវិតខ្លួនឯងដូចម្តេចឥឡូវនេះ? ជីវិតខ្ញុំ គឺការឈឺចាប់ រួចចប់!"។

ប៉ុន្តែ មិនដូច្នោះទេ គាត់នៅតែរីករាយ (គាត់មិនធ្វើពុតទេ) ខិតខំលាក់បំបាំងការឈឺចាប់ ដើម្បីកុំឲ្យដូនជីឯទៀតពិបាកចិត្ត។ ក្នុងគិលានដ្ឋាន គ្មានការសោកសៅទេ៖ "ចំពោះផ្លូវចិត្ត ដូចធម្មតា មានតែសេចក្តីរីករាយ គាត់ធ្វើឲ្យគេសើចគ្រប់គ្នា។ មានពេលខ្លះ គេដណ្តើមគ្នាចូលទៅកំដរគាត់ (...)។ ខ្ញុំគិតថាគាត់ស្លាប់ដោយកំពុងតែសើច ព្រោះគាត់ត្រេកអរណាស់"។ នេះជាពាក្យពេចន៍ក្នុងសំបុត្រ ដែលដូនជីម៉ារីនៃពិធីអរព្រះគុណព្រះជាម្ចាស់ សរសេរផ្ញើជូនឪពុកម្តាយគាត់។ ថេរេសា មានរូបមន្តផ្សេងៗគ្នាជាច្រើន ដើម្បីសម្តែងនូវទឹកចិត្តរីករាយ និងភាតរភាពពីកំណើតរបស់គាត់ ដូចជា៖ ការកំប្លែងលេងពាក្យល្បែងកំសាន្តប្លែកៗឲ្យគេសើច ការធ្វើត្រាប់ និងការកំប្លែងស្ងួតអំពីខ្លួនឯង ឬការអស់លទ្ធភាពរបស់គ្រូពេទ្យ។ ប្រភពនៃសេចក្តីរីករាយនេះ ចេញមកពីការទទួលយកទាំងស្រុងនូវព្រះបំណងរបស់ "ពុក ព្រះជាម្ចាស់"។ ដែលគាត់នឹងទៅជួបផ្ទាល់ ក្នុងពេលឆាប់ៗនេះ។ "សូមអ្នកម៉ែកុំពិបាកចិត្តអី ព្រះជាម្ចាស់បណ្តាលឲ្យខ្ញុំមានសុភមង្គល។ ខ្ញុំនៅតែស្រស់ស្រាយសប្បាយជានិច្ច។

ភាពទន់ភ្លន់ជាពន្លឺនៃ "ចិត្តដែលឆាប់រំភើប និងពោរពេញទៅដោយសេចក្តីស្រឡាញ់" ដែលអាចឲ្យទៅតាមតម្រូវការ ព្រមទទួល និងទាមទារមកវិញនូវការថើប "ថើបឮសូរប៊ិច!"។ សំណេរនៅខែមិថុនា រៀបរាប់អំពីសប្បុរសធម៌ជាភាតរភាព ដែលលាក់បំពួនវិរភាពរបស់គាត់។ រហូតដល់ទីបញ្ចប់ ថេរេសានៅតែជាគ្រូរបស់ពួកសាមណេរ ព្រោះគេមកសុំដំបូន្មាន ឬភាពញញឹមរបស់គាត់រហូត។ គាត់នៅតែបារម្ភចំពោះគេឯងគ្រប់គ្នា ដែលនៅជុំវិញខ្លួនគាត់។

គ្មាននរណាស្មានដល់ថា គាត់រស់នៅ "ក្នុងភាពងងឹតសូន្យសុង" ដូចស្ថិតក្នុងរូងក្រោមដី" ឬ "ហ៊ុំព័ទ្ធដោយជញ្ជាំង" បានយូរដូច្នេះ?

ព្រោះមានតែដូនជីម៉ារីដឺកុងសាក (Marie de Gonzague) មួយរូបគត់

ដែលគាត់និយាយអាថ៌កំបាំងនេះប្រាប់ថា ជាការលំបាកគួរឲ្យរន្ធត់ និងបញ្ចប់នៅថ្ងៃចុងក្រោយបំផុត។ ប្រឈមមុខនឹងសេចក្តីស្លាប់ ទទួលទារុណកម្មដោយការឈឺចាប់រូបរាងកាយ ថេរេសានៅតែខិតខំប្រាថ្នារកស្ថានបរមសុខជានិច្ចៈ គាត់ដូចជា "បិទទ្វារ" មានតែស្ថានបរមសុខទេ ដែលដឹងចម្លែកណាស់ មិនសមសោះ!"។ គាត់និយាយជាសម្ងាត់ទៅដូនជីអាញែសៈ "តើត្រូវស្រឡាញ់ព្រះជាម្ចាស់ និងព្រះមាតាឲ្យខ្លាំង កុំគិតរឿងអ្វីទៀតឬ!... តែខ្ញុំមិនឈប់ស្រឡាញ់ទេ"។ មើលទៅតាមបង្អួចឃើញ "រូងខ្មៅងងឹត" មួយក្នុងសួនច្បារ "ព្រលឹង និងរាងកាយខ្ញុំស្ថិតនៅក្នុងរូងបែបនោះ។ ឱ! ពិតជាងងឹតណាស់! ប៉ុន្តែ ខ្ញុំបានស្ងប់"។

អង្គុយតែម្នាក់ឯង នៅ "តុអ្នកមានបាប" គាត់គ្មានសង្ឃឹមជំនួយពីក្រៅទេ។ បូជាចារ្យភិតភ័យនឹងការល្បួងរបស់អ្នកសារភាពបាប កុំឈប់នៅត្រង់នោះ គ្រោះថ្នាក់ណាស់!"។ ថេរេសានៅតែអៀនប្រៀនជាមួយដូនជីឯទៀត ដោយខ្លាចពួកគេបារម្ភ។ គាត់មិនអាចទីពឹងលើអគ្គសញ្ញាទេ។ ថ្ងៃទី១៩ ខែសីហា គាត់ទទួលព្រះកាយព្រះគ្រីស្តជាលើកចុងក្រោយ។ "កាលបើគេយកព្រះកាយព្រះគ្រីស្តមកឲ្យគាត់ យើងនាំគ្នាចូលទៅទន្ទេញធម៌ "ទទួលសារភាព"។ កាលពីលើកមុនគាត់មានអាការៈខ្សោយខ្លាំង ពេលឮពួកយើងសូត្រ គាត់មួរម៉ៅ គាត់ឈឺចាប់ដូចជាមរណសាក្សី"។

ចាប់ពីពេលនោះមក ថេរេសាមិនអាចចូលរួមទទួលព្រះកាយព្រះគ្រីស្ត ប៉ុន្តែគាត់មិនពិបាកចិត្តទេ៖ "គឺជាការប្រោសប្រណីមួយដ៏ឧត្តុង្គឧត្តម ដែលបានទទួលអគ្គសញ្ញា ប៉ុន្តែបើព្រះជាម្ចាស់មិនអនុញ្ញាតក៏ល្អដែរ អ្វីៗទាំងអស់សុទ្ធតែជាការប្រោសប្រណី"។ ការប្រគល់ព្រះកាយព្រះគ្រីស្តចុងក្រោយនេះ ថេរេសាមានបំណងអធិដ្ឋានជូនអតីតបូជាចារ្យមួយរូប ព្រោះ "គាត់គ្មានសល់អ្វីទៀតទេ"។ អ្វីៗដែលខ្ញុំមាន អ្វីៗដែលខ្ញុំរកបានសម្រាប់ព្រះសហគមន៍ និងព្រលឹងឯទៀត"។ កង្វល់នៃបាបជន និងការសង្គ្រោះជាសាកល រឹងរិតតែឆាបឆួល គាត់បានសរសេរឆ្លើយឆ្លងនឹងប្អូនប្រុសទាំងពីរនាក់ ដែលគាត់បានសន្យាថា ជួយអស់ពីចិត្ត *"កាល*

*ណាខ្ញុំទៅដល់កំពង់ផែ ខ្ញុំនឹងបង្រៀនពួកអ្នក។ អ្នកត្រូវឆ្លងសមុទ្រកាត់ព្យុះព្យោមានៃផែនដីនេះ ដោយការលះបង់ និងសេចក្ដីស្រឡាញ់របស់កូនដែលដឹងថាព្រះបិតាមិនបោះបង់គេចោលវេលាមានគ្រោះថ្នាក់ឡើយ... មាគ៌ានៃការជឿទុកចិត្ត និងសេចក្ដីស្រឡាញ់បានត្រួសត្រាយសម្រាប់ពួកអ្នក"* ។

ជីវិតហាក់ដូចជាធម្មតា ពេលនៅគិលានដ្ឋានគ្មាននរណាគិតថា មានសន្តិមួយរូបកំពុងតែរង់ចាំសេចក្ដីស្លាប់។ ប៉ុន្តែពេលខ្លះ សម្ដីអាចកំបាំងបំភ្លឺអនាគតកាល ដែលជិតមកដល់៖ *"ដូនជីទាំងអស់គ្នា អ្នកដឹងទេថា អ្នកកំពុងថែទាំសន្តិតូចម្នាក់" "ប្រមូលគ្រប់កផ្កានេះទៅ (ផ្កាកូលាប) ប្អូនស្រី វានឹងធ្វើឲ្យអ្នកពេញចិត្តនៅពេលក្រោយ.. កុំឲ្យបាត់ឲ្យសោះ..."* កាលដែលគេសុំឲ្យនិយាយថ្ងៃស្លាប់ ថេរេសាប្រកែកនិយាយអំពីភាពក្រីក្របំផុតរបស់គាត់។ "ឱ! អ្នកម៉ែ គឺការដឹងជាមុន! ម៉ែដឹងថា ខ្ញុំក្រយ៉ាងណា! ខ្ញុំមិនដឹងអ្វីដែលម៉ែដឹងទេ! ខ្ញុំមិនគិតទុកអ្វីៗ ដែលខ្ញុំឃើញ និងដឹងឡើយ"។

ពាក្យពេចន៍ដែលគាត់និយាយនៅគិលានដ្ឋាន បានប្រទាក់គ្នាជាមួយនឹងសំណេរក្នុងសៀវភៅ រៀបរាប់អំពីព្រះមហាករុណាទិគុណរបស់ព្រះយេស៊ូ។ គឺដោយសារការប្រោសប្រណីពិតៗ ទើបដូនជីថេរេសាឈានទៅដល់ការលះបង់នេះ "នេះជាសម្ដីរបស់យ៉ូប ទោះជាព្រះជាម្ចាស់សម្លាប់ ក៏ខ្ញុំនៅតែសង្ឃឹមលើព្រះអង្គដែរ" សម្ដីនេះបានទាក់ទាញខ្ញុំតាំងពីក្មេងម្ល៉េះ ប៉ុន្តែទម្រាំមកដល់ការលះបង់ចោលនេះ គឺយូរណាស់។ ឥឡូវខ្ញុំមកដល់ហើយ ព្រះជាម្ចាស់បានបីត្រកងខ្ញុំក្នុងព្រះហស្តព្រះអង្គ ហើយដាក់ខ្ញុំនៅទីនោះ..."។

គាត់នៅតែមានស្មារតីភ្លឺស្វាង ស្គាល់ដែនកំណត់ ដាក់ខ្លួនសុភាពរាបសាទទួលស្គាល់ថា ខ្លួនមានជំងឺធ្ងន់ ខ្សោះកម្លាំង យំ ខ្វះការអត់ធ្មត់ចំពោះដូនជីខ្លះដែលមករំខាន៖ "ឱ! ខ្ញុំសប្បាយចិត្តដោយឃើញខ្លួនឯងមិនគ្រប់លក្ខណ៍ ហើយត្រូវការសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់នៅពេលស្លាប់!"។

គាត់ហាក់ដូចជាភ្លឺថ្លាបរិសុទ្ធ៖ "ដូចគេនឹងឃើញ ហើយអ្វីៗទាំងអស់បានមកពីព្រះជាម្ចាស់ ចំណែកឯជោគជ័យដែលខ្ញុំនឹងទទួលបាន ជាអំណោយដែលឥតគិតថ្លៃ មិនមែនសម្រាប់ខ្ញុំទេ ទាំងអស់គ្នាគង់តែឃើញ"។

ក្រោយពីការឈឺចាប់កម្រិតខ្ពស់បំផុតនៅចុងខែសីហា គេបានទាញគ្រែដាក់ចំកណ្ដាលគិលានដ្ឋាន។ តាមបង្អួច ថេរេសា អាចមើលឃើញផ្ការីកស្គុះស្គាយក្នុងសួនច្បារ (គាត់ចូលចិត្តផ្កា និងផ្លែឈើណាស់) មេឃមួយចំណិត ឮសំឡេងសូត្រធម៌ជាពួក។ សំឡេងតន្ត្រីពីចម្ងាយ។ គាត់ហាក់ដូចជាបានធូរស្បើយឥឡូវគាត់ឃ្លានហើយ។ ដូនជីមេផ្ទះ "ខិតខំធ្វើចំណីចំណុកឆ្ងាញ់ៗ" មានទាំងនំសូកូឡាទៀតផង!។

ថ្ងៃទី៣០ ខែសីហា គេដាក់គាត់លើគ្រែរុញមួយ រុញគាត់តាមរបៀងព្រះវិហាររហូតទៅដល់ទ្វារទីសក្ការបូជា ដែលគាត់ឃើញជាលើកចុងក្រោយ។ ដូនជីសឺណឺវីយែវ (Geneviève) ឆ្លៀតឱកាសថតរូបគាត់ជាលើកចុងក្រោយបំផុតរាងកាយស្គមស្គាំងយ៉ាងខ្លាំង ខិតខំញញឹម ថេរេសាបកស្រទាប់ផ្កាកុលាបដាក់លើឈើឆ្កាងដែលគាត់ដាក់ជាប់ខ្លួនជានិច្ច។

ថ្ងៃទី៨ ខែកញ្ញា គាត់ធ្វើបុណ្យខួបទីប្រាំពីរនៃការចូលបួសរបស់គាត់។ គេជូនផ្កាជាច្រើន គាត់ហូរទឹកភ្នែក ដោយសេចក្ដីត្រេកអរ "នេះជាការប៉ិនប្រសប់របស់ព្រះជាម្ចាស់ចំពោះរូបខ្ញុំ។ មើលពីខាងក្រៅ ខ្ញុំពេញចិត្តណាស់ ប៉ុន្តែខាងក្នុងវិញ ខ្ញុំស្ថិតនៅក្នុងការសាកល្បង... និងភាពស្ងប់ស្ងាត់ដែរ"។ គាត់ក្រងផ្កាពណ៌ខៀវពីរកម្រង ដើម្បីបូជារូបចម្លាក់ព្រះមាតា។

ត្រឡប់មកពីឈប់សម្រាកវិញ លោកគ្រូពេទ្យ ភ័ន្តភាំងនឹងសភាពជំងឺ។ ជាថ្មីម្ដងទៀត និងជាលើកចុងក្រោយ អាការៈជំងឺកាន់តែធ្ងន់ធ្ងរ បន្ទាប់ពីបានធូរស្រាលអស់រយៈពេល ១៩ថ្ងៃជាប់គ្នា។ រោគរបេងបំផ្លាញសួតខាងឆ្វេងទាំងស្រុង។ ថេរេសាថប់ដង្ហើម និយាយដាច់ៗ៖ "ម៉ែអើយ ខ្យល់អាកាសនៅលើផែនដី

នេះ មិនគ្រប់គ្រាន់សម្រាប់ខ្ញុំទេ តើកាលណាទៅទើបព្រះជាម្ចាស់ប្រទានខ្យល់ស្ថានបរមសុខ... ឱ! មិនដែលពិបាកដកដង្ហើមអញ្ចឹងទេ! ...។

ដូចអ្នកដំណើរអស់កម្លាំងហេវហត់ ដើរទ្រេតទ្រោតៗ ហៀបនឹងដល់ទិសដៅ ថេរេសាបានទៅដល់ចុងផ្លូវនៃការរងទុក្ខហើយ៖ ម៉ែនហើយ ប៉ុន្តែ ខ្ញុំនឹងដួលចុះក្នុងព្រះហស្តព្រះជាម្ចាស់!..."។ ប្រឈមមុខនៃសេចក្តីស្លាប់ មានពេលខ្លះគាត់ហាក់ដូចជាស្ទាក់ស្ទើរ "ខ្ញុំភ័យថា ខ្ញុំខ្លាចស្លាប់...ក្រោយមកខ្ញុំក៏លែងខ្លាចពិតហើយ! ខ្ញុំមិនស្តាយជីវិតទេ ឱ! ទេ... ខ្ញុំគ្រាន់តែចង់ថា៖ តើអ្វីទៅជាការបំបែកវិញ្ញាណចេញពីរូបកាយដ៏អាថ៌កំបាំងនោះ? ខ្ញុំមានអារម្មណ៍ជាលើកទីមួយហើយ ប៉ុន្តែ ខ្ញុំបានប្រគល់ខ្លួនថ្វាយព្រះជាម្ចាស់រួចទៅហើយ"។

ការស្លឈាមមែនទែន មានរយៈពេលពីរថ្ងៃ នៅថ្ងៃ២១ កញ្ញា ថេរេសាថ្ងូរ៖ "ឱ! នេះឬជាការស្លឈាម? ហាក់ដូចជាយូរណាស់"។

ព្រឹកថ្ងៃពុធ ទី២៩ អ្នកជំងឺដកចង្កាមាន់យ៉ាងលំបាក។ ដូនជីម៉ារីដឺកុងសាកកោះហៅព្រះសហគមន៍មកជួបជុំគ្នាជុំវិញគ្រែសូត្រធម៌។ ពេលថ្ងៃត្រង់ ថេរេសាសួរដូនជីកុងសាក "អ្នកម៉ែ នេះឬការស្លឈាម?... តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីស្លាប់? ខ្ញុំមិនដឹងជាស្លាប់ដូចម្តេចទេ!" ក្រោយពីលោកគ្រូពេទ្យពិនិត្យរួច គាត់សួរថា៖ "តើថ្ងៃនេះ ឬអ្នកម៉ែ?"

"ថ្ងៃនេះហើយ កូនស្រី ។ បើស្លាប់ភ្លាមៗ ខ្ញុំសប្បាយចិត្តណាស់!"។ បន្តិចក្រោយមក៖ "តើកាលណាទើបខ្ញុំដក ដង្ហើមលែងរួច? ... ខ្ញុំទ្រាំលែងបានហើយ! ឱ! សូមបន់ស្រន់ឲ្យខ្ញុំផង! ព្រះយេស៊ូ! ព្រះមាតា! ... ចាស៎! ខ្ញុំចង់ ខ្ញុំចង់ណាស់..."។

ពេលល្ងាច បូជាចារ្យម្នាក់មកផ្តល់អគ្គសញ្ញាលើកលែងទោស។ ពេលចេញពីគិលានដ្ឋានវិញ គាត់រំជួលចិត្តជាខ្លាំង ហើយប្រាប់ថា៖ "ព្រលឹងដ៏ល្អ! គាត់ប្រាកដជាទទួលការប្រោសប្រណី"។

យប់នោះដូនជីសឺណឺវីយែរ និងដូនជីម្នាក់ទៀត នៅមើលថែ ទោះជាគាត់បដិសេធក៏ដោយ។ ជាយប់ដែលមានការឈឺចាប់បំផុត។ ព្រឹកឡើងបងស្រីទាំងបីនាក់ នៅក្បែរគាត់ពេលអភិបូជា។ ថេរេសាដង្ហក់មើលទៅបដិមារព្រះមាតា៖ "ឱ! ខ្ញុំបានទូលអង្វរព្រះមាតាយ៉ាងខ្លាំងក្លា! ... ប៉ុន្តែជាការស្លូឈាមពិតៗ គ្មានការលួងលោមទេ..."។

ពេលរសៀល ថ្ងៃព្រហស្បតិ៍ ទី៣០ ខែកញ្ញា នេះ ថេរេសាងើបអង្គុយលើគ្រែខុសប្លែកពីមុន ព្រោះគាត់លែងក្រោករួចជាច្រើនសប្តាហ៍មកហើយ "ឃើញទេ ថ្ងៃនេះខ្ញុំមានកម្លាំងណាស់! ទេខ្ញុំមិនស្លាប់ទេ! ខ្ញុំអាចរស់បានរាប់ខែ រាប់ឆ្នាំទៀតផង! ។ បើតាមសាក្សី គាត់ខិតខំ "ប្រយុទ្ធតទល់នឹងការស្លូឈាម គួរឲ្យខ្លាចនេះ"។

ថ្ងៃរសៀលម៉ោង៣ អង្គុយលើគ្រែ គាត់ដាក់ដៃលើដូនជីអាញ៉េស និងដូនជីសឺណឺវីយែរ ដែលនៅជិតគាត់។ កាយវិការនេះ ធ្វើឲ្យនឹកឃើញដល់សម្តីគាត់កាលពីខែមិថុនា។ កាលនោះ គាត់និយាយអំពី "កាស្លាប់ដើម្បីសេចក្តីស្រឡាញ់" ដែលគាត់ចង់បាន៖ "ដូចខ្ញុំបានប្រាប់រួចមកហើយ បើអ្នកទាំងអស់គ្នា ឃើញខ្ញុំឈឺចាប់ខ្លាំង មិនឃើញសញ្ញាសុភមង្គលនៅពេលស្លាប់ កុំពិបាកចិត្តអី។ ព្រះជាម្ចាស់នៃយើង ទ្រង់សុគតក្នុងនាមជាអ្នករងគ្រោះ ដោយសារសេចក្តីស្រឡាញ់ អ្នកឃើញទេ កាលដែលព្រះអង្គហៀបនឹងសុគតយ៉ាងដូចម្តេចខ្លះ!..."។ ដូចគ្នានេះដែរ កាលពីខែកក្កដា ថេរេសាបាននិយាយថា៖ "ព្រះអម្ចាស់នៃយើង សុគតលើឈើឆ្កាង ក្នុងក្តីតក់ស្លុត តែទោះជាយ៉ាងណា ក៏ជាការសុគតដើម្បីសេចក្តីស្រឡាញ់ដែរ"។ (...) ស្លាប់ដើម្បីសេចក្តីស្រឡាញ់ មិនមែនស្លាប់ដោយមនោសញ្ចេតនាផ្អែសផ្អាស់ទេ។ ខ្ញុំសារភាពប្រាប់អ្នកតាមត្រង់ថា ហាក់ដូចជាខ្ញុំបានធ្វើការពិសោធន៍អញ្ចឹង"

ដូនជីអាញ៉េសបានដកស្រង់សម្ដីរបស់ថេរេសា៖
- ខ្ញុំលែងជឿលើសេចក្ដីស្លាប់ទៀតហើយ... ខ្ញុំក៏លែងជឿលើការឈឺចាប់ដែរ... យ៉ាងម៉េចក៏បាន!
- ឱ ព្រះជាម្ចាស់អើយ!
- ខ្ញុំស្រឡាញ់ព្រះជាម្ចាស់!
- ឱ ព្រះមាតាអើយ សូមជួយសង្គ្រោះខ្ញុំម្ចាស់ផង!
- បើនេះជាការស្លូឈាម តើសេចក្ដីស្លាប់នោះ ដូចម្ដេចទៅ?
- ព្រះជាម្ចាស់អើយ! ... មែន ព្រះអង្គសប្បុរសណាស់ ខ្ញុំយល់ថា ព្រះអង្គសប្បុរសណាស់
- ប្រសិនជាអ្នកជ្រាបថា ខ្ញុំម្ចាស់ថប់ដង្ហើមយ៉ាងណា!
- ព្រះជាម្ចាស់អើយ សូមមេត្តាដល់ក្មេងស្រីតូចរបស់ព្រះអង្គផង! សូមអាណិតនាងផង! ...

សម្ដី ថេរេសា ចំពោះដូនជីកុងសាក
- ឱ អ្នកម៉ែ ខ្ញុំធានាថា ពែងពេញហៀរ!
- ... ព្រះជាម្ចាស់មិនបោះបង់ខ្ញុំចោលទេ ប្រាកដហើយ...
- ... ព្រះអង្គមិនដែលបោះបង់ខ្ញុំឡើយ
- ... ព្រះជាម្ចាស់អើយ ខ្ញុំម្ចាស់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ប៉ុន្តែ សូមអាណិត ខ្ញុំម្ចាស់ផង!
- ប្អូនស្រីទាំងអស់គ្នា ប្អូនស្រី សូមអធិដ្ឋានឲ្យខ្ញុំផង!
- ព្រះជាម្ចាស់! ព្រះជាម្ចាស់អើយ ព្រះអង្គសប្បុរសណាស់!
- ឱ មែនហើយ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរណាស់! ខ្ញុំម្ចាស់ដឹង...
- ពិតមែន ខ្ញុំម្ចាស់ហាក់ដូចជា តែងតែស្វែងរកសេចក្ដីពិត ខ្ញុំយល់អំពីចិត្តសុភាពរាបសា ខ្ញុំម្ចាស់ហាក់ដូចជាសុភាពរាបសាហើយ។

- បំនងប្រាថ្នាក្នុងការឈឺចាប់ ដែលខ្ញុំបានសរសេរ ឱ! គឺពិតជាមានមែនហើយ!
- ខ្ញុំមិនសោកស្តាយ ដោយប្រគល់ខ្លួនឲ្យសេចក្តីស្រឡាញ់ទេ

ថេរេសា នៅតែបបេសនិយាយថា៖

"ឱ! ទេ ខ្ញុំមិនស្តាយទេ!"

ដូនជីអាញែសនិយាយប្រាប់ថា៖ "កាលនោះ ខ្ញុំនៅតែម្នាក់ឯងក្បែរថេរេសាប្រមាណជាម៉ោងបួនកន្លះ ខ្ញុំដឹងច្បាស់ថា នាទីចុងក្រោយមកដល់ហើយ ដោយឃើញទឹកមុខស្លេកស្លាំងភ្លាមៗរបស់អ្នកជំងឺ។ អ្នកម៉ែយើងត្រលប់មកវិញភ្លាមនោះសហគមន៍ទាំងមូលមកជួបជុំគ្នា។ ថេរេសាញញឹមដាក់គាត់ លែងនិយាយរហូតដល់ពេលដាច់ខ្យល់។ សំឡេងដកចង្កាមាន់ គួរឲ្យរន្ធត់ លាន់ឮក្នុងទ្រូងអស់រយៈពេលជាងពីរម៉ោង។ ឈាមច្រាលលើផ្ទៃមុខ បាតដៃ ពណ៌ស្វាយ ជើងត្រជាក់ដូចទឹកកក អវយវៈញ័រទទ្រើត។ ញើសតំនក់ធំៗលើថ្ងាស់ហូរកាត់ថ្ពាល់។ អ្នកជំងឺកាន់តែថប់ដង្ហើមបន្តិចម្តងៗ ជួនកាលថ្ងូរតិចៗ ដោយមិនដឹងខ្លួន ព្រោះពិបាកដកដង្ហើមពេក"។

ថេរេសាញញឹមដាក់ដូនជី សឺណឺវិយែរ ដែលជូតញើសលើថ្ងាស់ ហើយដាក់ទឹកកកមួយដុំតូចលើបបូរមាត់ក្រៀមស្ងួតរបស់គាត់។

ម៉ោង ៦ល្ងាច អ្នកជំងឺមើលទៅរូបសំណាកព្រះមាតាយ៉ាងយូរ គាត់ឱបឈើឆ្កាងយ៉ាងជាប់។ ដូនជីជាមេដឹកនាំ បានបញ្ជាឲ្យសមាជិកព្រះសហគមន៍ទាំងអស់ ដែលឈរជិតពីរម៉ោងទៅហើយចេញពីគិលានដ្ឋាន។

ថេរេសាដកដង្ហើមធំ៖

- អ្នកម៉ែ! មិនទាន់ស្លឈាមទេឬ?... ខ្ញុំជិតស្លាប់ហើយមែនទេ?...
- មែនហើយ កូនស្រី គឺការជិតស្លាប់ ប្រហែលជាព្រះជាម្ចាស់បន្ថែមពីរបីម៉ោងទៀត ក៏មិនដឹង។

- អញ្ចឹងក៏បាន តោះ! ... តោះយើងទៅ...

ឱ! ខ្ញុំចង់ឈឺចាប់យូរជាងនេះ...

ក្បាលគាត់ធ្លាក់មកលើខ្នើយ ងាកមកខាងស្តាំ។ ដូនជីអ្នកដឹកនាំអង្រួនជួងគិលានដ្ឋាន ដូនជីទាំងអស់ត្រលប់មកវិញយ៉ាងប្រញាប់ "បើកទ្វារទាំងអស់ចេញ"។ ក្រោយពីជួបជុំគ្នាហើយ ដូនជីទាំងអស់លុតជង្គង់ជុំវិញគ្រែ ថេរេសានិយាយមួយៗច្បាស់ៗ ដោយក្រលេកមើលទៅឈើឆ្កាងថា៖ "ឱ! ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ..." មួយស្របក់មកទៀត៖

"ព្រះជាម្ចាស់អើយ! ... ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គ! ..."

រំពេចនោះ ភ្នែកគាត់បញ្ចោញពន្លឺ ហើយសម្លឹងឥតព្រិច ទៅចំនុចមួយស្ថិតនៅខាងលើរូបបដិមារព្រះមាតាបន្តិច។ ទឹកមុខហាក់ដូចជាមនុស្សមានសុខភាពល្អ គាត់ហាក់ដូចជាសប្បាយភ្លឺក។ ក្រសែភ្នែកសម្លឹងនេះ មានរយៈពេលមួយចប់ធម៌ប្រកាសជំនឿ រួចគាត់បិទភ្នែកផុតដង្ហើម ប្រហែលជាម៉ោងប្រាំពីរ ម្ភៃនាទី យប់។ ក្បាលងាកទៅខាងស្តាំ បបូរមាត់ញញឹមដ៏អាថ៌កំបាំងគាត់ស្អាតណាស់ ដូចរូបថតដែលបងស្រីថតឲ្យ។ ស្របទៅតាមទម្លាប់សពត្រូវគេតម្កល់នៅកន្លែងសក្ការបូជា ក្បែរចម្រឹង ពីរសៀល ថ្ងៃសុក្រ រហូតដល់ល្ងាចថ្ងៃអាទិត្យ ហើយបញ្ចុះនៅថ្ងៃច័ន្ទ ទី៤ ខែតុលា ឆ្នាំ១៨៩៧ នៅទីបញ្ចុះសពលីស្យឺ។ គាត់បានសរសេរសំបុត្រមួយទៅបូជាចារ្យ ដែលជាប្អូនប្រុស ថ្ងៃទី៩ ខែមិថុនា "ខ្ញុំមិនស្លាប់ទេ ខ្ញុំចូលក្នុងជីវិត" ជីវិតដ៏អស្ចារ្យ ក្រោយមរណភាពរបស់ដូនជីនៅកាមែល ដែលគេមិនស្គាល់នេះ នឹងចាប់ផ្តើម...។



សន្តី ថេរេសា នៃព្រះកុមារយេស៊ូ
និងព្រះភក្រ្តដ៏វិសុទ្ធ

# ប្រវត្តិនៃព្រលឹងមួយ

( សម្រង់ )

ប្រែសម្រួលដោយលោកបូជាចារ្យ
**ហ្វ្រង់ស្វ័រ អេមេល្យដាល** ( MEP ) និង **អ្នកស្រី ហែម ឌី**

អនុញ្ញាតឲ្យបោះពុម្ពដោយលោក **អូលីវីយេ ឝ្មិតហាស្លែរ** (MEP)
អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ
ឆ្នាំ ២០១៣

Imprimatur by Bishop **OLIVIER SCHMITTHAEUSLER**, MEP

APOSTOLIC VICAR OF PHNOM PENH

CAMBODIA 2013